INSTITUT
DE CIVILISATION
INDIENNE
N° 1029

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMPUCHÉA SURIYA

# កម្ពុជសុរិយា

## សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគំរប់ ៨

ខ្សែ ១, ២, ៣, រួមគ្នា
កុង្សីយសេនាបតីបានអនុញ្ញាតហើយ
សម្ដេចសង្ឃនាយកទាំងពីរគណយល់ព្រម

PER.
933

BIBLIOTHÈQUE ROYALE DU CAMBODGE

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព. ស. ២៤៧៩
គ. ស. ១៩៣៦

ÉCOLE FRANÇAISE
BIBLIOTHÈQUE

# បញ្ជីរឿង

ទំព័រ

១ — បុណ្យទក្ខិណានុប្បទានជូនលោកល្វី-ហ្វីណូត៍ នៅវត្តប្រាង្គណ៍ (ខគ្គុង) . . . ១

២ — សិលាចារិកស៊ុម៉ង់ រឿងព្រះពុទ្ធសាសនាត្រង់ព្រះសម្មាសម្ពុទ្ធទ្រង់ប្រសូត . . . ១៣

៣ — ដោយប្រការយ៉ាងណាខ្លះដែលគេគោរពព្រះសម្ពុទ្ធនៅស្រុកឥណ្ឌៀ ស.បួណូ

រៀបរៀង ក្រម្ការ ជុំ-មៅ ប្រែជាភាសាខ្មែរ . . . . . . . . . . . . . ១៧

៤ — សាសនប្រវត្តិ ព្រះមហាពិទូរ ក្រសេម គន្ធបទបណ្ឌិត រៀបរៀង (ត) . . . ២៧

៥ — រឿងព្រេងខ្មែរ ដែលមិនទាន់បោះពុម្ពផ្សាយរឿងខ្លាអាកេទ . . . . . . . . ៤៣

## រូបផ្សេងៗ

១ — រូបលោកល្វី-ហ្វីណូត៍ ដែលដកល់ធ្វើបុណ្យនៅវត្តប្រាង្គណ៍ . . . . . . . ១

២ — រូបសិលាឆ្លាក់ត្រង់រឿងព្រះសម្មាសម្ពុទ្ធប្រសូត . . . . . . . . . . . ១៣

៣ — រូបស្ថានទីដកល់ព្រះត្រៃបិដក ១ ចប់សិលាចារិកនៅផែនថ្មកែវ នៅក្រុងមណ្ឌ-

លេ (ភូមា) . . . . . . . . . . . . . . . . . . . . . . . . . ២៩

៤ — រូបផែនសិលាចារិក នៅវត្តសង្គោមុនី ក្រុងមណ្ឌលេ (ភូមា) . . . . . . ៤១

# TABLE DES MATIÈRES


I. Cérémonie de transmission de mérite à la mémoire de M. Louis-Finot à Vat-Prang (Oudong)................... 1

II. Moulage en ciment de la naissance du Bouddha......... 13

III. De quelle manière le Bouddha fut vénéré dans l'Inde par Georges Bonneau — Traduit du Français en Cambodgien par Kromokar Chum-Mau (à suivre).................. 17

IV. Sāsanapravatti ou Histoire des religions par Préas Maha Pitou Krasem à la Bibliothèque Royale (à suivre)...... 27

V. Conte populaire Cambodgien inédit: Histoire du tigre.................................. 43


## ILLUSTRATIONS ET HORS TEXTE.


I. Portrait de Louis-Finot sur l'autel de la cérémonie de transmission de mérite à sa mémoire à Vat-Prang.......... 1

II. Naissance du Bouddha................................ 13

III. Mausolées abritant 729 stèles en marbre blanc sur lesquelles sont gravés recto-verso tous les textes du Tripitaka Pagode de Kuthodaw mandalay (Birmanie)............ 29

IV. Stèle gravées — Pagode de Sandamani — Mandalay (Birmanie).................................. 41



រូបលោក ល្វី - ហ៊ីណូត៍
ដែលគេដំកល់ធ្វើបុណ្យជូនលោក នៅវត្តប្រាង្គណ៌ ឧត្តុង្គ

# បុណ្យទក្ខិណានុប្បទាន

ឧទ្ទិស្សផលជូនលោក ល្វី-ហ្វីណូត

នៅទីវត្តប្រាង្គណ៍ (ឧដុង្គ) ប៉ុរាំងចាស់ (កំពង់ស្ពឺ)

បុណ្យនេះ គឺលោកព្រះវិសុទ្ធិវង្ស តាត ជាសិស្សបានរឭក ដល់គុណូបការរបស់លោក ហ្វីណូត ជាគ្រូ ដែលបានបង្ហាត់ បង្រៀនបំណេះសំស្ក្រឹត និងបំណេះផ្សេងៗ ក្នុងព្រះពុទ្ធសាសនា ដល់ខ្លួនលោក ទើបបានចាត់ចែងធ្វើនៅទីវត្តប្រាង្គណ៍ (ឧដុង្គ) ដែលជាវត្តរបស់លោក និងជាវត្តដែលលោក ហ្វីណូត ធ្លាប់ អញ្ជើញទៅ ។

បុណ្យនោះមានរបៀបដូចម្ដេចខ្លះ ដូចសេចក្ដីតទៅនេះ ថ្ងៃ ៥ កើតខែជេស្ឋ ឆ្នាំកុរសប្ដស័ក ត្រូវនឹងថ្ងៃ ៦ ខែយូវាំងឆ្នាំ ១៩៣៥ វេលាព្រឹកម៉ោង ១០ បាននិមន្តព្រះសង្ឃច្រើនជាង ១០០ អង្គមកទទួលភត្តក្នុងទីសាលាបុណ្យ ។ កាលដែលព្រះសង្ឃនិងពួកឧបាសកឧបាសិកា មកជួបជុំស្រេចហើយ មុននឹងប្រគេនបង្ហាន់ព្រះសង្ឃ លោកព្រះវិសុទ្ធិវង្ស តាត បានថ្លែងគុណលោកហ្វីណូត ដែលលោកមានចិត្តសប្បុរសជួយឧបត្ថម្ភដល់

កិច្ចការដែលជាប់ទាក់ទងដល់ព្រះពុទ្ធសាសនា នឹងសង្គ្រោះបំពោះខ្លួនលោកហើយបានឧទ្ទិស្សផលជូនទៅលោកហ្វីណូត៍ រួបប្រគេនបង្ហាន់ព្រះសង្ឃ ។

វេលាល្ងាចម៉ោង៥គត់ សន្និបាតប្រជុំធំក្នុងទីសាលាដែលមានរបៀបរៀបចំយ៉ាងប្រពៃ គួរឲ្យចង់មើលហើយគួរឲ្យមានចិត្តនឹកដល់លោកហ្វីណូត៍ ដែលទទួលមរណភាពហើយ ។ ឯរបៀបរៀបចំក្នុងសាលានោះ គឺពាសដាសដោយសំពត់ព៌ណសគ្រប់អន្លើទាំងអស់ ខាងលើពាសដោយសំពត់សធ្វើជាពិតានអាសនៈព្រះ ត្រង់កណ្ដាលក៏ពាសដោយសំពត់សទាំងអស់ នឹងប្រដាប់តាក់តែងដោយរនាំងវាំងននយ៉ាងថ្មីៗ ។ នៅទីមុខសាលាធ្វើជាបារ៉ាំប្រដាប់ដោយរំភាយនឹងទង់ជ័យផ្សេងៗ ព្រមទាំងទង់របកព៌ណស ដែលបង្ហូតឡើងទៅលើអាកាសដោយដងឫស្សីដ៏ខ្ពស់នៅពីខាងមុខសាលា ដើម្បីជាគ្រឿងសំគាល់តាមទំនៀមខ្មែរថាបុណ្យសព ។ ក្នុងកណ្ដាលសាលាត្រង់មុខអាសនៈព្រះ មានដំកល់តុថ្ម ១ វាំងមូលក្រាលកម្រាលសំពត់

សនឹងបិទព័ទ្ធជុំវិញដោយសំពត់ស ហើយដំកល់រូបថតលោកហ៊ីណូត៍នៅលើតុរាងមូលនោះ នៅជុំវិញរូបថតប្រដាប់តាក់តែងដោយផ្កាភ្ញីផ្សេង ៗ មានផ្កាម្លិះជាដើម ពីខាងលើមានធត្ររូតដែលធ្វើដោយផ្កាមានព័ណ៌សទាំងអស់ ។

ប៉ែកខាងស្តាំរៀបចំទីអាសនៈសម្រាប់ព្រះភិក្ខុសង្ឃ ។

ប៉ែកខាងឆ្វេងរៀបចំទីអាសនៈសម្រាប់មន្ត្រីបារាំង-ខ្មែរព្រមទាំងបណ្ឌិតាស្ត្រ ។

នៅវេលាម៉ោង ៩ គត់ ព្រះសង្ឃច្រើនជាង ១០០ អង្គព្រមទាំងមន្ត្រីបារាំងខ្មែរនឹងបណ្ឌិតាស្ត្រជាឧបាសកឧបាសិកា មានចំនួនច្រើនបានចូលទៅជួបជុំព្រមគ្នាក្នុងទីសាលា ។

បំណែកខាងព្រះសង្ឃឃើញលោកគ្រូព្រះសិរីសម្មតិវង្សឯម ចាងហ្វាងសាលាបាឡីជាន់ខ្ពស់ លោកព្រះវិសុទ្ធិវង្ស គាតអាចារ្យបង្រៀនសំស្ក្រឹត ដែលជាសិស្សលោកហ៊ីណូត៍ និងព្រះថេរានុត្ថេរច្រើនអង្គដែលជាក្រុមជំនុំប្រែព្រះត្រៃបិដកជាដើម ។

បំណែកខាងលោកមន្ត្រីបារាំងខ្មែរឃើញលោក ម៉ុងតូវ៉ានីជាអាំងស្ប៉ិកទ័រខាងរដ្ឋប្រសាសនោបាយជាជំនួសលោកឡឺរេ

ស៊ីដង់ត៍សុប៉េរិយ៉ើរ ព្រះអង្គម្ចាស់សុរាម្រិតទីក្រឡាហោម សេនាបតីក្រសួងសិប្បិយិការនឹងក្សេត្រាធិការ ព្រមទាំងសម្ដេចជាព្រះជាយាផង លោកសីដេស ជាចាងហ្វាងសាលាបារាំងសែសនៅបុងប្អូញប្រទេស ម៉ាដឹមហ្សែល កាប៉ីខ្សែស ជាអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ លោកគាមិសុងរេស៊ីដង់ត៍រួមខេត្រកំពង់ស្ពឺ ព្រមទាំងម៉ាដាម លោកហ្វារ៉ូជាដេឡេគេនៅអមរាជការខ្មែរ លោកបាម្និស ជាកុងត្រូល័រលិសស៊ីវិល លោកប៉ាម៉ងបេ ជាអ្នកប្រាជ្ញខាងវិជ្ជាស្គាល់របស់បូរាណ ដែលជាមិត្រនឹងលោកហ្វីណូត៍ អ្នកអង្គម្ចាស់ម៉ុងតាណាចៅហ្វាយខេត្រកំពង់ស្ពឺ ព្រមទាំងមន្ត្រីក្នុងឃុំទាំងអស់ ។

កាលដែលជួបជុំស្រេចហើយ លោកម៉ុងតូរ៉ានី នឹងព្រះអង្គម្ចាស់សុរាម្រឹត ចូលទៅអុចទៀន-ធូប ក្នុងទីបំពោះមុខរូបលោកហ្វីណូត៍ ដើម្បីសំដែងកិច្ចបូជាក្នុងកាលក្រោយបំផុតបំពោះទៅលោកហ្វីណូត៍ ។

នៅវេលាដែលអុចទៀននឹងធូបឆេះឡើង មានអណ្តាតភ្លើងនឹងផ្សែង សំដែងឲ្យយើងដែលក្រឡេកមើលទៅឃើញ

មានចិត្តរន្ធត់ញាប់ញ័រ ចំពោះទៅកាន់មរណធម៌របស់លោកហ្វីណូត៍ ។

ទើបលោកព្រះវិសុទ្ធិវង្ស តាត សូត្រសុន្ទរវាចាក្នុងកណ្ដាលទីប្រជុំនោះ រៀបរាប់ពីលោកហ្វីណូត៍ ដែលលោកមានសន្ដានចិត្តល្អ បានធ្វើកិច្ចការដែលនាំឲ្យមានប្រយោជន៍ដល់ព្រះពុទ្ធសាសនា ក្នុងកម្ពុជរដ្ឋ និងទំនុកបំរុងដល់ខ្លួនលោក ជាសេចក្ដីសង្ខេបថាៈ

លោកព្រះវិសុទ្ធិវង្ស ហ. តាត សូត្រក្នុងឱកាសបុណ្យឧទ្ទិស្សផលជូនលោកល្វីហ្វីណូត៍ នៅថ្ងៃ ៥ កើតខែជេស្ឋ ឆ្នាំកុរសប្តស័ក ព. ស. ២៤៧៧ ត្រូវនឹងថ្ងៃ ៦ យូវាំង ១៩៣៥ នៅទីវត្តប្រាង្គណ៍ (ឧដុង្គ) កំពង់ស្ពឺ ។

អាត្មាភាពមានសេចក្ដីអរគុណរាប់ពុំបាន ចំពោះអស់លោកទាំងឡាយដែលមានបណ្ដាស័ក្តិធំ ៗ បានអញ្ជើញមកជាអធិបតីនិងជាមង្គល ក្នុងឱកាសធ្វើបុណ្យឧទ្ទិស្សបញ្ជូនផលជូនទៅលោកហ្វីណូត៍ ជាគ្រូអាត្មាភាព ដែលលោកដល់នូវមរណកាលពីថ្ងៃ ២០ ខែម៉េឆ្នាំ ១៩៣៥ នេះ ។

នៅវេលាមុនដែលព្រះសង្ឃនឹងសូត្រធម៌ អាត្មាភាពសូមថ្លែងអំពីគុណូបការគុណរបស់លោកហ្វីណូត៌ ជូនអស់លោកឲ្យបានជ្រាបជាមុនសិន ។ ឯកិច្ចការដ៏ប្រសើរដែលលោកហ្វី-ណូត៌ បានធ្វើទុកឲ្យជាប្រយោជន៍ដល់ប្រទេសអាំងដូស៊ីន ។ នឹងដល់ពពួកជនក្នុងប្រទេសអាំងដូស៊ីននោះ អាត្មាភាពពុំបាច់នាំយកមកថ្លែងក្នុងទីនេះទេ អស់លោកទាំងឡាយសឹងបានជ្រាបដោយសព្វគ្រប់ហើយ ។

អាត្មាភាព សូមថ្លែងដោយសង្ខេបបំពោះកិច្ចការ ដែលលោកបានធ្វើជាប្រយោជន៍ដល់ព្រះពុទ្ធសាសនាក្នុងក្រុងកម្ពុជានេះ នឹងបំពោះខ្លួនអាត្មាភាព ដែលអស់លោកពុំជ្រាបសព្វគ្រប់ដូចសេចក្ដីតទៅនេះ ។

លោកហ្វីណូត៌ កាលដែលលោកនៅធ្វើជាចាងហ្វាងសាលាបារាំងសែសនៅចុងបូព៌ាប្រទេសនៅឡើយ លោកតែងមានចិត្តសប្បុរសនឹងសង្គ្រោះរាប់អាន ទំនុកបំរុងដល់ព្រះពុទ្ធ-សាសនា នឹងអ្នកកាន់ព្រះពុទ្ធសាសនាព្រមទាំងទីកន្លែងដែលជាទីដំកល់ព្រះពុទ្ធសាសនា ។

លោកបានជាវព្រះត្រៃបិដកមានចំនួនច្រើនក្បាល ពីប្រទេសអឺរ៉ុប ដោយប្រាក់របស់លោក យកមកដំកល់ទុកជាសម្បត្តិក្នុងសាលាបាលីជាន់ខ្ពស់ ។

លោកបានជួយឧបត្ថម្ភឲ្យកើតមានហោសៀវភៅ ក្នុងសាលាបាលីជាន់ខ្ពស់ ។

លោកជួយឧបត្ថម្ភ កិច្ចណាដែលខ្វះខាតពុំទាន់មាន ឲ្យកើតមានគ្រប់គ្រាន់ឡើង ទាំងបំណោះដែលត្រូវរៀនក្នុងសាលា លោកខំប្រឹងជួយខ្នះខ្នែងបំពេញឲ្យមានគ្រប់គ្រាន់ ដូចបំណោះសំស្ក្រឹតដែលមានព្រះរាជប្រកាសកំណត់ថា ត្រូវឲ្យរៀនក្នុងសាលាជាយូរហើយ តែមិនទាន់មានគ្រូដែលចេះសំស្ក្រឹតនឹងបង្រៀនបាន លោកហ្វីណូត៍ក៏ទទួលភារៈនេះពីរាជការប្រតិកត្តូរ៉ាត៍ក្នុងស្រុកខ្មែរ ទទួលយកព្រះសង្ឃពីរអង្គ គឺព្រះសាសន-សោភ័ណ ជួន-ណាត នឹងរូបអាត្មាភាព ដែលរាជការប្រតិកត្តូរ៉ាត៍បញ្ជូនពីស្រុកខ្មែរទៅ ឲ្យទៅនៅក្នុងបន្ទុកលោក ៗ ក៏ខំឈ្លៀតពេលបង្រៀនដោយខ្លួនលោកក្នុងឆ្នាំ ១៩២២-២៣ ដរាបដល់បានចេះគួរសមល្មមនឹងបង្ហាត់បង្រៀនបាន ។

លោកមិនគ្រាន់តែធ្វើប៉ុណ្ណោះ ហើយបោះបង់ចោលឡើយ គំនិតរបស់លោកនៅជាប់ក្នុងការជួយទំនុកបំរុងមកលើសាលាបាឡីជាន់ខ្ពស់ជាដរាប ទោះបីលោកអញ្ជើញទៅសំរាកឯស្រុកបារាំងក្នុងរវាង ១ ឆ្នាំឬ ២ ឆ្នាំក្តី លោកនៅតែមានសំបុត្រមកពន្យល់ពីការបង្ហាត់បង្រៀនបំណោះសំស្ក្រឹតរឿយ ៗ ព្រមទាំងឲ្យដំណឹងថាបើខ្វះខាតសៀវភៅអ្វី ឬក៏សង្ស័យនឹងបំណោះសំស្ក្រឹតត្រង់កន្លែងណា ឲ្យ ៗ ដំណឹងទៅលោក ៗ នឹងជួយបំពេញឬជួយពន្យល់ត្រាតែសម្រេចប្រយោជន៍តាមត្រូវការ ។

ម្យ៉ាងទៀត កាលដែលលោកអញ្ជើញត្រឡប់ទៅស្រុកបារាំងក្នុងជាន់ក្រោយបំផុតក្នុងឆ្នាំ ១៩៣០ ដែលលែងត្រឡប់មកវិញនេះ លោកសឺដេស ដែលធ្វើជាចាងហ្វាងសាលាបារាំងសែសដំណាងលោកមក នៅវេលាដែលបានអញ្ជើញមកស្រុកខ្មែរ បានប្រាប់ថា លោកហ្វីណូត៍ បានផ្តាំថាឲ្យអាត្មាភាពទៅនៅរៀនសំស្ក្រឹតឯសាលាបារាំងសែសបន្ថែមទៀត ដើម្បីឲ្យបានបំណោះនេះកើតបំរើនបែមឡើងសេចក្តីទាំងអស់នេះ រួបរួមទៅនាំឲ្យឃើញច្បាស់ថា ខ្លួនលោកមាន

បិត្តសប្បុរសមិនបេះផ្ដែតក្នុងការទំនុកបំរុងមកលើសាលាបាឡី ជាន់ខ្ពស់ជាសាលារៀនបំណេះខាងព្រះពុទ្ធសាសនា បិត្តគំនិតរបស់ លោកហ្វីណូត៍ ដែលសប្បុរសល្អមកលើពុទ្ធសាសនាយ៉ាងនេះ បើតាមធម៌របស់ព្រះពុទ្ធ ស៏ដែងថាជាគុណយ៉ាងឧត្តមបំផុត មិនអាចនឹងតបស្នងសងគុណឲ្យរួចបានឡើយ ដូចមាតាបិតាដែលមានបិត្តល្អទៅលើកូន មាតាបិតានោះមានគុណធំបំផុតត្រង់ដែលមានបិត្តល្អ ។

ឥឡូវនេះលោកហ្វីណូត៍ អញ្ជើញទៅកាន់បរលោកហើយ យើងអ្នកកាន់ព្រះពុទ្ធសាសនា មានសេចក្ដីស្ដាយលោកជាទីបំផុត មានអាការដូចជាបិតាដែលមានយសស័ក្តិធំមានទ្រព្យសម្បត្តិច្រើន កំពុងតែទំនុកបំរុងកូនចៅឲ្យបានសប្បាយក៏ស្រាប់តែធ្វើមរណកាលទៅ កូនចៅទាំងឡាយក៏បានសេចក្ដីទុក្ខព្រួយច្រើនយ៉ាងណាមិញ យើងអ្នកកាន់ព្រះពុទ្ធសាសនាក្នុងពេលនេះក៏ដូច្នោះដែរ ។

ឥឡូវនេះយើងពុំមានអ្វីនឹងតបឧបការគុណ ជូនឲ្យដល់ដែររបស់លោកដែលមានគុណធំនេះបានឡើយ មានតែកុសល

ដែលយើងបានធ្វើក្នុងថ្ងៃនេះយើងសូមឧទ្ទិស្សកុសលជូនទៅលោកហ្វីណូត៍ ឲ្យបានសម្រេចដល់ជាទីគាប់ចិត្តតាមប្រាថ្នារបស់លោក ។

អាត្មាភាពមានសេចក្ដីអរគុណ ។ល។ តាមប្រាថ្នារបស់លោក ។

លុះបប់សុន្ទរវាចាហើយ ព្រះសង្ឃគ្រប់អង្គបានសូត្រធម៌ព្រមគ្នា លុះសូត្របប់ហើយ ឧបាសកឧបាសិកាទាំងអស់បានសូត្រធម៌ព្រមគ្នា ឧទ្ទិស្សផលជូនទៅលោកហ្វីណូត៍ កាលដែលចប់កិច្ចសូត្រធម៌ហើយ លោកម៉ុងតូរ៉ាឌី ព្រមទាំងអស់លោកមន្ត្រីទាំងអស់ បានប្រគេនសៀវភៅបព្ជាក្ដនូក ១ ក្បាល ៗ នឹងរូបថតលោកហ្វីណូត៍ ព្រមទាំងសេចក្ដីសរសើរគុណលោក ១សន្លឹក ៗ ដល់ព្រះសង្ឃ ១ អង្គ ៗ ដរាបដល់គ្រប់អង្គទាំងអស់ ។ ឯសៀវភៅបព្ជាក្ដនូកនោះ សាលាបាឡីជាន់ខ្ពស់បានកសាងចែកជាធម្មទាន ឧទ្ទិស្សផលជូនទៅលោកហ្វីណូត៍ ព្រោះលោកមានគុណូបការច្រើនដល់ព្រះពុទ្ធសាសនា ។

ដល់ម៉ោង ៨ យប់ និមន្តព្រះធម្មកឋិក ២ អង្គទេសនា បុច្ឆា-វិសជ្ជនាដរាបដល់ម៉ោង ១០ យប់ចប់ ។

កម្មការក្នុងព្រះរាជបណ្ណាល័យ



សិលាចារិកសុីម៉ង់ រឿងព្រះពុទ្ធសាសនា ត្រង់ព្រះសម្មាសម្ពុទ្ធទ្រង់ប្រសូត ។

នៅអមសងខាងទ្វារខាងកើតនៃព្រះរាជបណ្ណាល័យកម្ពុជា មានសិលាចារឹក ២ របនាត្រង់ព្រះសម្មាសម្ពុទ្ធទ្រង់ប្រសូត ។

គំរូដើមនៃចារឹកនេះធ្វើដោយថ្ម សព្វថ្ងៃនៅ ៗ ទីដឹកល់របស់បុរាណសម្រាប់នគរនៅក្រុងបាងកក ។ សិលាចារឹកដើមនេះគេដឹកល់នៅក្នុងវត្តព្រះកែវជាឃ្លុយោ គឺព្រះយ៉ាស៊ីសហទេព (សេង) បានយកទីអង្គរហើយនាំយកទៅឯក្រុងបាងកកពីក្នុងព្រះពុទ្ធសករាជ ២៤៤១ ។

នៅក្រុងភ្នំពេញ មានរូបពុម្ពសំណាកនោះច្រើន ដែលធ្វើដោយស៊ីម៉ង់ ក្នុងរវាង ព. ស. ២៤៩៥ សព្វថ្ងៃមាននៅទីវត្តភ្នំ និងនៅមាត់ទ្វារខាងកើតព្រះរាជបណ្ណាល័យ ។ សិលាចារឹកនេះគេកសាងក្នុងសម័យអង្គរ គឺក្នុងរវាង ព. ស. ១៥០០- នៅបំឡាក់នោះ ឃើញព្រះនាងមហាមាយា ចាប់មែកឈើ ហើយឃើញព្រះអនាគតពុទ្ធប្រសូតចេញមកតាមកណ្ដៀតក្លម

ខាងស្តាំ យើញព្រហ្មព្រះកេស ៣ ព្រះហស្ត ៤ ទទួលយកព្រះមហាសត្តដោយសំពត់ ព្រះអនាគតពុទ្ធទ្រង់ឈានប្រាំពីរជំហាន ។

ស. ក.

## ដោយប្រការយ៉ាងណាខ្លះ ដែលគេគោរពព្រះបរមសម្មាសម្ពុទ្ធក្នុងស្រុកកម្ពុជា

ក្នុងវេលាដែលទ្រង់សម្ដែងព្រះធម្មចក្កប្បវត្តនសូត្រ នោះព្រះសម្មាសម្ពុទ្ធទ្រង់ប្រោសបានបញ្ចវគ្គិយទាំង ៥ ជាដំបូង ជាឯហិភិក្ខុ ។

ក្នុងសម័យនោះ នៅនគរពារាណសី មានកុមារម្នាក់ឈ្មោះយស ជាកូនអ្នកមាន ។ យសកុមារបានដើរទៅកាន់មិគទាយវ័ន បានស្ដាប់ធម្មទេសនា ហើយបានបួសបួស ។ នាងភរិយាយសកុមារព្រមទាំងឪពុកម្ដាយ ក៏បួលកាន់ព្រះពុទ្ធសាសនាជាមួយ ហើយឯកុមារឯទៀតៗ ជាច្រើនជាកូនអ្នកមានត្រកូល ក៏បួលទៅក្នុងសំណាក់ព្រះបរមសម្មាសម្ពុទ្ធជាមួយដែរ ។

ក្នុងកំណត់ ៣ ខែ ដែលព្រះបរមសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់គង់ក្នុងមិគទាយវ័ននោះទ្រង់បំបួសបានសិស្ស ៥៦ រូប ហើយទ្រង់បាត់ឲ្យចេញទៅផ្សាយព្រះពុទ្ធសាសនាក្នុងទីជនផ្សេងៗ ។

☼

☼ ☼

តពីវេលានោះមក ទ្រង់យាងទៅកាន់នគររាជគ្រឹះ ឬក្រុងឧសាជោ ដោយទ្រង់បានទទួលបេ្តជ្ញានឹងព្រះបាទពិម្ពិសារ ។ ដោយក្នុងសម័យនោះជារដូវភ្លៀង ហើយមានសត្វកង្កែបគីងគក់ លោតបុះឡើងប្រវាត់ដេរដាស នោះទ្រង់ក៏បង្អង់ពុទ្ធដំណើរសិន ដើម្បីកុំឲ្យអន្តរាយដល់ជីវិតសត្វអស់នេះ ។

លុះផុតរដូវភ្លៀងកាលណា ព្រះបរមគ្រូក៏ទ្រង់ពុទ្ធដំណើរទៅ លុះដល់ទីព្រៃឧរុវេលដែលកស្សបទាំង ៣ នាក់បងប្អូន តាំងសាសនាគោរពភ្លើងនៅក្នុងទីនោះ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ទេសនាប្រោសតាបសទាំង៣រូបនេះ ហើយតាបសទាំង៣ ក៏បោះបង់សាសនាព្រាហ្មណ៍ចោល ចូលបួសក្នុងសំណាក់ព្រះពុទ្ធសាសនាក្នុងវេលានោះទៅ មួយអន្លើដោយសិស្សគណចំនួន ១ ពាន់នាក់ ។

រួចពីនោះទ្រង់ពុទ្ធដំណើរតទៅទៀតជាមួយនឹងពុទ្ធបរិសទ្យទាំងនេះឆ្ពោះទៅកាន់រាជគ្រឹះនគរ ។ ក្នុងវេលានោះព្រះបាទពិម្ពិសារ យាងចេញពីក្នុងព្រះបរមរាជវាំងមក ដោយមានសេនាមាត្យហែហមជាច្រើន ដើម្បីទទួលព្រះបរមសាស្តាចារ្យ។

ដោយព្រះបរមគ្រូទ្រង់មិនបង់ឲ្យគេទទួលជាការអឹកធឹក នោះទ្រង់ក៏យាងចូលទៅប្រថាប់ក្នុងទីព្រៃមួយឈ្មោះថា ជោរិន គឺព្រៃលដ្ឋិវន ។ ព្រះបាទពិម្ពិសារក៏យាងទៅតាមព្រះសម្មាសម្ពុទ្ធក្នុងទីនោះ ហើយក៏ចូលកាន់ព្រះពុទ្ធសាសនាមួយអន្លើដោយអ្នកនគរទាំងអស់ ។

ក្នុងនគរនោះមានព្រៃ ១ យ៉ាងល្អ ឈ្មោះព្រៃបីក្លូន ឬព្រៃឫស្សីជារបស់សេដ្ឋីម្នាក់ឈ្មោះករន្ទ ។ ព្រះបាទពិម្ពិសារទ្រង់បាត់ឲ្យកសាងវត្ត ១ ក្នុងទីនោះថ្វាយដល់ព្រះបរមសាស្ដាចារ្យ ហើយព្រះអង្គក៏បានគង់សម្ដែងព្រះធម្មទេសនានឹងចាំវស្សាទី ២ និងទី ៣ ក្នុងទីនោះ ។ ក្នុងទីនេះហើយដែលព្រះអង្គប្រោសបានព្រាហ្មណ៍ពីរនាក់ដែលជាអ្នកប្រាជ្ញ គឺសារីបុត្ត ឬសារិបោត្យ ដែលទ្រង់តាំងជាសាវកស្ដាំ និងមោគ្គល្លាន ឬមោគ្គុនរេន ដែលទ្រង់តាំងជាសាវកឆ្វេង ។

* *

*

នៅឆ្នាំទី ៤ តពីទ្រង់បានពោធិញាណមក នោះព្រះបរមគ្រូទ្រង់យាងទៅកាន់ក្រុងវេសាលី ។ តាមផ្លូវទៅព្រះអង្គបានយាងកាត់ ក្រុងកបិលពស្តុនិងទេវទហ ក្នុងវេលានោះនគរទាំងពីរកើតទាស់ទែងគ្នា ដណ្ដើមទឹកស្ទឹងរោហិនី ដោយក្នុងសម័យនោះស្រុកកើតរាំងរាំងរហួត ។ ព្រះបរមគ្រូទ្រង់ញុំាងនគរទាំងពីរឲ្យមានមេត្រីនឹងគ្នាឡើងវិញបាន ហើយរួចពីនេះទ្រង់យាងទៅកាន់អារាម ទេវិតរុក្ខ ឬ អារាមព្រៃធំ នៅជិតក្រុងវេសាលី ព្រះអង្គទ្រង់គង់ចាំវស្សាទី ៤ និងទី ៥ ក្នុងទីនេះដើម្បីសម្ដែងព្រះធម្មទេសនាប្រោសសត្វ ។

វេលាផុតវស្សាទី ៥ ព្រះបរមសម្មាសម្ពុទ្ធទ្រង់យាងត្រឡប់មកកាន់នគររាជគ្រឹះវិញ ហើយទ្រង់ប្រថាប់ក្នុងទី ១ ឈ្មោះរោហិណីសេន ឬភ្នំ ត្នោតអស្ចារ្យ ។

*

* *

ក្នុងរវាងដែលទ្រង់ប្រថាប់ នៅក្នុងភ្នំត្នោតនោះព្រះអង្គបានជ្រាបជាព្រះបិតាជិតដល់ពេលនឹងទិវង្គត ។ ទ្រង់យាងទៅ

ជាប្រញាប់ ហើយបានសម្តែងធម៌ប្រោស ទ្រង់គង់ទាន់ជង្ហើម ហើយបានយាងទៅកាន់បុណ្យថ្វាយព្រះភ្លើង ។

រួចពីនោះទ្រង់ព្រះរាជទានឧបសម្បទជាភិក្ខុនីដល់ព្រះនាងយសោធរាដែលជាកន្សែសរពេជ្រនឹងព្រះនាងប្រជាបតី ជាព្រះមាតុច្ឆា នឹងជាព្រះអគ្គមហេសី ព្រះបាទសុទ្ធោទន ។

*

* *

តពីនេះព្រះបរមគ្រូទ្រង់យាងទៅកាន់ក្រុងកោសម្ពី ហើយគង់ចាំវស្សាទី ៦ ក្នុងទីនោះ ។

ក្នុងទីនេះទ្រង់បានជួបព្រះនន្ទជាប្អូន នឹងទ្រាជោទនជាមាមួយអន្លើដោយមិត្តសំឡាញ់កាលពីដើមទាំង ៨ នាក់ ដែលបានឮព្រះធម្មទេសនាហើយក៏បួលបួសក្នុងព្រះពុទ្ធសាសនាទាំងអស់គ្នា ។ ព្រះអង្គបានទទួលមនុស្សម្នាក់ឈ្មោះឧបាលិដែលមានត្រកូលទាបថោកឡើបួលបួសក្នុងព្រះពុទ្ធសាសនា ហើយទ្រង់ដាក់ឡស្មើស័ក្តិនឹងភិក្ខុទាំងអស់ក្នុងវេលានោះមានកើតរឿងរ៉ាវឡើង គឺពួកភិក្ខុចាស់ ៗ បំអកឡកឡឺយហើយ

ឲ្យឿលត្អះនាយអាយ ប៉ុន្តែរឿងរ៉ាវទាំងនេះស្ងប់ស្ងាត់ទៅវិញ ដោយព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងព្រះធម្មទេសនាប្រាប់ថា នៅអំពីលើដើមកំណើតនឹងវង្សត្រកូលនោះមានសីល ហើយ សីលនេះអាចធ្វើមនុស្សឲ្យមានមុខស្មើគ្នាទាំងអស់ ។

*

* *

ក្នុងសម័យជាមួយគ្នានេះ ព្រះអង្គម្ចាស់សុទត្ត បានសេរ ព្រះវិហារធំ ១ ឈ្មោះយុត្តវ្ជៈ នៅក្នុងនគរ កេសរៈ ថ្វាយព្រះ បរមសាស្ដាចារ្យ ។ នៅទីនេះហើយដែលស្រីស្នមទានម្នាក់ គោរពព្រះអង្គដោយកិច្ចយ៉ាងសំខាន់ ដូចខាងក្រោយនេះ ។

នៅទីជិតខាងព្រះវិហារនោះ មានស្រីម្នាក់ជាអ្នកក្រខ្សត់ ណាស់ឈ្មោះនាងនន្ទា នាងនេះនៅតែម្នាក់ឯង តែងដើរសុំទាន បាយទឹក ដើម្បីបរិភោគចិញ្ចឹមជីវិត ។

ក្នុងថ្ងៃ ១ នាងបានឃើញពួកខត្តិយវង្ស សេនាបតី និង នាហ្មឺនសព្វមុខមន្ត្រីធ្វើការបូជាចំពោះដល់ព្រះសម្មាសម្ពុទ្ធ និង ដល់ព្រះសង្ឃ ហើយនាងគិតក្នុងចិត្តថា ឱខ្លួនអញអើយ

កាលជាតិមុនអញបានធ្វើបាបកម្មអ្វី បានជាមកកើតជាអ្នកក្រ ជុនជាបដ្ឋប្ដេះ រកតែអ្វីនឹងបូជាព្រះបរមគ្រូដែលជាស្រែបុណ្យនេះគ្មានសោះ ។

នាងនឹកទៅតូចចិត្ត ហើយស្ដាយដែលបានកសាងមិនល្អ មកពីជាតិមុន ដោយហេតុនេះបានជាក្នុងថ្ងៃ ១ នាងដើរសុំទាន ហើយផ្សំបាន ១ កាកណិក[1] ទើបនាងទៅកាន់ផ្ទះអ្នកលក់ប្រេង ។ អ្នកលក់ប្រេងសួរមកកាន់នាងវិញថា ប្រេង ១ កាកណិកនោះបានតិចណាស់ ហើយយកទៅធ្វើអ្វីក៏មិនកើត នាងឯងទិញយកទៅធ្វើអ្វី? នាងឥន្ទាក៏បានប្រាប់សេចក្ដីប្រាថ្នារបស់នាងដល់អ្នកលក់ប្រេង ហើយអ្នកលក់ប្រេងមានសេចក្ដីអាណិតក៏ដងប្រេងយ៉ាងច្រើនឲ្យមក ។ នាងនន្ទាមានសេចក្ដីត្រេកអរខ្លាំង ក៏រត់យកប្រេងនេះដម្រង់ទៅព្រះវិហារ យុន្សូជៈ ហើយបូជាដល់ព្រះបរមលោកនាថដោយបញ្ចេញនូវវិបីភេទថា ខ្ញុំសូមបូជាពន្លឺតូបនេះបំពោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដោយបុញ្ញកិរិយាវត្ថុនេះ អំណើសតទៅក្នុងជាតិជាអនាគតខ្ញុំសូមឲ្យបានមានប្រាជ្ញាយល់

១ កាកណិក ជាខ្មែរហៅលក្រាក់ប៉ែបូរាណៈយើង ។

ច្បាស់ ហើយឲ្យបានដកខ្លួនផុតស្រឡះចេញពីក្នុងសេចក្ដីងងឹត ដែលអោបរុំសត្វទាំងឡាយរាល់គ្នា ។

លុះឱទ្ទិស្សផ្លូវប្ដេះរួបហើយ នាងក៏ក្រាបថ្វាយបង្គំព្រះបរមសាស្ដាចារ្យ វិលត្រឡប់ទៅទីលំនៅវិញ ។

លុះដល់ពេលអធ្រាត្រ ប្រទីបទាំងអស់ក៏រលត់ទៅ សល់នៅតែប្រទីបនាងទន្ធានៅឆេះជាដរាប ។ ព្រះមោគ្គល្លានបានពន្លត់អស់វារៈ ៣ ដងមិនរលត់ ។ ព្រះសម្មាសម្ពុទ្ធបានឃើញដូច្នោះ ក៏មានព្រះបន្ទូលទៅកាន់ថា មោគ្គល្លាន ប្រទីបនេះបានជាមិនរលត់ ព្រោះនាងនោះបានបូជាដោយចិត្តសទ្ធាយ៉ាងមុតមាំជាទីបំផុត បើទុកជាយកទឹកក្នុងមហាសមុទ្រទាំង ៤ មកចាក់ស្រោចពន្លត់ក៏ប្រទីបនេះមិនរលត់ឡើយ ។

ក្នុងឆ្នាំទី ៩ តពីបានត្រាស់មក ព្រះពិជិតមារទ្រង់គង់ចាំវស្សាក្នុងទីអារាម យុទ្ធជ្រះមានថ្ងៃ ១ ព្រះរាគោរ (រាហុល) បានយាងមកស្ដាប់ព្រះសទ្ធម្មទេសនាក្នុងទីនោះ ហើយក៏ចូលបួសក្នុងសំណាក់ព្រះពុទ្ធសាសនាទៅ ។

ក្នុងឆ្នាំទី ១២ និងឆ្នាំតទៅ ព្រះទសពលញាណទ្រង់ចាត់ព្រះអរហន្តធំ ៗ ឲ្យចេញផ្សាយព្រះពុទ្ធសាសនាទៅក្នុងទីដ៏ឆ្ងាយ ៗ ។ បំណែកព្រះអង្គទ្រង់យាងប្រោសសត្វក្នុងស្រុកជិតខាង ប្រោសបានមនុស្សជាច្រើនពាន់នាក់ ក្នុងពួកមនុស្សចូលបួសនេះមានខត្តិយវង្សពីរអង្គ ក្នុងរាជវង្សស្តេចដែលសោយរាជ្យជាដំណពីស្តេច ដោហ័ន ។

ក្នុងឆ្នាំទី ២១ ព្រះបរមលោកនាថទ្រង់ប្រោសបានព្រាហ្ម-ណ៍ម្នាក់ ដែលបានសំឡាប់មនុស្សជាច្រើន ហើយព្រះអង្គទ្រង់ប្រទានផ្នួសឲ្យបជាពុទ្ធបរិសទ្យឯទៀតៗ ដែរ ។

ក្នុងឆ្នាំទី ២២ ព្រះបរមគ្រូទ្រង់តាំងព្រះមហាអានន្ទជាអ្នកបំរើផ្ទាល់ព្រះអង្គជានិច្ច ដែលត្រូវតាមព្រះអង្គទៅណាៗ គ្រប់ទីដំបន់ ព្រះមហាអានន្ទនេះហើយដែលចាំបាននូវធម៌អាថ៌ទាំងអស់ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងប្រោសសត្វ ។

ក្នុងសម័យជាមួយនោះ មានកើតចលាចលក្នុងនគរតូចៗនៃប្រទេសឥណ្ឌាដោយច្បាំងនឹងគ្នាឯង ហើយព្រះបរមគ្រូទ្រង់

លៃពេលយាងទៅប្រថាប់នៅអារាមព្រៃធំម្ដង នៅអារាមយុត្ស្ជេះម្ដង និងនៅអារាមភ្នំត្នាតម្ដង ឲ្យស្មើគ្នា ។

ក្នុងឆ្នាំទី ៣៧ ព្រះអង្គគង់នៅវត្តភ្នំត្នាត ហើយទ្រង់ពិចារណានូវព្រះធម៌បុណ្ឌរីក ឬហោកេ្ក-កេ្យា ហើយព្រះអង្គសម្ដែងពន្យល់ព្រះធម៌នេះកំណត់ ៨ ឆ្នាំជរាបដល់ឆ្នាំដែលទ្រង់ចូលព្រះបរមនិព្វាន ។

✲

✲ ✲

# សាសនប្រវត្តិ

## ព្រះមហាពិទូរក្រសេម គន្ថរបនបណ្ឌិត នៅព្រះរាជបណ្ណាល័យ

រៀបរៀង

(៣)



នេះជាស្ថានទីដំកល់ព្រះត្រៃបិដក ១ ចប់ សិលាចារិកនៅផែនថ្មកែវ ចំនួន ៧២៩ ផ្ទាំង នៅវត្តកុថោដោវ ក្រុងមណ្ឌលេ (ភូមា) ។៚

## ក្បួនព្រះពុទ្ធរូបក្នុងលទ្ធិទក្ខិណនិកាយ

ឯក្បួនព្រះពុទ្ធរូបនេះបានពោលហើយថា កើតឡើងដោយពួកឧត្តរនិកាយផ្ដើមសាងឡើងជាដំបូង ពួកទក្ខិណនិកាយឃើញហើយក៏កើតជ្រះថ្លា ទើបនាំគ្នាសាងឡើងដែរ តាមយ៉ាងពួកឧត្តរនិកាយ តែការសាងព្រះពុទ្ធរូបនោះសូម្បីគ្រូដើមជាមួយគ្នាក៏ពិត តែកាលផ្សាយទៅក្នុងនានាប្រទេសហើយ រមែងមានលក្ខណប្រែប្រួលទៅតាមស្នាដៃរបស់ជាងក្នុងប្រទេសនោះ ៗ ជាធម្មតា ទាំងសាងថែមបំនួនច្រើនឡើងទៀតដោយលំដាប់ ក្នុងទីនេះនឹងបានរូបរួមព្រះពុទ្ធរូបអំបាលនោះដែលគេតែងសាងហើយដោយច្រើន មករៀងទុកដោយលំដាប់តាំងពីបឋម ពោធិកាល រហូតបច្ឆិមពោធិកាល វៀរលែងតែត្រង់មជ្ឈិមពោធិកាល ខ្ញុំមិនអាចនឹងរៀបរៀងឲ្យត្រូវលំដាប់បានដោយមិនមានពេលនឹងស្រាវជ្រាវរករឿងដើម តោងរៀងដោយស្មាន ជឿថាគង់ត្រឡប់មុខជាក្រោយ ក្រោយជាមុខខ្លះមិនខាន ។

១ គ្រាប្រសូត ធ្វើជារូបព្រះរាជកុមារទើបប្រសូតថ្មី ឈរខាងព្រះមាតា បំណែកឯព្រះមាតាឈរកាន់មែកឈើ ជួនកាលគេធ្វើទាំងរូបគ្រឿងប្រកបផង គឺរូបព្រះព្រហ្ម ព្រះឥន្ទ្រ ទេពធីតា និងផ្កាឈូក ៧ ផ្កា ។ ធ្វើដំណាលកាលព្រះមហាបុរសប្រសូត ដោយព្រះជាតិជាទីបំផុតនៅសួនលុម្ពិនីវ័ន ក្នុងរវាងតដែននៃនគរកបិលពស្តុនិងនគរទេវទហ ។

២ គ្រាមហាភិនេស្រ្កម ឬហៅថាគ្រាទ្រង់ផ្នួស ធ្វើជារូបមហាបុរសគង់ពត់ព្រះភ្នែន ព្រះហស្តឆ្វេងចាប់ព្រះមោលីស្ទួយឡើង ព្រះហស្តស្តាំទ្រង់ព្រះខាន់កាត់ព្រះមោលីនោះ ។ ជួនកាលគេធ្វើទាំងរូបដទៃប្រកបផង គឺរូបឆន្នអាមាត្យ រូបសេះព្រះទីនាំង រូបព្រះព្រហ្មយកត្រៃចីវរមកថ្វាយ រូបព្រះឥន្ទ្រយកប្រអប់កែវមកទទួលដាក់ព្រះមោលី ។ ធ្វើដំណាលកាលព្រះមហាបុរសកាត់ព្រះមោលីទ្រង់ព្រះផ្នួសនៅឆ្នេរស្ទឹងនេរញ្ជរា ក្នុងដែនប្រទេសមគធ ។

៣ គ្រាបំពេញទុក្ករកិរិយា ធ្វើជាព្រះពុទ្ធរូបស្គម គង់ពត់ព្រះភ្នែន ព្រះហស្តទាំងពីរធ្វើបែបគ្រាធ្យានមុទ្រ ជួនកាល

គេធ្វើព្រះហស្តទាំងពីរឱបព្រះឧរា ។ ធ្វើដំណាលកាលព្រះមហាសត្វធ្វើទុក្ករកិរិយា ដើម្បីពោធិញាណនៅពោធិព្រឹក្សមណ្ឌល ក្នុងដំបន់ស្រុកពុទ្ធគយា ដ៏តាំងនៅក្នុងរវាងតដែនប្រទេសមគធនឹងប្រទេសកោសល ។

៤ គ្រាពិចារណាកម្មដ្ឋាន ធ្វើជាព្រះពុទ្ធរូបឈរ សំយោកព្រះហស្តឆ្វេង លូកព្រះហស្តស្តាំផ្កាប់បេញទៅមុខជាកិរិយាចាប់ ។ ធ្វើដំណាលកាលព្រះអង្គពិចារណាបដិកូលកម្មដ្ឋានសព់នាងបុណ្ណាទាសី ទ្រង់ចាប់ទាញសំពត់ស្មបដែលរុំសពមកធ្វើជាចីវរទ្រង់ ។

៥ គ្រាទទួលបាច់ស្បូវ ធ្វើជាព្រះពុទ្ធរូបឈរសំយោកព្រះហស្តឆ្វេង ហុចព្រះហស្តស្តាំផ្ងាបេញទៅមុខ ជាកិរិយាទទួលបាច់ស្បូវ ជួនកាលគេធ្វើទាំងរូបបាច់ស្បូវផង ។ ធ្វើដំណាលកាលព្រះអង្គទទួលបាច់ស្បូវ ដែលសោត្ថិយព្រាហ្មណ៍ថ្វាយ ទ្រង់យកមកក្រាលគង់តាងបល្លង្កនៅក្រោមដើមពោធិ-ព្រឹក្ស ។

៦ គ្រាទទួលមធុបាយាស ធ្វើជាព្រះពុទ្ធរូបគង់សំយោក ព្រះបាទទាំងពីរយ៉ាងអង្គុយកោរអី ព្រះហស្តទាំងពីរលាតផ្ងា ដាក់លើព្រះជានុ បង្អោនព្រះអង្គបុះបន្តិច ជាកិរិយាទិនទទួល ។ ធ្វើដំណាលកាលព្រះអង្គទទួលភាជនមធុបាយាស ដែលនាងសុជាតាថ្វាយ ក្នុងថ្ងៃដែលបានត្រាស់ ។

៧ គ្រាសោយមធុបាយាស ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែន ព្រះហស្តឆ្វេងចាប់មាត់ភាជន ព្រះហស្តស្តាំលូកបុះក្នុងភាជន ជាកិរិយាលូកចាប់មធុបាយាសមកសោយ ។ ធ្វើដំណាលកាលព្រះអង្គសោយមធុបាយាស ដែលនាងសុជាតាថ្វាយ ។

៨ គ្រាបណ្តែតភាជន ធ្វើជាព្រះពុទ្ធរូបគង់លុតព្រះជានុ ព្រះហស្តទាំងពីរផ្គងផ្ងាលើព្រះជានុ ជាកិរិយាបណ្តែតលែងភាជន ។ ធ្វើដំណាលកាលព្រះអង្គសោយមធុបាយាសហើយយកភាជននោះទៅផ្សងបណ្តែតទឹកស្ទឹងនេរញ្ជរាដើម្បីផ្សងលរមើលព្រះបារមីជាបានត្រាស់ឬមិនបានត្រាស់ ។

៩ គ្រាផ្ចាញ់មារ ឬហៅគ្រាមារវិជ័យ ជាគ្រាជាមួយគ្នា ដែលឥណ្ឌៀហៅថា ភូមិស្បស៌មុទ្រ មានលក្ខណាការដូចពោលហើយ ។

១០ គ្រាសមាធិ ឬហៅថា ត្រាស់ដឹង ជាគ្រាជាមួយគ្នានឹងធ្យានមុទ្រ មានលក្ខណាការដូចពោលហើយ ។ ទីនេះរាប់ជាសត្តមហាស្ថានទី ១ ។

១១ គ្រាថ្វាយនេត្រ ឬហៅថា គ្រាអនិមិ្មសចេតីយ៍ ធ្វើជាព្រះពុទ្ធរូបឈរស្រែះព្រះហស្តទាំងពីរ ។ ធ្វើដំណាលកាលព្រះសាស្តាទើបបានត្រាស់ថ្មី ស្តេចចេញទៅទិសឦសាណនៃពោធិព្រឹក្ស ទ្រង់ឈរទតព្រះនេត្រមកដើមពោធិព្រឹក្សពិចារណាបារមីធម៌ ដែលបណ្តាលឲ្យបានសម្រេចពោធិញាណ អស់ ៧ ថ្ងៃ ៧ យប់ ដោយអិនព្រិចព្រះនេត្រសោះ ជួនកាលគេធ្វើទាំងដើមពោធិព្រឹក្សផងជាគ្រឿងប្រកប ។ ទីនេះរាប់ជាសត្តមហាស្ថានទី ២ ។

១២ គ្រានិរមិតរតនចង្ក្រម ឬហៅថា គ្រាចង្ក្រមកែវ ធ្វើជាព្រះពុទ្ធរូបឈរបង្ហើបកែងព្រះបាទខាងឆ្វេងបន្តិច ជា

កិរិយាយាងចង្រ្កម ព្រះហស្ដទាំងពីរឱបខ្វែងគ្នាពីខាងមុខជាកិរិយាសម្រួម ជួនកាលគេធ្វើមានផ្ទះកែវនៅម្ខាងជាគ្រឿងប្រកបផង ។ ធ្វើដំណាលកាលព្រះសាស្ដាស្ដេចចង្រ្កម អស់ ៧ ថ្ងៃ ៧ យប់ ក្នុងទីរវាងដើមពោធិព្រឹក្ស នឹងផ្ទះកែវដែលទ្រង់និរមិត្រឡើង ។ ទីនេះរាប់ជាសត្តមហាស្ថានទី ៣ ។

១៣ គ្រាពិចារណាធម៌ក្នុងផ្ទះកែវ ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែនក្នុងផ្ទះកែវ ព្រះហស្ដទាំងពីរដាក់ជម្រួតគ្នាលើព្រះភ្នែន ដូចគ្រាសមាធិ ។ ធ្វើដំណាលកាលព្រះសាស្ដាគង់ក្នុងផ្ទះកែវ ទ្រង់ពិចារណាធម៌ដែលព្រះអង្គបានត្រាស់ដឹងហើយនោះ ឃើញឫស្មីជារបស់គម្ពីរភាពកែ្រពេក ។ ទីនេះរាប់ជាសត្តមហាស្ថានទី ៤ ។

១៤ គ្រាចូលឈាន ធ្វើជាព្រះពុទ្ធរូបដូចគ្រាសមាធិ ឬធ្យានមុទ្រ ប្លែកតែគ្រានេះមានរូបដើមជ្រៃជាគ្រឿងប្រកប ជួនកាលគេធ្វើមានទាំងរូបធីតាមារផង ។ ធ្វើដំណាលកាលព្រះសាស្ដាចូលសមាធិឈាននៅក្រោមដើមជ្រៃ អស់វារ ៧ ថ្ងៃ ៧ យប់ ដើម្បីសោយវិមុត្តិសុខ ។

១៥ គ្រាសំដែងឱឡារិកនិមិត្ត ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្លែន ព្រះហស្តឆ្វេងលើកវាស្មើព្រះឱរា ជាកិរិយាបដិសេធព្រះហស្តស្តាំដាក់ផ្កាប់លើព្រះជានុ ។ ធ្វើដំណាលកាលព្រះសាស្តាគង់នៅក្រោមដើមជ្រៃ ទ្រង់បដិសេធហាមមារធីតាទាំង ៣ នាងដែលមកប្រលោមព្រះអង្គដោយកាម ។

១៦ គ្រាហាមមារ ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្លែនព្រះហស្តឆ្វេងដាក់ផ្ងារលើព្រះឱរូ ព្រះហស្តស្តាំលើកវាស្មើព្រះឱរា តែវាបែរបិតនឹងព្រះឱរា ។ ធ្វើដំណាលកាលព្រះសាស្តាគង់នៅក្រោមដើមជ្រៃ ទ្រង់ហាមមារាធិរាជអ្នកមកអារាធនាឲ្យព្រះអង្គប្រញាប់ចូលព្រះបរមនិព្វានទៅ, ព្រះអង្គត្រាស់ថា បរិសទ្យ៤ នៅមិនទាន់កើតមានបរិបូណ៌ដរាបណា តថាគតនឹងមិនទាន់ចូលនិព្វានដរាបនោះ ។ ទីនេះរាប់ជាសត្តមហាស្ថានទី ៥ ។

១៧ គ្រានាគប្រក់ ធ្វើជាព្រះពុទ្ធរូបបែបគ្រាធ្យានមុទ្រប្លែកតែគ្រានេះគង់លើភ្លែននាគជាៗនោះធ្វើជាក្បាល ៧ បើកពពារគ្របពីលើព្រះពុទ្ធរូប ។ ធ្វើដំណាលកាលព្រះសាស្តាទើបបានត្រាស់ថ្មី ស្តេចទៅគង់នៅក្រោមដើមមុចលិន្ទ (រាំងភ្នំ) ៧ ថ្ងៃ

៧ យប់ គ្រានោះភ្លៀងធ្លាក់បំពេញទាំងថ្ងៃទាំងយប់ មុចលិន្ទ-នាគរាជឡើង មកបើកពពារបាំងថ្វាយព្រះអង្គដើម្បីមិនឲ្យទទឹកទឹកភ្លៀង ។ ទីនេះរាប់ជាសត្តមហាស្ថានទី ៦ ។

១៨ គ្រាអធិដ្ឋានបាត្រ ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែនព្រះហស្តឆ្វេងហាប់កៀកបាត្រ ព្រះហស្តស្តាំធ្វើងារអង្អែលមាត់បាត្រ ជាកិរិយាតាំងព្រះហឫទ័យអធិដ្ឋានបាត្រ ។ ធ្វើដំ-ណាលកាលព្រះសាស្តាគង់នៅក្រោមដើមកែស ទ្រង់អធិដ្ឋានបាត្រសិលាទាំង ៤ ដែលព្រះចតុលោកបាលមហារាជទាំង ៤ យកមកថ្វាយមួយអង្គ ១ បញ្ចូលគ្នាទៅជាបាត្រតែ ១ ហើយទ្រង់ប្រើបាត្រនោះរហូតដល់និព្វាន ។

១៩ គ្រាទទួលផ្លែសម៉ ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែនព្រះហស្តឆ្វេង ដាក់ផ្ងារលើព្រះភ្នែន ព្រះហស្តទ្រង់កាន់ផ្លែសម៉ ។ ធ្វើដំណាលកាលព្រះសាស្តាគង់នៅក្រោមដើមកែសដដែលនោះទ្រង់ទទួលអាមលកផលដែលព្រះឥន្ទ្រាធិរាជនាំយកមកថ្វាយ ។

២០ គ្រាទទួលសត្តុ ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែនព្រះហស្តស្តាំដាក់ផ្ងារលើព្រះភ្នែន ព្រះហស្តឆ្វេងទ្រង់កាន់ដុំ

សត្វ ។ ធ្វើដំណាលកាលព្រះសាស្តាគង់នៅក្រោមដើមកែសដដែលនោះ ទ្រង់ទទួលសត្វរបស់ពាណិជពីរនាក់បងប្អូនឈ្មោះតប្បុស ១ ផល្លិក ១ នាំយកមកថ្វាយ ។

២១ គ្រាប្រទានព្រះកេសធាតុ ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែន ព្រះហស្តឆ្វេងដាក់ផ្កាលើព្រះភ្នែន ព្រះហស្តស្តាំចាប់ប្បូតព្រះកេសា ។ ធ្វើដំណាលកាលព្រះសាស្តាគង់នៅក្រោមដើមកែសដដែលនោះ ទ្រង់ប្បូតដកព្រះកេសធាតុ ៨ អង្គ ប្រទានដល់តប្បុសនឹងផល្លិកអ្នកថ្វាយសត្វដល់ព្រះអង្គ ពាណិជនោះបាននាំយកព្រះកេសធាតុអំបាលនោះទៅធ្វើព្រះចេតីយ៍បញ្ចុះទុកដែលហៅថា សិង្គុត្តរចេតីយ៍ នៅក្នុងរាមញ្ញប្រទេសព្រះចេតីយ៍នោះស្ថិតនៅដរាបដល់សព្វថ្ងៃនេះ ។ ទីនេះរាប់ជាសត្តមហាស្ថាន ទី ៧ ។



ផែនសិលាចារឹក នៅវត្តសង្គ្រាមុនី ក្រុងមណ្ឌលេ (ភូមា) ។ ៚

# រឿងខ្លាអាភេទ

រឿង៥៧

នៅក្នុងនគរ១ មានស្តេចសោយរាជ្យក្នុងនគរនោះ ឯស្តេចនោះបានសោយរាជ្យឡើងកាលណា ក៏គិតក្នុងព្រះទ័យថា បើមានខ្មាំងសត្រូវឯណាគេលើកមកវាយនគរ ហើយយើងគ្មានបំណេះវិជ្ជាអ្វីនឹងការពាររក្សានគរ ស្តេចនោះគិតដូច្នោះហើយ លុះដល់វេលាព្រឹក ស្តេចចេញចុងព្រះរាជរោងជុំអស់នាម៉ឺនមុខមន្ត្រី ស្តេចមានបន្ទូលនឹងអស់នាម៉ឺនថា បើសិនណាមានខ្មាំងសត្រូវ គេលើកមកវាយដណ្តើមយកនគរយើង ក្នុងនគរយើងនេះគ្មានស្តេច នាម៉ឺនឯណាដែលចេះវិជ្ជាការបំណេះខាងបំបាំងនោះគ្មាន បើដូច្នេះយើងទៅរករៀនបំណេះរបៀនខាងបំបាំងឲ្យពូកែនឹងបានរក្សាស្រុករក្សានគរកុំឲ្យខ្មាំងសត្រូវឯណា ប្លាំងដណ្តើមយកនគរយើងបាន ស្តេចមានព្រះបន្ទូលដូច្នោះហើយ អស់នាម៉ឺនសព្វមុខមន្ត្រីចូលចិត្តព្រមជាមួយនឹងស្តេច ហើយស្តេចឲ្យសម្តេចចៅហ្វានៅរក្សានគរ ជាមួយនឹងសព្វមុខមន្ត្រី ហើយយកមហេសីហោរាចៅចតុស្តម្ភទាំង៤ទៅជាមួយនឹងស្តេចទៅនគរតក្កសិលា រៀនបំណេះវិជ្ជាការពីអាចារ្យទិសាបាមោក្ខ ។

ឯស្ដេចនឹងមហេសី ហោរានឹងនាម៉ឺនបតុស្ដម្ភទាំង៤ លុះទៅដល់នគរតក្កសិលា ហើយចូលទៅកាន់ផ្ទះអាចារ្យទិសាបាមោក្ខ ហើយសូមរៀន សិល្បសាស្ត្រ ពីអាចារ្យទិសាបាមោក្ខទាំង ៧ នាក់ លុះរៀនសិល្បសាស្ត្រចេះចប់សព្វគ្រប់ហើយ ក៏លាអាចារ្យត្រឡប់មកនគរវិញ លុះដល់មកពាក់កណ្ដាលផ្លូវហើយ អត់បាយគ្មានស្រុកគេនៅ ហើយស្ដេចទ្រង់ព្រះចិន្ដានឹងអគ្គ-មហេសីនឹងហោរានឹងបតុស្ដម្ភទាំង៤ថា យើងឥឡូវនេះអត់បាយគ្មានភូមិស្រុកគេនៅ បើដូច្នេះយើងល្បងចំណេះរៀនដែលយើងរៀនមក គឺយើងនឹងដំណែងធ្វើជាខ្លាចាប់សត្វស៊ីក្នុងព្រៃនេះឲ្យឆ្អែត មានកំលាំងហើយសឹមយើងទៅទៀត គិតគ្នាព្រមដូច្នោះហើយស្ដេចដំណែងធ្វើជាមុខខ្លា ឯអគ្គមហេសីធ្វើជាខ្លួន ហោរាធ្វើជាកន្ទុយបតុស្ដម្ភទាំង៤ ធ្វើជាជើងទាំង៤ ហើយចូលទៅក្នុងព្រៃរកចាប់ប្រើសក្ដាន់ស៊ីជាចំណីសប្បាយក្នុងចិត្ត លុះដល់ពីរបីថ្ងៃភ្លេចគិតត្រឡប់មកជាមនុស្សវិញ ដោយសប្បាយក្នុងព្រៃ បានចំណីស៊ីឆ្អែតក៏នៅជាសត្វខ្លា លុះដល់សព្វថ្ងៃឥឡូវនេះបានជាសត្វខ្លាមានមុខសំបើម ពីព្រោះអំណាចស្ដេច

នៅខាងក្បាល ឯខ្លួនខ្លានោះអគ្គមហេសីជាស្រី បានជាខ្លួននោះ តូបបង្កេះនោះវៀរដោយសាជាស្រី ឯហោរនោះនៅកន្ទុយជាប្រផ្នូលតែងបួល បើថ្ងៃណាអត់ចំណីខ្លានោះបួលនឹងកន្ទុយ បើកន្ទុយនោះបក់ទៅទិសណាខាងណា ខ្លាក៏ទៅតាមខាងនោះ បានចំណីស៊ីឆ្អែតបរិបូរណ៍ដោយសាកន្ទុយនោះឯង ហើយមានឆ្នើម ៣ ពីព្រោះមនុស្ស ៣ នាក់ ទៅការឡាធ្វើជាសត្វខ្លា បានជាមានឆ្នើម ៣ ហើយកំលាំងក៏ខ្លាំង លុះដរាបមកដល់សព្វថ្ងៃនេះ ។

និយាយរឿងព្រេងអំពីសត្វខ្លាអស់ដំណើរតែប៉ុណ្ណោះ ។

# បញ្ជីរឿង


ទំព័រ

១ របៀបបុណ្យព្រះរាជទានព្រះភ្លើងព្រះសពព្រះអង្គម្ចាស់ក្សត្រី ហរិរ័ក្ខ មណ្ឌាទិព្យម៉ាល (ហៅថា មន្លា) . . . . . . . . . . . . . . . . . . . . . ៤៣

២ សាសនប្រវត្តិ ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត រៀបរៀង (ត) . . . ៤៧

៣ ដោយប្រការយ៉ាងណាខ្លះដែលគេគោរពព្រះបរមសម្មាសម្ពុទ្ធ នៅក្នុងស្រុកឥណ្ឌៀ ស. បូណ្ណ រៀបរៀង ក្រមការ ដុំ-មៅ ប្រែជាភាសាខ្មែរ (តចប់) . . . . . . ៦៧

៤ រឿងព្រេងខ្មែរ ដែលមិនទាន់បោះពុម្ពផ្សាយ រឿងចៅសុខចៅសៅ . . . . . ៧៧


## រូបផ្សេងៗ


១ រូបទ្វារហោធម្មមន្ទីរ អគ្គមហេសីស្ដេចភូមាទ្រង់សាង . . . . . . . . . . . . ៤៩

២ រូបព្រះចេតិយ៍លោកានន្ទ ស្ដេចភូមាសាង បញ្ចុះព្រះទន្តធាតុព្រះពុទ្ធអង្គ . . . . ៦៩

# TABLE DES MATIÈRES

I. Nécrologie de S. A. R. la Princesse Harirak Mondéatipmal dite Montha par Préas Maha Pitou Krasem à la Bibliothèque Royale .......... 53

II. Sāsanapravatti ou Histoire des religions par Préas Maha Pitou Krasem (à suivre) .......... 57

III. De quelle manière le Bouddha fut vénéré dans l'Inde par Georges Bonneau. Traduit du Français en Cambodgien par Kromokar Chum-Mau. (suite et fin) .......... 67

V. Conte populaire cambodgien inédit Chau Sok Chau Sao .......... 77

## HORS TEXTE

I. L'entrée de la salle de prédication Bois sculpté et doré. Mandalay (Birmanie) .......... 59

II. Le sacré chedi Lokananda contenant la relique d'une dent sacrée du Bouddha Pagan (Birmanie) .......... 69

# របៀបបុណ្យព្រះរាជទានព្រះភ្លើង ព្រះសព

## ព្រះអង្គម្ចាស់ក្សត្រី ហរិរ័ក្ខ មណ្ឌាទិព្យម៉ាល

## (ហៅមន្ទា)

សម្ភពពីឆ្នាំថោះសប្តស័ក ព.ស.២៣៧៧ ជាព្រះរាជបុត្រីព្រះករុណាព្រះបាទសម្តេចព្រះហរិរ័ក្សរាមាឥស្សរាធិបតី ព្រះចៅក្រុងកម្ពុជាធិបតីនិងចៅឃុំមណីជោតិ (ពាម ហៅ ក្រប) ជាព្រះមាតា ។ ទ្រង់រក្សាព្រះកិត្តិយសជាក្សត្ររហូតមកដល់កាលជាទីបំផុតនៃព្រះជន្ម គឺមកដល់ថ្ងៃ ១ ៗ៥ ១១ ឆ្នាំចឆស័ក ព.ស. ២៤៧៧ ត្រូវនឹងថ្ងៃ២៨ ខែឧកតូប ឆ្នាំ១៩៣៤ វេលាម៉ោង១២ ថ្ងៃត្រង់ ទ្រង់សុគតនៅព្រះដំណាក់ក្នុងឃុំលេខ ៣ ក្រុងភ្នំពេញ ដោយព្រះរោគជរា សិរីរួមព្រះជន្មបាន ៨០ឆ្នាំ ។ ព្រះរាជបុត្រីព្រះករុណាបរមកោដ្ឋដែលមានព្រះជន្មមកដល់ថ្ងៃនេះ មានតែព្រះអង្គមណ្ឌាទិព្យម៉ាល១ ព្រះអង្គប៉ុណ្ណោះ ។

ព្រះអង្គម្ចាស់នេះមានព្រះអធ្យាស្រ័យសុភាព មិនសូវប្រកាន់ព្រះអង្គ ទោះអ្នកតូចក្តីអ្នកធំក្តី ចូលទៅគាល់នៅព្រះដំណាក់ក្តី ឬជួបដោយតាមផ្លូវក្តី ទ្រង់ធ្វើនូវបដិសណ្ឋារទទាក់ទទួលដោយស្រួល ក្នុងបំណោមព្រះរាជវង្សានុវង្សទាំងពួងក៏ទ្រង់គោរពរាប់អានព្រះអង្គម្ចាស់នេះទាំងអស់ វេលាដែលសុគតហើយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ទទួលភារៈជាម្ចាស់ព្រះសព ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានកោដ្ឋមាសតូបដាក់ព្រះសព នឹងទ្រង់ព្រះមេត្តាប្រោសឲ្យធ្វើព្រះមេនតូបកំពូល ៥ ជាន់ នៅទីវាលមេន ដល់មកថ្ងៃ ៤ ៗ ១១ ឆ្នាំជាមួយគ្នានៅ ៣១ ឧកតូប ១៩៣៤ ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានក្បួនហែព្រះសព នឹងអ្នករាជការក្នុងក្រុមផ្សេង ៗ មកហែ នឹងព្រះមេត្តាប្រោសឲ្យទាហានក្រុមរក្សាព្រះអង្គគំនាប់ព្រះសពជាកិត្តិយសតាមទំនៀម ហើយហែព្រះសពទៅកាន់ទីព្រះមេន ។

វេលាម៉ោង ៥ រសៀល ព្រះករុណាជួបជុំដោយកុងស៊ុយសេនាបតី នាហ្មឺនសព្វមុខមន្ត្រីធំតូចទាំងពួង ព្រមទាំងអ្នកដំ-

ណាងលោកឡឺរេស៊ីដងត៍សុប៉េរិយ៉េរ ទ្រង់ព្រះរាជទានព្រះភ្លើង ព្រះសពព្រះអង្គ មណ្ឌាទិព្យម៉ាល ។ ព្រឹកឡើងរើសព្រះអដ្ឋិ ហែទៅដំកល់ទុកក្នុងហោព្រះបរមអដ្ឋិក្នុងព្រះបរមរាជវាំង និង ទ្រង់ធ្វើព្រះរាជកុសលតាមទំនៀម ។

សន្មតថាអស់សេចក្ដីតែប៉ុណ្ណោះ

សាសនប្រវត្តិ

# ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត

# នៅព្រះរាជបណ្ណាល័យ

រៀបរៀង

(ត)



ទ្វារចូលទៅកាន់ហោធម្មមន្ទីរ ព្រះនាងសុបយឡាត់ អគ្គមហេសីស្ដេចភូមា ទ្រង់សាងកាល ព. ស. ២៤២៨
ធ្វើដោយឈើមានក្បាច់រចនាបិទមាសយ៉ាងឯក ។

២២ គ្រាប្រទានអភ័យ ឬហៅថា "គ្រាប្រោសសត្វ" ជាព្រះគ្រាជាមួយគ្នានឹងគ្រាអភយមុទ្រ ធ្វើជាព្រះពុទ្ធរូបមានលក្ខណាការដូចពោលហើយ ។

២៣ គ្រាសំដែងធម្មចក្រ ឬហៅថា "គ្រាសំដែងបឋមទេសនា" ជាព្រះគ្រាជាមួយគ្នានឹងគ្រាចក្រមុទ្រ ធ្វើជាព្រះពុទ្ធរូបមានលក្ខណាការដូចពោលហើយ ។

២៤ គ្រាប្រទានឯហិភិក្ខុឧបសម្បទា ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នួន ព្រះហស្តឆ្វេងដាក់ផ្ងារលើព្រះឧរូ ព្រះហស្តស្តាំទ្រង់បោយបួល ជាកិរិយាហៅឲ្យចូលមក ។ ធ្វើដំណាលកាលព្រះសាស្តាគង់នៅព្រៃឥសិបតនមិគទាយវ័ន ទ្រង់ប្រទានឧបសម្បទាដល់បញ្ចវគ្គិយជាដើមដោយព្រះវាចាថា "ឯហិភិក្ខុ" ដូច្នេះ ដែលជាវិធីឧបសម្បទាបែបដំបូង ហើយសម្រាប់បំពោះព្រះអង្គប្រទានដោយព្រះអង្គឯង ។

២៥ គ្រាប្រទានពរ ជាព្រះគ្រាជាមួយគ្នានឹងគ្រាវរមុទ្រ ធ្វើជាព្រះពុទ្ធរូបមានលក្ខណាការដូចពោលហើយ ។

២៦ គ្រាបោមស្រមុទ ធ្វើជាព្រះពុទ្ធរូបឈរក៏មាន អង្គុយក៏មាន ព្រះហស្តទាំងពីរទ្រង់រា ។ ធ្វើដំណាលកាលព្រះពុទ្ធអង្គទ្រង់ផ្ចាញ់ពួកជដិល ទ្រង់យាងចុះចង្ក្រមក្នុងទឹក ទ្រង់រាព្រះហស្តទាំងពីរជាកិរិយាហាមឃាត់ទឹក មិនឲ្យទទឹកព្រះអង្គ ទឹកក៏ញែកជាចន្លោះឲ្យព្រះអង្គយាងចង្ក្រម គ្មានទទឹកព្រះអង្គដល់តិចឡើយ ពួកជដិលឃើញដូច្នោះក៏នឹកស្ញើបអស្ចារ្យក្នុងចិត្ត ក៏នាំគ្នាចុះចូលព្រះអង្គ ។

២៧ គ្រាជ្រើសអគ្គសាវក ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែន ព្រះហស្តឆ្វេងដាក់ផ្ងារលើព្រះភ្នែន ព្រះហស្តស្តាំលើកបង្គុលទៅខាងមុខ ជាកិរិយាបង្គុលបោះបំរូប ។ ធ្វើដំណាលកាលព្រះសាស្តាគង់នៅវេឡុវនវិហារទៀបក្រុងរាជគ្រឹះ ទ្រង់ជ្រើសយកឧបតិស្ស គឺព្រះសារីបុត្ត នឹងកោលិត គឺព្រះមោគ្គល្លានជាអគ្គសាវក ។

២៨ គ្រារំពឹង ជាព្រះគ្រាជាមួយគ្នានឹងគ្រារិតកំមុទ្រ ធ្វើជាព្រះពុទ្ធរូបមានលក្ខណាការដូចពោលហើយ ។

២៩ គ្រាលេលោ ធ្វើជាព្រះពុទ្ធរូបមានលក្ខណការដូចពោលហើយ ។

៣០ គ្រាឱបបាត្រ ធ្វើជាព្រះពុទ្ធរូបមានលក្ខណការដូចពោលហើយ ។

៣១ គ្រាធ្វើភត្តកិច្ច ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែន ព្រះហស្តឆ្វេងកៀកបាត្រ ព្រះហស្តស្តាំលូកបុះក្នុងបាត្រ ជាកិរិយាចាប់ភត្តមកសោយ ធ្វើដំណាលកាលព្រះសាស្តាសោយព្រះបិណ្ឌបាតដោយបាត្រ ។

៣២ គ្រាឲ្យបណ្តុះគ្រាប់ស្វាយ ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែន ព្រះហស្តឆ្វេងដាក់ផ្ងារលើព្រះជានុ ព្រះហស្តស្តាំទ្រង់កាន់គ្រាប់ស្វាយ ។ ធ្វើដំណាលកាលព្រះសាស្តាទ្រង់ឲ្យបណ្តុះគ្រាប់ស្វាយ ហើយទ្រង់លាងព្រះហស្តស្រោចលើគ្រាប់ស្វាយនោះ ៗ ក៏ដុះជាដើមធំមួយរំពេច សម្រេចដោយអំណាចបាដិហារ្យ វេលាក្រោយទ្រង់ធ្វើបាដិហារ្យផ្ចាញ់តិរត្ថីយ៍នៅដើមស្វាយនោះ ដូចមានពោលក្នុងគម្ពីរមហាបាដិហារ្យ ។

៣៣ គ្រាមហាបាដិហារ្យ ធ្វើជាព្រះពុទ្ធរូប មានលក្ខណការដូចពោលហើយ ។

៣៤ គ្រាទ្រង់បីវិរបួនជាន់ ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែន ទ្រង់ជណ្តាប់បីវិរបួនជាន់ ។ ធ្វើដំណាលកាលព្រះសាស្តាទ្រង់ជណ្តាប់បីវិរបួនជាន់លមើលក្នុងរដូវរងា ជាលម្មការពារសេចក្តីរងាបានឬទេ កាលៈនោះ ក៏ឃើញថាលម្មការពារបាន ទើបទ្រង់បញ្ញត្តិសំពត់សំឃាដិជា ២ យ៉ាងថា ភិក្ខុអ្នកនៅក្នុងប្រទេសក្តៅ គប្បីប្រើសំពត់សំឃាដិ២ជាន់ បើនៅក្នុងប្រទេសរងា គប្បីប្រើសំពត់សំឃាដិ ៤ ជាន់បាន ។

៣៥ គ្រាបុះចាកតាវតិង្ស ធ្វើជាព្រះពុទ្ធរូបឈរឬយាងសំយោកព្រះហស្តខាងស្តាំ លើកព្រះហស្តខាងឆ្វេងហើយជីបព្រះអង្គុលីជារង់មូល ជួនកាលៈគេធ្វើមានរូបព្រះឥន្ទ្រព្រះព្រហ្មផងជាគ្រឿងប្រកប ។ ធ្វើដំណាលកាលព្រះសាស្តាបុះអំពីតាវតិង្សលោក ក្នុងកាលដែលស្តេចទៅប្រោសព្រះពុទ្ធមាតា ។

៣៦ គ្រាបើកលោក ធ្វើជាព្រះពុទ្ធរូបឈរ បង្ហោនព្រះអង្គបុះបន្ទិច ព្រះហស្តឆ្វេងស្តាំកាងចេញបន្តិច ជាកិរិយា

វិវកឲ្យមើល ។ ធ្វើដំណាលកាលព្រះសាស្ដាចុះចាកតែត្រឹង្ស មកត្រង់ទ្វារនគរសង្កស្ស ទ្រង់ធ្វើបាដិហារ្យឲ្យទេវតា មនុស្ស នឹងតិរច្ឆាន វហូតដល់សត្វនរកឃើញព្រះអង្គគ្រប់ៗគ្នា ។

៣៧ គ្រាដោតម្ជុល ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែន ព្រះហស្ថឆ្វេងធ្វើជាកិរិយាកាន់ម្ជុល ព្រះហស្ដស្ដាំផ្គងនឹងដោត បេស ។ ធ្វើដំណាលកាលព្រះសាស្ដាទ្រង់ជាប្រធានជួយ ខ្វល់ខ្វាយដេរចីវរសំពត់បង្សុកូលរបស់ព្រះអនុរុទ្ធត្ថេរ ជាមួយ នឹងព្រះសាវកទាំងឡាយ គឺព្រះអង្គជាអ្នកដោតបេស ព្រះ សាវកឯទៀតជាអ្នកដេរ ។

៣៨ គ្រាគង់ទុកឃ្នាប ធ្វើជាព្រះពុទ្ធរូបគង់លើបល្លង្ក សំយោកព្រះបាទទាំងពីរយ៉ាងអង្គុយកោអី ព្រះហស្ដឆ្វេងដាក់ ផ្ងារលើព្រះឩរូ ព្រះហស្ដស្ដាំលើកវាស្មើព្រះឧរា ។ ធ្វើដំណាល កាលព្រះសាស្ដាស្ដេចទៅរម្ងាប់អាសន្នរោគនៅនគរវេសាលី តែ បើញខ្លះធ្វើព្រះហស្ដទាំងពីរផ្កាប់លើព្រះជានុ ។

៣៩ គ្រាគង់បាលិលេយ្យកវ័ន ធ្វើជាព្រះពុទ្ធរូបគង់ សំយុងព្រះបាទ ព្រះហស្ដឆ្វេងដាក់ផ្កាប់លើព្រះឩរូ ព្រះហស្ដស្ដាំ

ដាក់ផ្ការលើព្រះជានុ បង្អោនព្រះអង្គចុះបន្តិចជាកិរិយាទទួល ។ ធ្វើដំណាលកាលព្រះសាស្តាគង់នៅព្រៃបាលិលេយ្យកវ័ន ទ្រង់ទទួលផ្លិតឃ្មុំដែលស្វាថ្វាយ និងបំពង់ទឹកដែលដំរីថ្វាយ ជួនកាលគេធ្វើរូបស្វានឹងរូបដំរីជាគ្រឿងប្រកបផង ។

៤០ គ្រាបហាមព្រះញាតិ ធ្វើជាព្រះពុទ្ធរូបឈរ ព្រះហស្តឆ្វេងសំយោគចុះក្រោម ព្រះហស្តស្តាំលើករាជាកិរិយាហាមឃាត់ ។ ធ្វើដំណាលកាលព្រះសាស្តាស្តេចទៅឃាត់ពួកព្រះញាតិដែលទាស់ទែងគ្នា ដោយរឿងបង្ហូតទឹកចូលស្រែស្រូវ ។

# ដោយប្រការយ៉ាងណាខ្លះដែលគេគោរពព្រះបរមសម្មាសម្ពុទ្ធ នៅក្នុងស្រុកឥណ្ឌៀ (តបប់)



ព្រះចេតិយ៍លោកានន្ទ ស្តេចភូមាសាងទុកនៅវត្តលោកានន្ទ (បាគន) ទៀបឆ្នេរទន្លេឥរវតី កាល ព.ស. ១៦៥២ បញ្ចុះព្រះទន្តធាតុព្រះពុទ្ធអង្គ ដែលបានមកពីលង្កាទ្វីប ។ះ៚—

លុះព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់កំណត់ឈប់សម្ដែងព្រះធម្មទេសនាហើយទ្រង់ក៏យាងបុះពីភ្នំត្នោតមក ហើយយាងឆ្លងកាត់ខ្សែទឹកទន្លេគង្គដោយព្រះបាទឆ្ពោះទៅកាន់ពេលុវគ្រាម ជិតក្រុងវេសាលី ។ ទ្រង់គង់ចាំវស្សាក្នុងទីនេះក្នុងឆ្នាំគំរប់ ៤៥ ។

លុះផុតរដូវភ្លៀងកាលណា ទ្រង់ក៏យាងចូលទៅក្នុងក្រុងវេសាលី ដល់ទីនេះព្រះអង្គទ្រង់ញញឹម ហើយមានព្រះបន្ទូលថា នេះជាគ្រាក្រោយបំផុត ហើយដែលតថាគតចូលក្នុងទីក្រុងនេះ ។ រួចពីនេះទ្រង់ប្រមូលនូវពុទ្ធបរិសទ្យឲ្យមកជួបជុំនៅពន្ធគាម ហើយទ្រង់មានព្រះបន្ទូលថាដូច្នេះ ក្នុងកំណត់ ៣ ខែទៀត តថាគតនឹងបរិនិព្វានហើយ អ្នកទាំងអស់គ្នាប្តូរប្រព្រឹត្តតាមធម៌វិន័យ ។

រួចពីនេះព្រះបរមគ្រូយាងចេញពីក្រុងវេសាលី ឆ្ពោះទៅកាន់កុសិនារា ដែលយាងតាមផ្លូវទៅនោះទ្រង់ចូលសម្រាកព្រះកាយពល ក្នុងភូមិបាវា នៅផ្ទះជាងទងម្នាក់ឈ្មោះកុន្ទ (ចុន្ទ) នាយចុន្ទបានធ្វើនមស្សការដល់ព្រះអង្គហើយបានថ្វាយ

បង្ហាន់ ។ លុះបានសម្រាកព្រះកាយពលជាស្រេចហើយព្រះសម្មាសម្ពុទ្ធក៏ទ្រង់ពុទ្ធដំណើរតទៅទៀត ។

លុះឆ្លងផុតស្ទឹង កកុដ្ឋាហើយព្រះអង្គតាំងចាប់អាពាធជាទម្ងន់ ព្រោះទំនាយថាត្រូវតែឲ្យព្រះអង្គឈឺចាប់ ដើម្បីឲ្យបានមនុស្សទាំងអស់យកជម្រាប់តាមសេចក្ដីអត់ធ្មត់របស់ព្រះអង្គ ។ ទ្រង់បានសោយទឹកដែលអានន្ទដងមកថ្វាយ ហើយក៏យាងទៅដល់ទីមាត់ស្ទឹង ហិរញ្ញវតី ជិតក្រុងកុសិនារា ។ ក្នុងទីនោះមានដើមសាលា (រាំងភ្នំ) ដុះជាច្រើនជេរជាស ហើយព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះបន្ទូលថា អានន្ទ ចូរអ្នកទៅរៀបទីសេយ្យាសន៍ឲ្យតថាគត ក្នុងបន្លោះរាំងភ្លោះ ហើយដាក់ឲ្យតថាគតផ្ទំផ្ដោះព្រះកេសទៅខាងជើង ហើយបែរព្រះភក្ត្រទៅខាងលិច ។ អានន្ទក៏ចាត់ចែងតាមហើយ លុះបានឮថាព្រះបរមគ្រូទ្រង់ទីងយាងចូលកាន់ព្រះនិព្វាន តាំងខ្សឹកខ្សួលថាសព្វថ្ងៃខ្ញុំនៅល្ងង់ខ្លៅនៅឡើយ ហើយព្រះអង្គនឹងបរិនិព្វានបោលខ្ញុំ បើឥតអំពីព្រះអង្គទៅហើយ តើបាននរណានឹងបើកផ្លូវឲ្យខ្ញុំ ។

ក្នុងវេលានោះព្រះបរមសាស្តាទ្រង់ល្បងលោមអានន្ទថាដូច្នេះ ម្នាលអានន្ទ ក្នុងលោកនេះ គ្មានធម្មជាតិអ្វី ១ ដែលមិនប្រែប្រួលនោះទេ ។ តែកាលណាបានជួបគ្នាហើយតែងតែប្រាសព្រាត់គ្នាទៅវិញជាធម្មតា ទាំងព្រះពុទ្ធគ្រប់ព្រះអង្គក៏គង់គេចមិនផុតពីធម្មតាលោកនេះ ។ នែអានន្ទ ខ្លួនអ្នកបាននៅបំរើតថាគតគំរប់ ២៣ ឆ្នាំនេះហើយ ហើយតាមការពិតនោះសេចក្តីស្មោះត្រង់របស់អ្នកនេះនឹងបានទទួលបំណាច់មិនខាន ។

ក្នុងវេលានោះនៅទីកុសិនារា មានព្រាហ្មណ៍ម្នាក់ឈ្មោះសុភទ្ទ អាយុ ១២០ ឆ្នាំជាអ្នកបរិសុទ្ធដោយសីល ។ សុភទ្ទបានចូលទៅរកព្រះបរមគ្រូហើយនិយាយនឹងអានន្ទថា ខ្ញុំបានដឹងថាព្រះបរមគ្រូនឹងចូលព្រះបរមនិព្វាន ឥឡូវខ្លួនខ្ញុំនៅមានសេចក្តីសង្ស័យជាច្រើន ហើយខ្ញុំត្រូវការនឹងជំរះឲ្យរលីងជាមុនដែលព្រះអង្គនឹងយាងចូលកាន់ព្រះបរមនិព្វាន ។ អានន្ទពោលតបទៅវិញថា សូមកុំឲ្យអ្នកបង្អាក់សេចក្តីសម្រាករបស់ព្រះអង្គព្រោះទ្រង់មានព្រះអាពាធជាទម្ងន់ ។

ប៉ុន្តែព្រះបរមលោកនាថ ទ្រង់បានជ្រាបក៏ត្រាស់ហៅ សុភទ្ទឱ្យចូលទៅហើយទ្រង់សម្ដែងពន្យល់នូវព្រះចតុរារិយសច្ច សុភទ្ទក៏ចូលកាន់ព្រះពុទ្ធសាសនា ហើយទទួលផ្នួសជាភិក្ខុ ។ ដោយមានសេចក្ដីត្រេកអរជាយ៉ាងខ្លាំង សុភទ្ទភិក្ខុក៏រលត់សង្ខារ ក្នុងវេលានោះទៅ ។

តពីនោះមក ព្រះបរមសាស្ដាចារ្យទ្រង់មានព្រះបន្ទូលទៅ កាន់អានន្ទទៀតថា ម្នាលអានន្ទ អំណើសឥតអំពីតថាគតទៅ ចូរអ្នកកុំមានសេចក្ដីបារម្ភថា អ្នកគ្មានគ្រូអាចារ្យនោះឡើយ ព្រះធម៌ទាំងប៉ុន្មានដែលតថាគត បានសម្ដែងបានបញ្ញត្តដល់អ្នក នោះហើយ ជាគ្រូជាអាចារ្យអ្នក ។ ឥឡូវនេះចូរអ្នកឈប់កុំ និយាយ តថាគតនឹងចូលបរិនិព្វានហើយ ។

ព្រះបរមសម្មាសម្ពុទ្ធក៏យាងចូលកាន់ព្រះបរមនិព្វានក្នុងវេលានោះ ក្នុងកំណត់ព្រះជន្មាយុគំរប់ ៨០ ឆ្នាំគត់ ។ គឺក្នុងថ្ងៃ ១៥ កើតខែទីពីរ[១] ត្រូវ ៤៦៩ ឆ្នាំមុនគ្រិស្តសករាជ ប៉ុន្តែក្នុង

(១) ខែទី ២ យីប៉ុនត្រូវនឹងខែបុស្សយើង តែតាមសេចក្ដីក្នុងមហាបរិនិព្វានសុត្តបាលី ថាព្រះអង្គចូលបរិនិព្វានទៅថ្ងៃ ១៥ កើតខែវិសាខនេះជាងទៀងពិតរបស់យើង ។

សេចក្ដីផ្សេង ៗ ឯទៀតកំណត់ថា ៥៤៣ ឆ្នាំមុន គឺក្នុងឆ្នាំទី ២៣ នៃរជ្ជកាល ព្រះចៅលីង ដែលជាព្រះរាជាធិរាជទី ២៣ ក្នុងព្រះរាជវង្ស ជាវ ។

* * *

លុះដំណឹងរឿងព្រះបរមគ្រូទ្រង់ចូលព្រះបរមនិព្វាន ផ្សាយខ្ទរទៅហើយ បណ្ដាមនុស្សទាំងប៉ុន្មានដែលបានស្ដាប់ព្រះសទ្ធម្មទេសនារបស់ព្រះអង្គ ក៏មានសេចក្ដីសោកស្ដាយស្លុតស្ញប់រាល់គ្នា ហើយក៏មកប្រជុំគ្នាធ្វើបុណ្យបូជាព្រះបរមសពន្ធុះ ។ ពួកខត្តិយវង្ស ដែលនៅក្នុងក្រុងកុសិនារា និមន្តយកព្រះបរមសពទៅដឹកល់ក្នុងព្រះវិហារ តេន៍កញ្ចិ, ស្រោបស្រប់ដោយទឹកអប់ហើយគោរពនមស្សការគំរប់ ៧ ថ្ងៃ ៧ យប់ ។

នៅថ្ងៃទី ៨ ព្រះមហាកស្សបដែលជាសង្ឃនាយក និមន្តមកដល់ពីបាវា ហើយក៏បានធ្វើកិច្ចគោរពជាក្រោយបំផុតបំពោះព្រះបរមគ្រូ ។ ព្រះមហាកស្សបដឹកល់ព្រះបរមសពក្នុងវាំងក្រុងកុសិនារា ហើយធ្វើការគោរពនមស្សការអស់វារៈ ៧ ថ្ងៃទៀត ។

លុះគ្រប់កំណត់ ៧ ថ្ងៃហើយ ក៏ហែទៅដំកល់លើកន្លែងសម្រាប់ថ្វាយព្រះភ្លើង ។

ក្នុងវេលានោះស្តេចទាំង ៨ អង្គ ដែលជាសិស្សជំនិតរបស់ព្រះបរមគ្រូ កើតឈ្លោះប្រកែកដណ្តើមយកព្រះសារីរិកធាតុ ហើយមានព្រាហ្មណ៍ម្នាក់ឈ្មោះទោណេ បានវាយបំណែកព្រះសារីរិកធាតុជា ៨ ភាគ ។ បំណែកព្រះបង្កូមនោះបានបែកទៅដូច្នេះ គឺព្រះបង្កូមស្តាំខាងលើនឹងព្រះបង្កូមឆ្វេងខាងក្រោមបានទៅនគរភុជង្គនាគ ព្រះបង្កូមឆ្វេងខាងលើបានទៅក្រុងកលិង្គរដ្ឋ ក្នុងដែនកោសល ហើយព្រះបង្កូមស្តាំខាងក្រោមបានទៅគន្ធាររដ្ឋ សល់ពីនេះទាំងប៉ុន្មានបានបែកដល់ យក្ខគន្ធព្វក្នុងលោកឯទៀតផ្សេងៗ ។

# រឿងចោសុខចៅសៅ

# រឿងចៅសុខចៅសៅ

នេះនឹងនិយាយពីរឿងព្រេងថា មានពីរនាក់ស្រឡាញ់គ្នា ហើយទៅបួស មួយឈ្មោះចៅសុខ មួយឈ្មោះចៅសៅ បួសជាមួយផងគ្នានៅវត្តអង្គរ ដល់បួសយូរបន្តិចទៅសឹកមកវិញ រួចហើយសុំគ្នាធ្វើជាសំឡាញ់ ហើយបានសន្មតនឹងគ្នាថា បើនរណាក្រ ឲ្យជួយគ្នា ហើយទាំងពីរនាក់យកប្រពន្ធនៅរកស៊ីទៅ ឯចៅសុខរកស៊ីទៅមានទ្រព្យរបស់ច្រើន ឯចៅសៅល្ងង់ខ្លៅក្រពិបាក ហើយប្រពន្ធក៏មានសហាយ ឯចៅសុខឮថាប្រពន្ធចៅសៅមានសហាយហើយក្រពិបាកផង នោះចៅសុខទៅសួរចៅសៅនោះ បានទៅដល់ហើយឃើញចៅសៅក្រពិបាកណាស់ ក៏បបួលចៅសៅទៅរកស៊ី ហើយនិយាយថាឯងតាមពាក្យអញឬទេ នោះចៅសៅក៏ព្រមតាមពាក្យចៅសុខ ចៅសុខបបួលចៅសៅទៅកាប់ឈើធ្វើមឈ្នួសលក់ នោះចៅសៅក៏ព្រមតាមពាក្យចៅសុខៗ ក៏ព្រមទៅជាមួយគ្នា ឯកូនសេដ្ឋីដែលសហាយនឹងនាងប៉ុច ជាប្រពន្ធចៅសៅ ឃើញចៅ

សៅមិននៅផ្ទះ ទៅដេកនឹងប្រពន្ធចៅសៅ រួបហើយក៏វិលទៅផ្ទះវិញ ឯចៅសុខនឹងចៅសៅធ្វើមឈូសលក់បានមួយ ក៏យកមកដាក់ក្នុងផ្ទះ ហើយទៅធ្វើមឈូសទៀត ឯកូនសេដ្ឋីក៏ទៅដេកនឹងនាងប៊ុបទៀត ហើយដល់កណ្ដាលអធ្រាតចៅសុខហៅចៅសៅមកផ្ទះ ឯចៅសុខខំដើរដាច់មកមុនហើយហៅប្រពន្ធចៅសៅ ៗ បើកទ្វារ ឯកូនសេដ្ឋីភិតភ័យរត់ពុំរួច នាងប៊ុបយកទៅបំពួន ឲ្យដេកក្នុងមឈូស ហើយនាងប៊ុបទៅបើកទ្វារ ឲ្យចៅសុខចៅសៅចូលក្នុងផ្ទះនោះ នាងប៊ុបសួរថាដូចម្ដេចក៏បានជាវិលមកវិញ ចៅសៅប្រាប់ថា ចៅសុខឈឺក្បាល ហៅវិលមកវិញហើយចៅសៅប្រាប់នាងប៊ុប ឲ្យដណ្ដាំបាយស៊ី ស៊ីបាយរួចហើយ ក៏ចៅសុខដឹងជាសហាយនាងប៊ុបដេកនៅក្នុងមឈូស នោះចៅសុខសួរទៅចៅសៅរកផ្ដៅនឹងចងមឈូសក្រែងចោរវាលួច ហើយក៏យកផ្ដៅទៅចងរួចស្រេចហើយ យកដែកគោលទៅបោះថែមទៀត ឯចៅសៅពុំដឹងជាប្រពន្ធមានសហាយធ្វើតាមតែពាក្យចៅសុខ បង្គាប់ដូចម្ដេចក៏ព្រមតាម លុះព្រឹកឡើងចៅសៅប្រើប្រពន្ធឲ្យទៅរកទិញឥវ៉ាន់

ហើយនាងប៉ិចហួសទៅប្រាប់សេដ្ឋី ជាអាពុកម្ដាយឲ្យចាំទិញមឈូស ។ ដ្បិតកូនសេដ្ឋីទៅដេកនឹងខ្ញុំហើយ ៗ ប្ដីខ្ញុំមកទាន់បានរត់ចូលដេកក្នុងមឈូស ឥឡូវនេះប្ដីខ្ញុំសែងយកទៅលក់ហើយ ប្រាប់ហើយនាងប៉ិចក៏ត្រឡប់ះទៅផ្ទះវិញ លុះដល់ចៅសុខចៅសៅស៊ីបាយរួចហើយ ក៏សែងមឈូសយកទៅលក់ឯសេដ្ឋីឲ្យខ្ញុំមួយចាំមើលផ្លូវ ផ្ដាំថាបើឃើញអ្នកឯណាសែងមឈូសទៅលក់ ឲ្យរត់ទៅហៅសេដ្ឋី បន្តិចចៅសុខចៅសៅសែងមឈូសទៅដល់ផ្ទះសេដ្ឋី បានស្រែកថាអ្នកណាទិញមឈូសឬទេ នោះសេដ្ឋីឮហើយហៅទៅសួរថា លក់ថ្លៃប៉ុន្មានឯចៅសុខប្រាប់ថាឲ្យដាក់ប្រាក់ពីដីឡើងឲ្យស្មើនឹងមឈូស រួចសេដ្ឋីសុំថ្លៃចៅសុខ ឯចៅសុខមិនព្រម ហើយសេដ្ឋីះប្រើខ្ញុំកំដរទៅយកប្រាក់មកដាក់ស្មើនឹងមឈូសរួចហើយ ចៅសុខចៅសៅក៏យកប្រាក់ទៅផ្ទះ ចែកគ្នា ឯសេដ្ឋីក៏គាស់មឈូសយកកូនចេញ ឯចៅសៅក៏យកនាងប៉ិចធ្វើជាប្រពន្ធដូចដែលវិញ ។

ចប់រឿងនេះតែប៉ុណ្ណេះ ។

# បញ្ជីរឿង

ទំព័រ


១—សេចក្ដីអធិប្បាយអំពីបុរាណវត្ថុនៅទីពិពិធភណ្ឌ វត្តពោធិវាល លោកហង់រី ប៉ារម៉ង់ទេ នឹងលោករ. ដាលេត៍ រៀបរៀង ក្រម្ការដុំ-មៅ ប្រែជាភាសាខ្មែរ . . . . . . . . ៨៧

២—ដោយប្រការយ៉ាងណាខ្លះដែលគេគោរពព្រះសម្មាសម្ពុទ្ធនៅស្រុក កោរេ ស. បូណូ រៀបរៀង ក្រម្ការដុំ-មៅ ប្រែជាភាសាខ្មែរ (តចប់). . . . . . . . . . . . . . ១០៧

៣—សាសនប្រវត្តិ ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត រៀបរៀង (ត) . . . . ១១៥

៤—រឿងព្រេងខ្មែរ ដែលមិនទាន់បោះពុម្ពផ្សាយ គឺរឿងអាពុកក្មេករើសកូនប្រសា. . ១២៥


# រូបផ្សេងៗ


១—រូបព្រះចេតីយ៍ទីបមាស នៅក្រុងមណ្ឌលេ . . . . . . . . . . . . . . . . . ១០៥

២—ព្រះពុទ្ធរូបកក្កុសន្ធ នៅខាងលិចវិហារអានន្ទ ស្រុកបាគន (ភូមា) . . . . . . . ១១៧

# TABLE DES MATIÈRES


I. Description de quelques pièces du musée de Vat-Povéal par H. Parmentier et R. Dalet (à suivre).............. 87

II. De quelle manière le Bouddha fut vénéré en Corée par Georges Bonneau — Traduit du Français en Cambodgien par Kromokar Chum-Mau........................ 107

III. Sāsanapravatti ou Histoire des Religions par Préas Maha Pitou Krasem (suite et fin)........................ 115

IV. Conte populaire Cambodgien inédit :
Beau-père choisissant un gendre..................... 125


## HORS TEXTE


I. Le sacré chedi de la pagode d'Eindawya (Mandalay) construit en 2350 de l'ère bouddhique sous le Roi Pagan.... 105

II. Statue du Bouddha, sanctuaire Ouest du temple d'Ananda construit sous Kyanzittha 1634 de l'ère Bouddhique, Pagan (Birmanie)........................... 117

# សេចក្ដីអធិប្បាយអំពីវត្ថុបុរាណ
# នៅក្នុងទីពិពិធភណ្ឌវត្តពោធិវាល

របស់


លោកហង់រី ប៉ារម៉ង់ចេ ចាងហ្វាងជាកិត្តិយស
ក្រសួងពិនិត្យ ប្រាសាទបុរាណ ក្នុងប្រទេសឥណ្ឌូស៊ីន
និង លោក រ.ដាលេត៍

សេចក្ដីសំគាល់នេះសម្រាប់បំពេញ សេចក្ដីអធិប្បាយ ដែលបានបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីខ្មែរ ៦ នៃឆ្នាំទី ៣ ។

គេបានដឹងថា ពិពិធភណ្ឌស្ថាន វត្តពោធិ៍វាលនៅបាត់ដំបង គឺលោកគ្រូព្រះធម្មលក្ខណញាណ អ៊ី ទូត បានចាត់ចែងរៀបចំ តាំងពីឆ្នាំ ១៩២៦ ហើយតាំងដំកល់ក្នុងទីព្រះវិហារតែម្ដង



ដែលមានមុខឈមឆ្ពោះបូព៌ទិសា ។ ដោយសេចក្ដីសុំអំពីលោកចៅអធិការ ដែលជាអ្នកតាំងបង្កើត ពិពិធភណ្ឌស្ថានតូបនេះ យើងបានតាំងធ្វើបញ្ជីវាយវត្ថុ សម្រាប់របស់ដែលជាបំឡាក់

បូរាណ ហើយមានដំនៀបំពោះការរិះរកប្រាសាទបូរាណ ជួនកាលក៏យ៉ាងសំខាន់ យើងពិនិត្យវត្ថុដែលដំកល់នៅក្នុងទីព្រះវិហារជាដើមរួចហើយទើបយើងបេញមកឯទីរបៀងខាងក្រៅជាកន្លែងដែលដំកល់នូវថ្មចំឡាក់ផ្សេង ៗ ។

នៅខាងក្រោយទីអាសនៈ ហើយនៅខាងលិចទៅ មានទូកញ្ចក់ ២ ។ ទូខាងត្បូងនៅថ្នាក់ខាងក្រោមមានចានផ្សេង ៗ ដែលសុទ្ធតែមកពីស្រុកចិន ។ មានចានជ្រៅយ៉ាងល្អ ១



លាបថ្នាំបែតងខ្ចីគេធ្វើក្នុងរវាង ព. ស. ១៦៥០ ពួកចិនក្នុងសម័យរាជវង្ស សុង បានធ្វើ គឺជាវត្ថុដែលមានដំឡៃយ៉ាងសំខាន់សម្រាប់ប្រមូលមកជាពួក ហើយដែលគេប្រឡំថាជារបស់ខ្មែរ ព្រោះរកឃើញនៅទីភ្នំតាផ្ដេ ក្នុងខណ្ឌមោងឫស្សី ។ ចាននេះមានប្រវែងខ្សែកាត់កណ្ដាលមាត់ពីម្ខាងទៅម្ខាងចំនួន ៣៦ សង្ទីម៉ែត្រ នៅប៉ែកខាងលើនៃទូកញ្ចក់នោះមានគ្រឿងឡាយឃុក្រោមចិន ១ ពួកនឹងចានខ្មែរ-សៀម ។

នៅលើថ្នាក់អាសនៈ មានវត្ថុដែលជាការរចនាបូរាណរបស់ខ្មែរផ្សេង ៗ គឺបំណែកថ្ម ១ ដុំកំពស់ ២៥ សង្ទីម៉ែត្រ ដំណាងផ្កាយនព្វគ្រោះទាំងប្រាំបួន ១ មានថ្មចំឡាក់យ៉ាងល្អក្នុងសម័យអង្គរ ព្រមទាំងក្បាំងមានរង្វង់ស្រប នៅពីលើសសរបំណែកថ្មនេះមានរូបទាំង ៤ ជាដំបូង គឺព្រះអាទិត្យគង់លើសេះ ២ ព្រះចន្ទគង់លើបល្លង្ក រូប ១ អង្គុយចោងហោងលើសត្វបក្សាទ ១ មានត្រចៀកវែង រូបទី ៤ អង្គុយលើសត្វស្លាប ។ រូបទាំងនេះកាន់របស់ផ្សេង ៗ សម្រាប់ដំណែង គឺព្រះអាទិត្យកាន់ផ្កាឈូក ២ ព្រះចន្ទកាន់ផ្កាឈូក ១ រូប

ទី ៣ កាន់......... រូបទី ៤ កាន់ដៃកម្ពូលមានជង ។ ថ្មនេះជារចនារបស់សាសនាព្រាហ្មណ៍ ។ រូបពីនេះមានក្បាលទុកសក់បុកម្ពូលឡើងទៅលើ ពុកមាត់យ៉ាងស្តើង រោមចិញ្ចើមជាប់គ្នា ទងត្រចៀកបោះ សម្រាប់ពាក់គ្រឿងមាសពេជ្រដែលមែន ភ្នែកវែងមានប្រស្រីជាទីសំគាល់បានមកពីវត្តបាសិនឃុំតាប៉ូង រូបនេះកសាងឡើង តាំងពីក្នុងសម័យមុនអង្គរ ។ តពីនោះមក មានព្រះកេសព្រះពុទ្ធ ១ ដែលរចនាយ៉ាងខ្ចីខ្ចួក្នុងសម័យអង្គរ មានឧស្ណកន្តុចបន្តិច រូបពីនោះមកមានផ្ដាយនព្វគ្រោះទាំង ៩ តួប ៗ ទៀត តាមសាសនាព្រាហ្មណ៍ ផ្ដាយមួយ ៗ នៅចំពីមុខរស្មី ១ អស់ទាំងវាហនរៀបរៀងគ្នាដូច្នេះគឺសេះ ២ នៅអែបនឹងបង្គោល បល្លង្ក សេះ ១ សត្វស្លាប ១ ដំរី ១ សេះ ១ គោ ១ រាជសីហ៍ ១ រាហូលើកដៃស្តាំ បានមកពីឃុំតាប៉ូង ហើយប្រហែលជានាំយកមកដំកល់ក្នុងវត្ត ១ ជិតវត្តពោធិ៍វាល ចំនួនរវាង ១០០ ឆ្នាំហើយ រូបនេះកំពស់ ២១ សង្ទីម៉ែត្រ ហើយបន្ទា ៦៧សង្ទីម៉ែត្រ ធ្វើដោយថ្មភក់ក្រហម ។

នៅមុខទីអាសនៈ  គេសំគាល់ឃើញមានទេវតា ៨ អង្គ ដៃកាន់ផ្ទាំងភ្លើង សព្វថ្ងៃគឺអគ្គិសនី ។ របស់នេះគេធ្វើអំណោយមកប្រហែល ៥ ឬ ៦ ឆ្នាំហើយ ក្នុងរូបទាំងនេះ តើទំនងជាមានផ្កាយនព្វគ្រោះដោយស្រែពេចស្រែពិលផងឬទេ  ដោយជាការតាមតែប្រទះ  នោះខ្ញុំបានសំគាល់ឃើញជំនិះរបស់ទេវតាទាំងនេះ គឺ ខ្លា គោ កណ្តុរ យក្ស យក្សទៀត សេះ ពពែ ស្វា រូបដែលជិះលើពពែនឹងលើគោ នោះតូចៗជាងរូបឯទៀត ហើយទំនងជាចាស់ជាងរូបទាំងអស់នេះសុទ្ធតែទំបមាស ។

នៅទីបែរនោះ  មានស្តូប ១ យ៉ាងល្អ  ធ្វើដោយថ្មភក់លឿងខ្ចី រាង ៤ ជ្រុងទ្រវែង  តាមទំនងធម្មតាទូទៅរបស់សីមា មានកំពូលវិចិត្រក្បាច់ក្បូរ ។  នៅពីមុខនីមួយៗ នោះមានរូបរាំឈរ ១  ធ្វើឲ្យសំគាល់បានថាមានដោះដោយច្បាស់លាស់ ពិតមែនជាមិនសូវលេចទុលឡើង  រូបនោះស្លៀកសំពត់ធ្វើឲ្យដឹងថា  ភេទជាប្រុស  សំពត់ដែលស្លៀកមានជាយវែងស្តើងហើយជាប់បេញ  រូបនោះមានដៃ ១០ គូ  ក្បាលក្បៀបមានក្បាល ៥ ជំរួតមកពីលើ រូបមានក្បាល ២ ទៀត ទាំងអស់ក្បាល

៨ ដែលមើលឃើញ គេអាចនឹងសន្មតក្បាល ២ ទៀតបាន ដោយងាយក្នុងបណ្ដាក្បាលទាំងនេះ ហើយថែម ១ ទៀត




ដែលមើលមិនឃើញទាំងអស់ គឺបន្ថែមចំនួនក្បាលទាំងនេះឲ្យបានគ្រប់ជា ១១ ឡើង ។ រូបនេះមានពាក់កងដៃនឹងកងជើង គឺ

ជារូប ហេវជ្រ ដែលជាពោធិសត្វក្នុងព្រះពុទ្ធសាសនាប៉ែកខាងលទ្ធិមហាយាន ។ នៅមុខម្ខាងទៀតជារូបស្រីអង្គុយលើបល្ល័ង្កមានដៃ ៧ គូ និងក្បាល ៣ ដែលមើលឃើញ ។ សំលៀករូបនោះគឺជាសារុង សក់ប្លងបុកមូលឡើងទៅលើវិតក្រប្លបត្រង់គល់គ្មានគ្រឿងមាសពេជ្រ រូបនេះនៅក្រោមទេវស្ថាន ១ យ៉ាងស្រាល ដែលមានសសរយ៉ាងធ្នារមានហោជាងទាប ។ នៅមុខម្ខាងទៀតជាទី ៣ នោះមានរូបស្រី មានសក់ភ្ជងខ្ពស់រាងដូចជាកន្ទុយមាន់ញី រូបនោះឈរស្លៀកសារុងធូតយ៉ាងល្អិត រូបនេះមានដៃ ៤ ហើយវត្ថុដែលកាន់នៅដៃនោះមើលមិនច្បាស់ ។ មានកងដៃនឹងរយ៉ាត្រចៀក ។ រូបស្រីទាំង ២ នេះ ដំណាងប្រាជ្ញាបារមិតា ក្នុងព្រះពុទ្ធសាសនាគណមហាយាននិកាយ ។ ទំហំព្រះស្តូបបារិកនេះ គឺ ២៦×១៨×៦៣ សង្ទីម៉ែត្រ ។ ដើមកំណើតវត្ថុនេះឥតនរណាដឹង គេគ្រាន់តែបានដឹងថា បានមកពីក្នុងដំបន់បាត់ដំបង មានមនុស្សនាំយករូបនេះមក ហើយក៏រត់បាត់ទៅវិញមួយរំពេចទៅ ។

តពីនេះទៅទៀត ឃើញមានសុំទ្វារយ៉ាងល្អ ១ ធ្វើពីថ្មភក់ក្រហម មានក្បាលសិង្ហ ១ ជាដើមក្បាច់ចេញភ្ជាប់ទៅនឹងសិង្ហពីរទៀតដែលឈរហើយចេញក្បាច់ភ្ញីល្ងិពីនេះទៅ ទៅផុតត្រឹមរូបយក្ស ២ ដែលមានដៃនឹងជើងយះកន្ទាំង ហើយមានបាតដៃលាធំឡើង ៗ នៅលើក្បាលសិង្ហទី ១ មានយក្ស ២.



ឈរនៅ ជើង ១ នៅលើក្បាលនេះ ដៃ ១ ដាក់ក្រោមកំណល់ជើង ១ ទៀតជាន់លើសំពត់ក្បាច់ដែលនៅជិតទីនោះ ៗ នៅលើក្បាលយក្សទាំងនេះ មានរូបពីរអង្គុយពីលើទៀត ហើយនៅលើក្បាលរូបទាំងនេះមានបែបជាក្លោងទ្វារកាច់រង្វង់ ៗ ដែលរចនាដោយសន្លឹកវល្លិដែលវារតាមរំពត់រង្វង់ រង្វង់នេះគេធ្វើសម្រាប់រូបដែលជាសំខាន់ ៗ រូបនេះអង្គុយក្នុង ទំនងប្រហែល

គ្នានឹងបង្គុយសម្រួលសម្រាប់ស្តេច លើខ្នងសេះ ១ ដែលរបេះក្បាលបាត់ តែស្គាល់បានដោយជើងដែលដាក់លើកំណាល់នឹងដោយត្រចៀក ។ រូបនេះមានជើងឆ្វេង ដាក់លើគល់គូថសេះ ហើយជើងស្តាំដាក់លើជង្គង់ឆ្វេងនៃរូបតូបនៅខាងស្តាំ បំណែកឯរូបតូបដែលនៅពីខាងឆ្វេងប្រឹងប្រទប់នូវជង្គង់ឆ្វេងនៃរូបនេះ ។ រូបនេះកាន់នូវគ្រឿងសម្រាប់យស ដែលគេអាចនឹងសំគាល់បានថានៅខាងដៃឆ្វេង ដូចជាខ្សែសម្រាប់បងកណ្តាប់ ១ នៅដៃស្តាំដូចជាកាន់ក្បូរស្រូវ ។ នៅលើរំពត់ចុងបំផុតនៃកន្សោមផ្កានោះ ប៉ែកខាងឆ្វេងមានក្បាច់រលប់បាត់ ហើយខាងស្តាំរំពត់នោះទ្រព្រះវិស្ណុដែលឈរពីលើ ។ មុននឹងផុតកន្សោមផ្កានោះ មានក្បាលសិង្ហ នៅក្នុងបង្កោង មានរំពត់ផ្កាពីរបញ្ចោញនូវក្បាលពស់មួយៗមក ។ ស៊ុំទ្វារនោះ ប៉ែកខាងលើផុតត្រឹមក្បាច់ដែលរចនាជារូបមនុស្សអង្គុយបែបអ្នកស្រុកឥណ្ឌៀ ចំនួន ១១ រូប ដៃដាក់ក្នុងភ្នែន ស៊ុំទ្វារនេះសមជារបស់ទេវស្ថាន ១ ដែលឧទ្ទិស្សដល់សាសនាព្រាហ្មណ៍ មានបណ្តោយចំនួន ៨៩ សង្ទីម៉ែត្រ

ហើយកំពស់ចំនួន ៤២ សង់ទីម៉ែត្រ  រកឃើញក្នុងទួលមួយ អន្លើនៅជំពួន  ក្នុងភូមិជ្រោយម្ទេស ។

ផ្សេងពីនេះទៅទៀតមានផ្នែកកណ្ដាលនៃសុំទ្វារយ៉ាងល្អ ១ ធ្វើពីថ្មភក់ក្រហម  មានរូបព្រះឥន្ទ្រឈរក្នុងទំនងបែបប្លាំងឬបែបរាំ, នៅពីមុខវង្វង់ទ្វារ មានរំពត់១ តាំងជាគ្រឿនវិអស-និបាត វជ្រ ហើយជង្គង់ស្ដាំលុតចុះលើខ្នងដំរីក្បាលបី ឈ្មោះ ឯរាវិណ ដែលមានជើងមុខ ៤ ក្បាលទាំងសង-ខាងមានប្រមោយចាប់នូវកំរងផ្កា ដែលចេញពីមាត់សិង្ហមក  ហើយសិង្ហនេះ



មានជើងលេចឡើងពីលើគល់កំរងផ្កា ។ នៅពីខាងលើក្បាច់ទាំងអស់  មានក្បាច់យ៉ាងក្រាស់របនាជារូបមនុស្សដូច ៗ គ្នាទាំងអស់ អង្គុយលុតជង្គង់ទំនងដូចគ្នានឹងរូបព្រះឥន្ទ្រដែរ  ប៉ុន្តែគ្មានកាន់ វជ្រ នឹងគ្មានវង្វង់ជុំវិញខ្លួន  នៅជា

កណ្ដាលឃើញរូបតាបសម្នាក់អង្គុយភាវនា ។ រូបព្រះឥន្ទ្រ គេរចនាដោយគ្រឿងតុបតែងយ៉ាងឆើត ហើយដំរីមានខ្សែឆ្នូតដូចគ្នា នៅក្បាលនឹងត្របៀក ។ សុំទ្វារនេះធ្វើអំពីថ្មភក់ក្រហមយ៉ាងល្អ ហើយឆ្លាក់ក្បាច់យ៉ាងជ្រៅ មានតែកំពស់ម្យ៉ាងដែលយើងអាចដឹងបាន គឺ ០,ម៧២ ថ្មនេះបានមកពីទួលដំពួនភូមិជ្រោយម្ទេស គឺជាសុំទ្វារសម្រាប់ទេវស្ថានព្រាហ្មណ៍ ១ ។ ខាងឆាយសុំទ្វារនេះមានរូបប្រុសឈរ ១ ធ្វើពីថ្មភក់ព័ណ៌ប្រផេះ ហើយសំលៀកមានជាយជារំយោលសំយុងចុះជបត្នះពីខាងមុខ ហើយនៅខាងក្រោយមានរចនាជារំយោលបំណាងធម្មតា នៅខាងក្រោមតូចបន្តិច ។ រូបនេះវាស់ពីជង្គង់ទៅក៏បាន ០,ម៤២ បានមកពីអន្លង់សាន ។

ត្រូវតែនិយាយឲ្យដឹង អំពីរូបស្រីឈរ ១ ស្លៀកសារុងឆ្នូត មានដើមទ្រូងទទេ ហើយមានដោះគ្រាន់តែជាហេតុ មានជាយសំពត់ធ្លាក់ចុះ មកគ្របខ្សែក្រវាត់ដែលរចនាជារំយោល មានពាក់ខ្សែកយ៉ាងល្អពាក់កងកន់ កងដៃនិងកងជើង រូបនេះ

ធ្វើដោយថ្មភក់ប្រវែងកំពស់ ០,ម៤០ បានមកពីទីជាមួយគ្នានឹងរូបប្រុសដែរ ។

ត្រូវតែនិយាយអំពីរូបយ៉ាងល្អ ១ នោះដែរ ដែលមានដៃ ៤ ធ្វើពីថ្មភក់ ហើយសឹករលួ ដោយហាលខ្យល់ហាលថ្ងៃ ដៃបាក់ទាំងអស់ត្រឹមជិតស្មា ។ នៅក្បាលមានពាក់មកុដ ៣ ថ្នាក់



រាង ៨ ជ្រុង សំពត់ស្លៀកមានផ្នត់បុះក្រោម ហើយចុះពីចង្កេះមកដល់ខាងក្រោមប្លក់សំយុង ដែលមានផ្នត់យ៉ាងទូលាយខាងឆ្វេងសង្កត់ពីលើ ។ ទងត្រចៀកយារវែងមកតែគតមានពាក់អ្វីទេ ហើយគតមានទំនងបោះ សម្រាប់ពាក់គ្រឿងមែនទែនឡើយ ។ រូបនេះកំពស់ ០,ម៨៣ បានមកពីភូមិតាវែរនៅក្នុងដំបន់បាត់ដំបង ។

រូប ១ ទៀតជារូបស្រីយ៉ាងល្អ ជារូបតារាឬទេវធីតាក្នុងព្រះពុទ្ធសាសនាលទ្ធិមហាយាន ដែលគេធ្វើបង្ខូចទៅហើយកែធ្វើជាដោះឡើងវិញ ជើងនឹងដៃបាក់អស់ មានស្លៀកសារុងធ្នួតសំយុងចុះមានផ្កាល្អិត ៗ ហើយក្រវាត់ខ្សែក្រវាត់មានរំយោល មានជាយសំពត់ចុះមកពីលើ



ហើយបុងជាយខាងក្រោមមានគំនូយ៉ាងលំបាកនឹងយល់ ។ សារុងនឹងជាយមានកម្រាស់ពីរជាន់ ។ ទងត្រចៀកទាំងពីរបាក់ដាច់បាត់ ។ មានសក់លេចឡើងល្មមមើលឃើញ មានកន្លែងកន្ត្រគអង្កងជាដើមក្បាំងមុខនោះគ្របចុះមកលើត្រចៀកទាំងពីរ ។ នៅពីខាងលើសក់ហើយដាច់ផុតពីក្បាំងមុខទៅ មានម្កុដបន្តុបឡើង ៥ ថ្នាក់រាងស្រួចនឹងមានកំពូលធម្មតាតទៅលើទៀត ។ ថ្នាក់ពីរខាងក្រោមរបស់ម្កុដនោះ នោះជាកន្លែងដែលមានរបនា ជាព្រះអមិតាភត្ថូប ១ អង្គ ។ រូបនេះធ្វើពី

ថ្មភក់ប្រផេះប្រកបដោយចំឡាក់យ៉ាងល្អិតផ្ចារ កំពស់ ០,ម៉ែ៧០ បានមកពីកំពង់ពិលភូមិខ្សាច់ពួយ ។

នៅទីបំផុតរបៀង មានហោរង ១ យ៉ាងល្អ ហើយក្នុងជ្រុង ១ នោះមានរបនាជារូបគ្រុឌបេញង៉ានឹងហោះ ។ នៅក្នុង



បំពុះមានជុំមូល ១ ក្នុងនោះ ។ គ្រុឌនេះមានដៃជាមនុស្ស តែក្រញាំជាសត្វស្លាប នៅភ្លៅមានស្លាបពាសពេញ ហើយជាយសំពត់ក៏ដូចគ្នាដែរ នៅពីខាងលើមានកន្ទុយ មុខនោះ

មានបំពុះមិនមែនប្រមុះទេ ហើយបប្ចូរមាត់ ក៏ប្រប្ញទៅតាមភ្នែកមូលហើយជិតគ្នា នៅក្នុងវង្វង់ដែលគេរបនាជាស្លឹកឈើស្រួច ក្បាលមានពាក់ក្បាំង ហើយមានកំពូលស្រួចជាម្កុដ ។ រូបនេះធ្វើដោយថ្មភក់ព័ណ៌បៃតងចាស់ កំពស់ ០,ម ៦៣៥ កំរាស់ ០,ម៦៦៥ មិនគិតបំពុះ បើគិតបំពុះផងត្រូវ ០,ម ៨៤៥ ។ រូបនេះបានមកពីអន្លង់សាន ។



ព្រះចេតីយ៍ទឹបមាស ធំខ្ពស់ នៅវត្តអេនទ្វាយៈ ក្រុងមណ្ឌលេ
ព្រះចៅឬគន សាងកាល ព. ស. ២៣៥០ ។

ដោយប្រការយ៉ាងណាខ្លះដែលគេគោរព
ព្រះសម្មាសម្ពុទ្ធក្នុងស្រុក គោរេ ។

គឺក្នុងសម័យដែលព្រះសកៈ (ព្រះសម្មាសម្ពុទ្ធ) គង់ព្រះធរមាននៅឡើយ ទ្រង់គង់ក្នុងព្រះវិហារព្រៃធំជិតក្រុងវេសាលី សម្តែងព្រះធម្មទេសនា បំពោះដល់ព្រះអរហន្តចំនួន ២០០០ អង្គ និងពួកពុទ្ធបរិសទ្យក្នុងត្រកូលទាំង ៤ ចំនួន ១២០០ រូប ។ ក្នុងទីជិតនោះ មានស្តេច ១ អង្គទ្រង់នាមថា គ័ក្កេ មានកងទ័ពចំនួន៥០០នាក់សោយរាជ្យក្នុងនគរ១ មានមនុស្ស៦០០.០០០ នាក់ ។

ក្នុងស្រុកនោះមានកើតមហាភ័យ មានមនុស្សស្លាប់ជាច្រើនរាប់មិនអស់ ហើយក្នុងអាកាសឮតែសព្ទសម្រែកថ្ងូញថ្ងូរនឹងទួញយំ គឺជាសម្រែក កិទោគ្យរ ដែលជាមេរបស់ មានមុខមាត់ខ្មៅដូចធ្យូង មានភ្នែក ៥ ជាភ្លើង ហើយមានធ្មេញប្រជ្រួសគ្នា មានសណ្ឋានដូចជាផ្លែក្បែរបក មេរបស់នេះតែងហោះទៅមកកណ្តាលអាកាស ហើយបាចសាចនូវមេជម្ងឺដែលឆ្លងពី ១ ទៅ ១ ពាសពេញទាំងអស់ ។

ស្តេចគ័ក្កៃ មានសេចក្តីភិតភ័យជាខ្លាំង ក៏ផ្ញើសេនាយោធា បាត់ឲ្យយាំទ្វារព្រះរាជវាំងដោយមធ្យ័ត ។ ប៉ុន្តែពួកទាហានទាំងនេះដួលស្លាប់នៅនឹងកន្លែងរាល់គ្នា ហើយក្នុងវេលានោះ នាង ឡោសេ ដែលជាព្រះរាជបុត្រីតែ ១ របស់ទ្រង់ព្រះជន្ម ១៣ ឆ្នាំ ជាទីសំឡាញ់បំផុត ក៏ត្រូវឋាប់ព្រះរោគនេះដែរ ។

ព្រះរាជាក៏បាត់ឲ្យហៅពេទ្យយ៉ាងបំណាននឈ្មោះ គិបា មក ពេទ្យបំណាននេះក៏រសាយដៃមើលមិនជា ។ ក្នុងវេលានោះ ពួកព្រះរាជវង្សានុវង្ស ក៏តាំងប្រជុំគ្នាបំនួន ៥០០ រូប ពិគ្រោះការក្នុងព្រះបរមរាជវាំង ហើយក៏សម្រេចសេចក្តីថា ត្រូវតែទៅ សុំឲ្យព្រះលោកនាថសាស្តាបារជួយ ។

ព្រះបាទ គ័ក្កៃ ក៏ឡើងគង់លើព្រះទីនាំងគជេន្ទ្រស ពួកព្រះរាជវង្សានុវង្សក៏ជិះសេះហែហាមទៅមួយអន្លើ ដោយរាជបរិពារ ប្រមាណ ៨៤.០០០ នាក់ ។ លុះយាងទៅដល់អារាមនោះ ហើយ ក៏ចូលទៅក្រាបថ្វាយបង្គំទៀបព្រះបាទព្រះបរមសម្មាសម្ពុទ្ធ ហើយក្រាបទូលថា ខ្ញុំព្រះអង្គ សូមសេចក្តីអនុគ្រោះព្រះអង្គ ដើម្បីពួកបណ្តាជនទាំងអស់ និងដើម្បីបុត្រីសំឡាញ់តែ ១

របស់ខ្ញុំព្រះអង្គអាយុ ១៣ ឆ្នាំដែលត្រូវចាប់ជម្ងឺជាទម្ងន់ ហើយជីវិតមានគ្រោះថ្នាក់ដូចជាប្រទីបត្រូវខ្យល់ ស្មើតែនឹងរលត់ទៅហើយ សូមព្រះអង្គមេត្តាជួយសង្គ្រោះឲ្យផុតអំពីមហាភ័យនេះឲ្យទាន ។

ព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះបន្ទូលទៅកាន់ថា :

ជំងឺនេះមានបិសាចមេរបស់១ជាអ្នកបង្ក ហើយតថាគតគ្មានអាវុធនឹងកំចាត់មេរបស់នេះទេ ។ ប៉ុន្តែផុតពីលោកនេះទៅមានព្រះពុទ្ធ១ព្រះអង្គដែលមានមុខងារត្រូវជួយដោះទុក្ខ ទ្រង់ព្រះនាមថាព្រះ អមិត ។ ព្រះអង្គគង់នៅក្នុងទីផុតព្រហ្មដែនខាងលិច ក្នុងស្រុកឈ្មោះថាសេចក្ដីសុខយ៉ាងបរិបូរណ៍ ព្រះអង្គគង់នៅជាមួយនឹងអគ្គសាវក២ព្រះអង្គ ។ ដូច្នេះឲ្យស្ដេចយាងត្រឡប់ទៅព្រះរាជវាំងវិញ ហើយឧទ្ទិស្សនឹករកទៅព្រះមហាករុណានៃព្រះ អមិត នឹងជួយដោះទុក្ខព្រះរាជបុត្រីនឹងបណ្ដាជនទាំងអស់បានជាប្រាកដ ។

លុះយាងមកដល់ព្រះរាជវាំងវិញ ហើយព្រះបាទ គ័ក្កេក៏តាំងអុបធូបទៀនផ្កាបូជា ហើយអង្គុយគោរពឆ្ពោះទៅទិសខាងលិចឧទ្ទិស្សនឹករកព្រះអមិត ។ មួយស្របក់លេចព្រះពុទ្ធ

អមិតយាងមកដល់ ។ ទ្រង់និម្មិតព្រះអង្គឲ្យតូចបុះឲ្យមានទំហំធម្មតារបស់អ្នកទ្វីបនេះ ។ ព្រះហស្តស្តាំទ្រង់ទំលាក់ឲ្យទាបបុះហើយមេព្រះហស្តសង្កត់ផ្ទប់ទៅនឹងម្រាមទាំងពីរខាងក្រោយជាដំណាងនៃសេចក្តីមេត្តា ព្រះហស្តឆ្វេងលើកឡើងយកបាទព្រះហស្តមកខាងព្រះភក្ត្រ ជាសំគាល់នូវជ័យជំនះលើបិសាចទាំង ១០៨ ដែលជាអ្នកធ្វើទុក្ខដល់មនុស្ស នៅសងខាងព្រះអង្គ គឺកន្ទុន១ ទៃសីសី១ កាន់រម្បរធម៌១សំណុំ ហើយនៅផ្នែងព្រះកេសមានរូបព្រះអមិតនៅជាប់នៅនោះ ។

ព្រះអមិត និងព្រះអគ្គសាវកទាំងពីរព្រះអង្គតាំងបញ្ចេញនូវរស្មីពីលើក្លោងទ្វារព្រះរាជវាំងមក ហើយក៏ភ្លឺពេញទាំងនគរអស់ទាំងភ្នំ ដើមឈើនឹងស្មៅ ចាប់ពន្លឺមាសទាំងអស់ ពួកបិសាចបែកខ្ចាត់ខ្ចាយទៅគ្រប់ទិសទាំង ៤ ព្រះរាជបុត្រីនឹងអាណាប្រជានុរាស្ត្ររបស់ស្តេច ក៏បានសះស្បើយជារោគពីពេលនោះមក ។

☼

☼ ☼

ព្រះបាទ គ័ក្ក មានសេចក្ដីអរព្រះគុណបំពោះព្រះសក្កៈជាទីបំផុត ហើយក៏យាងត្រឡប់ទៅរកព្រះអង្គវិញ ក្រាបថ្វាយបង្គំហើយទូលអង្វរព្រះអង្គសុំឲ្យបានព្រះអមិត គង់នៅជានិច្ចក្នុងព្រះរាជវាំង ។

វេលានោះព្រះសក្កៈទ្រង់ត្រាស់សួរថា មហារាជមានលោហជាតិ ឈ្មោះអម្ពុទគោន ឬទេ ព្រះរាជាទូលតបវិញថា ឱព្រះលោហជាតិនោះមានតែលើភ្នំ សុមិសេន នៅគល់ឈើ ១ ឈ្មោះ អម្ពុជុំកំពស់៥០០យោជន៍ មនុស្សយើងកាលណានឹងអាចទៅយកបាន ។

ព្រះសម្មាសម្ពុទ្ធទ្រង់តបវិញថា មានតែលោហជាតិនេះឯងទើបអាចនឹងសាងព្រះរូបព្រះអមិតបាន ។ ប៉ុន្តែគេអាចនឹងទៅយកឯទីពិភពនាគក៏បានដែរ ។

ទើបទ្រង់មានព្រះបន្ទូលទៅកាន់ មោក្កេនរេន ថា មោក្កេនរេន ចូរអ្នកទៅកាន់ភោនភុជង្គនាគ ហើយយកលោហជាតិនោះមក ។

មោក្កេនវេនទទួលបង្គាប់ហើយ ក៏ហោះទៅកាន់ព្រះបរម-រាជវាំងស្តេចនាគ ដែលគេហៅថា ព័ត្យនន្ទ ។ ស្តេចនាគឱនគោរពពុទ្ធទូត ហើយក៏បើកនូវឃ្លាំងធំទាំង ៣ យកវត្ថុដែលត្រូវការនោះថ្វាយ ។ មោក្កេនវេនត្រឡប់មកក្នុងទីចំពោះព្រះភក្ត្រព្រះសម្មាសម្ពុទ្ធវិញ ហើយព្រះអង្គឲ្យប្រគល់លោហធាតុនោះដល់ស្តេច គ័ក្កេ ៗ យកទៅដាក់ក្នុងកែវមួយធ្វើពីមរកដ ហើយដំកល់ក្នុងព្រះឱទ្យាន ។

ក្នុងវេលានោះព្រះអមិតនឹងព្រះសកៈ ទ្រង់ប្រតិស្ឋាននៅសងខាងកែវនោះ ហើយបញ្ចេញនូវព្រះរស្មីទៅលើកែវនោះ លោហធាតុអម្ពុទគោន ក៏ឆេះរលាយ ហើយក្លាយទៅជារូបព្រះអមិតព្រមទាំង កន្ទុន នឹងទៃសីសិ ។ គ្រានោះព្រះអមិតក៏យាងចូលទៅ ហើយចាប់ព្រះរូបនោះលើកឡើង មានព្រះបន្ទូលទៅកាន់រូបនោះថា ចូរអ្នកនៅក្នុងលោកនេះចុះ ដើម្បីស្រោចស្រង់មនុស្សលោក ។ ហើយព្រះរូបក៏ឱនទាបចុះជាការគោរព ។

ព្រះអមិតគង់នៅក្នុងព្រះរាជវាំងស្តេចគ័ក្កេកំណត់ ២ ថ្ងៃនឹង ២ យប់តទៅទៀត លំដាប់តពីនោះទ្រង់ហោះទៅកាន់ទិស

ខាងលិច ទាំងព្រះរូបក៏ហោះទៅតាមផង លុះហោះជូនទៅដល់ហើយក៏វិលត្រឡប់មកតាំងនៅក្នុងកន្លែងដដែលវិញ ។

ព្រះរាជាទ្រង់ចាត់ការសាងព្រះវិហារ ១ ក្នុងព្រះឧទ្យានហើយតាំងទ្រង់សីលបរិសុទ្ធ តាំងប្ដេជ្ញាថ្វាយព្រះអង្គបំរើព្រះអមិត ១ ជីវិត ។

✲

✲ ✲

ព្រះរូបនេះនៅ ៗ ក្នុងស្រុកឥណ្ឌៀកំណត់៩០០ ឆ្នាំ ហើយក៏ហោះបាត់ទៅក្នុងអាកាសទៅ ។

ក្នុងសម័យនោះព្រះចៅ បិនវ្យ ក្សត្រទី ១៤ ក្នុងរាជវង្សឧទ្យ សោយរាជសម្បត្តិនៅក្រុង កុទវ ក្នុងដែនកោរេ ។

ក្នុងរាត្រី ១ ទ្រង់បានឮសំឡេង ១ ស្រែកថា យើងមកថែរក្សាអ្នក ។ លុះភ្ញាក់ព្រះនេត្រឡើងក៏ឃើញព្រះរូបព្រះអមិតមានរស្មីព្រោងព្រាត ។ ស្ដេច បិនវ្យ ក៏ធ្វើនមស្សការអុបធូបបូជា ប៉ុន្តែព្រះរូបនោះក៏យាងចុះដោយព្រះអង្គឯង ទៅកាន់ទីព្រះឧទ្យានទៅ ។

ព្រះរូបនេះតាំងនៅ ៗ ទីនោះកំណត់ ២០០ ឆ្នាំ ។

សាសនប្រវត្តិ

ព្រះមហាពិទូរ ក្រសេម គន្ថរបនបណ្ឌិត រៀបរៀង

(តចប់)



ព្រះពុទ្ធរូបកក្កុសន្ធ នៅទិសបស្ចិមនៃវិហារអានន្ទ ព្រះជោកិយ៍នសិទ្ធា
សាងកាល ព. ស. ១៦៣៤ បាគន (ភូមា) ។

៤១ គ្រាប្រិណាមព្រះវក្កលិ ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែន ព្រះហស្តឆ្វេងដាក់ផ្កាប់លើព្រះជានុ ព្រះហស្តស្តាំបក់ចេញជាកិរិយាបណ្តេញឱ្យចេញទៅ ។ ធ្វើដំណាលកាលព្រះសាស្តាបណ្តេញព្រះវក្កលិឱ្យចៀសចេញ មិនឱ្យនៅមើលតែព្រះរូបព្រះឆោមរបស់ព្រះអង្គប៉ុណ្ណោះ ។

៤២ គ្រាទរមានដំរីនាឡាគិរី ធ្វើជាព្រះពុទ្ធរូបយាង មានរូបដំរីជាគ្រឿងប្រកប ជួនកាលមានទាំងរូបព្រះអានន្ទត្ថេរផង ។ ធ្វើដំណាលកាលព្រះសាស្តាទ្រង់ទរមានដំរីនាឡាគិរី ជាដំរីសឹកដែលព្រះបាទអជាតសត្រូវ កាលនៅមិនទាន់ជ្រះថ្លាក្នុងព្រះពុទ្ធអង្គ បានលែងមកឱ្យព្រេចព្រះអង្គៗ ទ្រង់ទរមានដោយឫទ្ធិឱ្យបាក់បបទៅ ។

៤៣ គ្រាទទួលទឹកត្នោត ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែនទ្រង់ឱបបាត្រ មានរូបពានរជាគ្រឿងប្រកប ។ ធ្វើដំណាលកាលព្រះបរមសាស្តាគង់នៅនគរវេសាលី គ្រានោះមានស្វា ១ យកបាត្រទៅដាក់ទឹកត្នោតលើដើមត្នោតនាំមកថ្វាយ ។ គ្រាទរមានដំរីនាឡាគិរីនឹងទទួលទឹកត្នោតពានរ ពួកផ្តៀ

កណ្ដាលធ្លាប់សាងមកហើយក្នុងបុរាណសម័យ ដូចយ៉ាងព្រះពុទ្ធរូប ៨ គ្រានៅស្រុកសាន់ថៃ ក៏មានព្រះពុទ្ធរូបគ្រានេះផង ។

៤៤ គ្រាបង្អុរភ្លៀង (ខ្លះហៅថា គ្រាគន្ធាររដ្ឋ ដែលហៅដូច្នេះ ព្រោះអ្នកប្រទេសគន្ធារបាន ផ្ដើមសាងឡើងជាដំបូង) ធ្វើជាព្រះពុទ្ធរូបឈរ ព្រះហស្ដឆ្វេងបោយបួល ព្រះហស្ដស្ដាំហុចទៅអុំ ជាកិរិយាទទួលទឹក ។ តែបែបខ្លះធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែន ព្រះហស្ដធ្វើដូចពោលហើយ ។ ធ្វើដំណាលកាលព្រះសាស្ដាទ្រង់អធិដ្ឋានឲ្យភ្លៀងធ្លាក់ ដោយមានរឿងថាគ្រានោះប្រទេសកោសលរាំងភ្លៀង អ្នកនគរអត់ទឹកខ្លាំងណាស់ ទើបនាំគ្នាទៅក្រាបទូលសុំភ្លៀងនឹងព្រះអង្គ ៗ ក៏បណ្ដាលឲ្យភ្លៀងធ្លាក់មក ។

៤៥ គ្រាស្រង់ទឹក ធ្វើជាព្រះពុទ្ធរូបឈរ ដណ្ដប់សាដកផៀងព្រះអង្សា ព្រះហស្ដឆ្វេងសំយោកចុះក្រោម ព្រះហស្ដស្ដាំលើកផ្គងជាកិរិយាជុះព្រះកាយ ។ ធ្វើដំណាលកាលព្រះសាស្ដាទ្រង់ស្រង់ទឹកភ្លៀងដែលអ្នកស្រុកកោសលទូលសុំនោះ ។

៤៦ គ្រាសេយ្យាសន៍ ធ្វើជាព្រះពុទ្ធរូបផ្ទំដូចគ្រាបរិនិព្វាន ប្លែកតែគ្រានេះគ្មានរូបព្រះស្តូបនឹងរូបព្រះសាវក ជាគ្រឿងប្រកប គឺសំដៅយកត្រង់ដែលព្រះអង្គផ្ទំដោយធម្មតា ។

៤៧ គ្រាឈរ ធ្វើជាព្រះពុទ្ធរូបឈរ សំយោកព្រះហស្ត ទាំងពីរ ដូចយើងឈរធម្មតា ។

៤៨ គ្រាភ្នែនលេប ឬហៅថា គ្រាភ្នែនពេជ្រ ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែន តែពែនប្រទាស់ឲ្យឃើញបាតព្រះបាទ ទាំងពីរ ព្រះហស្តធ្វើយ៉ាងគ្រាផ្ចាញ់មារ ។ ព្រះពុទ្ធរូបគ្រានេះ ជាប់ដោយបាដិហារ្យ ។ (ព្រះគ្រាដទៃ តែគេធ្វើជាភ្នែនលេប ក៏មានដែរ) ។

៤៩ គ្រាប្រតិស្ឋានព្រះបាទ ធ្វើជាព្រះពុទ្ធរូបឈរសង្កត់ ចុងព្រះបាទចុះជាកិរិយាប្រឹងជាន់ចុះឲ្យឃើញស្នាមព្រះបាទ ។ ធ្វើដំណាលកាលព្រះសាស្តាប្រតិស្ឋានព្រះបាទទុក ជាទីរលឹក របស់សត្វទាំងឡាយ ដូចដែលមានប្រាកដក្នុងរឿងថា ព្រះ អង្គជាន់ទុកនៅទីផ្សេងៗ មានភ្នំសច្ចភណ្ឌ ភ្នំសុវណ្ណកូដជា ដើម ។

៥០ គ្រាដាក់អាយុសង្ខារ ឬហៅថា គ្រាដាក់ព្រះជន្ម ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែន ព្រះហស្ដឆ្វេងដាក់ផ្កាប់លើព្រះជានុ ព្រះហស្ដស្ដាំស្ទាបព្រះឧរា ។ ធ្វើដំណាលកាលព្រះបរមសាស្ដាទ្រង់ជ្រាបកំណត់នៃព្រះជន្មាវសានហើយ ត្រាស់ប្រាប់មារាធិរាជនឹងអានន្ទត្ថេរថា នៅ ៤ ខែទៀត តថាគតនឹងបរិនិព្វានហើយ ។

៥១ គ្រាសំដែងជរាធម៌ ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែន ព្រះហស្ដទាំងពីរចាប់ព្រះជានុទាំងពីរ ។ ធ្វើដំណាលកាលដែលព្រះអានន្ទត្ថេរជ្រាបថា ព្រះសាស្ដាដាក់អាយុសង្ខារហើយ លោកក៏ចូលទៅក្រាបទូលអារាធនាឲ្យគង់ព្រះជន្មនៅតទៅទៀត ព្រះអង្គទ្រង់សំដែងជរាធម៌ថា សង្ខាររបស់តថាគតចាស់គ្រាំគ្រាហើយ ត្រូវតែបែកទំលាយទៅជាធម្មតា ។

៥២ គ្រាទទួលព្រះឧទក (ទឹកឆាន់) ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែន ព្រះហស្ដឆ្វេងដាក់ផ្កាប់លើព្រះជានុ ព្រះហស្ដស្ដាំទ្រង់កាន់បាត្រ ។ ធ្វើដំណាលកាលព្រះសាស្ដា ប្រឈួនធ្ងន់ហើយស្ដេចយាងទៅនគរកុសិនារា ទៅដល់ស្ទឹង ១ ដ៏មាន

ក្នុងរាំងផ្ទៃ ត្រាស់ប្រើអានន្ទត្ថេរឲ្យយកបាត្រទៅដងទឹកមកថ្វាយសោយ ។

៥៣ គ្រាឆាគារលោកន៍ ឬហៅថា គ្រាទតក្រុងវេសាលី ធ្វើជាព្រះពុទ្ធរូបឈរ សំយោកព្រះហស្តឆ្វេង ព្រះហស្តស្តាំលើករាស្មើព្រះឱរា ងាកព្រះភក្ត្រទតមកខាងក្រោយ ។ ធ្វើដំណាលកាលព្រះអង្គប្រឈួនហើយ ស្តេចព្រះពុទ្ធដំណើរទៅនគរកុសិនារា លុះទៅដល់នគរវេសាលី ស្តេចចូលទៅបិណ្ឌបាត វេលាបេញផុតមកហើយ ស្តេចងាកទៅទតក្រុងនោះវិញហើយត្រាស់ថា តថាគតឃើញក្រុងវេសាលី វេលានេះជាគ្រាក្រោយបំផុតហើយ ។

៥៤ គ្រាបរិនិព្វាន ធ្វើជាព្រះពុទ្ធរូបដូចពោលហើយ ។

នៅមានព្រះពុទ្ធរូប ៣ បែបទៀត គឺគ្រាហាមព្រះវិមបន្ទន់ ធ្វើជាព្រះពុទ្ធរូបឈរសំយោកព្រះហស្តខាងឆ្វេង លើកព្រះហស្តខាងស្តាំរា ។ គ្រាផ្ចាញ់មហាជម្ពូបតិ ធ្វើជាព្រះពុទ្ធរូបទ្រង់គ្រឿងយ៉ាងស្តេចចក្រ ។ គ្រាហាមសមុទ្រ ធ្វើជាព្រះពុទ្ធរូបរាព្រះហស្តទាំងពីរ ។ ពីរបែបខាងដើម ឃើញ

មានទីមកដែរ តែរឿងនោះជារបស់កើតឡើងក្នុងជំនាន់ក្រោយតាមផ្លូវយោបល់យល់ថា "បៀតទៅខាងមិនពិត" ។ មួយវែបខាងក្រោយនោះ មិនដែលប្រទះឃើញទីមកសោះ គ្រាន់តែឮពាក្យបរប្បរាថា គ្រាមួយនោះ នៅទីសមុទ្រ (មិនប្រាកដជាសមុទ្រណា) កើតលលកបោកបក់ខ្លាំង ជាហេតុឲ្យអ្នកដែរជលមាគ៌កើតភ័យអន្តរាយច្រើន សេចក្ដីនោះជ្រាបដល់ព្រះបរមសាស្ដា បានស្ដេចយាងទៅឃាត់សមុទ្រនោះ ៗ ក៏ស្ងប់លលកទៅ ។

ដោយហេតុរឿងទាំង ៣ នេះមិនជាប់នៅក្នុងផ្លូវពិចារណារបស់ខ្ញុំ ៗ ទើបមិនយកទៅដាក់បញ្ចូលក្នុងបំណោមបំនួនលេខរៀងនៃក្បួនព្រះពុទ្ធរូប ដែលបានរៀបរៀងមកហើយខាងលើ តែបើប្រសិនជាលោកណាជ្រាបថា មានរឿងរ៉ាវមកពិតមែនក្រៅពីរឿងដែលខ្ញុំប្រទះឃើញមកហើយ ក៏សូមលោកនោះមេត្តាបំភ្លឺខ្ញុំផង ។

ក្បួនព្រះពុទ្ធរូបសន្មតថាចប់តែប៉ុណ្ណេះ ។

# រឿងអាពុកក្មេករើសកូនប្រសា

## រឿងអាពុកក្មេកកើសកូនប្រសា

កាលពីដើមមានតាចាស់ជូនចាស់ម្នាក់ នៅស្រុកណាខ្ញុំមិនដឹង ប៉ុន្តែឮគេនិយាយត ៗ គ្នាមកថាៈ

តាចាស់យាយចាស់នោះគាត់មានកូនក្រមុំម្នាក់ល្អណាស់ អ្នកណាទៅដណ្ដឹងក៏គាត់មិនព្រមឲ្យ ។

គាត់ថាអ្នកណាតមកុំជេរម្ដាយគេបាន គាត់ឲ្យកូនគាត់ជាប្រពន្ធអ្នកនោះ ។

ជូនមួយថ្ងៃនោះមានចៅកំឡោះម្នាក់ មុខមាត់ស្អាតបាតចូលទៅដណ្ដឹងកូនគាត់ ៗ ថា អើអញឲ្យឯង ៗ កុំព្រួយចិត្តប៉ុន្តែឯងតមជេរម្ដាយហើយទទួលបំរើអញ តាមពាក្យអញបានអញឲ្យឯង បើតមមិនបានអញផ្ដាប់មិនឲ្យឯង អញប្រាប់ឯងមុនឲ្យដឹង ក្រោយឯងកុំថាអញកាច ។

ចៅនោះថាខ្ញុំបាទតមជេរម្ដាយបាន ហើយធ្វើការអ្វី ៗ បានទាំងអស់ ខ្ញុំបាទទទួលទាំងអស់ តាមប្រសាស់លោកឪពុក, តាចាស់ថាអើ បើឯងតមជេរម្ដាយបានឯងទៅចុះ ព្រឹកមកវិញពីព្រលឹម ចៅនោះក៏លាវិលទៅផ្ទះវិញ ។

លុះព្រឹកឡើងមកវិញចូលទៅបំរើអាពុកក្មេក  តាចាស់ប្រើកូនក្រមុំគាត់ឲ្យរៀបបាយទឹកឲ្យអ្នកកំឡោះនោះស៊ីៗរួច ហើយក៏តាចាស់ប្រាប់ទៅកូនប្រសាថា  កូនទៅចាប់ក្របីទៅភ្ជួរស្រែចុះ  កូនភ្ជួរស្រែដល់កាលណាឬសៅខាងស្រែនោះយំតេរៗ សឹមឯងដោះក្របីលែងចុះ ។

ហើយអ្នកកំឡោះទៅចាប់ក្របីមកទឹមស្រេចហើយភ្ជួរស្រែ អ្នកកំឡោះនោះភ្ជួរស្រែតាំងតែពីព្រឹកដល់ថ្ងៃត្រង់ក៏ឬពុំមានយំ ក្របីដើរពុំរួចក៏ឬចេះតែឈឹងពុំមានយំ  អ្នកកំឡោះឃ្លានបាយណាស់  ទ្រាំពុំបានដេរម្តាយថា៖

ម្តាយអាឬនេះកាលណានឹងយំឡើង  ចៅនោះដេរតែប៉ុណ្ណោះ  តាចាស់ស្ទុះចេញពីក្រោយឬថា  ល្ហើយចុះឯងដោះក្របីលែងហើយទៅផ្ទះឯងចុះ  អញផ្តាច់កូនហើយ  ឯងតមដេរម្តាយមិនបានទេ  ចៅកំឡោះហ្មោងនោះ  ក៏ដោះក្របីទៅផ្ទះវិញ ។

លុះដល់ឯក្រោយទៀតមានអ្នកកំឡោះ  ចូលទៅដណ្តឹងកូនតាចាស់នោះទៀត នោះក៏គាត់បង្គាប់ផ្តាំដូចជាអ្នកកំឡោះមុន

អ្នកកំឡោះក្រោយមានប្រាជ្ញា ទៅភ្ជួរស្រែវេចបាយទៅស៊ីផង លុះភ្ជួរដល់ថ្ងៃណាស់ ឃ្លានបាយក៏បញ្ឈប់ក្របីស៊ីបាយ ភ្ជួរដល់ថ្ងៃជ្រេពីត្រង់ក៏ឬពុំឮយំក្របីអស់ជើងដើរពុំរួច អ្នកកំឡោះនោះកាលណាបើបរក្របីទៅជិតឬនោះ ក៏ស្រដីថា ឱលោកឬអើយយំឡើងក្របីដើរពុំរួច ហើយអាណិតក្របីផង ខ្លួនខ្ញុំឥតបើអីទេ ខ្ញុំមានបាយស៊ីភ្ជួរដល់យប់ក៏បានដែរ បើពុំអាណិតខ្ញុំអាណិតតែក្របី ដ្បិតវាជាសត្វ អ្នកកំឡោះនោះ អង្វរដូចម្ដេចក៏ឬពុំមានយំ ពៅនោះក៏ពុំមានដែរ ដ្បិតវាដឹងជាតាចាស់នៅពួនក្រោយឬ វានិយាយអង្វរយូរទៅ តាចាស់នោះមើលមកឃើញក្របីដើរពុំរួច ក៏គាត់នឹកអាណិតក្របីគាត់ ៗ យំក្រោយឬនោះឮតែកេរ ៗ អ្នកកំឡោះនោះក៏ដោះក្របីលែងឲ្យស៊ីស្មៅ ហើយមកផ្ទះអាពុកក្មេកវិញ តាចាស់នោះក៏ឲ្យកូនក្រមុំគាត់លើកបាយមកឲ្យអ្នកកំឡោះនោះស៊ី លុះល្ងាចតានោះប្រាប់ថាកូនណើយទៅផ្ទះឯងបុះព្រឹកសឹមឯងមកវិញ ពៅកំឡោះនោះក៏លាទៅផ្ទះ លុះយប់ក៏មកលបស្ដាប់នៅក្រោមដំណេកតាចាស់

នោះ ស្តាប់ការគិតនឹងប្រពន្ធគាត់ទាល់តែគាត់ដេក ទើបវាទៅដេក ។

លុះដល់យប់តាចាស់ជូនចាស់ចូលដេកក៏តានិយាយនឹងជូនថា ជូន អាទេះវាតមជេរម្តាយបាន ប៉ុន្តែរូបរាងវាអាក្រក់មិនសមនឹងកូនយើង ដូច្នេះយើងរកកល់យ៉ាងណា ឲ្យវាខឹងវាជេរម្តាយ យើងនឹងផ្តាច់វាទៅ ។

ជូនឆ្លើយថា ងាយទេ បើដូច្នេះតាឯងចូលក្នុងការុង ១ ការុង ១ ដាក់អង្ករ ហើយព្រឹកឡើងវាមកខ្ញុំប្រាប់វាថា តាឯងទៅកាប់ឧសលើភ្នំមុនហើយ ៗ ខ្ញុំឲ្យវារែកតាឯងនឹងអង្ករទៅ លើភ្នំហើយបើធូន់វាខឹងវាជេរនោះតាឯងនៅក្នុងការុងឮហើយមកវិញផ្តាច់វាបានដោយងាយ តាយាយគិតគ្នាដូច្នោះហើយក៏គាត់ទៅដេកទៅ ឯអ្នកកំឡោះលបស្តាប់ក្រោមផ្ទះឮដឹងអស់ការហើយក៏វិលទៅផ្ទះដេក ។

លុះព្រឹកអ្នកកំឡោះនោះ ទៅបំរើម្តាយក្មេកអាពុកក្មេកក៏ស្រាប់តែឃើញយាយចាស់បង្ហាញមែ្រក ហើយប្រាប់ថាកូនអើយ ឪឯងទៅកាប់ឧសលើភ្នំហើយ គាត់ផ្តាំថាឲ្យកូនឯងរែក

អង្ករនេះឡើងទៅតាមគាត់ឲ្យឆាប់ ដ្បិតគាត់ទៅពីព្រឹកមិនទាន់ហូបបាយ កូនឯងមានតែរែកទៅឲ្យឆាប់ នឹងអាលដណ្តាំបាយឲ្យឪឯងហូប ហៅនោះក៏ទទួលម្រែកហើយរែកទៅ លុះរែកទៅឆ្ងាយដល់ជើងភ្នំក៏រែកឡើងបន្តិចទៅវាធ្ងន់ណាស់ ក៏រែកចុះមកហើយស្តីថា ឱឪអើយខ្ញុំឃ្លានបាយហើយ ខ្ញុំរែកឡើងទៅជាឆាប់ពុំបានទេ វាធ្ងន់ម៉្លេះនរណានឹងរែកឡើងទៅរួចវិញ បើឪគាត់អាណិតគាត់ដេរបន្ទោសដូចម្តេចក៏ទទួល និយាយហើយរែកចុះមកវាលវិញ លុះរែកទៅដល់ឃើញស្រូវស្ទួតល្អ ហើយក៏រែកទៅដាក់ឈប់កណ្តាលស្រូវនោះ ហើយដើរទៅបាត់ ១ ស្របក់ដើរត្រឡប់មកវិញ ហើយយកភ្លើងដុតជុំម្រែក លុះភ្លើងឆេះស្រូវជុំវិញ ហើយក្តៅដល់តាចាស់នៅក្នុងម្រែកនោះ ៗ ក៏គាត់បម្រិះញ័រទាំងការុង ភ័យណាស់ក្រែងភ្លើងឆេះស្លាប់ ប៉ុន្តែចេញពុំរួច អ្នកកំឡោះធ្វើជារត់មកពីណាហើយ ៗ ស្រែកថា ជើនរណាដុតភ្លើងឆេះម្រែកអញអស់ហើយ ធ្វើម្តេចក៏ទៅយកឲ្យបាន ភ្លើងឆេះជុំវិញចូលពុំរួចទេ ថាហើយស្រែកឈរនៅក្រៅ លុះដល់ភ្លើងឆេះដល់ការុងក្តៅតាចាស់ណាស់

ទើបស្ទុះចូលទៅក្នុងភ្លើងអូសម្រែកបេញពីភ្លើងរូបហើយ ភ្លើងឆេះដាច់ខ្សែការុង ភ្លើងរលាកតាចាស់ត្រដររញ៉រ ៗ ក៏ហៅកំ-ឡោះស្រាយការុងបេញ ឃើញតាចាស់ជាអាពុកក្មេករលាកសុទ្ធតែភ្លើងឆេះទាំងក្បាលផង ក៏វាជំរាបថា ដើលោកឪ ម្តេចក៏មិនប្រាប់កូន កុំអីភ្លើងឆេះស្លាប់ទៅហោលម៉ែឲ្យនៅមេម៉ាយ ហើយតាចាស់ដឹងហើយខឹងណាស់ តែពុំដឹងបើនឹងគិតធ្វើដូចម្តេច ឡើងដើរតយង៉យមកផ្ទះវិញទ្រមខ្លួនមួយថ្ងៃ ណានឹងវាអូសបេញពីភ្លើង ណានឹងរលាកភ្លើង មកផ្ទះវិញគ្មានស្តីមួយម៉ាត់ ដល់ផ្ទះហើយប្រាប់ឲ្យកូនប្រុសទៅផ្ទះព្រឹកសឹមមក ។ ឯកូនប្រុសាក៏លាទៅផ្ទះ ដល់យប់ក៏លបទៅពួនក្រោមផ្ទះស្តាប់ទៀត ។

លុះយប់ក៏តាចាស់ដូនចាស់ចូលដេក និយាយគិតគ្នាទៀតតាថាគិតដូចម្តេចនឹងផ្តាច់វាបាន អានេះមានប្រាជ្ញាធំណាស់នឹងឲ្យកូនយើងទៅវាៗមិនសមនឹងកូនយើង ពីថ្ងៃមិញវាដឹងជាឯងនៅក្នុងការុង វាវែកទៅដល់កណ្តាលផ្លូវវាថាធ្ងន់ណាស់តែម្តាយវាមិនជេរ វារកទីណាមានស្បូវស្ងួត ហើយវាវែកម្រែកទៅដាក់

កណ្ដាលស្បូវ ហើយវាដើរទៅរកភ្លើងមកដុតជុំវិញ ភ្លើងឆេះ ហើយវាធ្វើជាស្រែកថា នរណាដុតភ្លើងនេះ ឆេះម្រែកវាអស់ ហើយវាឈរស្រែកមិនចូលយក ទុកទាល់តែភ្លើងឆេះ ដល់ក្ដៅ ទើបបានវារត់ចូលទៅអូសចេញមក អញភ័យណាស់ប៉ុន្តែចេញ មិនរួចវាចងមាត់ការុងជាប់ រលាកអស់ទាំងខ្លួន ឥឡូវនេះយើង នឹងគិតធ្វើដូចម្ដេចនឹងផ្ដាច់បាន យាយថាឥឡូវនេះយើងគិត តាឯងធ្វើម្ចាស់ វាឲ្យធ្វើឆ្កែរួចនាំទៅបណ្ដើរអណ្ដើក ឲ្យវា វារដូចឆ្កែ បើរកអណ្ដើកមិនបាន ឬវាបោលមិនទាន់ដូច្នេះ យើងផ្ដាច់វាបាន តាចាស់ថាអើ ដូនគិតដូច្នេះត្រូវ ព្រឹកអញ ធ្វើដូច្នឹង តាយាយគិតគ្នាដេកទៅ ឯអ្នកកំឡោះនោះស្ដាប់ដឹង អស់ការហើយវិលទៅផ្ទះវិញ ដេកដល់មាន់រងាវ យកអណ្ដើក ពុនយកទៅចងទុកក្នុងស្មៅគុម្ពោតឯវាល ឯនេះឯនោះ ពាស ពេញតែវាល ដែលតាចាស់គាត់គិតទៅរកអណ្ដើកនោះហើយ វិលមកផ្ទះដេក ។

លុះព្រឹកព្រហាមឡើង ចៅនោះទៅដល់ផ្ទះអាពុកក្មេក ម្ដាយក្មេក ៗ ក៏ឲ្យកូនក្រមុំគាត់រៀបបាយ លើកមកឲ្យចៅនោះ

ស៊ីៗរួចហើយក៏ប្រាប់ថា កូនឥឡូវនេះ យើងទៅបណ្ដើរអណ្ដើកប៉ុន្តែយើងគ្មានឆ្កែ កូនឯងធ្វើឆ្កែ ឪធ្វើម្ចាស់ យើងទៅរកក្រែងបានមួយពីរយកមកស៊ី អានោះឆ្លើយបាទ ហើយតាចាស់ពុនបាយសំណុំទឹកបំពង់ដើរចេញពីផ្ទះទៅ ឯអានោះក៏បោលជើង៤ តាមក្រោយទៅដល់វាលកន្លែងវាចងអណ្ដើកនោះក៏វាបោលទៅមុនចូលស្មៅកំប៉ូត ១ កោះដុំងៗ តាចាស់រត់ទៅដល់ចាំបានអណ្ដើក ១ ឆ្កែបោលទៅទៀតចាំបានអណ្ដើក៦-៧ ដល់ថ្ងៃត្រង់តាចាស់ឃ្លានបាយពេកណាស់ អង្គុយគិតស្រាយបាយស៊ី ឯឆ្កែនោះមើលទៅខាងឃើញក្របីមួយហ្វូង ក៏បោលទៅដេញចាំក្របី រត់ចូលពេញស្រូវស្រែអ្នកស្រុក ។

តាចាស់ឃើញហើយ រត់ទៅដេញឆ្កែដេញក្របីចេញពីស្រែ ឆ្កែបោលមកស៊ីបាយអស់ហើយបោលទៅបាត់ ។ ឯអាពុកក្មេកម្ចាស់ឆ្កែ លុះវិលមកវិញរកស៊ីគ្មាន ឆ្កែស៊ីអស់ខឹងណាស់ដេញវាយពុំទាន់ ណាអស់កំលាំង ឃ្លានបាយផងឆ្ងាយ ក៏ខំដើរមកផ្ទះវិញទាំងអត់បាយដើរពុំចង់រួចបន្ទោសឆ្កែមិនបាន ដ្បិតឆ្កែវាបំណាំតែដូច្នឹង ក៏ដល់ផ្ទះស៊ីបាយរួចហើយ

ប្រាប់ឲ្យកូនប្រសាទៅផ្ទះ ព្រឹកសឹមមកវិញ ដល់យប់កូនប្រសានោះមកលបស្ដាប់តាយាយគិតគ្នាទៀត ។

លុះដល់យប់ជូនតាចូលដេក ហើយតានិយាយប្រាប់យាយពីរឿងដែលកូនប្រសាសព្វគ្រប់ហើយ តាឲ្យយាយជួយគិតទៀត នោះជូនចាស់ប្រាប់ថា ពីមុនវាធ្វើផ្ដេ តាឯងធ្វើម្ខាស់ វាធ្វើបាបតាឯងបានជូហ្នោះ ។

ព្រឹកនេះតាឯងឲ្យវាធ្វើម្ខាស់ តាឯងធ្វើផ្ដៅវិញ តាយាយគិតគ្នាហើយដេកទៅ ឯចៅនោះលបស្ដាប់ដឹងការហើយទៅផ្ទះដេក ។

លុះព្រឹកឡើងចៅនោះទៅបំរើអាពុកក្មេកទៀត នោះតាយាយឲ្យកូនក្រមុំលើកបាយមកឲ្យស៊ី ៗ រួចហើយក៏តាយាយប្រាប់ថាកូនឡើយពីម្សិលមិញឯងធ្វើផ្ដេ ថ្ងៃនេះឯងធ្វើម្ខាស់ ៗ អញធ្វើផ្ដៅវិញ ចៅនោះឆ្លើយបាទ ហើយប្រគល់បាយទឹកឲ្យវាពុនទៅឯតាវារធ្វើផ្ដៅបោលតាមក្រោយទៅ ។

លុះហួសពីផ្ទះឆ្ងាយបន្តិចវាខំដើរលឿនកុំឲ្យអាពុកក្មេកវាបោលទាន់ ។

ឯតាបោលពុំទាន់ផ្សិតខ្លួនបាស់ដើរត្រែកៗតាមក្រោយវាក៏វាបែរមកវាថា ឆ្កែអីស៊ីតែបាយបង្គួស់ទៅមុខមិនទៅដើរតែក្រោយម្ចាស់ រកអណ្តើកម្តេចបាន ថាហើយវាយឆ្កែឲ្យបោលទៅមុន ឯតាបាស់បោលក្នុងស្មៅមិនរួចបេះតែដើរតាមក្រោយ អណ្តើកក៏រកគ្មានបាន កូនប្រុសាវាវាយស្ទើរតែនឹងស្លាប់ ហត់ស្ទើរតែនឹងដាច់ខ្យល់ពុំហ៊ានស្រដីខ្លាសកូនប្រុសា ។

លុះទៅឆ្ងាយហើយដល់ថ្ងៃត្រង់ វាស្រាយបាយស៊ីហើយវាថា ឆ្កែអីរកអណ្តើកមិនបាន ដើរតែក្រោយមនុស្ស ស៊ីតែបាយបង្គួស់ហើយវាមិនឲ្យបាយស៊ី វាឲ្យតែផ្អឹងឆ្អែងអង្កៀមក៏មិនបែកផ្សិតគ្មានធ្មេញ ឃ្លានណាស់អង្គុយមើលតែមុខវា ។

លុះតែវាស៊ីហើយវាវាយ ១ ព្រនង់ទៀតវាថា ណ្ហើយទៅផ្ទះវាមិនផែះទេ ឆ្កែប្លែងយ៉ាងនឹងនេះ ហើយវាឡើងដើរវិលទៅផ្ទះវិញ ។

ឯតាបាស់ហត់ណាស់វារពុំរួច ឡើងដើរទៅតាមក្រោយវាទៅដល់ផ្ទះវាប្រាប់ម្តាយក្មេកវាថា ម៉ែៗអណ្តើករកមិនបានទេផ្សិតឆ្កែមិនឆ្វាក់ ។

ឯតាចាស់ទឹងណាស់ប្រាប់កូនប្រសាថា ឯងទៅផ្ទះបុះព្រឹកសឹមមកវិញ ឯអានោះក៏លាទៅហើយដល់យប់ក៏មកពួនលបស្ដាប់ក្រោមផ្ទះទៀត ។

លុះដល់យប់ពេលប់កាលឯណាតាយាយចូលដេក តានិយាយប្រាប់យាយពីរឿងកូនប្រសាវាធ្វើបាប ហើយបង្អត់ទាំងបាយផង ។

ដូនថាណ្ហើយឲ្យកូនទៅវាទៅផ្ដាប់វាមិនបានទេ អានេះមានប្រាជ្ញាណាស់ ឯងគិតអីវាដឹងមុនអស់ វាធ្វើបាបស្ទើរតែនឹងស្លាប់ក៏មិនរាង នោះតាចាស់ឆ្លើយថានឹងឲ្យទៅវា មើលទៅរូបរាងវា ៗមិនសមនឹងកូនយើងសោះ ប៉ុន្តែនឹងធ្វើកល់ឲ្យវាខឹងវាជេរម្ដាយវាមិនជេរ ដូច្នេះដូនជួយគិតអញម្ដងទៀត បើវាធ្វើតាមមិនបានសឹមផ្ដាប់វាទៅ នោះដូនចាស់ថាអើតឡូវនេះមានតែគិតដូច្នេះ តាឯង មាន់រងាវ ឡើងលុបមុខស៊ីស្លាប្លបបាយហើយចូលទៅក្នុងការុង១ ការុងមួយប្រកអង្ករ បើព្រឹកឡើងវាមកខ្ញុំប្រាប់វាថាតាឯងទៅផ្សារទិញទំនិញ ហើយខ្ញុំឲ្យវារែកទៅឲ្យទាន់វេលាស៊ីបាយព្រឹក ដ្បិតផ្លូវទៅផ្សារក៏ឆ្ងាយដែរ បើវារែក

ទៅមិនទាន់ មកវិញផ្ដាច់វាទាំងងាយ មួយទៀតដល់កណ្ដាលផ្លូវវាធ្ងន់វា ប្រហែលជាវាឃើញស្ងាត់ហើយវាដើរមិនខាន តាចាស់ថាអើជួប្រេះត្រូវ គិតគ្នាហើយដេកទៅ ឯកូនប្រសាលបស្ដាប់នៅក្រោមផ្ទះដឹងការហើយក៏ទៅផ្ទះដេកទៅ ។

លុះព្រឹកឡើងក៏ហៅនោះរៀបខ្លួន ដើរចេញទៅបំរើអាពុកក្មេកទៀត ដល់ហើយម្ដាយឲ្យកូនក្រមុំលើកបាយមកឲ្យហៅនោះស៊ីទៀត ស៊ីហើយក៏ប្រគល់ម្រែកឲ្យកូនប្រសាររែកទៅតាមអាពុកក្មេកឯផ្សារជួបគំនិតជូនតាគិតគ្នាពីល្ងាចនោះ ។

អានោះរែកដើរទៅហើយគិតថា ម្ដងនេះអញធ្វើអាពុកក្មេកអញនេះឲ្យ ៗ កូនអញកុំឲ្យរកកល់ធ្វើបញ្ឆោតអញក្រោយទៀត ហើយគិតតែរែកដើរទៅ លុះដល់កណ្ដាលផ្លូវដាក់ម្រែកចុះហើយថា ការុងនេះបងមាត់មិនជាប់ ហើយវាយកខ្សែបងថែមទៀត ហើយរែកដើរទៅដល់កណ្ដាលផ្លូវ មានព្រៃកមានស្ពាន ក៏ឈប់ដាក់ម្រែកលើស្ពានបុងក្ដារ នៅតែបន្តិចនឹងធ្លាក់ពីស្ពាន ហើយថាឱអញ្ចើយប្លែណាស់ហើយ ម្លេះសមឱដើរមិនខានឡើយ ម្រែកក៏ធ្ងន់ រែកម្ដេចទៅឲ្យទាន់ ឱដើរក៏ដើរចុះ អញដាក់

នៅនេះទៅវាលសិន រូបសឹមទៅទៀត និយាយដើរទៅ ។

មួយស្របក់ក៏កាន់ឈើ ១ ធំដើរមកពីនាយបុកក្តារស្ពាន គ្រាំ ៗ ធ្វើជាដំរីឆ្លងនូវស្ពាន ហើយស្រែកថា នរណាដាក់ម្រែក នៅលើស្ពាន ដំរីអញវាជាន់ខ្ទេចអស់ហើយយកបេញឡើងធាប់ ស្រែកហើយបុកក្តារដើរគ្រាំ ៗ ចូលមក ។

ឯតាចាស់នៅក្នុងការុងគិតស្មានជាដំរីមែន ភយ័ក្រែងជាន់ស្លាប់ ស្រាប់តែវិតចៀសផ្លូវដំរីហួសពីក្តារធ្លាក់ទៅក្នុងទឹក ៗ ចូលក្នុងការុងឈ្លក់ទឹកត្រដររញ៉េរទាំងការុងស្ទើរតែនឹងស្លាប់ ។

ឯកូនប្រសាវោះឃើញដូច្នោះ ក៏ទុកឲ្យផឹកទឹកបន្តិចឲ្យអស់ខ្ទេចទៀត ។

ហើយធ្វើជាមកពីវាលស្រែកថាជើនរណាហ៊ានបរដំរីធាយម្រែកអញធ្លាក់ទៅក្នុងទឹកទទឹកអង្ករអស់ ឱអញ្ចើយឱដេរថែមទៀតហើយថ្ងៃក៏កាន់តែយូរ ឥឡូវស្រាប់តែទទឹកអង្ករអស់ថែមទៀត ហើយវាឃើញអាពុកក្មេកវាបង្រិះញ៉រក្នុងការុងក៏វាថា ឱមានទាំងត្រីមកបបែះផង ល្ហើយអញបុះទៅស្រង់យកមកមើលថាហើយលោតទៅស្រង់យកឡើងមកហើយថា អើបើវាទទឹក

នឹងស្រាយហាលថ្ងៃ ហើយវែកយកទៅឲ្យម៉ែធ្វើនំបញ្ចុកទុកឲ្យ ឪ ចាហើយស្រាយមើលឃើញតាចាស់នៅក្នុងការុងក៍វាថា ឳឪរើយដូចម្ដេចមិនស្រែកប្រាប់ខ្ញុំ កុំអីនឹងស្លាប់លង់ទៅហើយ វាបរដំរីមកពីណាមិនដឹង វាឲ្យដំរីធាយធ្លាក់ទៅក្នុងទឹក ។

តាចាស់ស្ដាប់ហើយឡើងឈរ ដើរវិលមកផ្ទះវិញមិនមាន ស្ដីអ្វីយម៉ាត់ ដល់ទៅផ្ទះគិតរិះអស់បំណោះពុំហ៊ានគិតទៀត ឲ្យ រៀបរណ្ដាប់ការឲ្យកូនក្រមុំទៅអ្នកកំឡោះនោះទៅ ។

យើងធ្វើរឿងព្រេងនេះឲ្យអស់អ្នកផង ដែលមានកូនក្រមុំ ផងមើលឲ្យបានដឹង បើនឹងឲ្យកូនមានប្ដី ធ្វើអាពាហ៍ពិពាហ៍ ក្ដីក៏ឲ្យទៅ បើមិនបង់ឲ្យក៏ស្ងៀម ពុំនោះមានតែនិយាយ មុនឲ្យអ្នកដែលមានខ្លួនខាងប្រុស ឲ្យបានដឹងកុំធ្វើយ៉ាងរឿង តាចាស់ដូនចាស់រើសកូនប្រសានេះមិនល្អទេ ពិបាកតែរបម្ហូប គង់បានទៅគេ ។ ៚

ចប់រឿងនេះតែប៉ុណ្ណោះ

ÉCOLE FRANÇAISE
BIBLIOTHÈQUE
D'EXTRÊME ORIENT

N° D. 2180

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMPUCHÉA SURIYA

# កម្ពុជសុរិយា

## សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ៨

ខែ ៤, ៥, ៦, រួមគ្នា

កុង្សីយសេនាបតីបានអនុញ្ញាតហើយ

សម្ដេចសង្ឃនាយកទាំងពីរគណយល់ព្រម

PER
933

BIBLIOTHÈQUE ROYALE DU CAMBODGE

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព. ស ២៤៧៩
គ. ស. ១៩៣៦

ÉCOLE FRANÇAISE
BIBLIOTHÈQUE

# បញ្ជីរឿង


១— សេចក្ដីអធិប្បាយអំពីបុរាណវត្ថុ នៅទីពិពិធភណ្ឌវត្ថុពោធិ៍ភាល (តចប់).... ១

២— រឿងព្រះពុទ្ធសាសនារបស់យីប៉ុន លោក បូណ្ណ រៀបរៀង ក្រម្ការ ដុំ-មៅ ប្រែជាភាសាខ្មែរ.................... ១៩

៣— ដោយប្រការយ៉ាងណាខ្លះ ដែលគេគោរពព្រះបរមសម្មាសម្ពុទ្ធនៅស្រុកចិន លោក បូណ្ណ រៀបរៀង ក្រម្ការ ដុំ-មៅ ប្រែជាភាសាខ្មែរ (ត)..... ៤៣


# រូបផ្សេងៗ


១— ព្រះពុទ្ធរូប រចនាយីប៉ុន.................... ១៨

២— រូបភ្នំតូចនៅស្រុកមណ្ឌលេ (ភូមា) សឹងពេញទៅដោយអារាមស្ថាន..... ៤១

៣— រូបក្លោងទ្វារហោត្រៃ ១ នៅវត្តគេកតាវ ស្រុកមណ្ឌលេ (ភូមា)...... ៤៩

# TABLE DES MATIÈRES

I. Description de quelques pièces du musée de Vat-Povéal par H. Parmentier et R. Dalet (suite et fin)........... 1

II. Bouddha japonais par Georges Bonneau — Traduit du Français en Cambodgien par Kromokar Chum-Mau...... 19

III. De quelle manière le Bouddha fut vénéré en Chine par Georges Bonneau — Traduit du Français en Cambodgien par Kromokar Chum-Mau.............................. 43

## HORS TEXTE:

I. Bouddha japonais.................................. 15

II. La colline sacrée à Mandalay centre du Bouddhisme en Birmanie........................................ 41

III. L'entrée de la Bibliothèque de la pagode de Taiktaw à Mandalay — Bois sculpté............................ 49

# សេចក្តីអធិប្បាយអំពីវត្ថុបុរាណនៅទីពិពិធភណ្ឌវត្តពោធិ៍វាល

## (ត)

ខាងឆាយទៅទៀតមានសុំទ្វារ ១ គួរឲ្យមើល; ក្បាច់បំឡាក់យ៉ាងធម្មតាមិនពិនិត្យផ្ចិតផ្ចង់ ប៉ុន្តែមានរឿងរ៉ាវយ៉ាងជាទីមានប្រយោជន៍ ។ នៅត្រង់កណ្ដាលធ្វើជាភ្នំបែបគ្រាន់តែជាហេតុឲ្យដឹងបាន ភ្នំនោះនៅពីលើក្រុងរាពណ៍ ដែលមានដៃស្ដាំ ៩ និងដៃឆ្វេង ៩ មានក្បាលកណ្ដាល ១ ក្បាលខាងស្ដាំ ៤ ក្បាលខាងឆ្វេង ៥ ទាំងអស់មានក្បាល ១០ និងដៃ ១០ គូ ។ ដៃលឈរនៅពីខាងស្ដាំហើយកាន់អាវុធ ១ នោះគឺរូបស្វា ។ ព្រះឥសូរនឹងនាងឧមា គង់លើភ្នំនៅពីលើផ្ទូរដើមឈូក ព្រះឥសូរកាន់ដំបងក្នុងព្រះហស្ដស្ដាំ នាងឧមាបែបភ័យហើយដៃស្ដាំកៀកពីលើព្រះហស្ដព្រះឥសូរ ។ ព្រះបាទស្ដាំព្រះឥសូរជាន់ទប់ទៅនឹងដី ដើម្បីទប់ភ្នំឲ្យនឹង ហើយជាន់កំទេចក្រុងរាពណ៍ ឃើញជើងក្រុងរាពណ៍ ៥ លេចចេញពីខាងក្រោមភ្នំមក ។ នៅជាខាងស្ដាំមានរឿងចម្បាំង គេស្គាល់បានថាជារឿងដកយកមកពីរឿងរាមាយណ មានមនុស្សម្នាក់ឈរលើរាជរថទិមសិង្ហ ហើយកាន់ស្នាដំឡើងបាញ់ រថនោះបរលើទីផ្ទៃដីដែលគេធ្វើជាហេតុ មិនមែនជាតួភ្នំទេ ។ នៅលើចន្ទោលរទេះដែលរថនាជាក្បាលពស់

នៅចុងបំផុត នោះឃើញព្រះព្រហ្មគង់នៅបែបទំនងងាប្បាំង ឃើញមានព្រះហស្ត ៤ និងព្រះកេស ៣ ព្រះកេស ១ បាំងបាត់ មានកាន់អាវុធ ១ យាឡើងដោយព្រះហស្តឆ្វេងខាងក្រោម បែបជាដាវខ្លីឬដំបង ។ នៅខាងឆ្វេងគឺក្បាលបង្គោលរថ ហើយនៅខាងក្រោយក្បាលសិង្ហឃើញមានទង់សំគាល់ ១ តែមិនឃើញមានអ្នកកាន់ ។ ទង់សំគាល់នេះមានរចនាជារូបមនុស្សតូច ១ ដែលមានជើងជាន់មកលើផ្ទៃខាងលើនៃដងទង់សំគាល់នោះ រូបមនុស្សនោះតាំងងាគ្រវីនូវអាវុធ ១ ។ រថនឹងទង់ផ្ដោះមុខទៅកាន់រឿងជាទីទុក្ខសោក ១ រឿងនោះឃើញមានមុខប្រាសាទ ៣ ថ្នាក់រលំធ្លាក់ចុះ ហើយនៅពីខាងក្រោមដំបូលឃើញមានអ្នករងគ្រោះកាប ៣ រូប អ្នករងគ្រោះទី ១ គឺមនុស្សប្រុសមើលឃើញច្បាស់ណាស់ល្អ ហើយ ២ រូបទៀតឃើញតែក្បាលលេចមក ។ អ្នករងគ្រោះក្រោយគេ គឺសត្វដំរី ដែលឃើញតែក្បាលចេញមកពីក្នុងបំណោមប្រកាប់ប្រចាក់នោះ ។ នៅខាងក្រោមរថចម្បាំងពីឆ្វេងទៅស្ដាំរាប់តាំងពីកង់រថចម្បាំងទៅគេសំគាល់ឃើញរូបផ្សេងៗ គឺ រូបអ្នកគោរព ១ មានដៃប្រណម្យ រូប

ព្រះគណេសអង្គុយ ១ ដៃខាងក្រោមធ្វើទំនងជាសមាធិ ដៃខាងលើកាន់នូវផែនទាំងមូល ១ ហើយដៃស្តាំខាងលើកាន់នូវភក្តស្តាំរាងសំបើម ។ ក្បាលងាកទៅឆ្វេងទៅខាងក្រោយប្រហែល ៣ ភាគក្នុង ៤ ភាគ រូបពីនេះឃើញមានរូបមនុស្ស ៣ ទៀតដេកស្តូកជារូបស្លាប់ឬហៀបនឹងស្លាប់ ។ នៅជាបន្ទោះភ្នំទាំងពីរ ឃើញមានរូបអ្នកគោរពត្តូប ១ ហើយនៅជិតនោះឃើញក្បាលសិង្ហ១អើតចេញពីភ្នំ ព្រះឥស្សរនឹងនាងឧមាមក ។ នៅខាងក្រោមរថ បែរខាងឆ្វេងហើយជាខាងក្រោយ ឃើញរូបអ្នកគោរពពីរ ។ រថនោះប៉ែកខាងក្រោមគេរចនាជាខ្សែមាឥជរ ។ រឿងជាខាងឆ្វេងនៃពួក១ជុំនោះឃើញមិនក្រទីក្រទាទេ ។ ក្នុងទីជ្រៅទៅឃើញមានរថដូចគ្នាទិមសិង្ហពីរតែមើលទៅឃើញតែ ១ រូបនេះស្មាដៃធ្លាក់គ្រាន់បើ ។ ចុងបន្ទោលមានរូបនាគក្បាល ៣ ហើយនៅខាងក្រោយមានទង់សំគាល់ដូចជារូបជាន់មុននោះដែរ ។ នៅលើរថឃើញព្រះឥស្សរឈរមានព្រះហស្តពីរខាងស្តាំកាន់នូវត្រីសូលដងវែង ហើយខាងឆ្វេងកាន់នូវផ្កាឈូក ។ នៅពីខាងឆ្វេងមានស្រីពីរនាក់ឈរកាន់ផ្កាឈូក ១លើក ១ស-

យុង ។ អ្នកបររថជារូបតូច ១ អង្គុយរាងបែបស្រយុតមានដៃឆ្វេងកាន់នូវដំបង ។ នៅខាងក្រោយរថមានអ្នកគោរព ៣ នាក់អង្គុយលុតជង្គង់ ។ នៅជាបន្ទោះភ្នំ២នេះ មានអ្នកគោរពម្នាក់ទៀត ។ សុំទ្វារនេះធ្វើដោយថ្មភក់ប្រវែង បណ្ដោយ ១ ម៦០ កំពស់០ម៤៣ បានមកពីភូមិជ្រៃខ្ទែត្របាត់ដំបង រឿងរ៉ាវទាំងអស់នេះសុទ្ធតែដកយកមកពីក្នុងរឿងសង្គ្រាមព្រាហ្មណ៍ទាំងអស់ ។

នៅប៉ែកខាងត្បូងនៃផ្លូវសសរខាងកើតនោះ មានរូបព្រះ



គណេសឈរ ១ មានដៃ៤ យ៉ាងសិកវិលរេប រូបនេះ របេះមកពីផែនថ្មហោជាង ធ្វើដោយថ្មភក់មានកំពស់ ០ម៧៥ បើវាស់ទាំងផែនផងត្រូវ ០ម៩៥ រកឃើញនៅវត្តព្រះល្វងក្នុងបាត់ដំ-បង ។

មានលោកេស្វរ ១ ឈរ ព្រះហស្ត ៤ បាក់ព្រះហស្តត្រឹមកំភួនទាំងត្រឹមក ឈរនៅលើជើងទ្រនាប់ គេស្គាល់បានដោយមានរូបព្រះអមិតាភនៅលើផ្នួងព្រះកេស សំពត់ដែលស្លៀកនោះមានផ្នត



បណ្តោយចុះក្រោម រូបភាពរបស់រូបនេះតាមធម្មតារូបដែលគេធ្លាប់ឃើញដូច្នោះដែរ ជើងទ្រង់ធ្ងន់ មានកំពស់ប្រហែល ១ម០៥ បានមកពីទីជាមួយគ្នានឹងរូបព្រះគណេស ។

ត្រង់កន្លែងផ្សេងដទៃទៅទៀត មានសុំទ្វារ ១ យ៉ាងល្អធ្វើពីថ្មភក់ពណ៌ក្រហម មានរូបព្រះ ១ អង្គគង់បែបទំនងល្ខោនដៃស្ទាំកាន់ផ្កាឬលំពែងកោងដែលគេធ្វើសម្រួលតាមលំនាំក្បាច់ ។ ព្រះនោះគង់លើក្បាលសិង្ហ ១ ហើយក្បាលសិង្ហនេះកកេរនូវក្បាលដំរី ដែលមានប្រមោយចាប់នូវកន្ទុយសិង្ហទាំងពីរដែលឈរមករួមគ្នា ។ សិង្ហទាំងពីរនេះមានជើងក្រោយជាន់លើកំពែងត្របកឈូក ។ ឯក្បាលសិង្ហធំនោះមានជើងនៅខាងលើត្របៀកដំរី ហើយត្របៀកដំរីក៏មានផ្នតចុះពីលើមកដែរ ។ កំរងផ្កាចេញពី

រង្វះមាត់សិង្ហទាំងពីរនៅខាងស្ដាំនឹងនៅខាងឆ្វេងហើយបង្កងជារង្វង់ចុះទៅក្រោមហើយក្លបខ្វេងឡើងវិញជាពាក់កណ្ដាលរង្វង់មូល ហើយនៅពីលើនេះមានគ្រុឌឈរជើងបំហៀងខ្លួនបំ ។ គ្រុឌនេះដៃបំពីមុខស្លាប ហើយមានក្រញាំជាជើង ឃើញជាមានប្រមុះជាជាដែលមានចំពុះ ។ មានកន្ទុយទំងមានជាយសំ-ពត់ជាស្លាបធ្លាក់ចុះតាមចន្លោះជើងទាំងពីរដល់ផ្ទៃខាងក្រោម ។ មានប្រដាប់ពាក់ត្របៀក និងមានមកុដថ្នាក់ពាក់ផង ។ កំរងផ្កានោះផ្គុំជាបាច់ឡើងដោយបំណងដើមឈូក ។

បុរាណវត្ថុដែលប្រមូលផ្ដុំក្នុងទីពិពិធភណ្ឌវត្ថុពោធិ៍វាលនេះបំណែកខាងក្បាច់ធ្លាក់នោះ នាំឲ្យយើងពិនិត្យសង្កេតខ្លះដោយមិនមែនឥតប្រយោជន៍ ។ ជាដើមយើងត្រូវសំគាល់ថា មានវត្ថុតិចណាស់ដែលរចនាក្នុងសម័យព្រះពុទ្ធសាសនាពី ព. ស. ១០៤៣ ដល់ ១១៤៣ ហើយបំណែកវត្ថុឯទៀតហាក់ដូចជាចូលមកក្នុងសម័យដែលគេកំពុងរាប់អានថ្មភក់ក្រហម គឺទំនងជាក្នុងរវាងព្រះពុទ្ធសករាជ ១៥០០ ។ ក្នុងសម័យនោះដោយអំណាចថ្មដែលក្រៃយ៉ាងធុនល្អក់ខ្ចីផ្ចិតផ្ចង់ទូវក្បាច់ចំឡាក់ឲ្យសំខាន់ឡើង ។

## បញ្ជីបន្ថែមសម្រាប់បុរាណវត្ថុ

ក្នុងទីពិពិធភណ្ឌ វត្តពោធិ៍វាល តាមសេចក្ដីកត់សំគាល់

របស់លោក ផាលេត៍

នៅវត្តពោធិ៍វាល មានរូបអាបិទវី ១ យ៉ាងល្អ គឺជារូបប្រុស ១ កំណាត់ ស្រី ១ កំណាត់ ប៉ុន្តែជាការគួរស្ដាយណាស់ ដែលរូបនេះគ្មានក្បាលនឹងដៃ-ជើង ។ រូបនេះមានដៃតែ ២ សល់នៅតែលើកំផ្លូនដៃស្តាំ ។ ពីរភេទនេះ នឹងសំគាល់តែដោយដើមទ្រូង នឹងដោយសំពត់ស្លៀក ព្រោះកន្លែងឯទៀតបាក់បាត់អស់រលីង ។ គ្រឿងប្រដាប់កាយនឹងជាយសារុងសំពត់ដែលសំយុងដូចគ្នានឹងប្រដាប់សម្រាប់រូបឯទៀតធម្មតានោះដែរ ។ គ្រឿងប្រដាប់កាយនោះគឺ កងកនឹងកងដៃ ហើយសំពត់ដែលស្លៀកនោះមានវិតភ្ជាប់ដោយខ្សែក្រវាត់ ។ កងកធ្វើមានកម្រាស ២ ជាន់ ហើយជមស្រួប



បុះមកបូលក្នុងបន្លោះដោះទាំងពីរ ហើយមានផ្កាតូប ១ នៅ
កណ្ដាលមានត្របក ៤ ក្លែប ៤ ជ្រុងពៀប ។ បន្ទះកណ្ដាល
នៃកងកនោះមានធ្វើជាសន្លឹកឈើ ៣ ជ្រុងជាជួរ ។ ក្នុងជួរលើ
នោះមានស្លឹកតូចៗ ជួរខាងក្រោមនោះស្លឹកឈើធំៗជាង ហើយ
មានបុងស្រួបផ្ដោះទៅកណ្ដាល ។

បំណែកកងដៃមានផ្កា ១ នៅជាកណ្ដាលរាង ៤ ជ្រុងពៀប

ខ្សែក្រវាត់នោះរាង ៤ ជ្រុងទ្រវែងហើយជុំមូល មានបន្ទះ
ពងត្រីនៅខាងលើមានខ្សែហោមធ្វើជាស្លឹកឈើដំរៀបគ្នាគ្រាន់តែ
ជាហេតុឲ្យដឹង ។

នៅមានផ្ចិត ២ ហើយងផ្ចិតធ្វើជារន្ធ ១ រាងដូបភ្នែកនៅ
កណ្ដាលខ្សែធ្នូត ដែលធ្លាក់ចុះពីលើមក ។

ប៉ែកខាងស្ដាំភេទជាប្រុស សំគាល់បានដោយមានដោះ
រាប ហើយមានបុងដោះនៅជាកណ្ដាលស្នាមបុប ១២ ដែល
គេធ្វើជារោម ជើងលាតទទេនៅខាងប៉ែកខាងក្រោមសំពត់ ។

ហើយសំពត់នេះនៅជាយខាងក្រោមមានខ្សែ ៣ មានរបាផា ស្រទាប់ផ្កា ៣ ស្រទាប់ គ្រាន់តែជីកជាខ្សែៗ ឯក្បាលខ្សែក្រ-វាត់នៅពីខាងក្រោយខ្នង ក្បាលខ្សែក្រវាត់ ១ បំហៀងធ្វើជាក្បាច់ស្លាបមេអំបៅ ។

ប៉ែកខាងឆ្វេងដែលជាស្រីនោះ មានដោះមូលក្បិតួបល្មម



ហើយក្បាលដោះហាក់ដូចជារិលរេចអស់ សំពត់ដែលស្លៀកនោះបែបជាសារុងគ្មានបំជាយ ហើយវាងរីកចុះទៅក្រោម ។ ពីខាងមុខមានជាយសំយុងវែងចុះក្រោមដែលគេទុកដាក់បានហៅជាផ្នត់សំពត់ធ្លាក់ចុះមកជា ៣ ជាន់ ។

កំពស់រូបដែលសល់នៅប៉ុន្មានត្រូវ ០ᴹ៥៥ រូបនេះទំនងជាសាងក្នុងរវាង ព.ស. ១៥០០ ឆ្នាំ គេរកឃើញនៅក្នុងព្រៃក្នុងដំបន់សិរីសោភ័ណ



រូប ១ ទៀតជារូបព្រះព្រហ្មឈរ មានក្បាល ៤ នឹងដៃ ៤ មានដៃ ១ខ្លះបាក់ត្រឹមកខ្លះបាក់ត្រឹមកំភួន ។ ក្បាលទាំង ៤ នោះមានមុខរបនាយ៉ាងថ្លិតថ្លង់ មានមាត់តូចហើយបបូរមាត់ក្រាស់ ច្រមុះត្រង់រាងខុបយ៉ាងស្រាល ។ ភ្នែកបើកធំ ៗ មានត្របកភ្នែកជាខ្សែ២ជាន់ ហើយមើលឃើញប្រស្រី ចិញ្ចើមរាងកោងបន្តិច ។ មានពុកបង្កាត់ខ្ទាំងពីជើងសក់ចុះមក ហើយប្រជុំស្រួបក្រោមចង្កា ត្របៀកដាច់ពីគ្នា មានបោះប្រហោង សំរាប់បំពាក់គ្រឿងមែនខែន ។

ផ្នូងសក់ប្លូងក្រប្លួបឡើងទៅលើជា ៤ ផ្នូង មានបំណងរិតភ្ជាប់គ្នាពីខាងក្រោម ។

រាងភេរបស់រូបនេះល្អទាំងអស់ស្មើរតែគ្មានកកិតអ្វី ។ ផ្ចិតតូប ដោះនៅឃើញច្បាស់ ពោះរាងសំអោក ។

រូបនេះស្លៀកសំពត់មានជាយពីរជាន់ ហើយមានខ្សែក្រវាត់ ។

ជើងគេរបនាមិនល្អ កជើងជុំវិញសំប៉ើមហើយរាងធ្ងន់ហើយមានប្រដាប់ទប់ពីខាងក្រោយទៀត ។ ជើងតូបហើយមានម្រាមមិនស្មើគ្នា ។ រូបនេះឈរនៅលើផែនថ្មមូល ១ លាតឥតក្បាច់ ខ្សែបន្ទាត់កាត់កណ្ដាលប្រវែង ០ម៣៥ ហើយកម្រាស់៩សង្ទីម៉ែត្រ ។

រូបនេះធ្វើពីថ្មភក់យ៉ាងម៉ដ្ឋ ។ កំពស់ទាំងមូល ១ម៤៤ បានមកពីភូមិត្នោត ស្រុកល្វា ។

នៅមានរូបព្រះឥស្វរ ១ ទៀតប្អែកនៅនឹងសសរ ។ រូបនេះនៅគ្រប់ទាំងមូល មានដៃ ២ ។ ជើងទាំង ២ ដែលជាប់នៅនោះគេដាក់ប្អែកនៅសសរដែលទល់មុខគ្នា ។

ក្បាលមានពាក់ក្បាំង នឹងផ្នួងសក់មូលធំតូបឡើងទៅលើ ។ មុខរាង ៤ ជ្រុង មានពុកបង្កាត់ទ្វជុំវិញ បង្ការាង



ប្រែក ហើយពុកបង្កាមកផ្គុំគ្នានៅក្រោមបង្កាញោបឡើងលើ ។ ភ្នែកបើកធំ មានប្រស្រីហើយត្របកភ្នែក ២ ជាន់ធ្វើជាខ្សែ ។ រោមចិញ្ចើមត្រង់ ស្ទើរតែមិនក្រឡោតផុតសាច់ ។ នៅកណ្ដាលថ្ងាសមានភ្នែក ១ ទៀត ដែលគ្រាន់តែធ្វើជាស្នាមសំគាល់ ។ ច្រមុះត្រង់ បបូរមាត់មានពុកមាត់យ៉ាងស្ដើងអម ។ ទងត្រចៀកយារបុះ ហើយចោះរន្ធសម្រាប់បំពាក់គ្រឿងមែនទែន ។

ឯក្បាំងមួលនោះមានបំឡុកជ្រៅជាងធម្មតា ។

មានសក់ចាក់កណ្ដាញ់ ផ្នួងសក់រាងមូលរីកពីក្រោមទៅលើ ។ ពីខាងលើផ្នួងសក់មានក្រវិលបែបបង្កក្ដោបរបនាជាផ្កា ៤ ក្លែប ។ ក្បាំងនេះមានបំណង់នៅកន្ទួតអួង មានជាបំណងបង់ជារំយោល ។

កធំហើយខ្លីមានផ្នត់លំអ ៣ ជាន់ ។ ដៃរាងស្គមបន្តិចហើយបត់បន្តិចឡើង ។ ដៃស្ដាំនោះមានមេដៃនឹងចង្អុលដៃ

ផាប់គ្នា បាតដៃផ្កាប់ទៅខាងដី ម្រាមឯទៀតសុទ្ធទ្រង់បត់បន្តិច ក្នុងសណ្ឋានសន្ទា ។ ដៃឆ្វេងមានសណ្ឋានបែបគ្នា ប៉ុន្តែបាតដៃផ្ងារឡើងលើ ។ រាងខ្លួនល្អគ្រាន់បើ មានផ្ចិតជ្រៅ ១ សង្ទីម៉ែត្រ ក្បាលដោះធ្វើឃើញច្បាស់ ហើយមានពោះ ៨ កន្លែងជុំវិញ ។

សំពត់មានផ្នត់យ៉ាងល្អិត មានជាយពីរជាន់ ។ នៅខាងខ្នងឃើញកន្លែងផុតជាយសំពត់ ហើយមានក្បាលខ្សែក្រវាត់ ៤ ធ្នឹងទ្រវែង ។

ជើងតូចមើលឃើញស្នាមផ្អឹងខ្នង នៅក្បាលជង្គង់ឃើញមានប៉ោងចេញយ៉ាងស្រាល ។ ម្រាមជើងមិនស្មើគ្នា ហើយជើងជាន់លើជុំប្ញ ១ រាង ៤ ជ្រុងទ្រវែង បណ្ដោយ ៣២ សង្ទីម៉ែត្រ ទទឹង ៣២ សង្ទីម៉ែត្រ កម្រាស់ ៦ សង្ទីម៉ែត្រកន្លះ ។

នៅមានគ្រឿងសំគាល់ជាបង្ហើយក្នុងរូបនេះទៀត គឺក្របកដៃទាំងអស់មានឃើញស្នែកជាផ្នត់ ៗ មើលឃើញច្បាស់ ។

រូបនេះធ្វើពីថ្មភក់ប្រផេះក្រមៅ កំពស់ប្រហែល ១ម៣០ មិនគិតទ្រនាប់ សាងក្នុងរវាង ព. ស. ១៥០០ ឆ្នាំ បានមកពីឃុំសឿ ស្រុកល្វា ។




ព្រះពុទ្ធរូបជនាយីប៉ុន

## សេចក្តីឧទ្ទិស្សដល់សេចក្តីប្រែជាភាសាខ្មែរ

...គឺជាមិត្រចិត្ត ដែលភ្ជាប់ប្រទេសយីប៉ុន ដែលកាន់ព្រះពុទ្ធសាសនា មកនឹងស្រុកខ្មែរដែលកាន់ព្រះពុទ្ធសាសនា នឹងជាសេចក្តីយ៉ាងធម្មតាមិនថ្លៃថ្លាជ្រៅជ្រះ តែជាពន្លឺយ៉ាងពិតប្រាកដរបស់ព្រះពុទ្ធសាសនាស្រុកយីប៉ុន ដែលខ្ញុំពេញចិត្តនឹងប្រគេនដល់ព្រះភិក្ខុសង្ឃទាំងឡាយក្នុងកម្ពុជប្រទេស ។

ត· បូណ្ណ

# រឿងព្រះពុទ្ធសាសនារបស់យីប៉ុន

៖សោតបុណ្ណ រៀបរៀង ក្រម្ការ ដុំ-មៅ ស្រង់ដោយអន្ទើមកប្រែជាភាសាខ្មែរ ។

## ផ្នែកទី ១

## ការត្រាស់ដឹងរបស់ព្រះ សិត្តតៃសិ

តាំងពីរវាង ៣០០០ ឆ្នាំកន្លងមកហើយ នៅក្នុងស្រុកឥណ្ឌៀ ១ កន្លែងដែលទឹកទន្លេគង្គសាយភាយទៅដល់ នោះមានពួកអារ្យមកពីទិសពាយ័ព្យមកតាំងជានគរ នៅក្នុងទីនោះ ព្រោះទីនោះជាកន្លែងដែលធ្វើស្រែចំការបានផលល្អបរិបូណ៌ ។ ក្នុងទីនោះមានប្រាសាទសម្រាប់ស្តេចជាច្រើនអង្គ ។

នៅទីនោះហើយដែលមានច្បាប់ម្យ៉ាងហៅថាច្បាប់ដែកចាត់បែកមនុស្សទៅជាបួនពួកដាច់ស្រឡះពីគ្នា គឺជាដំបូងពួកព្រាហ្មណ៍ដែលត្រូវមើលត្រូវសូត្រនឹងត្រូវបូជា បន្ទាប់មកពួកសិត្តិរ (ខត្តិយ) ដែលជាម្ចាស់ដីនឹងជាម្ចាស់អំណាច តមកទៀតពួកពិស (វេស្ស) ដែលជាអ្នកធ្វើជំនួញ ហើយក្រោយបំផុតមានពួកសុទរ (សូទ្រ) ដែលជាពួកបាវព្រះធរណី ។

នៅទីនោះហើយដែលពួកព្រាហ្មណ៍តាំងគោរពនូវលោក នឹងព្រះផ្សេងៗ ក្នុងលោក ដូចយ៉ាងព្រះព្រហ្ម ព្រះអាទិត្យព្រះចន្ទ្រ ទឹកនឹងភ្លើងជាដើម ។

នៅទីនោះហើយដែលកើតមានបែបគោរពសាសនាដល់ទៅ ៩៥ ពួក មានពួកគ្រូទាំង ៦ ជាដើម ។

នៅទីនោះហើយដែលមានកើតសាសនាថ្មី ១ ឡើងហៅថាព្រះពុទ្ធសាសនា ដែលជាសាសនាកំចាត់បង់នូវការប្រកាន់បែកមនុស្សជាបួនពួកឲ្យបាត់បង់បេញ ។

ក្នុងសម័យមួយ នៅប្រទេសកោសរ មានពួកអារ្យ មកតាំងនៅដោយមាន ក័នស្ទឹ ជាមេ ហើយមកតាំងទីក្រុងឈ្មោះអយោធិយា ។ ស្ដេចក័នស្ទឹ មានរាជបុត្រា ៤ អង្គ ព្រះរាជបុត្រាទាំង ៤ អង្គនេះ មាន ១ ថ្ងៃក៏យាងចេញអំពីនគរទៅដោយមិនសប្បាយព្រះទ័យនឹងកលឧបាយរបស់ព្រះស្នំនៃព្រះវររាជបិតា ។ លុះយាងក្នុងព្រៃជាយូរថ្ងៃវង្វេងមិនដឹងទីដំបន់ណាក៏បានជួបនឹងតាបស ១ អង្គ មានសម្បុរសាច់នោះក្រហមឈ្មោះ

ថា កបិរ លុះតាបសនោះបានដឹងជាព្រះកុមារទាំង ៤ ព្រះអង្គជាបុត្រាក្សត្រ ក៏ថ្វាយដីទាំងប៉ុន្មានជារបស់គាត់មក ។

ព្រះកុមារទាំង ៤ ព្រះអង្គក៏តាំងសាងទីក្រុង ១ ឡើង ឲ្យឈ្មោះថា កបិរពោ ដើម្បីជាទីរឭកដល់ឈ្មោះតាបសដែលបានថ្វាយដីមក ។ លុះបានតាំងទីក្រុងស្រួលបួល មានសេនាយោធាមាត្យសព្វគ្រប់ហើយ ក៏តាំងព្រះកុមារជាបងឲ្យឡើងគ្រងរាជ្យជាស្ដេចក្នុងក្រុងនោះ ក្សត្រ ៤ អង្គនេះបានយកប្អូនស្រីបង្កើតទាំង ៤ អង្គជាព្រះអគ្គជាយា ហើយក៏តាំងលើកព្រះវង្សនេះឡើងឲ្យហៅថា សក ។

លុះក្រោយតពីនោះមក ព្រះកុមារដែលបន្ទាប់ពីព្រះរៀមតាំងប្ដេមគំនិតបែកពួកសក១បំបែកឲ្យឆ្លងត្រើយស្ទឹងរោហិនីទៅតាំងទីក្រុង ១ នៅលើត្រើយខាងឆ្វេងនៃស្ទឹងនោះឲ្យឈ្មោះថា កោរិ ដែលទៅជាទីក្រុងយ៉ាងស្កុកស្គម្ភ១ ក្នុងប្រទេសថ្មី ។ ដើម្បីនឹងឲ្យបានត្រកូលនេះគង់ឈាមនៅជាបរិសុទ្ធ នោះមានតាំងច្បាប់បញ្ញត្តិថាត្រកូលស្ដេចទាំងពីរនគរនេះត្រូវតែផ្សំផ្គុំគ្នាទៅវិញទៅមកកុំឲ្យលាយឡំនឹងពូជដទៃ ។

ក្នុងរវាង ៦០០ ឆ្នាំ មុនគ្រិស្តសករាជ ទីក្រុងកបិរជោ ដែលនៅជាបន្លោះដែនកោសរ ដែនមគធ ក្រុងវៃសាលី ស្ទឹងរោហិនីនឹងស្ទឹងរប្តិ នោះមានទំហំប្រហែល ៥០០ យោជន៍ ៤ ជ្រុង ។ នៅក្នុងក្រុងនោះហើយដែលស្តេចជោហ័នសោយរាជ្យ ស្តេចនេះជាព្រះរាជបុត្រច្បង ក្នុងព្រះរាជបុត្រទាំង ៧ នៃស្តេចសិម្ហហានុ នឹងព្រះនាងកញ្ចន ។

ព្រះចៅជោហ័ន បានយកព្រះអនុជរូមអយ្យិកា ពីរព្រះអង្គ ក្នុងត្រកូលស្តេចក្រុងកោរិជាព្រះមហេសី គឺព្រះនាងប្រជាបតី នឹងព្រះនាងមាយា ដែលប្រកបដោយលក្ខណាយ៉ាងប្រសើរ ។ ទ្រង់បានព្រះរាជបុត្រពីរព្រះអង្គអំពីព្រះនាងប្រជាបតី គឺព្រះរាជ-បុត្រី ១ អង្គទ្រង់នាម រូបនន្ទា នឹងព្រះរាជបុត្រា ១ អង្គទ្រង់នាម នន្ទ ។ ឯព្រះនាងមាយានោះមានប្រាថ្នាចង់បានព្រះរាជបុត្រ ដូចម្តេចក្តីក៏មិនបានឡើយ ។

លុះដល់មកព្រះជន្មាយុ គំរប់ ៤៥ ឆ្នាំ ព្រះនាងក៏តាំងទ្រង់គភ៌ ហើយវេលាដែលគភ៌ចាស់ខែ ព្រះនាងក៏យាងទៅគង់ឯសួន វិម្មិនិ ក្នុងព្រះដំណាក់ ១ ដែលជារបស់សម្រាប់ក្សត្រ ។

មកក្នុងនគររបស់ព្រះវរបិតាព្រះនាង ដែលនៅជាបន្លោះនគរព្រះស្វាមីនឹងព្រះបិតា ដែលព្រះនាងយាងមកគង់ក្នុងទីនេះ គឺដើម្បីកុំឲ្យមានប្រទូស្តកមន្ទិលដល់ព្រះបរមរាជវាំងដោយការប្រសូតបុត្រ ។

នៅថ្ងៃទី ៨ នៃខែទី ៤ នៅវេលាដែលព្រះនាងកំពុងតែយាងក្រសាលក្រោមម្លប់ឈើ នោះទ្រង់បណ្ដាលឈឺព្រះឧទរនឹងប្រសូតព្រះរាជបុត្រ ព្រះនាងក៏ប្រាសថ្លៃទៅគល់ឈើឈ្មោះមុជុ គឺដើមឈើផ្ចិតខុក្ខ ហើយក៏ប្រសូតព្រះរាជបុត្រមកដោយឥតឈឺចាប់ឡើយ ព្រះរាជបុត្រនេះហើយដែលបានត្រាស់ជាព្រះអរហំសម្មាសម្ពុទ្ធ ជាគ្រូលើមនុស្សនឹងទេវតាទាំងអស់ ។

ក្នុងវេលានោះគេបានដង្ហែព្រះនាងនឹងព្រះកុមារទៅក្នុងនគរកបិលវត្ថុវិញ ព្រះអសិតតាបសបានឈ្ងោកពិនិត្យមើលសព្វសព៌ាង្គកាយព្រះកុមារក៏ឃើញនូវមហាបុរិសលក្ខណៈទាំង ៣២ យ៉ាងនឹងអនុព្យញ្ជនទាំង ៨០ យ៉ាង សម្រាប់អ្នកបុណ្យ ហើយក៏បន្លឺនូវពិភេទឡើងថា ក្នុងពួករាជត្រកូលទាំងអស់ ព្រះកុមារនេះហើយមានបុណ្យបារមីជាងគេទាំងអស់ ។ បើនៅជាយរា-

វាសនឹងបានបង្ក្រាបស្រុកឥណ្ឌៀទាំង ៥ បំណែក បើចេញទ្រង់ផ្នួសនោះនឹងបានជាម្ចាស់ត្រៃលោកដោយពិត ៗ ឱខ្លួនអញ ជរាណាស់ទៅហើយនឹងមិនបានទាន់ជាប់ទៅជាមួយឡើយ ។

ដោយហេតុទំនាយនោះហើយ ទើបថ្វាយព្រះនាមព្រះកុមារជាព្រះសិទ្ធ ដែលមានន័យថា ឥស្សេរជោ ឬ បំពេញប្រក្បល្អគ្រប់យ៉ាង ហើយមានបន្ថែមព្រះគោរម្យភ្ជាប់ទៅទៀត ជាតែសិ ឬព្រះអង្គម្ចាស់ ។

លុះព្រះកុមារប្រសូតបាន ៧ ថ្ងៃ ព្រះនាងមាយាក៏ទ្រង់សោយព្រះទិវង្គតទៅកើតក្នុងទីថ្មីទៀត ។

* *

*

ព្រះកុមារសិទ្ធតែសិនោះ ព្រះនាងប្រជាបតីទទួលយកទៅថែរក្សា ។ តមកបានចាត់ការបង្រៀនវិជ្ជាព្រះកុមារគ្រប់យ៉ាង គឺព្រាហ្មណ៍ ភទ្ទិបង្រៀនវិទ្យាសាស្ត្រទាំង ៥ យ៉ាង ព្រាហ្មណ៍វិស្វមិត្របង្រៀនវេទ ហើយព្រាហ្មណ៍ ក្សាន្តិទេវា បង្រៀនក្បួនទាហាន ។

ព្រះរាជកុមារមានប្រាសាទ ៣ សម្រាប់រដូវក្ដៅ ១ រដូវរងា ១ និងរដូវភ្លៀង ១ ។

ប៉ុន្តែព្រះរាជកុមារទ្រង់មិនត្រេកដោយគ្រឿងដំរេកសម្រាប់វ័យរបស់ព្រះអង្គឡើយ ទ្រង់តែងតែយាងទៅពិចារណាហើយភាវនាក្រោមម្លប់ឈើក្នុងសួនច្បាររបស់ព្រះអង្គ ។

ព្រះបាទសុទ្ធោទនទ្រង់មានព្រះវិតក្កក្នុងព្រះរាជហឫទ័យ និងទំនាយរបស់អសិតតាបសណាស់ ដើម្បីនឹងទាក់ព្រះរាជបុត្រឲ្យតាំងនៅជាប់ក្នុងភេទជាឃរាវាស ទ្រង់តាំងចាត់ការជាគ្រឿងសប្បាយយ៉ាងច្រើនប្រការ ។

ការរាំរែកប្រគំតូរ្យតន្ត្រីនិងធ្វើបុណ្យផ្សេងៗ បន្តគ្នាក្នុងព្រះបរមរាជវាំងបំបិទមិនឲ្យឃើញនូវជរាព្យាធិនិងមរណៈ ។ ទ្រង់ចាត់ប្រមូលបុត្រីពួករាជត្រកូលទាំងអស់ដែលល្អៗ យកមកឲ្យនៅគាល់បំរើជាប្រក្រតី ហើយអស់ទាំងបុត្រីអ្នកនគរដែលល្អៗទាំងប៉ុន្មានក៏ប្រមូលយកមកនៅបំរើទាំងអស់ តាមសេចក្ដីប្រាថ្នាព្រះកុមារ ។

លុះដល់ទ្រង់ចំរើនវ័យវិឌ្ឍនាការគ្រប់ ១៧ ឆ្នាំ ព្រះវររាជ-បិតាតាំងផ្សំផ្គុំព្រះនាងយសោធរាជាព្រះអនុជរួមអយ្យិកា ជាបុត្រីព្រះចៅក្រុងកោលិយ៍ប្រកបដោយលក្ខណគ្រប់យ៉ាង ឲ្យធ្វើជាព្រះអគ្គមហេសី ។ ព្រះសិទ្ធត្ថសិក៏គង់នៅជាមួយនឹងព្រះនាងយសោធរាជរាបដល់ព្រះជន្មបាន ២៩ ឆ្នាំ ។

*

* *

ក្នុងឆ្នាំនោះហើយ ព្រះសិទ្ធត្ថសិទ្រង់ឃើញនិមិត្ត ៤ ប្រការ ។ ទ្រង់ឃើញអ្នកសុំទានម្នាក់បាក់ធ្មេញគ្រហុបបង្គាញ់រតត្រាក់ហើយក៏បានជ្រាបនូវជរា ទ្រង់ឃើញមនុស្សជំងឺមានសំឡេងខ្សាបខ្សាវ ហើយក៏បានជ្រាបនូវព្យាធិ ទ្រង់ឃើញខ្មោច ១ មានភ្នែកសំឡឹងគ្រលួង ក៏បានជ្រាបនូវមរណា ទ្រង់ឃើញអ្នកបួស ១ រូបមានព្រះភ័ក្ត្រយ៉ាងស្ងប់ឥតសៅហ្មង ក៏បានជ្រាបនូវជ័យជំនះរបស់វិញ្ញាណក្នុងជរាព្យាធិនឹងមរណា ។

រួចពីនេះទ្រង់ចូលទៅទូលព្រះវររាជបិតាថា សូមព្រះវររាជបិតាមេត្តាប្រោសអនុញ្ញាតទូលព្រះបង្គំដើរចេញអំពីព្រះ

អង្គ ទូលព្រះបង្គំបានឃើញច្បាស់នូវជរាព្យាធិ និងមរណ ហើយ សូមមេត្តាអនុញ្ញាតឲ្យទូលព្រះបង្គំចេញឆ្ងាយពីស្រុក ទេសដើម្បីស្វែងរកនូវគ្រឿងរំលត់ទុក្ខ ។

ព្រះបាទសោហ៍ន ទ្រង់តបវិញដោយសំឡេងញ័រប៉ុផុកថា នែកូនមាសអាពុក ខ្លួនអ្នកមានភ័ព្វមានសំណាងបំផុតក្នុងទី នេះ ដូចម្តេចហើយក៏គិតបោះបង់ប្រាសាទរាជស្ថានហោលព្រម ទាំងពួករាស្ត្រប្រជាទាំងអស់ដែលមានសេចក្តីស្រឡាញ់គោរព កោតខ្លាចអ្នកទាំងអស់គ្នា ជាមុននឹងគិតដល់ទុក្ខរបស់មនុស្ស ទាំងអស់ក្នុងលោកត្រូវអ្នកគិតដល់ទុក្ខបិតាសិន ។ ត្រូវកូនកុំ ទៅណា ខ្លួនអាពុកចាស់ហើយ អាពុកប្រគល់រាជសម្បត្តិឲ្យ អ្នកទាំងអស់ ហើយខ្លួនអាពុកចេញទៅបួសជាជំនួសអ្នក វិញ ។

ក្នុងវេលានោះព្រះសិទ្ធត្ថគ្រាន់តែទូលថាដូច្នេះ

– ព្រះវរបិតា ការនេះកូនបានប្តេជ្ញាជាស្រេចហើយប៉ុន្តែកូន នឹងបន្តួយថ្ងៃដែលត្រូវចេញទៅ បន្តិចទៅទៀត ។

✡

✡ ✡

ក្នុងពេលជាមួយនោះ ព្រះនាងយសុទរ ប្រសូតព្រះរាជ-បុត្រា ១ ព្រះអង្គ ហើយក៏បានថ្វាយព្រះនាមព្រះឱរសនោះថា រាគោរ ។ ទាំងអស់គ្នាក្នុងព្រះបរមរាជវាំង ក៏ត្រេកសប្បាយ លេងសើចអឺអ៊ឹងក្នុងទីនោះ តែព្រះមហាសត្វ ១ ព្រះអង្គទ្រង់ពិ-ចារណាថា៖

– ឥឡូវអញបានបុត្រា ១ ហើយ ៗ បុត្រានេះនឹងធ្វើឲ្យព្រះវរបិតាស្បើយទុក្ខនូវវេលាដែលបាត់អញទៅ ។ ក្នុងវេលានេះ អញនឹងចេញទៅបាទហើយ ។

ដោយហេតុនេះហើយ ទើបនៅយប់ទី ៨ នៃខែទី ១២ ព្រះសិត្តតៃស ទ្រង់ក្រោកឡើងពីព្រះបន្ទំ យាងកាត់ព្រះដំណាក់ដែលមនុស្សដេកស្ងាត់ប្រៀប បង្គាប់ឲ្យចងអាឥកណ្ឋកជាសេះសំឡាញ់របស់ព្រះអង្គ ឈ្មោះថា ចាឲ គឺជាស្តេចសេះ ហើយទ្រង់បំផាយចេញទៅជាមួយនឹងឆន្នពីក្រោយ ។

រឿងព្រះពុទ្ធសាសនារបស់យីប៉ុន

លោក បូណ្ណ រៀបរៀង ក្រមុារ ជុំ-ម៉ៅ ស្រង់ដោយអនុវត្តនៀមកប្រែជាភាសាខ្មែរ

## ផ្នែកទី ១

## ការត្រាស់ដឹងរបស់ព្រះសិទ្ធត្ថៃសិ

— ២ —

— ៥ —

ព្រះសិទ្ធត្ថៃសិ ទ្រង់ឈប់នៅមាត់ត្រើយម្ខាងនៃស្ទឹង អវិធិ នៅជាយព្រៃយ៉ាងជ្រៅ ។ ទ្រង់កាត់ព្រះកេសា ទ្រង់ផ្លាស់ពត់កញ្ចាស់កណ្ដាចសម្រាប់តាបសជាអ្នកសុំទាន ប្រគល់គ្រឿងអលង្ការសម្រាប់ក្សត្រទៅឲ្យនាយឆន្ន ហើយទ្រង់មានព្រះបន្ទូលទៅកាន់ថា:

— នែឆន្នសំឡាញ់ អ្នកដែលនៅជាមួយតែងតែព្រាត់ប្រាស គ្នាជាធម្មតា បើមិនឆាប់ក៏យូរ ។ ចូរអ្នកត្រឡប់ទៅវិញចុះ ហើយប្ដាយគ្រឿងប្រដាប់ដែលឥតប្រយោជន៍នេះទៅព្រះវរបិតាអញ ។

លុះឆន្នយំដើរវិលទៅនគរវិញទៅ ព្រះសិទ្ធត្ថតែសក់យោង ចូលទៅក្នុងព្រៃទៅ ។

✲ ✲

✲

ទ្រង់បានជួបនឹងតាបសម្នាក់ ឈ្មោះ ភគវិត ដែលមានគោលធម៌ គឺសេចក្ដីទុក្ខលំបាកដែលបានក្នុងជាតិនេះ នឹងបានទៅជាសេចក្ដីសុខជាភ័ព្វសំណាងក្នុងជាតិមុខ ហើយក៏ប្រព្រឹត្តខ្លួនឲ្យលំបាកយ៉ាងតឹង ជាអត្តកិលមថានុយោគ ។

ព្រះសិទ្ធត្ថទ្រង់សួរថា បុះប្រយោជន៍អ្វីដែលធ្វើខ្លួនឲ្យលំបាកយ៉ាងនេះ? តាបសតបវិញថា ប្រយោជន៍ឲ្យបានទៅកើតក្នុងទេវលោកជាទីសប្បាយឥតទុក្ខ ។

ប៉ុន្តែទ្រង់មានព្រះបន្ទូលបញ្ចាក់ទៅវិញថាៈ

— ឧបមាថាបានទៅកើតនៅទេវលោកមែនប្រកបដោយភោគសម្បត្តិគ្រប់យ៉ាង បានសេចក្ដីសុខសេចក្ដីសប្បាយ តើបំណងដែលធ្លាក់ទាក់ឲ្យកើតពីជាតិ ១ ទៅជាតិ ១ នោះតើដាច់បាត់ឬទេ? អ្នកមិនឃើញថាសេចក្ដីប្រព្រឹត្តិរបស់អ្នកនេះ មិនមែនអ្វីក្រៅអំពីប្រមូលយកទុក្ខទៅចងភ្ជាប់នឹងទុក្ខទេឬ? ។

លុះជ្រាបច្បាស់ថាតាបសនេះរកផ្លូវត្រូវមិនឃើញដូច្នេះ ហើយព្រះអង្គក៏យាងឆ្ងាយទៅគង់នៅក្រោមម្លប់ឈើ១ ។

☼

☼ ☼

មានរាជបំរើជាច្រើនដែលព្រះបាទជោហ៊ានទ្រង់បាត់ឡាតាមមកអញ្ជើញស្តេចត្រឡប់ទៅវិញ បានដល់ទីបំពោះព្រះភក្ត្រ ហើយក៏ក្រាបទូលថាៈ

– សូមទ្រង់ព្រះមេត្តាប្រោស ព្រះវររាជបិតា ព្រះរាជទេពី នឹងព្រះរាជវាំងទាំងមូល មានសេចក្តីសៅសោកសង្រេងសង្រែទាំងអស់គ្នាដោយព្រះអង្គយាងចេញមកនេះ ។ – ព្រះអង្គមិនស្តេចត្រឡប់ទៅកាន់អ្នកដែលទន្ទឹងព្រះអង្គទេឬអ្វី ។

ក្នុងវេលានោះព្រះសិត្ថទ្រង់តបទៅវិញតែប៉ុណ្ណោះថាៈ

– យើងស្វែងរកនូវសេចក្តីព្រាត់ប្រាសយ៉ាងមិនជាវិលវិលជាមាត្រជាជាងរងទុក្ខយ៉ាងធ្ងន់ ដែលកែខៃមិនបានកើតឡើងដោយការព្រាត់ប្រាសយ៉ាងបិតបេរជានិច្ចនោះ ។

ប៉ុន្តែក្នុងវេលានោះព្រះសិត្ថទ្រង់អនុញ្ញាត ពួករាជបំរើនោះនៅ ៥ នាក់ដើម្បីកំដរព្រះអង្គ ។

ព្រះសិទ្ធត្ថទ្រង់នាំអ្នកកំដររទាំង ៥ នាក់ឆ្លងកាត់ទន្លេគង្គាឆ្ពោះទៅនគររាជគ្រឹះ ដែលជាទីក្រុងនៃប្រទេសមគធ ។

លុះទ្រង់យាងទៅជិតដល់ព្រះបរមរាជវាំង ព្រះបាទពិម្ពិសារទ្រង់ត្រាស់សួរដល់ពួកសេនាមាត្យទាំងឡាយថា ដែលចូលមកក្នុងនគរនោះតើជាអ្នកណា សេនាយោធាទាំងឡាយក៏ក្រាបទូលទៅវិញថា គឺជាព្រះសិទ្ធត្ថតៃសិ ព្រះរាជបុត្រាព្រះចៅក្រុងកបិលវត្ថុ ។ ព្រះបាទពិម្ពិសារក៏ទ្រង់យាងចេញទៅគំនាប់ដោយមធុរវាចាថាៈ – សូមឲ្យទ្រង់យាងមកជាសុខ ហើយសូមឲ្យប្រាប់ហេតុខ្ញុំ អំពីដែលនាំឲ្យទ្រង់បោះបង់បោលព្រះបរមរាជវាំងព្រះវររាជបិតា ។ ប្រសិនបើទ្រង់ប្រញាប់បង់សោយរាជសម្បត្តិ ខ្ញុំនឹងថ្វាយនគរខ្ញុំ ឬប្រសិនបើទ្រង់ត្រូវការធ្វើសឹកសង្គ្រាមខ្ញុំនឹងថ្វាយសេនាអាហារខ្ញុំទាំងប៉ុន្មាន ។

វេលានោះព្រះសិទ្ធត្ថមិនព្រមទទួល ហើយទ្រង់តបវិញថាៈ – សេចក្តីប្រាថ្នាតែម្យ៉ាងរបស់ខ្ញុំគឺកំចាត់បំផ្លាញនូវទុក្ខដែលមានដោយជាតិ ទុក្ខដែលមានដោយជរា ទុក្ខដែលមានដោយព្យាធិ

នឹងទុក្ខដែលមានដោយមរណ ។ ខ្ញុំមិនមែនដើរបេញពីរាជ-វាំងព្រះវរបិតាមកដើម្បីនឹងបំពេញនូវដំរេកទាំង ៥ យ៉ាងសម្រាប់លោកឡើយ ។

ព្រះបាទពិម្ពិសារក៏លុតជង្គង់ប្រណម្យ ហើយទូលអង្វរដូច្នេះថា:

– កាលណាទ្រង់បានសម្រេចសេចក្ដីប្រាជ្ញាហើយ សូមមេត្តាយាងមកប្រោសខ្ញុំផង ។

ព្រះសិទ្ធត្ថ ក៏ព្រមទទួល ។

*

* *

ក្នុងសម័យនោះឯង នៅក្នុងដែនមគធ មានតាបសពីររូប ដែលល្បីល្បាញក្នុងផ្លូវវិជ្ជានឹងក្នុងសេចក្ដីបរិសុទ្ធនៃសីល ។ តាបស១អង្គឈ្មោះ អរាករម ១អង្គទៀតឈ្មោះ ឧទ្ទករាម ។ ព្រះសិទ្ធត្ថ ក៏យាងទៅកាន់សំណាក់តាបសទាំងពីរអង្គនោះដើម្បីពិគ្រោះសួរអំពីប្ញាក់ឈាន ។ ហើយតាបសអរាករម ក៏ពន្យល់មកតាមវិធីដែលធ្លាប់ប្រដៅសិស្សតៗមក តាំងពីកំណើតសត្វរហូតដល់ធ្វើឈានផ្សេងៗ ដែលជាទីនាំទៅកាន់ទី

រលត់ទុក្ខពោលគឺព្រះនិព្វាន ។ ប៉ុន្តែក្នុងវេលានោះព្រះសិត្តតែសិ ទ្រង់មិនព្រមទទួលយកដោយដេញដោលទៅឃើញមិនផុតអំពីសេចក្ដីរលត់ជាតិ ហើយក៏ទ្រង់យាងចេញពីទីនេះទៅពិចារណាក្នុងព្រះអង្គថា ដែលនឹងរកនូវសច្ចឲ្យឃើញនោះត្រូវតែរំពឹងតែដោយព្រះអង្គឯង មិនត្រូវពឹងរកអ្នកឯណាមួយឡើយ ។

ទ្រង់ព្រះចិន្តាដូច្នេះហើយក៏ទ្រង់យាងឆ្លងស្ទឹង នេរញ្ជរាឆ្ពោះទៅកាន់ជើងភ្នំ ពុរោគោពោធិ ទាព្រៃឧរុវេលា ឬ កុគ្យោវិនគឺព្រៃទុក្ករកិរិយា ។ ទ្រង់ចូលសំណាក់ក្នុងទីងងឹត ១ កន្លែងហើយតាំងធ្វើឈាន ។

✲

✲ ✲

នៅទីនោះហើយទ្រង់គង់ផ្គត់ព្រះភ្នែនពែនព្រះបាទមានព្រះជិវ្ហាទល់នូវក្រអូមលើ ហើយទ្រង់ទប់ដង្ហើមចេញចូលមិនឲ្យប្រព្រឹត្តទៅ ទ្រង់សោយអាហារក្នុង ១ ថ្ងៃតែល្ង ១ គ្រាប់នឹងបាយ ១ គ្រាប់ អស់វារ ៦ ឆ្នាំគត់ ។

ពួកបញ្ចវគ្គិយ បានឃើញព្រះអង្គប្រព្រឹត្តយ៉ាងនេះដូច្នេះហើយក៏ធ្វើតាម ហើយបំរុងខ្លួនចាំធ្វើជាសិស្សនៅវេលាដែលព្រះអង្គបានត្រាស់ក្នុងថ្ងៃណា ។

⁂

ព្រះសិទ្ធត្ថតែសិមិនវង្វេងភាន់គំនិតឡើយ ទ្រង់ឃើញថាដែលប្រព្រឹត្តយ៉ាងនេះដូច្នេះ ឥតបានសម្រេចមគ្គផលអ្វីបន្តិចសោះ ក៏ទ្រង់តាំងត្រិះរិះក្នុងព្រះអង្គថា:

– ដែលរកផ្លូវត្រូវឃើញអាស្រ័យដោយប្រាជ្ញា ប្រាជ្ញាកើតឡើងអាស្រ័យដោយឥន្ទ្រិយ៍ប្រព្រឹត្តទៅស្រួល ឥន្ទ្រិយ៍ប្រព្រឹត្តទៅស្រួលបាន អាស្រ័យដោយអាហារ បើដូច្នេះការអត់អាហារមិនមែនជាឧបាយនាំឲ្យរកឃើញសច្ចធម៌ឡើយ ។

ទ្រង់ពិចារណាដូច្នេះហើយក៏ក្រោកឡើងយាងចុះទៅស្រង់ក្នុងស្ទឹងនេរញ្ជរា ។

⁂

ក្នុងសម័យនោះមានស្រីគង្វាលចៀមម្នាក់នៅ ៗ មាត់ស្ទឹងនោះ ឈ្មោះនាងនន្ទាពរ វេលាដែលបានឃើញព្រះសិទ្ធត្ថតែសិហើយនាងក៏ចូលមកថ្វាយបង្គំហើយថ្វាយទឹកដោះ ។

ព្រះសិទ្ធទទួលយកមកសោយក៏មានកំឡាំងពលំឡើង ។ បញ្ចវគ្គិយ បានឃើញដូច្នោះហើយក៏តាំងពិគ្រោះនឹងគ្នាថា ព្រះសមណនេះមិនមែនជាគ្រូយើងទេ ព្រោះផ្លាស់ចិត្តបេញទៅហើយ ហើយក៏នាំគ្នាគេចចោលព្រះអង្គអស់ទៅ ។

វេលាដែលនៅកំព្រាតែ ១ ព្រះអង្គឯង ព្រះសិទ្ធតែសិទ្រង់យាងឆ្ពោះទៅពុទ្ធគយា ក្នុងដែនមគធជនដែល ។ ក្នុងទីនោះមានដើមឈើ ១ ដើមឈ្មោះ ពោធិ៍ជុំ ហើយនៅក្រោមដើមឈើនោះមានបល្លង្កថ្មើមថ្ម ១ ។ ព្រះសិទ្ធតែសិទ្រង់យកស្មៅស្រស់ទៅក្រាលពីលើទើបទ្រង់គង់ ហើយតាំងប្រេជ្ញាក្នុងព្រះអង្គថាៈ

–អញនឹងក្រោកបេញអំពីទីនេះ លុះតែកាលណាបានត្រាស់ដឹង ។ ទ្រង់តាំងវេធ្មើឈានឡើងជាថ្មី ហើយក៏ពិចារណាតែ ១ ព្រះអង្គឯងកាត់បង់នូវវិមុតិសង្ស័យ ហើយក៏បំរើនឡើងដល់ថ្នាក់ដែលបានផ្ចាញ់បង់នូវមារាធិរាជ ។

តមកទៀត ទ្រង់ពិចារណាអំពីជាតិរបស់មនុស្សរៀងតាមបច្ច័យធម៌ ទ្រង់ឃើញច្បាស់នូវសេចក្ដីវង្វេងវិលវល់របស់

សត្វក្នុងវដ្តសង្សារ ទ្រង់ជ្រាបច្បាស់នូវហេតុដែលនាំឲ្យកើតទុក្ខ ហើយបើកនូវផ្លូវដែលរលត់ទុក្ខ ។

ក្នុងពេលនោះព្រះអង្គបានព្រះជន្ម ៣៦ ឆ្នាំ ហើយបានព្រះនាមថា សកមុនីពុទ្ធ ។

៧

នូវវេលាដែលបានត្រាស់បរមាភិសម្ពោធិញាណហើយ ព្រះសម្មាសម្ពុទ្ធទ្រង់ពិចារណាក្នុងព្រះអង្គថាៈ

— តើជាប្រយោជន៍អ្វីនឹងសម្ដែងធម៌ឲ្យសត្វទាំងពួងស្ដាប់ ព្រោះធម៌ដែលអញរកឃើញនេះ ឃើញដោយការតយុទ្ធយ៉ាងពេញទី ។ សេចក្ដីពិតឬសច្ចធម៌ជាកំពូលខ្ពស់ដែលលំបាកនឹងឡើងទៅដល់ ប្រកបដោយអាថ៌កំបាំងយ៉ាងជ្រៅដែលបិទមិនឲ្យឃើញដល់ប្រាជ្ញាស្មារតីរបស់សាមញ្ញសត្វ បើសត្វទាំងឡាយមានសេចក្ដីប្រាថ្នានឹងសេចក្ដីព្យាបាទពាសពេញខ្លួនគ្រប់គ្នាដូច្នេះ កាលណានឹងយល់ធម៌នេះបាន ។

ព្រះអង្គគង់នៅក្រោមដើមពោធិ៍ទុំ នោះកំណត់ ៧ ថ្ងៃ ៣ ដង តាំងព្រះទ័យថានឹងនៅស្ងៀមមិនសម្ដែង ។

ក្នុងវេលានោះព្រហ្មាពោរន្តនោ ដែលជាអាពុកសត្វទាំងអស់ ហោះចុះពីលើមេឃមកលុតជង្គង់នៅចំពោះព្រះភក្ត្រព្រះអង្គ លើកដៃប្រណម្យ ហើយទូលថាៈ

– បពិត្រព្រះបរមសាស្ដាចារ្យ សូមព្រះអង្គមេត្តាសម្ដែងធម៌ប្រោសសត្វទាំងឡាយ ដ្បិតសត្វទន្ទឹងព្រះអង្គណាស់ កាលណាព្រះអង្គទ្រង់សម្ដែងនឹងមានសត្វជាច្រើនយល់នូវធម៌របស់ព្រះអង្គ ។

ព្រះសម្មាសម្ពុទ្ធទ្រង់តបទៅវិញថាៈ

– ម្នាលព្រហ្ម តថាគតពិចារណាអំពីសេចក្ដីលំបាកដែលតថាគតបានទ្រាំមកទាំងប៉ុន្មាន ហើយក៏លែងចង់សម្ដែងធម៌ប្រោសសត្វសោះ ។ ប៉ុន្តែតាំងពីថ្ងៃនេះតទៅតថាគតបើកទ្វារឱ្យទាំងអស់គ្នា អ្នកណាដែលមានត្រចៀកចូរឮចុះ ហើយអ្នកដែលបានឮសំដីតថាគតចូរឱ្យបានសេចក្ដីរីករាយចុះ ។

⁂

ក្នុងវេលានោះព្រះសម្មាសម្ពុទ្ធទ្រង់ក្រោកឡើង ហើយយាងឆ្ពោះទៅកាន់ភ្នំមេរុដើម្បីឱ្យជួបនឹងតាបសអរនឹងឧទោរ

លុះបានជ្រាបថាតាបសទាំងពីរមរណភាពទៅហើយទ្រង់ក៏ត្រឡប់យាងទៅឯពារាណសីវិញ ។ ឆ្ពោះកាន់ទី ១ ដែលហៅថា ភោកុយោធ ឬព្រៃម្រឹគ ដែលទ្រង់ប្រាកដក្នុងព្រះទ័យថា ប្រាស់ជានឹងជួប តាបស ៥ អង្គដែលរត់ចោលព្រះអង្គមិនខាន ។

លុះបានឃើញព្រះអង្គយាងមកពីចំងាយ តាបសទាំង៥ ក៏គិតថា:

— សមណៈនេះមិនសមគួរនឹងសម្តែងធម៌ឲ្យយើងស្តាប់ឡើយ ព្រោះធ្វើឲ្យដាច់នូវទុក្ករកិរិយាបង់ ។

តាបសទាំង ៥ ក៏គិតរត់គេចទៅទៀត ។

ប៉ុន្តែព្រះសម្មាសម្ពុទ្ធទ្រង់ឃាត់ទុកបានដោយព្រះមធុរវាចា ហើយព្រះអង្គទ្រង់សម្តែងនូវសច្ចទាំង ៤ ប្រការ បើកផ្លូវព្រះនិព្វានដល់តាបសទាំង ៥ អង្គ ។

នេះហើយអាការដែលព្រះធម្មចក្រវិលទៅជាដំបូង ។

⁂

តាំងពីថ្ងៃនោះមក ព្រះបរមសម្មាសម្ពុទ្ធទ្រង់សម្តែងធម៌ប្រោសសត្វទាំងពួង ។ ទ្រង់សម្តែងធម៌ឈ្មោះកោគោនក្បៀ

កំណត់ ២១ ថ្ងៃ ទ្រង់សម្តែងធម៌ឈ្មោះ អគុ-ក្សោ កំណត់ ១២ ឆ្នាំ ទ្រង់សម្តែងធម៌ឈ្មោះ ហោទោ-ក្សោ កំណត់ ៨ ឆ្នាំ ទ្រង់សម្តែងធម៌ឈ្មោះ ទៃហន្សុ ក្សោ កំណត់ ២០ ឆ្នាំ ទ្រង់សម្តែងធម៌ឈ្មោះ ហោកេ្ក-ក្សោ កំណត់ ៨ ឆ្នាំ ហើយទ្រង់សម្តែងធម៌ឈ្មោះ នេហាន-ក្សោ កំណត់ ១ ថ្ងៃ ។

(ចប់ផ្នែកទី ១)



ភ្នំតូច ១ នៅស្រុកមណ្ឌលេ សឹងពាសពេញទៅដោយវត្តអារាម ជាទីប្រជុំព្រះពុទ្ធសាសនា ១ អន្លើ នៅស្រុកភូមា ។

ដោយប្រការយ៉ាងណាខ្លះ ដែលគេគោរព

ព្រះបរមសព្វញ្ញូសម្ពុទ្ធក្នុងស្រុកចិន

ក្នុងឆ្នាំទី ៧ នៃសករាជ យុង-ពីង ព្រះចៅរាជាធិរាជ មីងទី ជាក្សត្រទី ២ នៃរាជវង្ស ហ័ន ទ្រង់ព្រះសុបិនយ៉ាងចំឡែក ។ គឺទ្រង់ឃើញមនុស្សម្នាក់មានកំពស់ ១៦ ហត្ថពណ៌ដូចមាស ដើរកាត់មុខព្រះបរមរាជវាំង មានមនុស្សហែហមជាច្រើន នៅខាងស្តាំមានធ្នូ ១ និងសរ ២ ។

ព្រះចៅរាជាធិរាជទ្រង់ប្រជុំអស់នាហ្មឺនសព្វមុខមន្ត្រី ហើយផណ្ដាំងសួរអំពីដែលទ្រង់សុបិននេះជានឹងមានហេតុភេទដូចម្ដេច ។

ក្នុងវេលានោះមានលេខាធិការដែលកាន់កាប់ក្បួនខ្នាតក្រាបទូលថា ប្រសិនបើយកអក្សរដែលសរសេរថា ធ្នូ មកផ្សំគ្នាជាមួយនឹងគំនូស ២ ដែលជាជំនួសសរនោះ នឹងកើតឡើងជាពាក្យ ១ ម៉ាត់ ដែលហៅថា ពុទ្ធ គឺជាព្រះអរហន្ត ១ អង្គ ដែលបានត្រាស់ប្រាជ្ញាសរពេជ្ញ ក្នុងស្រុកឥណ្ឌៀ

កាលក្នុងរជ្ជកាលរាជវង្ស ជាវ សោយរាជ្យក្នុងស្រុកចិន គឺច្បាស់ជាព្រះពុទ្ធនេះហើយដែលឲ្យឃើញក្នុងសុបិននេះ ។

ព្រះចៅមីងទី ក៏ទ្រង់ម្នីម្នាបាត់រាជទូតទៅក្នុងប្រទេសឥណ្ឌៀ ដើម្បីនាំយកនូវធម៌វិន័យរបស់ព្រះសម្មាសម្ពុទ្ធ ។ ទ្រង់បានបាត់មន្ត្រី ២ រូបឈ្មោះត្សៃគ័ន ១ នឹងត្សិន-គឹង ១ ដែលបានចេញពីស្រុកចិនទៅជាមួយនឹងបក្ខពួកជាច្រើន ។

ពួករាជទូតទាំងនេះបានទៅក្នុងស្រុកឥណ្ឌៀកំណត់ ៣ ឆ្នាំ បានប្រាស្រ័យជាមួយនឹងលោកអ្នកប្រាជ្ញធំ ៗ ក្នុងសម័យនោះ គឺ សោមតោ នឹងបិកុហោរ៉ន ហើយបានគម្ពីរពីអ្នកប្រាជ្ញទាំងនេះ ៦ ហ្មឺនគម្ពីរព្រមទាំងព្រះពុទ្ធរូប ព្រះសារីរិកធាតុនឹងវត្ថុផ្សេង ៗ សម្រាប់គោរព ហើយអ្នកប្រាជ្ញទាំងនេះបានជូនត្រឡប់ទៅស្រុកចិនវិញ ក្នុងឆ្នាំទី ១០ នៃសករាជ យុង-ពីង ។

*

* *

ធម៌អាថ៌របស់ព្រះពុទ្ធសាសនា ក៏ផ្សាយពាសពេញក្នុងស្រុកចិនទាំងមូល, លុះដល់មកក្នុងខែទី ១ ក្នុងឆ្នាំទី ៥ តមក

នោះមានពួកអ្នកបួសក្នុងសាសនា តៅ នាំបង្កជាជំលោះយ៉ាងធំឡើង ហើយតាំងប្តេជ្ញាចិត្តថានឹងការពារសាសនាខ្លួនកុំឲ្យពុទ្ធសាសនាផ្សាយចូលមកដល់ ហើយពួកអ្នកបួសក្នុងសាស-នា តៅ ចំនួន ៧០០ រូប តាំងធ្វើពាក្យបោះត្រាទាំងអស់គ្នាយកទៅថ្វាយព្រះចៅរាជាធិរាជ សុំឲ្យយកពួកគ្រូក្នុងព្រះពុទ្ធសាស-នាមកធីប្រឡងគ្នា ដើម្បីឲ្យឃើញអានុភាពរបស់សាសនានីមួយៗ ។

ព្រះចៅរាជាធិរាជទ្រង់ក៏បាត់ឲ្យប្រជុំពួកអ្នកបួសក្នុងទីព្រះវិហារ សេះស ដែលកសាងទុកជាទីរឭកដល់ សេះស ដែលបាននាំគម្ពីរពីស្រុកឥណ្ឌៀមក ។ នៅចំកណ្តាលព្រះវិហារនោះតាំងដំកល់ទេវរូបសម្រាប់នគរ ហើយខាងស្តាំដាក់ពួកអ្នកបួសដែលកាន់សាសនាសម្រាប់ស្រុករៀងមក នៅទីខាងឆ្វេងដាក់ពួកគ្រូៗក្នុងព្រះពុទ្ធសាសនា ។ ព្រះចៅរាជាធិរាជ មឹងទីក៏យាងទៅកាន់ទីនោះមួយអន្លើដោយសេនាបតីនាហ្មឺនសព្វមុខ

មន្ត្រីនឹងព្រះបរមរាជវង្សានុវង្ស ។ ហើយនៅទីខាងក្រោយពួកទាំងពីរនេះ មានសាធារណជនណែនណាន់តាន់តាប់ ។

អ្នកបួសសាសនាតៅ ១ អង្គដើរចូលទៅជើងបល្ល័ង្កទេវរូបហើយពោលថា ការជឿសាសនាដែលផ្ដេសផ្ដាសនោះនាំវិជ្ជួលចលាចលក្នុងព្រះនគរ ហើយដើម្បីនឹងធ្វើឲ្យឃើញអស្ចារ្យក្នុងសាសនារបស់ខ្លួន ក៏តាំងចាប់សៀវភៅធម៌អាថ៌កំបាំងខាងតរបស់សាសនាខ្លួនបោះទៅក្នុងគំនរភ្លើងក៏ឆេះខ្ទេចទៅ ហើយក៏តាំងស្មុះចូលទៅប្រឹងនឹងដើរលុយភ្លើង ដើម្បីធ្វើសេចក្ដីអស្ចារ្យឲ្យកើតឡើង តែមិនអាចនឹងធ្វើបានឡើយ ។

ពួកគ្រូក្នុងព្រះពុទ្ធសាសនាក៏តាំងដើរចូលទៅហើយតាំងសច្ចារំលឹកដល់គុណព្រះរតនត្រ័យ ទើបបោះគម្ពីរទៅក្នុងអណ្ដាតភ្លើង លុះទាញយកមកវិញ ឃើញមានពន្លឺរឿងផ្លៀវផ្លូបជាមាស ។ មិនតែប៉ុណ្ណោះពួកគ្រូទាំងនោះបានធ្វើឲ្យកើតជាឥន្ទធនូឡើង ហើយក៏ធ្វើខ្លួនឲ្យអណ្ដែតឡើងទៅលើអាកាសវេហាស៍ ដំណេតខ្ពុះ ។

ក្នុងវេលានោះអ្នកដែលទៅជួបជុំទាំងអស់កើតសេចក្ដីជ្រះថ្លា ហើយមានពួកគ្រូដែលកាន់សាសនាសម្រាប់ស្រុកបំនួន ២៦០ រូប ពួកនាយទាហាន ៣៩០ រូប និងពួកអ្នករៀន ៦០០ រូប បួលបួសក្នុងព្រះពុទ្ធសាសនា មានស្រីៗ ក្នុងព្រះបរមរាជវាំង បំនួន ១៩០ រូប បួលបួសដែរ ។ ព្រះចៅរាជាធិរាជទ្រង់បាត់ឡសាងអារាមយ៉ាងធំៗបំនួន ១០ គឺឡសាង ៣ ក្នុងព្រះនគរដែលជារាជធានី ហើយ ៧ ទៀតក្រៅកំផែងនគរ ។ អារាមទាំងអស់នេះបានទទួលការឧបត្ថម្ភយ៉ាងបរិបូណ៌ដូចគ្នាទាំងអស់ ។



ក្លោងទ្វារហោត្រៃ ១ សាងដោយឈើ កាល ព. ស. ២៤០២ នៅ
វត្តតេកការ (មណ្ឌលេ) សិងជាវត្តនៃសង្ឃនាយក គណៈមហានិកាយ ។

# បញ្ជីរឿង


១– ដោយប្រការយ៉ាងណាខ្លះដែលគេគោរពព្រះសម្មាសម្ពុទ្ធនៅស្រុកយីប៉ុន (តចប់). ៥៧

២ – សេចក្ដីអធិប្បាយពីវិធីសាងប្រាសាទនគរវត្ត លោកហ. មាហ្សស រៀបរៀង ក្រមការ ដុំ-មៅ ប្រែជាភាសាខ្មែរ. . . . . . . . . . . . . . . . . . . ៧៥

៣ – កម្មបថពិស្ដារ ព្រះអាចារ្យង៉ែត ឥន្ទ រៀបរៀង. . . . . . . . . . . . . . . ៩៩


# រូបផ្សេងៗ


១ – ព្រះពុទ្ធរូបគ្រាផ្ចាញ់មារ នៅវិហារចេតក្យាមុង ស្រុកធ្យូនគុយ (ភូមា). . . . . ៥៥

២ – រូបលោកសង្ឃភូមាកាន់ត្រាដែលស្ដេចព្រះភគិនាថមកក្រុមសង្ឃការី នៅក្រុងមណ្ឌលេ. . . . . . . . . . . . . . . . . . . . . . . . . . ៧៣

៣ – រូបភាពផ្ដិតថ្នាំ របស់លោកស៊័រ្យបារិយែរ គួរ. . . . . . . . . . . . . . ៩៨

# TABLE DES MATIÈRES

I. De quelle manière le Bouddha fut vénéré au Japon par Georges Bonneau — Traduit du Français en Cambodgien par Kromokar Chum-Mau .......... 57

II. Les travaux de l'édification des monuments d'Ang-Kor par H. Marchal — Traduction du Kromokar Chum-Mau. .... 75

III. Extrait et traduction en cambodgien des poèmes Pali par Achar Nghet-Inh (à suivre) .......... 99

## HORS TEXTE:

I. Statue du Bouddha Bhumisparça Mudra — Pagode Thetkya — Muni — Pagan (Birmanie) .......... 55

II. Bonze birman tenant les cachets Shwegyiung — Sayadau. Temple de Taiktaw — Mandalay (Birmanie) .......... 73

III. Tête des bonzes croquis de G. Barrière .......... 98



ព្រះពុទ្ធរូប ភូមិស្បសិមុទ្រ គ្រាផ្ចាញ់មារ នៅវិហារថេតក្យាមុនី
ស្រុកធ្យូនគុយ ឆ្នេរទន្លេឥរវតី (ភូមា)

## ដោយប្រការយ៉ាងណាខ្លះ ដែលគេគោរព ព្រះសម្មាសម្ពុទ្ធនៅស្រុកយ៉ីប៉ុន

ក្នុងសម័យនោះ ព្រះចៅសីមីក្សត្រទី ៤១ ដែលតពីស្ដេចបិតវ្យ មកសោយរាជ្យសម្បត្តិនៅក្រុង កុទរ ក្នុងដែនកោរេ ។ មានថ្ងៃ ១ ទ្រង់បានឮព្រះពុទ្ធរូបនិយាយមករកថា យើងចង់ទៅនៅក្នុងស្រុកខាងកើត គឺស្រុកយីប៉ុន សូមឲ្យអ្នកនាំយើងទៅ ។

ស្ដេចសីមីក៏ទ្រង់ចាត់ការឲ្យតសំពៅ ១ យ៉ាងធំ ហើយនាំព្រះពុទ្ធរូបនឹងគម្ពីរដីកា នឹងវត្ថុផ្សេង ៗ សម្រាប់សាសនាទៅដំកល់ ទ្រង់ចាត់អគ្គមហាសេនាឈ្មោះ នុរិសិដ៏ ឲ្យទៅជារាជទូតចំពោះព្រះចៅរាជាធិរាជ គិមមី នាថ្ងៃទី ១៣ នៃខែទី ១០ គេឃើញសំពៅពីស្រុកកោរេ ចូលចតនៅកំពង់ឈ្មោះននិវ៉ា ។

ព្រះមហាក្សត្រទ្រង់គង់នៅក្នុងព្រះបរមរាជវាំង កនាសាសី នៅសិកិសីមា ក្នុងដំបន់សិកិ ខែត្រយមតោ នៅទីនោះហើយដែលរាជទូតស្ដេច កុទរ បានថ្វាយព្រះពុទ្ធរូប គម្ពីរដីកានឹងវត្ថុ

ផ្សេងៗ សម្រាប់សាសនាបំពោះព្រះពៅ គិមមី ។ ហើយថ្វាយទាំងព្រះអក្សរសាស្ត្រស្តេចស្រុក កោរេ ផង ដែលមានសេចក្ដីដូច្នេះ ។

ក្នុងសាសនាទាំងអស់ មានតែសាសនានេះដែលខ្ពស់បំផុតជាងគេ ។ ពួកអ្នកចាស់បុរាណពិនគ្មានភ័ព្វនឹងបានស្គាល់ព្រះពុទ្ធរូបនេះឡើយ ។ ព្រះពុទ្ធរូបនេះឲ្យនូវសេចក្ដីសុខឥតប្រៀបបាន ហើយអាចប្រាប់ឲ្យដឹងនូវសេចក្ដីដែលបរិសុទ្ធក្នុងជាតិមុខ ។

សេចក្ដីប្រាថ្នារបស់មនុស្ស ផ្សាយទៅដល់គ្រប់ឃ្លាំងសម្បត្តិក្នុងលោក ហើយនៅមិនស្កប់ស្កល់ជាដរាប ឃ្លាំងរបស់ធម៌ដ៏ប្រសើរនេះ ជាឃ្លាំងដែលគ្មានខ្វះអ្វីដែលអាចនឹងបំពេញសេចក្ដីប្រាថ្នារបស់មនុស្ស ។ ព្រះធម៌ថ្មីនេះបានផ្សាយទៅក្នុងស្រុកឥណ្ឌៀទាំង ៥ បំណែក និងក្នុងនគរទាំង ៣ នៃដែនកោរេ ហើយគ្មានមនុស្សណាម្នាក់ដែលមិនបានកាន់សា-សនានេះឡើយ ។

ដោយហេតុនេះហើយបានជា ទូលបង្គំជាខ្ញុំជាក្សត្រ ក្រុងកុទរ ចាត់អគ្គមហាសេនាឈ្មោះ នុរិសិជី ឲ្យនាំឈ្លូកស របស់ព្រះពុទ្ធមកថ្វាយទ្រង់ករុណាវិសេស ។ ទូលបង្គំសូមឲ្យទ្រង់ករុណាវិសេស ធ្វើឲ្យរីកក្នុងព្រះនគរឡើង ដើម្បីឲ្យសមតាមព្រះពុទ្ធដីកា ដែលទ្រង់បានសំដែងទុកថា ធម៌របស់តថាគតនឹងផ្សាយចេញទៅទិសខាងកើត ។

ព្រះចៅរាជាធិរាជ គិមមី តាំងចាត់ការប្រជុំសេនាបតី នឹងនាហ្មឺនសព្វមុខមន្ត្រីធំ ៗ ហើយទ្រង់ត្រាស់ដណ្ដឹងសួរថា យើងនឹងត្រូវទទួលព្រះពុទ្ធសាសនាឲ្យចូលក្នុងនគរឬទេ អគ្គ-មហាសេនាឈ្មោះ សោគៈណូអ៊ីណាម ក្រាបទូលថា មិនសមបើនឹងទទួលយកធម៌នេះឡើយ ព្រោះជាធម៌ដែលគេប្រតិបត្តិក្នុងរាជធានីពួកហាន ក្នុងនគរទាំង ៣ នៃដែនកោរេ នឹងក្នុងនគរដទៃផ្សេង ៗ ទៀត អ្នកស្រុកយើប៉ុន អាចនឹងប្រព្រឹត្តិកាន់នូវសាសនានេះឥតទាស់ ។ ទីប្រឹក្សាម្នាក់ឈ្មោះម៉ូណូណូប-ណូឌិគោសិ នឹងសេនាបតីក្រសួងពម្មការ ឈ្មោះ នកាតោ-មីណូកាមកោ ទទឹងទាស់នឹងគំនិតនេះយ៉ាងដាច់ខាត ហើយ

ក្រាបទូលថា សាសនារបស់ស្រុកយើង គឺការគោរពនូវព្រះរាជបិតរ(១) ដែលយើងតែងគោរពនមស្សការបូជាគ្រប់ដើមវង្ស ។ បើយកព្រះដទៃផ្សេងពីប្រទេសដទៃមកបញ្ចូលក្នុងការគោរព នឹងនាំឲ្យព្រះយើងមានសេចក្ដីក្រោធធ្វើឲ្យយើងបានសេចក្ដីអន្តរាយជាប្រាកដ ។ សូមកុំឲ្យទទួលយកពុទ្ធសាសនាមកដំកល់ក្នុងទីណា ១ ឡើយ ។

ព្រះចៅរាជាធិរាជទ្រង់ព្រះវិចារណ៍ ហើយត្រាស់ថា បើដូច្នេះព្រះពុទ្ធរូប គម្ពីរដីកានឹងវត្ថុសម្រាប់សាសនាដែលគេថ្វាយមកនេះ ត្រូវប្រគល់ឲ្យទៅអគ្គមហាសេនា ។

សោគៈណូអ៊ីណាម មានសេចក្ដីសោមនស្សជាខ្លាំងហើយធ្វើនូវសួនសម្រាប់វង្សត្រកូលនៅឪភារិទក្នុងដំបន់ តកៃជី ទៃត្រយមុ-តោឲ្យទៅជាព្រះវិហារឡើង ដើម្បីដំកល់នូវព្រះរូបអមិទ ។

*

* *

ក្នុងសម័យនោះផ្លួនជា មានកើតជំងឺក្នុងព្រះនគរស្លាប់មនុស្សជាច្រើនពាសពេញដោយផ្លូវថ្នល់ ។ ម៉ូណូណូបណូ-

(១) គឺបុព្វបុរស របស់ព្រះចៅរាជាធិរាជស្រុក យីប៉ុន ។

ឱគោសិ និងនកាគោមីណ្ឌកាមកោ ឡើងទៅគាល់ព្រះចៅរាជាធិរាជដោយរួសរាន់ ហើយយកសេចក្ដីក្រាបទូលថា មហាភ័យដែលកើតមាននេះ មិនមែនជាធម្មតាសម្រាប់ស្រុកទេ គឺច្បាស់ជាព្រះរាជបិតរមានសេចក្ដីក្រោធ ដោយមានសេនាបតីម្នាក់គោរពព្រះពីប្រទេសដទៃ ៗ សូមឲ្យព្រះអង្គកំចាត់រំលាយនូវព្រះរូបដែលនាំពីកោះរមក ព្រមទាំងព្រះវិហារដែលដំកល់នោះចោលបង់ ។

ព្រះចៅរាជាធិរាជ ទ្រង់ក៏ប្រគល់កិច្ចនេះឲ្យដល់សេនាបតីទាំងពីរ ៗ ក៏លើកកងយោធាទៅកាន់ទី ឱភរិទ ហើយដុតបំផ្លាញនូវព្រះវិហារ យកព្រះពុទ្ធរូបទៅទំលាក់ចោលក្នុងបឹងឈ្មោះ ឥម្ពះ ជាខាងលិចស្ទឹង អស្សុកៈ នៅក្នុងដំបន់ តកែជីវៃត្រយមតោ ដដែល ។

លុះវេលាយប់ មានកើតភ្លើងឆេះក្នុងព្រះបរមរាជវាំង ព្រះចៅរាជាធិរាជទ្រង់កើតវិបដិសារីក្នុងព្រះអង្គ ក៏ត្រាស់ហៅអគ្គមហាសេនាមកហើយទ្រង់មានព្រះបន្ទូលថា ប្អូនអ្នកទៅស្រង់យកព្រះពុទ្ធរូបពីក្នុងបឹងដែលគេទំលាក់ទៅនោះមកជា

ប្រញាប់ ហើយអ្នកទៅរៀបចំសំអាតព្រះរាជវាំង មុកុហារៈឲ្យស្អាតតាំងធ្វើជាព្រះវិហារឡើងដើម្បីដំកល់ព្រះពុទ្ធរូបនេះ ។

សោគៈណូ អីណាម ក៏ធ្វើតាមព្រះរាជបញ្ជា ហើយនិមន្តព្រះពុទ្ធរូបទៅដំកល់ក្នុងទីព្រះវិហារថ្មី ។ តពីនោះបាននិមន្តលោកសង្ឃ ១២ អង្គពីកោរេមក គឺ ៧ អង្គពីនគរ កុទរ ហើយ ៥ អង្គពីនគរ កោរេ ។

✲

✲ ✲

ព្រះបៅរាជាធិរាជ គិមមី ទ្រង់ទិវង្គតក្នុងព្រះជន្មាយុគំរប់ ៦៣ ឆ្នាំ ក្នុងឆ្នាំទី ២៣ នៃរជ្ជកាលរបស់ទ្រង់ ។ ព្រះអង្គមានព្រះរាជបុត្រ ២៥ អង្គអំពីព្រះអគ្គទេវី ៥ ព្រះអង្គ ហើយព្រះរាជបុត្រា ៤ ព្រះអង្គបានសោយរាជសម្បត្តិ ព្រះរាជបុត្រា ១ អង្គដែលទទួលរាជ្យជាដំណពីទ្រង់មកនោះគេស្គាល់ព្រះនាមក្នុងពង្សាវតារថាទ្រង់ព្រះនាម ពិទត្សូ តេន្នោ ។

ប៉ុន្តែក្នុងខណៈនោះ សោគៈណូឧមកោ ជាកូន អីណាម ម៉ូណូណូបណូមោរិយ ជាកូនឱគោជិ និងនកាតោម៉ណូ ក៏ត្បូមិជាកូនកាមកោ បានទទួលបន្ទុកនឹងបិត្តគំនិតពីអាពុកមក

រាល់ៗគ្នាទាំង ៣ នាក់ ទើបការតយុទ្ធគ្នាតាំងផ្ដើមជាថ្មីឡើង ។

ដល់មកក្នុងឆ្នាំទី ១៤ និងចុងបំផុតនៃរជ្ជកាលព្រះចៅពិទត្យ តេឡោ នាខែទី ៣ មានកើតជំងឺឆ្លងក្នុងព្រះនគរ ។ ក្នុងវេលានោះ ម៉ូណូណូបណូមោរិយ និងនកាតោមីណូកត្សមិ ចូលគាល់ព្រះចៅរាជាធិរាជ ហើយក្រាបទូលដោយសេចក្ដីដូច្នេះ ជាការខុសធំណាស់ ដែលគោរពប្រតិបត្តិព្រះរបស់ប្រទេសដទៃ យើងខ្ញុំបានក្រាបទូលរឿងនេះជាច្រើនគ្រាណាស់មកហើយ ។ ឥឡូវនេះ សោគៈណូឧមកោ នាំសាធារណជនគោរពសាសនា ដែលនាំឲ្យកើតអន្ដរាយនេះ នាំឲ្យអាណាប្រជារាស្ត្រភាន់ច្រឡំ ហើយធ្វើឲ្យព្រះដែលយើងធ្លាប់គោរពក្នុងព្រះនគរមានសេចក្ដីក្រោធឡើង កើតមានជាមហាភ័យ មនុស្សកើតជំងឺស្លាប់ដេរដាសគ្រប់ខែត្រខណ្ឌ ជាការគួរស្បើមណាស់ ។ សូមព្រះអង្គបាត់ឲ្យកំទេចព្រះវិហារនិងព្រះរូបនោះចេញ ហើយឲ្យទ្រង់បញ្ញត្តិហាមផ្ដាច់កុំឲ្យគោរពសាសនាដែលចូលមកពីនគរ កុទរនេះ ។

ព្រះចៅរាជាធិរាជទ្រង់អនុញ្ញាតតាមសេចក្ដីសុំនេះ ។ ក្នុងថ្ងៃនោះ ម៉ូណូណូបណូមោរិយ និងនកាតោមីណូ ក៏ត្រូវ ក៏តាំងលើកបក្ខពួកទៅដុតបំផ្លាញនូវព្រះវិហារ ដែលសោគៈណូឱមកោ សាង ហើយចាប់លោកសង្ឃ ១ អង្គនឹងយាយជី ៣ អង្គទៅដាក់ក្នុងគុកទៅ ។

លុះមានជ័យជំនះដូច្នេះហើយ ម៉ូណូណូបណូមោរិយ ក៏ទាញយកព្រះពុទ្ធរូបមក ដំបូងយកញញូមកវាយកំទេច តែមិនបែក រួចពីនេះយកទៅបោះក្នុងភ្លើង ប៉ុន្តែព្រះពុទ្ធរូបនេះ បញ្ចេញនូវរស្មីមកកំចាត់នូវអណ្ដាតភ្លើងនោះវិញ លុះធ្វើមិនសមសេចក្ដីប្រាថ្នាដូច្នេះហើយក៏យកទៅបោះចោលក្នុងបឹង ឥម្ពុៈដដែលវិញ ។

ព្រះពុទ្ធរូបនៅក្នុងបាតបឹងនោះអស់វារៈ ១៧ ឆ្នាំ តែកាលណាបង់ដើបឡើងក៏ដើបឡើងបាន តាមទំនងដូចនឹងពោលតទៅនេះ ។

ក្នុងឆ្នាំទី ១៧ នៃរជ្ជកាលរបស់ទ្រង់ ព្រះនាងស៊ីកោរាជាធិរាជប្រទេស យីប៉ុន ទ្រង់ត្រាស់បង្គាប់ឲ្យហៅហ្វាយ

ខែត្រៗសិនណោះ ចូលទៅកាន់ទីព្រះបរមរាជវាំងឧភរិទ ខែត្រ យមតោ ។ ចៅហ្វាយខែត្របានយកមនុស្សម្នាក់ដែលជាអ្នកក្រ តែលោកអាណិតរាប់អាន នៅភូមិ ឱមិ ១ណ្ណ អ៊ីណា ឡេជូន ទៅផង ។ មនុស្សនោះឈ្មោះ ហោនុះយោសិមិត្សុ ហើយ មានប្រពន្ធឈ្មោះ យ៉ាយ៉ូយ ។

លុះមកដល់ទីក្រុង យោសិមិត្សុ មានប្រាថ្នានឹងដើរមើល កន្លែងដែលសំខាន់ ៗ ហើយក៏បានអនុញ្ញាតពីចៅហ្វាយខាយ ១ថ្ងៃដើម្បីដើរមើល ។ ក្នុងវេលាដែលកំពុងតែដើរតាមក្បែរ មាត់បឹង ឥម្ពុៈ ក៏ស្រាប់តែឮសំឡេងស្រែកហៅចំឈ្មោះខ្លួនចេញ ពីក្នុងបឹងមកថាៈ

— យោសិមិត្សុ ; យោសិមិត្សុ !

ក្រឡេកមើលទៅស្រាប់តែឃើញរូបមានពន្លឺរស្មីដើរពី កណ្ដាលបឹងចូលមកកាន់ខ្លួន ហើយក៏និយាយមកថាៈ កុំខ្លាច អ្វី យើងជាព្រះពុទ្ធរូបដែល ម៉ូណូណូបណូ មោរិយ ទំលាក់ ចោលក្នុងបឹងនេះ ។ ក្នុងសម័យដែលស្ដេចគ័ក្កៃរស់នៅក្នុង

ស្រុកឥណ្ឌៀនោះ ព្រះអមិទពុត្ធ បានបញ្ចេញព្រះរស្មីឲ្យយើងមានវិញ្ញាណឡើងតាំងពីនោះមកប្រហែល ១៥០០ឆ្នាំហើយ ។ យើងមកនៅក្នុងស្រុកនេះដើម្បីឲ្យបានសេចក្ដីសុខដល់អ្នកស្រុករាល់គ្នា ឥឡូវយើងយកអ្នកឯងជាខ្ញុំ មិនបោះបង់អ្នកឯងចោលទេ ។ យើងត្រូវការឲ្យអ្នកឯងនាំយើងទៅក្នុងវិហារត្រូវអ្នកឯង កាលណាអ្នកឯងត្រឡប់ទៅវិញ ។

យោសិមិត្សុ ឱនកាយគោរព ហើយនាំយកព្រះពុទ្ធរូបនេះទៅដំកល់ក្នុងកន្លែងអាត្មា ។ លុះព្រឹកស្អែកឡើងក៏ធ្វើជាបុតហ្មាយរ៉ាយរឿងក្រាបទូលព្រះនាងរាជាធិរាជ ។ ព្រះនាងមានព្រះបន្ទូលថា: ត្រូវអ្នកធ្វើតាមព្រះបន្ទូលរបស់ព្រះពុទ្ធរូបហើយហែយកទៅដំកល់ក្នុងវិហារ សិនណោះទៅ ។

ក្នុងវេលានោះព្រះនាងបានចាត់ ហទៈណូទែពុ នៅកោសឲ្យជូនព្រះពុទ្ធរូបទៅ ប៉ុន្តែយោសិមត្សុ សុំលីដោយខ្លួនឯងទៅដរាបលុះដល់ផ្ទះខ្លួន នៅភូមិ ឱមិ ។ លុះយកទៅដល់ផ្ទះគ្មានកន្លែងគួរសមល្មមដំកល់ក៏តាំងបូកបាយអនឹងឬ នៅទី

ខាងលិចផ្ទះ ធ្វើបែបជាបល្ល័ង្កឡើង ហើយដឹកលន្ទូវព្រះពុទ្ធរូបនេះ ។

នាងយ៉ាយ៉ូយជាប្រពន្ធ មិនទាន់ព្រមជឿពាក្យដែលប្ដីនិយាយប្រាប់ ហើយនិយាយទៅកាន់ប្ដីថាៈ ដែលអ្នកជឿនោះអាចនឹងប្រាកដបាន តែថានឹងឲ្យខ្ញុំជឿជាមួយផងឯណាបាន ព្រោះខ្ញុំមិនបានឮលោកហាជាតុនេះនិយាយផងសោះ ។ នាងនេះនិយាយស្ទើរមិនទាន់ផុតមាត់ ស្រាប់តែព្រះពុទ្ធរូបបញ្ចេញនូវព្រះរស្មីភ្លឺប្រិះឡើង ហើយសម្ដែងប្រាប់ យោសិមិត្សម្ដងទៀតសម្ដែងប្រាប់អំពីដែលព្រះអមិទ បានបញ្ចេញនូវព្រះរស្មីឲ្យហើយសម្ដែងអំពីជាតិកំណើតត ៗ គ្នារបស់យោសិមិត្ស ដែលកាលពី ៤០០០ ឆ្នាំមុននេះបានកើតជាស្ដេច ។

នាងយ៉ាយ៉ូយ ជាមនុស្សរឹងប្អឹង ក៏ជឿជាក់ក្នុងចិត្តជាប្រាកដ ហើយគោរពព្រះពុទ្ធរូបនោះឥតលោះពេល ហើយយោសិមិត្ស ធ្វើការគោរពដោយកិច្ចយ៉ាងប្រសើរតាមដោយភាពខ្លួនជាអ្នកទំទំលក្រ ។ មានរាត្រី ១ នោះ យោសិមិត្សអស់ប្រាក់រលីងហើយគ្មានអ្វីទិញប្រេងអុជ ក៏អង្គុយកើតទុក្ខក្នុង

ផ្ទះដោយមិនបានអុចប្រទីបជាពុទ្ធបូជានៅលើអាសនៈ ក្នុងវេលានោះព្រះពុទ្ធរូបតាំងបញ្ចេញនូវព្រះរស្មីភ្លឺបញ្ចាំងពាសពេញផ្ទះ យោសិមិត្តក៏តាំងឱនគោរពនមស្ការ ហើយពន្លឺនោះក៏បាញ់ចូលទៅក្នុងចង្កៀង ឆេះចង្កៀងឡើង គឺដូចគ្នានឹងកាលពី១២០០ ឆ្នាំមុននោះ មានកើតអស្ចារ្យដូច្នេះម្តងនៅទីករនគរធំ ដំបន់សិនធោ ដែលសព្វថ្ងៃហៅថា នគរនោ ។

ក្នុងឆ្នាំដំបូងនៃរជ្ជកាលព្រះនាងហៅរាជាធិរាជ កោគ្យោកុនោះព្រះពុទ្ធរូបមានព្រះបន្ទូលម្តងទៀតចំពោះទៅនឹងយោសិមិត្តថា: យើងចង់ឲ្យអ្នកឯងនាំយើងទៅឯដំបន់ មិនោជិ ក្នុងខែត្រដដែលនេះ ។

យោសិមិត្ត ទទួលតាម ហើយក៏នាំយកព្រះពុទ្ធរូបទៅដំកល់ក្នុងទី ករនគរធំ ក្នុងព្រះវិហារដែលខ្លួនកសាង ។ តមកមានព្រះរាជបញ្ញត្តិតាំងឈ្មោះព្រះវិហារនោះជាឈ្មោះថាសេនកូជិ អក្សរទាំង ៣ តួនេះមើលបានជាសំដីយ៉ីប៉ុនថា យោសិមិត្តទេវ ឬព្រះវិហាររបស់ យោសិមិត្ត ។

ក្នុងឆ្នាំទី ២ នៃរជ្ជកាលព្រះនាងបៅរាជាធិរាជ កោតេ្យក្ន យោសិសុក ជាកូនតែ ១ របស់ យោសិមិត្ត មានជំងឺឈឺហើយស្លាប់ទៅ ។ អាពុកម្តាយកើតទុក្ខនឹងពណ៌នាមិនបាន ។ ហើយក៏នាំគ្នាទៅសំពះបន់ព្រះពុទ្ធរូបថា បពិត្រព្រះគុណម្ចាស់ថ្លៃ យើងខ្ញុំទាំងពីរនាក់នេះជរាណាស់ទៅហើយ ហើយយោសិ-សុកជាកូនយើងដែលត្រូវនៅបំរើព្រះអង្គជាជំណាពីយើងនោះស្លាប់ទៅហើយ ។ ដោយឫទ្ធានុភាពរបស់ព្រះអង្គនោះ យើងខ្ញុំសូមឲ្យកូនខ្ញុំរស់ឡើងវិញ ។

ក្នុងវេលានោះព្រះពុទ្ធរូបក៏ហោះបំពោះទៅឋាននរក បាំងពន្លឺទៅលើស្រមោលយោសិសុកដែលគេបានប្រគល់ទៅឲ្យពេជ្ឈឃាដ ហើយបាំងពន្លឺបំពោះទៅកាន់បល្លង្ក អេម្មអ្រទៀត ។ ស្តេចនរកក៏តាំងលុតជង្គង់បុះ ហើយទូលសួរថា ព្រះអង្គមានបើត្រូវការអ្វីនឹងខ្ញុំឬអ្វី ព្រះពុទ្ធរូបក៏ត្រាស់តបទៅវិញថា នៅលើដីស្រុកយីប៉ុនក្នុងខេត្តសិនតោ មានមនុស្សម្នាក់ឈ្មោះ ហោគ្នៈយោសិមិត្ត មានកូនប្រុស ១ ឈ្មោះ យោសិសុក ស្លាប់មកហើយ គេបាននាំមកក្នុងទីនេះយើងមកដោះមនុស្សនេះ សុំឲ្យ

អ្នកលើកទោសបោល ហើយឲ្យត្រឡប់ទៅលើដីវិញ ។ យោសិសុកជាកូនយោសិមិត្ស ក៏រួចពីគេធ្វើទុក្ខធ្វើបាប ហើយក៏តោងព្រះពុទ្ធរូបឡើងមកលើដីវិញ ។

ព្រះពុទ្ធរូបក៏យាងចូលទៅប្រតិស្ឋានក្នុងកន្លែងដដែលវិញ ។ យោសិសុកបានចូលទៅគាល់ សម្ដេចព្រះនាងរាជាធិរាជ ហើយបានយកសេចក្ដីក្រាបទូលថ្វាយសព្វគ្រប់ប្រការ ហើយព្រះនាងក៏មានសេចក្ដីជ្រះថ្លាដោយពេញទី ទើបត្រាស់បង្គាប់ឲ្យសង់ព្រះវិហារ សេនកូជិ ជាថ្មី ឲ្យធំស្កុកស្កម្ភឡើង ដោយយកប្រាក់ពន្ធក្នុងខែត្រ កៃ និងខែត្រ សិនសោ ទាំងអស់មកចំណាយ ហើយទ្រង់ចារឹកអក្សរដោយព្រះហស្ដព្រះនាង លើផែនក្ដារដែលត្រូវព្យួរនៅមាត់ទ្វារ បែរមុខទៅខាងកើត ។

*

* *

ដោយហេតុជាទីអស្ចារ្យនេះហើយដែលព្រះពុទ្ធរូបនេះ តាំងនៅជាការដាច់ខាតក្នុងប្រទេសយីប៉ុន ហើយគេកំណត់ព្រះនាមជាព្រះរូបខ្លឹមសារ ដែលអ្នកស្រុកគោរពរាប់អានដរាប តាំងពីវេលានោះមក ។

នេះហើយដែល កោពោទេសិ ជាគ្រូធំក្នុងគណៈ សិន-គោន បានសរសេរនឹងដក់ដោយដៃឯង លើផែនក្ដារនៅក្នុងទីព្រះវិហារ ។ នេះហើយដែលទេនគ្យោទេសិ ជាគ្រូធំក្នុងគណៈទេនទៃ បានយកធម៌មកដំកល់ទុកក្នុងព្រះវិហារ សេនក្វូជិ ។ នេះហើយដែល កេនសិនទេសិ ជាគ្រូធំក្នុងគណៈសិន បានយកមែកស្រល់ ដែលកាប់ពីលើភ្នំ ទេនិបិយម មកដំកល់លើអាសនៈព្រះអមិទ សូមឲ្យមែកស្រល់ ដែលទុកដំណាងព្រះធម៌ដ៏ប្រសើរនេះ គង់នៅស្រស់ឥតស្វិតស្រពោនតទៅ ។

ហើយនៅក្នុងកន្លែងដដែលនេះ គេឃើញមែកស្រល់ដែលដោត ៧០០ ឆ្នាំហើយ នៅស្រស់ដដែលដូចពីដំបូង ។

នៅទីព្រះវិហារ សេនក្វូជិ នេះហើយ ដែលមនុស្សទាំងអស់ ទាំងប្រុសស្រីចាស់ក្មេង រលាដែលស្លាប់ទៅហើយត្រូវបូលមកដើម្បីជំនុំជំរះទោសទ្ទន ។

* *

*

បេះតែប្រព្រឹត្តិដូច្នេះតទៅ ពី ១ តមនុស្សទៅ ១ តមនុស្ស ដរាបលុះព្រះស្រីព្រះអមិទ្ធ ដែលត្រូវនៅលើដីកំណត់ ៦០០០ ឆ្នាំ វិលត្រឡប់ទៅភោគស្ងួត ដែលហៅថាដីបរិសុទ្ធនៅទិសខាងលិចវិញ ។

បប់



លោកសង្ឃភូមាកាន់ត្រា ដែលស្ដេចភូមាព្រះរាជទានមកក្រុមសង្ឃការី
នៅក្រុងមណ្ឌលេ កាល ព. ស. ២៣៩៣ ។

# អំពីវិធីកសាងប្រាសាទ នគរវត្ត

លោក ហ. ម៉ារ្សាល់

ជាអ្នកគ្រប់គ្រង ប្រាសាទបុរាណនៅអង្គរ

អធិប្បាយ

ក្នុងបណ្ដាប្រាសាទទាំងប៉ុន្មាន ដែលសេចក្ដីស៊ីវិល្យៃបុរាណខ្មែរទុកឲ្យយើងនោះប្រាសាទនគរវត្ត អាចនឹងទុកជាក់បានថាជាលក្ខណនៃវិធីកសាងរបស់ខ្មែរ ដែលដល់មកក្នុងសម័យចុងនៃសេចក្ដីផ្លាស់ប្រែបែបក្បួនកសាង ។ គេអាចនឹងនិយាយបានថា បើទុកជាមានប្រាសាទផ្សេង ៗ ជាច្រើន ដែលកើតក្រោយនគរវត្តនេះក្ដី ក៏ប្រាសាទនគរវត្តនេះឯងជាទីសំគាល់នូវចុងបំផុតនៃសម័យសំខាន់ របស់ការរចនាតាមក្បួនបុរាណ (ព. ស. ១៦៥០) ។ ដែលតាមពិតនោះ គឺថាតអំពីប្រាសាទនេះមក យើងប្រទះឃើញតែការកសាងដែលប្លែក ៗ បែបប្រាសាទបាយ័ន ដែលកើតឡើងដោយសេចក្ដីស្រវឹងយស់របស់ស្ដេច ជយវរម័នទី ៧ ហើយប្រាសាទទាំងនេះមានបែបកសាងជាទីសំគាល់បានដោយច្បាស់លាស់ ហើយដែលធ្វើឲ្យយល់

បានន្ទូវសេចក្តីធ្លាក់ដុនដាបចុះរបស់ស្រុក ប្រាសាទជាន់ក្រោយ ទាំងនេះកំណត់នូវសេចក្តីធ្លាក់ចុះ នៃវិធីកសាងប្រាសាទខ្មែរ ដែលតែងធ្វើរៀងរៀបដរាបត ៗ មក មានរំពត់កោងឡើងលើ ដោយប្បាស់លាស់ ហើយមានខ្នាតមានថ្នាក់ល្អ ។

ការរចនាបុរាណខ្មែរប្តើមឡើងដោយប្រាសាទកំពូលស្រប ដែលនៅដាច់តែឯង សង់ដោយឥដ្ឋ ជាទីរឭកនៃការរចនាខ្មែរ ជាន់ដំបូង គឺការរចនាដែលគេកំណត់នាមថា របនាព្រះឥន្ទ្រ-វរម័ន ហើយដែលប្រាសាទលលៃ (ព. ស. ១៤៤៣) សល់នៅជាគំរូ ១ យ៉ាងសំខាន់ក្នុងបណ្តាប្រាសាទទាំងនេះ ។ ការរចនានេះតាំងប្តើមនូវការព្រាងនៃរោងថែវពិមានអាកាស ដែលទុកដាក់ជាលក្ខណជាតុនៃសម័យទី ២ ។

តពីនោះមក តាំងយកថ្មភក់មកប្រើជំនួសឥដ្ឋបន្តិចម្តងៗ ។ ប្រាសាទកំពូលស្របទាំងឡាយ ដែលនៅដាច់តែឯង ឬនៅជាជួរដែលកសាងក្នុងជាន់ដំបូង នោះតែងតែធ្វើឲ្យមានកំពូល ៥ កំពូលធំខ្ពស់នៅជាកណ្តាល កំពូល ៤ ទៀតនៅជុំវិញគ្រប់ជ្រុង

ទាំង ៤ ។ ដូចយ៉ាងប្រាសាទតាកែវ (ព.ស. ១៥៤៣) ដែលបញ្ចេញភាពរាងយ៉ាងសក្តិសម នៅជាកណ្តាលមេឃ ។

បើគ្រាន់តែធ្វើវិមានដំបូលកុងបុះភ្ជាប់ពីកំពូល ១ ទៅកំពូល ១ ហើយធ្វើវិមានដូចគ្នានៅថ្នាក់ខាងក្រោមទៀត នោះគេនឹងប្រទះឃើញផែនទីនគរវត្តទាំងមូល ។

ប៉ុន្តែការដែលរិះស្វាបរកនាំឲ្យឃើតយូរដំណើរក្នុងការធ្វើឲ្យសម្រេចនៃប្រាសាទនេះ ដែលជាប្រាសាទ ១ យ៉ាងសំខាន់ជាងគេក្នុងបណ្តាពួកប្រាសាទដែលមានមិនតែក្នុងស្រុកខ្មែរ នឹងស្រុកជិតខាងឡើយ គឺក្នុងបណ្តាប្រាសាទ ដែលមាននៅក្នុងលោកទាំងមូល ។

ប្រាសាទបាពួន ទុកជាថ្នាក់បន្តពី ១ ទៅ ១ នៃប្រាសាទតាកែវ (ព.ស. ១៥៤៣) នឹងនគរវត្ត (ព.ស. ១៦៤៣) ។

ប្រាសាទបាពួន មានផែនទីដែលយល់បានថាចំឡងយកបែបមកពីពិមានអាកាស តែមិនឲ្យស្មោះ ហើយបាត់ធ្វើឲ្យជំនាញជាង ប៉ុន្តែមិនបរិបូណ៌ដូចប្រាសាទតាកែវ ។ ផែនទី

ប្រាសាទបាពួននេះ ពង្រីកឲ្យធំឡើងឲ្យទូលាយ បន្ថយទ្វារក្រៅដើម្បីធ្វើឲ្យលេចតួប្រាសាទទាំងមូលត្រដុំងត្រដួបឡើង ហើយបើកនូវផ្លូវចូល ដើម្បីភ្ជាប់គ្នាទៅនឹងកន្លែងផ្សេងៗក្នុងប្រាសាទនោះ ។

បំណែកជាងដែលកសាងប្រាសាទនគរវត្ត នៅមានកិច្ចគ្រាន់តែពិនិត្យបញ្ជាក់នូវការដែលត្រូវធ្វើឲ្យមាំមួន ក្នុងការកសាងប៉ុណ្ណោះ មានការបោះបង់នូវវិធីដែលមិនមាំមួន នឹងដែលនាំឲ្យមានគ្រោះថ្នាក់ ដោយយកឈើទៅប្រើពីខាងក្នុងស៊ុំទ្វារ នឹងការដែលបង្ខិតនូវថែរគ្រប់ថ្នាក់ឲ្យឃ្លាតពេញល្មម ដើម្បីកុំឲ្យជណ្ដើរដែលឡើងនោះមកទាល់នឹងជញ្ជាំង ឬទាល់នឹងទ្វារ ហើយនឹងការដែលរិះគិតលៃឲ្យសមកំពស់ សមទំហំគ្រប់កន្លែងទាំងអស់ ដើម្បីឲ្យបានសមជាទីបំផុត ហើយឲ្យលេចនូវកំពូលកណ្ដាលត្រដឹមត្រដួបស្កឹមស្កៃឡើង ។

ឃើញថាផែនទីប្រាសាទនគរវត្ត ដែលជាងកសាងប្រាសាទខ្មែរបានរចនាធ្វើឡើង នោះបានជាភស្តុតាងនៃសេចក្ដីបេះ

ដឹងយ៉ាងច្បាស់លាស់ ក្នុងវិធីមើលជិតមើលឆ្ងាយ និងវិធីដែលបង្ហាញឲ្យឃើញទាំងមូល ។

ម្យ៉ាងវិញទៀត ផែនទីនេះជាបែបយ៉ាងងាយ ហើយបែបងាយនេះធ្វើឲ្យដឹងនូវការហាត់រៀនយ៉ាងយូរយារ និងសេចក្ដីយល់យ៉ាងពិតប្រាកដ ដែលមិនមែនជាបែកឯង ។

បើទុកជាគេបានស្គាល់ គំនិតអ្នកប្រទេសអាស៊ី ក្នុងបំឡាក់យ៉ាងស្អាតសាសពេញលើជញ្ជាំង និងលើទីឯទៀតផ្សេង ៗ ហើយបើទុកជាក្បាច់ដែលស្អេកស្កាសនេះជូនកាលដដែល ៗ ហើយនាំឲ្យទ្រាន់ចិត្ត ក៏គង់តែមិនដល់ទៅនាំឲ្យអផ្សុកចិត្ត ដូចជាក្បាច់ក្នុងប្រាសាទខ្លះនៅស្រុកឥណ្ឌៀឡើយ ហើយបើទុកជាស្អេកស្កាសដូច្នេះក្ដី ក៏ប្រាសាទនគរវត្តនៅតែលេចត្រដឹមត្រដួបយ៉ាងសមរម្យទាំងមូល ។

ជាងសាងប្រាសាទមិនបានបង្វែរលះបង់បំពោះជាងឆ្លាក់ឡើយ ហើយតួប្រាសាទទាំងមូលធ្វើឲ្យយល់នូវសេចក្ដីជំនាញដែលជាទីពេញចិត្តដល់សេចក្ដីយល់របស់យើងក្នុងការល្អ ។

កំពូលកណ្តាលនៃប្រាសាទ នគរវត្ត តាំងនៅក្នុងដំបន់ឥសាណ ក្នុងទីខាងជើងទន្លេសាប នៃក្រុងកម្ពុជា (ខែត្របាត់ដំបងចាស់) ។

គឺជាប្រាសាទ ដែលគេប្រទះឃើញជាដំបូងមុនគេពីភូមិសៀមរាប ដែលនៅចំងាយ ៦ គីឡូម៉ែត្រខាងត្បូង ប្រាសាទឯទៀតទាំងប៉ុន្មានក្នុងទីប្រជុំអង្គរ នោះរៀងរាយដេរដាសទៅខាងជើងនឹងខាងកើត ។ ទីក្រុងនគរធំ មានកំផែងខាងត្បូងចំងាយមួយគីឡូម៉ែត្រអំពីគូខាងជើងនគរវត្តទៅ ។

បើនិយាយអំពីទិសវិញ នោះប្រាសាទនេះខុសអំពីក្បួនធម្មតា ព្រោះទ្វារធំបើកពីទិសខាងលិចទៅវិញ ។

អ្នកសាងប្រាសាទនគរវត្ត ប្រហែលជាសង់ប្រាសាទនេះពីខាងកើតផ្លូវថ្នល់ដែលឆ្ពោះទៅកាន់ទីក្រុង ដើម្បីឲ្យបានជិតស្ទឹងដែលជាទីដឹកនាំប្រជាប់ប្រដា ហេតុនេះហើយបានជាបើកមុខពីខាងលិច ដើម្បីចេញទៅកាន់ផ្លូវថ្នល់ធំដែលជាផ្លូវចូលទៅឯទីក្រុងស្តេច ។

ក៏ស្តុតាងដែលថាមានផ្លូវធ្លាធំនោះ នឹងបញ្ជាក់មិនបាន ព្រោះរកស្នាមជាន់ផ្លូវនោះមិនឃើញ ហើយសំអាងដែលថា មានផ្លូវនេះនឹងទុកនៅបានតែដោយការទាល់គ្មានអ្វីថា ។ ប៉ុន្តែ សំអាងនេះហាក់ដូចជាមិនមែនមិនទំនង ហើយដរាបដល់មក វេលានេះ មិនទាន់មានសេចក្តីអធិប្បាយណា ១ អំពីដែល ប្រាសាទគរវត្តតាំងខុសទំនងធម្មតាឡើយ កាលបើដូច្នេះ សំអាងនេះគួរឲ្យទុកនៅជាទីអាងសិន ។

ក៏ប៉ុន្តែត្រង់នេះនៅមានសេចក្តីសំគាល់ម្យ៉ាង គឺផ្លូវសព្វថ្ងៃ ដែលទៅកាន់នគរធំ ហើយដែលប្រហែលជាត្រូវគ្នានឹងផ្លូវធ្លាខ្មែរ ចាស់នោះ ទ្រង់រៀបចូលទៅក្នុងទ្វារខាងត្បូងរបស់ទីក្រុង ។ ម្យ៉ាងវិញទៀត ប្រសិនបើជាពិនិត្យមើលផែនទីប្រាសាទបុរាណ នៅអង្គរ នោះនឹងឃើញកំផែងនឹងគូរបស់នគរវត្តខាងមុខខាង លិចនឹងខាងកើត នោះមិនពេញជាកាត់ស្មោះពីខាងជើងទៅ ខាងត្បូងទេ គឺទ្រង់បញ្ចិតបន្តិចតាមទិសជាបន្ទោះ ឧត្តរ ឥសាណ នឹង ទក្សិណ និរតី ។ គេអាចនឹងវិនិច្ឆ័យសេចក្តីបាន

ជាផ្លូវធ្លាខ្មែរដែលនាំឲ្យប្រាសាទនគរវត្តយកទិសតាមនោះ កាលជាន់ដើមកាប់តាមទំនងបញ្ឈិតទិសខាងជើងនឹងខាងត្បូង ។

ប៉ុន្តែដោយក្នុងសម័យឥឡូវគេមិនទាន់ស្គាល់ច្បាស់នូវព្រំប្រទល់កំផែងទីក្រុងរបស់ស្តេច ក្នុងសម័យដែលកសាងប្រាសាទនគរវត្តនៅឡើយនោះ គួរតែបង្អង់កុំអាលវិនិច្ឆ័យសេចក្តីអំពីរឿងនេះ ។

តែបើទោះជាដូច្នេះក្តី ក៏គេអាចនឹងស្គាល់បានថានៅសងខាងផ្លូវដែលឆ្ពោះទៅកាន់ទ្វារខាងត្បូងនៃប្រាសាទនគរធំ នោះមានដំណែលប្រាសាទជាច្រើនដែលសង់ពីឥដ្ឋ ដែលគេអាចនឹងស្គាល់បានថាក្នុងសម័យបាខែង ហើយប្រាសាទទាំងនេះត្រូវនៅ ៗ មាត់នៃផ្លូវធ្លាចាស់ ។

ផែនទីទាំងមូលនៃប្រាសាទនគរវត្ត មានបែបផែនត្រូវគ្នានឹងបែបផែននៃការកសាងប្រាសាទធំ ៗ ឯទៀត ក្នុងសម័យពី ព.ស. ១៦៤៣ ដល់ ១៧៤៣ ដែរ ហើយមានការគោរពសាសនានឹងពិធីបុណ្យជាទំនៀមមកបូលជាមួយផង គឺមានអាសនៈ ១ នៅជាកណ្តាល ដែលមានថែវរាងវង់មូលនៅជុំវិញ

ហើយតាំងជាផ្ទៃខាងក្នុង ក្នុងថែវទាំងនេះមានប្រាសាទផ្សេងដទៃដែលតភ្ជាប់គ្នាទៅនឹងអាសនៈដោយថែវទាំងនេះ ។

បែបភាពកសាងរបស់ខ្មែរ បិទមិនឲ្យមានបន្ទប់ធំៗទូលាយៗ បានដោយហេតុមិនបេះប្រក់ ដោយហេតុនេះហើយបានជាប្រាសាទឬទាំងអស់ សុទ្ធតែជាទីប្រជុំនូវប្រាសាទតូចៗភ្ជាប់គ្នាឡើង ដែលមានថែវនឹងកំពូលកណ្តាលជាប្រធាន ។ នៅនគរវត្ត ឃើញសក្តិសមគ្រប់កន្លែងទាំងអស់ កំពស់ខឿនក្រោមគេបានគិតលៃ ឲ្យបានផ្ទៃខាងក្នុងទូលាយហើយវែងដើម្បីឲ្យបានឃ្លាតឆ្ងាយ ហើយជាទីនាំឲ្យឃើញសំបើម ។

ដើម្បីនឹងឲ្យជាក់ច្បាស់អំពីប្រាសាទទាំងមូលនោះ គ្រាន់តែយកចំនួនទទឹងបណ្តោយមកពោលតែប្លោលៗ ក៏ឃើញថាជាការគួរជាជាងដែលនិយាយឲ្យមានបែបបទវែងៗទៅទៀត ។

មាត់គូខាងក្រៅដែលព័ទ្ធកំផែងនៃប្រាសាទនោះបំដាយ ១ គីឡូម៉ែត្រ ៥០០ ពីខាងកើតទៅខាងលិច ហើយបំដាយ ១ គីឡូម៉ែត្រ ៣០០ ពីខាងជើងទៅខាងត្បូង ។

ជញ្ជាំងកំផែងធ្វើដោយថ្មបាយក្រៀមទាំងអស់ ខុះតែត្រង់ជ្រុងដែលគេសង់ជាប្រាសាទមានទ្វារចូល កំផែងនេះប្រវែង ១ គីឡូម៉ែត្រ ០២០ ពីខាងកើតទៅខាងលិច ហើយ ៨១៥ ម៉ែត្រ ពីខាងជើងទៅខាងត្បូង ។

ឯតួប្រាសាទមែនទែន នោះជណ្ដើរបង្កាន់ដៃតភ្ជាប់ពីថែវទៅថ្នាក់ទី១ចំងាយ៦០០ម៉ែត្រ អំពីទីព្រះលានតូច ដែលនៅពីមុខផ្លូវធ្លាក្រៅឆ្លងកាត់គូខាងលិចមក ប្រាសាទនេះ មានថែវ ៣ ជាប់នឹងកំផែង រាង ៤ ជ្រុងទ្រវែង មានថ្នាក់ស្របឡើងពីលើខឿនកាន់តែខ្ពស់ឡើង ៗ ។

ទំហំក្នុង១ថ្នាក់ ៗនោះវាស់យកតាមលេខកត់ទៅឃើញដូចខាងក្រោមនេះ លើកតែត្រង់ល្បាក់ខឿនចេញ គឺ

ថ្នាក់ទី ១= ២០០ម + ១៨០ម

ថ្នាក់ទី ២= ១១៥ម + ១០០ម

ថ្នាក់ទី ៣= ៦០ម + ៦០ម

គេសំគាល់ឃើញថាទំហំ ៤ ជ្រុងទ្រវែង ដែលប្រកបនឹងថែវជាប់កំផែង ដែលមានដំបូលបង្គុំមូលបុះនេះ កាលណា

តែរួមទៅវិញតែជិតទៅជា ៤ ជ្រុងឡើង ហើយថ្នាក់លើបំផុត ដែលជាអាសនៈកណ្ដាល នោះឃើញទៅជា ៤ ជ្រុងយ៉ាង ស្មោះ ។

ឯចំណែកខាងកំពស់វិញ ឃើញធ្វើតាមទំនងក្បួន នព្វន្ត ឡើងជិតទៅដល់ទីអាសនៈកណ្ដាល ។ កំពស់ខឿន ទាំងនេះ គឺថ្នាក់ទី ១ ត្រូវ ៣ ម ៥០ ថ្នាក់ទី ២ ត្រូវ ៧ម ថ្នាក់ទី ៣ ត្រូវ ១៣ ម ប្រសិនបើគេបញ្ចូលកំពស់ខឿនចំនួន ២៣ ម ៥០ ទៅជាមួយនឹងកំពូលកណ្ដាលដែលមានកំពស់ ៤២ ម នោះត្រូវជា ៦៥ ម ៥០ ។

ដែលនៅរៀងគ្នាក្នុងផ្លូវខាងក្នុងជិតមុខប្រាសាទខាងលិច ដែលជាមុខធំ ក្នុងថ្នាក់ទី ១ នឹងទី ២ នោះ គឺជាប្រាសាទ តូចៗ ៤ ប្រកបឡើងដោយវិមានល្វែង ៣ ហើយមានរបាំងជា ទ្វារទាំង ៤ មុខ ប្រាសាទទាំងនេះគេតែងហៅជាធម្មតាថា បណ្ណាល័យ ប៉ុន្តែក្នុងទីនេះគេអាចនឹងទុកជាកន្លែងដំកល់វត្ថុ សម្រាប់សាសនាក៏បាន ។ នៅថ្នាក់ក្រោមទាំងសងខាងផ្លូវ

ខាងលិច ដែលចូលទៅប្រាសាទនោះ នោះមានប្រាសាទតូចពីរដូចគ្នា ។

អំពីប្រាសាទតូចៗ ដែលភ្ជាប់ទៅក្នុងប្រាសាទធំទាំងនេះ ដែលគេមិនទាន់ស្គាល់ច្បាស់ជាធ្វើដើម្បីប្រយោជន៍អ្វី នោះខ្ញុំយល់ថា គួរទុកឈ្មោះតាមដែលខ្មែរធ្លាប់ហៅមកដល់សព្វថ្ងៃនេះសិនចុះ លុះកាណាតែបានសេចក្ដីច្បាស់ប្រាកដមកជាក្រោយសឹមដំរូវឡើងវិញជាថ្មី ។

បណ្ណាល័យ នៅថ្នាក់ជាន់ក្រោមហៅថារោងក្រយា នៅថ្នាក់ទី ២ ហៅថាប៉ម ហើយនៅថ្នាក់ទី ៣ ហៅថាហោត្រៃ ។ ពាក្យខាងក្រោយនេះត្រូវគ្នានឹងពាក្យថា "បណ្ណាល័យ" ។

ឈ្មោះទី ១ សំដៅទៅលើគ្រឿងអាហារ ទំនងជាឈ្មោះផ្ទះបាយឬឃ្លាំងទុកគ្រឿងប្រដាប់សម្រាប់ម្ហូបបំណី ឈ្មោះនេះមិនទំនងនឹងឲ្យទទួលយកបាយឡើយ ។

ហើយឈ្មោះទី ២ សំដៅលើគ្រឿងដែលជាបន្ទាយ ក៏មិនបានទំនងឲ្យជឿថាជាពិតដែរ ។

ដែលធ្វើឲ្យមានប្រាសាទតូចៗនេះឡើង ដោយមានសួល ឈើរត្រង់នៅពីខាងមុខ នោះប្រយោជន៍ដើម្បីបន្ទយសួលពីខាងជើងទៅខាងត្បូងនៃប្រាសាទ កាត់តាមអាសនៈទៅជ្រុងខាងកើត គឺធ្វើឲ្យបានថ្នាក់ ២ ជាដំបូងនោះមានបណ្ដោយយ៉ាងវែងនៅស្លាបខាងលិចនៃថែវមុខខាងត្បូងនឹងខាងជើង ។ ផ្លូវធំដែលចូលទៅកាន់មុខប្រាសាទទាំងនេះ មិននៅចំកណ្ដាលទេ ។

នៅជុំវិញប្រាសាទ មានទីព្រះលានដែលមានជើងកល់ផុតឡើង កំពស់ប្រមាណ ២ ម៉ែត្រពីផ្ទៃដីខាងក្រៅ ។ ទីនេះមានកំពស់ស្មើគ្នានឹងផ្ទៃនឹងផ្លូវធ្លាចូលពីខាងលិច ។ ទីព្រះលានដែលមានស្មៅដុះពាសពេញនេះ មានប្រកាន់ដៃថ្មព័ទ្ធជុំវិញ ហើយនៅចុងប្រកាន់ដៃនីមួយ ៗ សុទ្ធតែមានក្បាលនាគនៅសងខាងជណ្ដើរ នឹងសងខាងផ្លូវដែលចូលមក ។

ទ្វារធំដែលចូលមកកាន់ប្រាសាទពីទិសខាងលិចនោះមាន ៣ ទ្វារកណ្ដាលនោះ ពីខាងមុខមានផ្ទៃខ្ពស់ឡើងរាងជើងក្អែក ហើយជញ្ជាំងដែលធ្វើទប់ផ្ទៃនេះមានសសរមូល ១ ជួរ

គាំទៀត ដើម្បីទ្រទ្រង់ក្រាលខាងផ្ទៃលើ មានជណ្ដើរ ៣ សម្រាប់ឡើងទៅកាន់ទីផ្ទៃនេះ គឺពីខាងជើង ១ ខាងត្បូង ១ និងខាងលិច ១ ។

ទីផ្ទៃនេះមានកំពស់ស្មើគ្នានឹងខឿនក្រៅនៃថែវថ្នាក់ទី ១ និងកន្លែងកណ្ដាល ថែវដែលលើក ៣ កាំជណ្ដើរឡើង ។

កាលណាតែស្ដេចយាងចូលក្នុងប្រាសាទឬយាងចេញពីប្រាសាទនេះ នោះទ្រង់ប្រថាប់នៅលើផ្ទៃនេះជាមួយនឹងរាជ-បរិពារ ដើម្បីនឹងវិនិច្ឆ័យសេចក្ដីបណ្ដឹងរាស្ត្រ ឬដើម្បីនឹងទស្សនានូវសេនាទាហានដែលលើកជាក្បួនជុំវិញប្រាសាទនេះ ។ កន្លែងដែលនៅជុំវិញផ្ទៃនេះ ទាបជាងបន្តិចនោះទុកសម្រាប់នាហ្មឺនសព្វមុខមន្ត្រីដែលមានបណ្ដាស័ក្តិទាបមក ។

គេប្រទះឃើញទីផ្ទៃបែបនេះ នៅទ្វារចូលក្នុងប្រាសាទឯទៀតជាច្រើនក្នុងទីបរិវេណអង្គរ ។

តែបើទោះជាយ៉ាងដូចម្ដេចក្ដី ក៏ត្រូវកុំយល់ថាកន្លែងទាំងនេះធ្វើទុកសម្រាប់ឡើងដំរី ដូចជាអ្នកតែងរឿងខ្លះបានពោលនោះឡើយ ។

សេចក្ដីដែលឃើញមានបង្កាន់ដៃធ្វើជារូបនាគបណ្ដោយតាមគែមផ្ទៃ ក៏ល្អមឲ្យកំបាត់នូវសំអាងនេះបានយ៉ាងធួន ។

បំណែកទិសខាងលិចមានថែវដែលមានដំបូល ៣ ខ្នងតភ្ជាប់ថែវថ្នាក់ទី ១ ទៅនឹងថែវថ្នាក់ទី ២ ដែលមានផ្ទៃកំពស់ដេញខ្ពស់ៗ ឡើង តាមបណ្ដោយផ្លូវបូលទាំង ៣ ដែលនៅកណ្ដាល ។

មានថែវ ១ កាត់ទទឹងបំកណ្ដាលថែវទាំង ៣ នេះមកទៀតធ្វើឲ្យមានជាទី ៤ ជ្រុងជ្រៅ ៤ មានរាងជាស្រះ ហើយដែលមានមនុស្សជាច្រើនយល់ថាជាស្រះ ព្រោះក្រឡេកមើលទៅនាំឲ្យយល់ស្គាល់បានថាដូច្នេះ ប៉ុន្តែលុះសង្កេតពិនិត្យទៅ សេចក្ដីយល់នេះឃើញមិនពិត ។ តាមការពិតនោះ កន្លែងទាំងនេះមិនមែនកន្លែងសម្រាប់ដើរឆ្លងឡើយ ព្រោះមិនឃើញធ្វើអ្វីសម្រួលការដើរឆ្លងកាត់ទៅមកសោះ កន្លែងនេះគ្រាន់តែជាផ្នែករបស់ផ្លាក្នុងនៃថ្នាក់ទី ១ ដែលកាត់ទទឹងថែវទាំង ៣ ដែលរំទើបនឹងពោលហើយប៉ុណ្ណោះ ។ បាននៃទីដែលគេហៅថាស្រះនេះ

គឺជាផ្ទៃដីនៃទីធ្លាក្នុងនេះឯង ដែលគេបានក្រាលថ្មវិញ មិនដាំស្មៅដូចទីឯទៀត ។

ជាមុននឹងសារុបសេចក្ដី អំពីសេចក្ដីយល់ឃើញរបស់ខ្ញុំ ដែលនាំឲ្យបោះបង់សេចក្ដីជឿថាស្រះបេញនោះ ខ្ញុំធ្វើសេចក្ដីសំគាល់យ៉ាងធម្មតាសិន គឺថាប្រសិនបើជាងខ្មែរបានធ្វើជាស្រះមែន ហេតុអ្វីក៏ស្រះទាំងនេះគ្មានដក់ទឹកសោះ ទោះក្នុងរដូវភ្លៀងក្ដី ។

ប៉ុន្តែសេចក្ដីសំអាង ដែលជាសំខាន់ជាងគេរបស់ខ្ញុំ ដូចមានខាងក្រោយនេះ គឺថាបណ្ដាស្រះទាំងប៉ុន្មានដែលគេកសាងក្នុងសម័យអង្គរនោះ សុទ្ធតែមានធ្វើជាថ្នាក់បុះគ្រប់ជ្រុងទាំង ៤ ដរាបដល់ផ្ទៃទឹក ។ ខ្ញុំនឹងយកស្រះទាំងប៉ុន្មានដែលមានក្នុងក្រុងនគរធំមកជាគំរូតួយ៉ាង ព្រមទាំងស្រះប្រាសាទនាគព័ន្ធនឹងស្រះស្រង់ដែលគេតែងស្គាល់ដឹងគ្រប់គ្នា ។ តាមដែលខ្ញុំបានដឹងនោះ គឺថាក្បួននេះគ្មានយ៉ាងម៉ិបប្លែកទៅទៀត ក្រៅអំពីស្រះទាំង ៤ ដែលនៅក្នុងកំផែងទី ២ ខាងកើតនៃបន្ទាយព្រះខ័នទៅកំពង់ស្វាយឡើយ ។

ស្រះនៅក្រៅកំផែងនគរវត្ត ដែលជាគូជុំវិញកំផែង នោះក៏មានជាថ្នាក់សម្រាប់ចុះដូបគ្នាទាំងអស់ ។

ខ្ញុំពោលបន្ថែមថា គ្មានប្រាសាទណាមួយក្នុងសម័យ ព.ស. ១៦៤៣ ដល់ ១៦៧៣ មានស្រះទឹកនៅទីខាងក្នុងឡើយ ដែលខ្ញុំនិយាយនេះគឺខ្ញុំថា គេមិនដែលធ្វើស្រះសម្រាប់ដូតទឹកនៅក្នុងកំផែងប្រាសាទឡើយ ព្រោះប្រហែលជានឹងមានធ្វើជាតួប្រាសាទអ្វី១ ក្នុងទីប្រាសាទធំៗ សម្រាប់ជាបន្ទប់ទឹកមិនខាន ។

ក្រៅអំពីទ្វារធំទាំង ៣ នោះអាចនឹងចូលទៅកាន់ថែវថ្នាក់ទី ១ បាន ដោយបង្កាន់ដៃដែលនៅក្នុងប្រាសាទជ្រុង ។ ឯទ្វារធំនៅកណ្ដាលនោះទុកសម្រាប់ស្ដេចឬមន្ត្រីធំ ៗ ហើយឯទ្វារដែលនៅៗជ្រុងនោះទុកសម្រាប់សាធារណជន ដើរចូលទៅក្នុងថែវដើម្បីមើលរឿងរ៉ាវដែលឆ្លាក់នៅលើជញ្ជាំង ។ ក្នុងសង្ខាននេះគួរតែវិនិច្ឆ័យសេចក្ដីថា ពួកអ្នកចូលទៅមើលនោះមិនអាចនឹងដើរមើលបានជុំវិញឡើយ ក្នុងថែវទី ១ នេះ ដោយឥតបុះមក

កាន់ទីព្រះលានខាងក្នុងឡើយ ។ ឧបមាដូចជាបានរូវលោដែល មើលរឿងនៅជញ្ជាំង នៅទីស្លាបប៉ែកខាងជើងនៃមុខខាងលិច និងរឿងនៅជញ្ជាំង នៅទីស្លាបប៉ែកខាងលិចនៃមុខខាងជើង នោះ ហើយអ្នកដើរមើលត្រូវតែចុះទៅកាន់ទីជ្រុងខាងជើងខាង លិច ដើម្បីនឹងទៅមើលរឿងតទៅទៀត ដោយចូលតាម ជ្រុង ១ កន្លែងទៀត ហើយដើម្បីនឹងកុំឲ្យដើរកាត់កន្លែងដែល ទុកសម្រាប់មន្ត្រីធំៗ ឬក៏អធិការនៃប្រាសាទ ។

សេចក្ដីឧបមានេះនាំឲ្យឃើញថាសាធារណជនមិនដែល បានចូលទៅកាន់ថ្នាក់ទី ២ នៃប្រាសាទនេះឡើយ ត្រង់នេះមាន សេចក្ដីបញ្ជាក់ដោយភាពទំនងនៃថែវថ្នាក់ទី ២ នេះឯង គឺគ្មាន ទំនងឲ្យមនុស្សច្រើនដើរព័ទ្ធជុំវិញទេ ។ គេអាចនឹងសំគាល់ បានដោយដាក់ថា ថែវថ្នាក់ទីមួយទាំងប៉ុន្មាននោះបោះបង្អួច ១ ឲ្យមើលលេចទៅទីខាងក្នុងសោះ ហើយថ្នាក់ទី ២ ទៀតក៏គ្មាន បោះជារន្ធអ្វីឲ្យមើលលេចចេញទៅក្រៅឡើយ ។ គឺមានសេចក្ដី កំណត់ជាដាច់ខាតត្រូវធ្វើថ្នាក់ទាំងពីរឲ្យដាច់ស្រឡះពីគ្នា លើក

តែត្រង់ផ្លូវចូលចំកណ្តាលពេញ ដែលមានតែអ្នកមានយសស័ក្តិ ទើបអាចដើរចូលបាន ។

ថែវទាំងប៉ុន្មានក្នុងជាន់ទី ២ នោះគេធ្វើឡុងធំត ទំនងគេទុកសម្រាប់តែពួកលោកសង្ឃដើរស្មឹងស្មាធិភាវនា នឹងគយឃ្លាំផ្លូវប្រាសាទកណ្តាលអំពីទីនេះទៅ ។ ឯប្រាសាទជ្រុងនៃថ្នាក់ទី ២ នេះ មានកំពូលទំនងជាបំរុងទុកដំកល់ទេវរូបផ្សេង ៗ ដូចយ៉ាងប្រាសាទជ្រុងនៅក្នុងជាន់ទី ៣ ដែរ ។

ចំណែកឯថែវក្នុងជាន់ទី ១ វិញ នោះឥតមានកន្លែងធ្វើជាកំពូលល្មមឲ្យជឿបានថាជាទីអាសនៈឡើយ ។ ឃើញថាថែវថ្នាក់ទី ១ ទំនងជាសម្រាប់សាធារណជនណាស់ ហើយគេអាចនឹងពោលបានថា កន្លែងរបស់ប្រាសាទនគរវត្ត ដែលជាទីស័ក្តិសិទ្ធិនោះ គឺរាប់តាំងតែពីថ្នាក់ទី ២ ឡើងទៅ ។

ក្រៅអំពីផ្លូវធំទាំង ៣ ដែលចូលតាមថែវរបស់លានរាងជើងក្អែកនៃមុខខាងលិច នោះគេអាចនឹងទៅកាន់ថ្នាក់ទី ២ បាន ដោយជណ្តើរខ្ពស់ល្មមដែលនៅៗទីកណ្តាលនឹងនៅជ្រុងថែវទាំងនេះ ។

ផ្លូវឡើងទៅកាន់ថ្នាក់ទី ៣ ក៏មានជណ្តើរបី ៗ ក្នុង ១ ជ្រុង គ្រប់ជ្រុងទាំង ៤ តែបំណែកខាងមុខធំដែលនៅខាងលិចប្លែកពីជ្រុងឯទៀតបន្តិចដោយមានផ្លូវតូច ១ ក្រាលថ្ម លើកខ្ពស់ឡើងដោយមានសសរតូច ៗ ទ្រ ផ្លូវតូចនេះភ្ជាប់ទ្វារធំនៅជាន់ទី ២ ទៅនឹងបង្កាន់ដៃកណ្តាល និងភ្ជាប់ទៅនឹងប្រាសាទតូច ៗ ពីរ ដែលជាប់មកនឹងប្រាសាទធំ ។

ថ្នាក់ទី ៣ បង្ហាញឲ្យឃើញនូវផែនទីគ្រឿងរបនាកណ្តាល តាមធម្មតាប្រាសាទធំៗរបស់ខ្មែរ ។ មានកំពូលយ៉ាងសំខាន់ ដែលគេសម្រាប់ដំកល់នូវព្រះទេវរូបនៅជាកណ្តាល ហើយមានកំពូល៤នៅជុំវិញគ្រប់មុំទៀត ដែលទុកជាអាសនៈបន្ទាប់បន្សំ។ គឺជាផែនទីប្រាសាទមេបុណ្យ ប្រែរូប តាកែវ ហើយតក្រោយមក គឺប្រាសាទបន្ទាយក្តី និងតាព្រហ្ម ប៉ុន្តែមានកែប្រែប្រឡំបល់ ដែលនាំឲ្យបាត់សេចក្តីល្អទៅវិញ ដូចយ៉ាងបែបសាងប្រាសាទក្នុងសម័យបាយ័ននោះឯង ។

តាមសេចក្តីរៀបរាប់អំពីបែបភាពប្រាសាទដែលមានមកហើយនេះ គេអាចនឹងឃើញបានជាសេចក្តីសំអាងរបស់អ្នក

តែងរឿងខ្លះ ដែលទុកដាក់នគរវត្តថាជាប្រាសាទសម្រាប់ស្តេចគង់ មិនគួរឲ្យជឿតាមឡើយ ។

ផ្លូវដែលចូលពីក្រៅទៅកាន់ប្រាសាទនគរវត្តនោះ មានក្រាលថ្មហើយមានទទឹង ១២ ម៉ែត្រ មានបង្កាន់ដៃសងខាងជាខ្លួននាគលូនកាត់គូនៅមុខកំផែង ហើយមានទីវាលដែលមានខឿន ១ មានបង្កាន់ដៃហើយមានសត្វសិង្ហឈរចាំនៅ ។

មានប្រាសាទ១មានទ្វារ៣ ហើយមានស្ពានពីរចេញទៅខាងជើងនឹងទៅខាងត្បូង កាត់ផ្លូវជញ្ជាំងកំផែង ដើម្បីភ្ជាប់ទៅនឹងផ្លូវខាងក្នុង ។ ទ្វារទាំង ៣ នេះប្លែកអំពីទ្វារក្រៅនៃប្រាសាទឯទៀតផ្សេង ៗ ព្រោះទ្វារទាំង ៣ នេះទុកសម្រាប់អ្នកថ្មើរជើង នៅពីមុខមានសុំហើយមានបង្កាន់ដៃ ។

ដោយត្រូវគិតថា គង់មានគេហស្ថានផ្សេងៗ សង់ខាងក្នុងកំផែងជាបន្ថែមដោយគ្រឿងដែលស្រាលៗមានឈើជាដើម ដូចយ៉ាងទីសម្រាប់នៅ កន្លែងជាឃ្លាំងដាក់របស់ទ្រព្យ នោះការដឹក

នាំឥវ៉ាន់ចេញចូល នោះគេត្រូវចេញចូលតាមទ្វារ ២ ដែលនៅៗ ចុងបំផុតស្លាបទាំងសងខាងនៃប្រាសាទកណ្ដាលដែលជាទ្វារ សម្រាប់បររទេះនឹងសត្វពាហនៈចេញចូលបាន ។ ទ្វារទាំងនេះ សព្វថ្ងៃគេឲ្យឈ្មោះថាទ្វារដំរី ប៉ុន្តែទំនងជាមិនបំរុងសម្រាប់តែ ដំរីម្យ៉ាងប៉ុណ្ណោះទេ ។

ដែលគេធ្វើទ្វារនេះ ក្នុងកន្លែងដាច់តែងឆ្ងាយពីវិហារជិត ខាងដែលចូលទៅខាងក្នុង នាំឲ្យសន្និដ្ឋានបានថាជាទ្វារសម្រាប់ ចេញចូលក្នុងការងារជាធម្មតា ។

ក្នុង ៣ ជ្រុងទៀតនោះ មានកន្លែងកណ្ដាលអាសនៈមក កាត់ឲ្យដាច់អាសនៈនោះ មានផ្លូវចូលចេញតែមួយហើយមាន ធ្វើជាបន្ទប់ ២ បណ្ដោយតាមគ្នា ។

គោបុរៈដែលនៅ ៗ មុខខាងជើងនឹងខាងត្បូងនេះ មិនជា ឃើញមានប្រយោជន៍ធំអ្វីឡើយ ព្រោះគេមិនអាចឆ្លងរំលងគូ ដែលនៅជុំវិញកំផែងទៅបាន ។ គោបុរៈទាំងនេះប្រយោជន៍ គ្រាន់តែចុះទៅកាន់ផ្លូវតូចដែលនៅអមជើងកំផែងក្រៅប៉ុណ្ណោះ ។

បំណែកទិសខាងកើត គេមានធ្វើផ្លូវមួយក្នុងវេលាដែលជីកគូអមកំផែងដើម្បីនឹងដឹកនាំប្រដាប់ប្រដា ។ នៅសងខាងផ្លូវនេះឃើញមានស្នាមជញ្ជាំងនៅឡើយ ធ្វើឲ្យដឹងបានថាជាមាត់ស្រះដែលមានថ្នាក់ៗ ដោយហេតុនេះគេអាចនឹងវិនិច្ឆ័យសេចក្ដីថា ស្រះដែលមានខាងប៉ែកខាងលិចនឹងប៉ែកខាងកើតនេះ ជាស្រះ ២ ជាប់ពីគ្នាមិនមែនជាប់ជាមួយគ្នាទេ ។

លោកស៊ែរ្ស បារីយ៉េរ ជាជាងផាត់ពណ៌គំនូរ ជាតិបារាំងសែសដែលបានទទួលគ្រឿងឥស្សរិយៈយសយ៉ាងខ្ពស់ ក្នុងការផាត់ពណ៌គំនូរបារាំងសែស ព្រោះលោកជាជាងដែលមានគុណវុឌ្ឍិយ៉ាងច្រើន ។ គឺជាជាងជំនាញក្នុងការផាត់ភាពភូមិឋាននឹងរូបភាព ។ រាជការក្រុងបារាំងសែស ទើបនឹងបញ្ជូនខ្លួនលោកមកក្នុងប្រទេសឥណ្ឌូស៊ិន ដើម្បីឲ្យលោកធ្វើនូវភាពភូមិឋាន ជាផ្ទាំងៗ យកទៅតាំងនៅក្រុងបារាំងសែស ឲ្យបានជាតិបារាំងទាំងឡាយ ដឹងស្គាល់នូវសេចក្ដីលំអផ្សេងៗ នៃភូមិឋានប្រទេសឥណ្ឌូស៊ិន នឹងអ្នកប្រទេសនេះ ។



នេះជារូបភាពពីរ ដែលលោកស៊ុយប្រារីយែរ អនុញ្ញាតឲ្យយើងបោះពុម្ព គឺជារូបភាពដែលលោកផាត់នៅក្រុងភ្នំពេញ ។

យើងមានសេចក្ដីសោមនស្សណាស់ ដែលបានបង្ហាញរូបនេះដល់សាធារណជនដែលចូលមកមើលព្រះរាជបណ្ណាល័យ ។

# កម្មបថ ពិស្ដារ

# អារម្ភកថា

## អាចារ្យ ង៉ែត-ឥន្ទ្រ នាមធាយាព្រហ្មត្ថេរ

ខ្ញុំមានសេចក្ដីនឹករឭកដល់មាតារបស់ខ្ញុំ ដែលលោកទទួលមរណភាពទៅនៅថ្ងៃព្រហស្បតិ៍ ២ រោចខែផល្គុន ឆ្នាំមមីទោស័ក ព. ស. ២៤៧៣ ក្នុងអាយុសង្ខារគំរប់ ៦៧ ឆ្នាំ ពីត្រឹមថ្ងៃមរណភាពមកដល់ថ្ងៃ ១៣ កើតខែចេត្រឆ្នាំវកចត្វាស័ក ព. ស. ២៤៧៤ ខ្ញុំព្រមទាំងបងប្អូនទាំងអស់ធ្វើទក្ខិណានុប្បទាន និងធម្មទាន ឧទ្ទិស្សផលបុណ្យជូនទៅចំពោះមាតាបិតារបស់ខ្ញុំ ក្នុងឃុំដំណាក់កន្ទួត ខណ្ឌកំពង់ត្រាច ខេត្តកំពត ។

កាលមុននឹងធ្វើបុណ្យនោះខ្ញុំបានស្រង់យកនានាគាថា និងកុសលាកុសលកម្មបថ ក្នុងគម្ពីរអង្គុត្តរនិកាយទសកនិបាតសា-មញ្ញវគ្គមកប្រែជាភាសាខ្មែរជាមួយនឹងលោកអាចារ្យ (ឈ-ស៊ុម) គ្រូបង្រៀនសាលាបាឡីរងវត្តក្រាំងដូង ឃុំសំរោង ស្រុកទូកមាស ខេត្តកំពត លុះរៀបរៀងស្រេចហើយ បានយកទៅប្រគេនលោកគ្រូអាចារ្យ (ហ.ចៀវ) អាចារ្យសាលាបាឡីជាន់ខ្ពស់ក្រុង

ភ្នំពេញឲ្យលោកជួយផ្ទៀងផ្ទាត់ លោកក៏បានជួយផ្ទៀងផ្ទាត់ត្រឹមត្រូវតាមបាឡីសព្វគ្រប់ ។

ខ្ញុំបានរកលោកគ្រូបង្រៀនបឋមវិជ្ជា (ឧត្ត) វត្តក្រាំងដូងឲ្យជួយសរសេរបំឡងដាក់សៀវភៅបែកជាធម្មទានក្នុងឱកាសបុណ្យនោះ ។

## គាថាដែលដកយកពីគម្ពីរផ្សេងៗ

### មកប្រែជាភាសាខ្មែរ

១– សហស្សមបិ ចេ វាចា  អនត្ថបទសញ្ហិតា
ឯកំ អត្ថបទំ សេយ្យោ  យំ សុត្វា ឧបសម្មតិ ។

(ធម្មប១)

ថាបើវាចាដែលបុគ្គលពោលទៅហើយ សូម្បីដល់ទៅ ១ ពាន់ម៉ាត់ក៏ដោយ ប៉ុន្តែជាពាក្យមិនប្រកបដោយបទមានប្រ-យោជន៍ ឯបទមានប្រយោជន៍ត្រឹមតែ ១ បទប៉ុណ្ណោះក៏ប្រសើរវិសេសជាង ព្រោះបុគ្គលបានស្តាប់ (សំដីនោះ) ហើយរមែងស្ងប់រម្ងាប់ (នូវរាគាទិកិលេស) បាន ។

២– សហស្សមបិ ចេ គាថា  អនត្ថបទសញ្ហិតា
ឯកំ គាថាបទំ សេយ្យោ  យំ សុត្វា ឧបសម្មតិ ។

(ធម្មប១)

ថាបើគាថាដែលបុគ្គលពោលទៅហើយ សូម្បីដល់ទៅ១ ពាន់គាថាក៏ដោយ ប៉ុន្តែមិនប្រកបដោយបទមានប្រយោជន៍ ឯបទដែលមានប្រយោជន៍ត្រឹមតែ ១ បទប៉ុណ្ណោះ ក៏ប្រសើរ

វិសេសជាង ព្រោះបុគ្គលបានស្តាប់បទគាថានោះហើយរមែងស្ងប់រម្ងាប់ (នូវរាគាទិកិលេស) បាន ។

៣– យោ ច គាថាសតំ ភាសេ អនត្ថបទសញ្ហិតំ
ឯកំ ធម្មបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។

(ធម្មបទ)

ទោះបើបុគ្គលណាមួយពោលនូវពាក្យដល់ទៅ១រយគាថាក៏ដោយ ប៉ុន្តែមិនប្រកបដោយបទមានប្រយោជន៍ ឯបទធម៌ដែលមានប្រយោជន៍ត្រឹមតែ១បទប៉ុណ្ណោះក៏ប្រសើរវិសេសជាង ព្រោះបុគ្គលបានស្តាប់ហើយរមែងឲ្យស្ងប់រម្ងាប់ (នូវរាគាទិកិលេស) បាន ។

៤– យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ
ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ ។

(ធម្មបទ)

ទោះបីបុគ្គលណាមួយមានជីវិតរស់នៅបានដល់ទៅ១រយឆ្នាំក៏ដោយ ប៉ុន្តែជាអ្នកទ្រុស្តសីលមានចិត្តមិនខ្ជាប់ខ្ជួន (ក្នុងកុសលធម៌) ជីវិតរបស់បុគ្គលនោះមិនប្រសើរស្មើនឹងជីវិតរបស់

អ្នកដែលរស់នៅត្រឹមតែមួយថ្ងៃ  តែជាអ្នកមានសីលមានប្រាជ្ញា ពិនិត្យពិចារណានោះឡើយ ។

៥– ឧស្សូរសេយ្យំ អាលស្សំ  បណ្ឌិក្កំ ទីឃសោត្តិយំ
ឯកស្សទ្ធានគមនំ  បរទារុបសេវនំ
ឯតំ ព្រាហ្មណ សេវស្សុ  អនត្ថំ តេ ភវិស្សតិ ។
(ធម្មបទ)

ដេកដល់ថ្ងៃ ១ ខ្ជិលច្រអូស ១ ខ្ញូបកាច ១ ដេកទ្រមក់ ១ ដើរផ្លូវឆ្ងាយតែម្នាក់ឯង ១  សេពគប់បំពោះប្រពន្ធអ្នកដទៃ ១ ម្នាលព្រាហ្មណ  អ្នកចូរសេពអំពើទាំង ៦ យ៉ាងនេះចុះ  សេចក្តីវិនាសនឹងមានដល់អ្នកមិនខាន ។

៦– នោ ចេ អស្សសកាពុទ្ធិ  វិនយោ វា សុសិក្ខិតោ
វនេ អន្ធមហិសោវ  ចរេយ្យ ពហុកោ ជនោ
យស្មា ច បនិធេកច្ចេ  អាចារម្ហិ សុសិក្ខិតា
តស្មា វិនិតវិនយា  ធីរា ចរន្តិ សុសមាហិតាតិ ។
(ទីបនី)

ថាបើមិនមានប្រាជ្ញារបស់ខ្លួន ឬមិនមានវិន័យដែលខ្លួនបានសិក្សាល្អហើយក៏ប្រៀបដូចក្របីខ្វាក់ដែលគេបរង្គុតទៅក្នុងព្រៃយ៉ាងណា ជនជាច្រើនដែលគ្មានប្រាជ្ញាឥតបានសិក្សាវិន័យក៏មានសភាពយ៉ាងនោះដែរ ប៉ុន្តែជនពួកខ្លះក្នុងលោកនេះដែលបានសិក្សាប្រពៃ ហើយក្នុងសំណាក់អាចារ្យ ព្រោះហេតុដូច្នោះបានជាអ្នកប្រាជ្ញទាំងឡាយ ប្រព្រឹត្តវិន័យដែលអាចារ្យណែនាំត្រឹមត្រូវ ហើយជាអ្នកមានចិត្តខ្ជាប់ខ្ជួនហើយដោយប្រពៃ ។

៧ – វាចានុរក្ខី មនសា សុសំវុតោ
កាយេន ច អកុសលំ ន កយិរា
ឯតេ តយោ កម្មបថេ វិសោធយេ
អារាធយេ មគ្គំ ឥសិប្បវេទិតន្តិ ។

(ធម្មបទ)

បុគ្គលត្រូវរក្សាវាចា ត្រូវសង្រួមចិត្ត ដោយប្រពៃ មិនត្រូវធ្វើអកុសលកម្មដោយកាយ ត្រូវជំរះកម្មបថទាំងបីនេះឲ្យម៉ត់ចត់ ត្រូវត្រេកអរចំពោះមគ្គដែលឥសី គឺព្រះពុទ្ធជាម្ចាស់ទ្រង់ប្រកាសទុកហើយ ។

ក្នុងសាមញ្ញវគ្គ គម្ពីរអង្គុត្តរនិកាយ ទសកនិបាត

## អកុសលកម្មបថ

គន្លងឬផ្លូវនៃអំពើជាអកុសល ហៅថា អកុសលកម្មបថ ៗ នេះមាន ១០ យ៉ាងគឺ កាយកម្ម អំពើដែលធ្វើដោយកាយ មាន ៣ យ៉ាង វចីកម្ម អំពើដែលធ្វើដោយវាចាមាន ៤ យ៉ាង មនោកម្ម អំពើដែលធ្វើដោយចិត្តមាន ៣ យ៉ាង រួមត្រូវជា ១០ ក្នុងមួយ ៗ បែកចេញជា ៤ យ៉ាង តាំងអំពីបាណាតិបាតរៀងរហូតដល់មិច្ឆាទិដ្ឋិ រួមទាំងអស់ត្រូវជាអកុសលកម្មបថ ៤០ យ៉ាងដូច្នេះតទៅ ។

ចត្តារីសាយ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ម្នាលភិក្ខុទាំងឡាយបុគ្គលប្រកបព្រមហើយដោយធម៌ទាំងឡាយ៤០ប្រការដែលខ្ញុំនាំមកហើយយ៉ាងណា ក៏តាំងនៅក្នុងអបាយយ៉ាងនោះ ។

កតមេហិ បត្តារីសាយ ធម៌ទាំងឡាយ៤០ប្រការដូចម្ដេច

១ – អត្តនា ច បាណាតិបាតី ហោតិ គឺជាអ្នកមានចេតនាជាហេតុញាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វដោយខ្លួនឯង ។

២ – បរញ្ច បាណាតិបាតេ សមាទបេតិ គឺបបួលឬដឹកនាំអ្នកដទៃឲ្យធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

៣ – បាណាតិបាតេ ច សមនុញ្ញោ ហោតិ គឺជាអ្នកមានចិត្តត្រេកអរក្នុងកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ ។

៤ – បាណាតិបាតស្ស ច វណ្ណំ ភាសតិ គឺពោលពណ៌នាគួរគុណនៃកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

៥ – អត្តនា ច អទិន្នាទាយី ហោតិ គឺជាអ្នកមានចេតនាជាហេតុកាន់យកនូវវត្ថុដែលគេមិនបានឲ្យដោយកាយ ឬដោយវាចា ដោយខ្លួនឯង ។

៦–បរញ្ច អទិន្នាទានេ សមាទបេតិ គឺបបួលឬដឹកនាំអ្នកដទៃឲ្យកាន់យកនូវវត្ថុដែលគេមិនបានឲ្យដោយកាយឬដោយវាចា ។

៧–អទិន្នាទានេ ច សមនុញ្ញោ ហោតិ គឺជាអ្នកមានចិត្តត្រេកអរក្នុងកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យដោយកាយឬដោយវាចា ។

៨–អទិន្នាទានស្ស ច វណ្ណំ ភាសតិ គឺពោលពណ៌នានូវគុណនៃវត្ថុដែលគេមិនបានឲ្យដោយកាយឬដោយវាចា ។

៩–អត្តនា ច កាមេសុ មិច្ឆាចារី ហោតិ គឺជាអ្នកមានកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយដោយខ្លួនឯង ។

១០–បរញ្ច កាមេសុ មិច្ឆាចារេ សមាទបេតិ គឺបបួលឬដឹកនាំអ្នកដទៃឲ្យប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

១១–កាមេសុ មិច្ឆាចារេ ច សមនុញ្ញោ ហោតិ គឺជាអ្នកមានចិត្តត្រេកអរក្នុងកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

១២–កាមេសុ មិច្ឆាចារស្ស ច វណ្ណំ ភាសតិ គឺពោលពណ៌នានូវគុណនៃកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

១៣– អត្តនា ច មុសាវាទី ហោតិ គឺជាអ្នកពោល នូវពាក្យកុហកដោយខ្លួនឯង ។

១៤– បរញ្ច មុសាវាទេ សមាទបេតិ គឺបបួលឬដឹកនាំអ្នកដទៃឲ្យពោលនូវពាក្យកុហក ។

១៥– មុសាវាទេ ច សមនុញ្ញោ ហោតិ គឺជាអ្នកមានចិត្តត្រេកអរក្នុងកិរិយាពោលនូវពាក្យកុហក ។

១៦– មុសាវាទស្ស ច វណ្ណំ ភាសតិ គឺពោលពណ៌នានូវគុណនៃកិរិយាពោលនូវពាក្យកុហក ។

១៧– អត្តនា ច បិសុណាវាចោ ហោតិ គឺជាអ្នកមានកិរិយាពោលនូវពាក្យញុះញង់ស៊កសៀតបំបែកបំបាក់អ្នកដទៃ ដោយខ្លួនឯង ។

១៨– បរញ្ច បិសុណាយ វាចាយ សមាទបេតិ គឺបបួលឬដឹកនាំអ្នកដទៃ ឲ្យពោលនូវពាក្យញុះញង់ស៊កសៀតបំបែកបំបាក់អ្នកដទៃ ។

១៩ – បិសុណាយ វាចាយ ច សមនុញ្ញោ ហោតិ គឺជាអ្នកមានចិត្តត្រេកអរក្នុងកិរិយាពោលនូវពាក្យញុះញង់សិកសៀតបំបែកបំបាក់អ្នកដទៃ ។

២០ – បិសុណាយ វាចាយ ច វណ្ណំ ភាសតិ គឺពោលពណ៌នានូវគុណនៃកិរិយាពោលនូវពាក្យញុះញង់ សិកសៀតបំបែកបំបាក់អ្នកដទៃ ។

២១ – អត្តនា ច ផរុសាវាចោ ហោតិ គឺជាអ្នកមានកិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោកដេរប្រទេចអ្នកដទៃជាដើម ដោយខ្លួនឯង ។

២២ – បរញ្ច ផរុសាយ វាចាយ សមាទបេតិ គឺបបួលឬដឹកនាំអ្នកដទៃឲ្យពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោកដេរប្រទេចអ្នកដទៃជាដើម ។

២៣ – ផរុសាយ វាចាយ ច សមនុញ្ញោ ហោតិ គឺជាអ្នកមានចិត្តត្រេកអរក្នុងកិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោកដេរប្រទេចអ្នកដទៃជាដើម ។

២៤– ផរុសាយ វាចាយ ប វណ្ណំ ភាសតិ គឺពោល ពណ៌នានូវគុណនៃកិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោកជេរប្រទេចអ្នកដទៃជាដើម ។

២៥– អត្តនា ច សម្ផប្បលាបី ហោតិ គឺជាអ្នកមានកិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍ដោយខ្លួនឯង ។

២៦– បរញ្ច សម្ផប្បលាបេ សមាទបេតិ គឺបបួលឬដឹកនាំអ្នកដទៃឲ្យពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

២៧– សម្ផប្បលាបេ ច សមនុញ្ញោ ហោតិ គឺជាអ្នកមានចិត្តត្រេកអរ ក្នុងកិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

២៨– សម្ផប្បលាបាយ ចវណ្ណំ ភាសតិ គឺពោលពណ៌នានូវគុណនៃកិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

២៩– អត្តនា ច អភិជ្ឈាលុ ហោតិ គឺជាអ្នកមានចិត្តសំឡឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបំរុងនឹងឲ្យបានមកជាទ្រព្យរបស់ខ្លួន ដោយខ្លួនឯង ។

# បញ្ជីរឿង

ទំព័រ

១– បរិវត្តគមនាគម ដំណើរអង់តួរណេ ក្នុងដែនកូស័ងស៊ីន ក្នុងឆ្នាំ ១៩៣៣ របស់ព្រះសាសនសោភណ ជី. ណាត ចាងហ្វាងរងសាលាបាឡី រៀបរៀង (ខេត្រហាទៀង) . . . . . . . . . . . . . . . . . . . . . ១០៩

២– អធិប្បាយពីវិធីសាងប្រាសាទនគរវត្ត របស់លោក ហ. មាហ្សាល (ត) . . . . ១៤៣

៣– កម្មបថពិស្តារ របស់ព្រះអាចារ្យ ង៉ែត-គង្គ រៀបរៀង (ត) . . . . . . . . . . ១៦៥

៤– រឿងធ្មេញដែយបណ្ឌិត របស់បុរាណ . . . . . . . . . . . . . . . . . ១៨១

# រូបផ្សេងៗ

១– រូបព្រះចេតិយ ៤ ជ្រុង នៅស្រុកបេគូ (ភូមា) . . . . . . . . . . . . . . ១៤១

២– រូបលោកសង្ឃភូមា ត្រឡប់ពីបិណ្ឌបាត រៀបនឹងចូលទៅក្នុងវត្ត . . . . . . ១១៧

# TABLE DES MATIÈRES


I. Tournée en Cochinchine de M. le Secrétaire Général de l'Institut Bouddhique (Hatiên et Châudôc)............. 119

II. Les travaux de l'édification des monuments d'Ang-Kor par H. Marchal — Traduit du Français en Cambodgien par Kromokar Chum-Mau.................................. 143

III. Extrait et traduction en cambodgien des poêmes Pali par Achar Nghet-Inh.................................. 165

IV. Conte populaire cambodgien inédit Histoire de Thmenh Chhey (à suivre).................................. 181


## HORS TEXTE:


I. Le bonze birman revenu de sa tournée de quête arrive devant l'entrée de sa pagode........................ 141

II. Pyramide à quatre faces (face sud) Pagode Kaikpun — Pégou (Birmanie).................................. 117



លោកសង្ឃភូមា ត្រឡប់មកពីបិណ្ឌបាតរៀបនឹងចូលទៅក្នុងវត្ត ។

បរិវជ្ជគមនាគម

## ដំណើរអង់គួរណោ

តាំងពីខែត្របាគៀងរៀងដល់ខែត្រាវិញ (កូស័ងស៊ីន) នៃអគ្គលេខាធិការ ពុទ្ធសាសនបណ្ឌិត្យ (ការប៉ីវ៉ែស) និង ព្រះសាសនសោភណ (ជោតញ្ញាណោ) ជួន-ណាត ចាង-ហ្វាងវង់សាលាបាឡីជាន់ខ្ពស់ ភ្នំពេញ ។

ព្រះសាសនសោភណ ជាអ្នកកត់ត្រាហើយរៀបរៀង ដូចមានសេចក្ដីតទៅនេះ:

ថ្ងៃអង្គារ ៤ កើតខែមិគសិរឆ្នាំរកាបញ្ចស័ក ព. ស. ២៤៧៦ ត្រូវនឹងថ្ងៃ ២១ ខែណោវ៉ំម គ. ស. ១៩៣៣ ម៉ោង ១៤ កន្លះ យើងចេញអំពីភ្នំពេញតាមផ្លូវកំពតដោយរថយន្តរាជការលេខ ៤៨ ទៅ ដល់ទៅគុសបែកទៅខាងឆ្វេងតាមផ្លូវទៅកំពង់ត្រាប-បាគៀង ។ រថយន្តផ្ទុកសៀវភៅព្រះរាជបណ្ណាល័យនឹងពុទ្ធ-សាសនបណ្ឌិត្យក៏ចេញទៅជាមួយគ្នាដែរ ។ ម៉ោង ១៧ ដល់ ទៅវត្តអង្គសុរភី ឃុំកន្ទោរ ខណ្ឌកំពង់ត្រាប ខែត្រកំពត ។

ខ្ញុំនឹងលោកព្រះគ្រូបរិយត្តិធម្ម ហាស់-ស៊ុក ដែលទៅជាមួយផងព្រមទាំងកម្មការឈ្មោះ អួង- ជី ស្ងួហ៊្វរឈ្មោះ យិន-ម៉ី កុមារកំឡោះឈ្មោះ ស៊ុន-ទិត ជាវេយ្យាវិចករបស់ខ្ញុំ នឹងកុមារជំទង់ឈ្មោះ យ៉ាវ-ស្រេង ជាវេយ្យាវិចករបស់លោកព្រះគ្រូបរិយត្តិធម្ម ហាស់-ស៊ុក ចូលទៅឈប់សំណាក់នៅវត្តអង្គស៊ុរភី ។ លោកគ្រូដែលចៅអធិការវត្តនេះជាមិត្រស្និទ្ធស្នាលនឹងខ្ញុំយូរឆ្នាំមកហើយលុះបានឃើញយើងទាំងអស់គ្នាចូលទៅដល់ ក៏មានសេចក្ដីរីករាយសាទរណាស់ ។ លោកអគ្គលេខាធិការហួសទៅសំណាក់ឯភោជនាគារ (បង្គលោ) នៅកែប ស្ងួហ៊្វរឈ្មោះកេត-ផន ក៏ទៅសំណាក់ឯកែបដែរ ។

## ខែត្រហាតៀង

ថ្ងៃពុធ ២២ ណោវ៉ែម ១៩៣៣ (៥ កើតខែមិគសិរ)

ម៉ោង ៧ កន្លះ (ព្រឹក) យើងចេញពីវត្តអង្គស៊ុរភីសំដៅទៅខែត្រហាតៀង (ខ្មែរហៅខែត្រពាម) ដែនកូសាំងស៊ីន ។ ម៉ោង ៨ (ព្រឹក) ដល់ទៅវត្តកោះបន្ទះ ឃុំគីឡូ (ខ្មែរហៅឃុំកោះបន្ទះ) ក្នុងខែត្រហាតៀង ។ យើងបានចូលទៅក្នុងវត្តនេះ

មានពួកបព្វជិតវត្តផ្សេងទៀត២វត្តគឺវត្តកោះទទា១ វត្តតាតែន១ ជា៣នឹងវត្តកោះបន្ទុះ មានភិក្ខុ-សាមណេររួមទាំងអស់ ២៥រូប មានគ្រហស្ថប្រហែលជា៧០នាក់ មកប្រជុំចាំយើង លោកអគ្គលេខាធិការបាន់និយាយពន្យល់រួចហើយ ខ្ញុំក៏បាននិយាយពន្យល់តាមដំណើរដែលនាំឲ្យមានសេចក្ដីចំរើន រួចហើយបានឲ្យចែករូបថ្ដិតពុម្ពដល់ពួកបព្វជិតនឹងពួកមន្ត្រីឃុំ ព្រមទាំងបណ្ណាភាស្រ្តជួបរបៀបការក្នុងខេត្តនេនិញដែរ ។

ម៉ោង៩ នឹង ៤៥ មីនុត ចេញពីនោះសំដៅទៅទីរួមខេត្តហាតៀង ម៉ោង១០ដល់ហាតៀង បើករថយន្តឡើងទៅឈប់សម្រាកនៅភោជនាគារលើភ្នំផារីដាយ ឆាន់ចង្ហាន់នៅទីនោះ។ ទីភោជនាគារនេះសប្បាយប្លែក ព្រោះតាំងនៅលើភ្នំផារីដាយក្រឡេកមើលទៅទិសខាងកើត ឯត្បូង ឯលិច ឃើញសមុទ្ទធំធេងល្អល្ហៃ មានខ្យល់អាកាសស្រួលណាស់ ។

ម៉ោង១៤ចេញពីទីនេះទៅវត្តគីរីវង្សរ៉ែងក្នុងឃុំទ្បុកទ្រី វត្តនេះនៅលើកំពូលភ្នំ ប៉ុន្តែភ្នំនោះមានកំពស់ល្មមឡើងស្រួលមិនហត់ទេ ។ មានពួកបព្វជិតទាំងភិក្ខុសាមណេរចំនួន ១៤ រូបនឹង

ពួកគ្រហស្ថប្រហែល ៤០ នាក់មកប្រជុំចាំយើង ៗ បាននិយាយពន្យល់សព្វគ្រប់ហើយឲ្យបែករូបថ្តិតពុម្ព ដល់ម៉ោង ១៦ ត្រឡប់មកទីរួមខេត្ត ចូលទៅជួបនឹងលោកឡាត់មិនិស្ត្រាទ័រនាមឡង់ដ្រុង[(១)] (ឡឺរេស៊ីដង់ត៍) ខេត្តហាតៀង ។ លោកឡាត់មិនិ-ស្ត្រាទ័រនេះមានអធ្យាស្រ័យសុភាពទន់ភ្លន់ សំដែងបដិសណ្ឋាររួសរាយរាក់ទាក់នឹងយើងជាច្រើន លោកមានប្រសាសន៍បំពោះមកនឹងខ្ញុំថា លោកចង់ឲ្យពួកបព្វជិតខ្មែរក្នុងខេត្តហាតៀងចេះនិយាយភាសាបារាំងសែសណាស់ ព្រោះថាប្រសិនបើមានបព្វជិតរូបខ្លះមានកិច្ចការអ្វីមករកលោក ហើយចេះនិយាយភា-សាបារាំងសែសផ្ទាល់បំពោះខ្លួនលោកតែម្តងនោះស្រួលណាស់នឹងអាចញ៉ាំងសេចក្តីពិតមិនឲ្យល្អៀងទៅបាន ។ លុះនិយាយការសព្វគ្រប់ហើយ យើងលាលោកឡាត់មិនិស្ត្រាទ័រត្រឡប់មកឯភោជនាគារវិញ ឈប់សំណាក់អាស្រ័យនៅទីនោះ មានភោ-ជនាគារដល់ ២ ជាប់ដោយឡែកពីគ្នា ស្រួលសំណាក់ណាស់ ។

(១) Landron.

ថ្ងៃព្រហស្បតិ៍ ២៣ ណោវែម ១៩៣៣ (៦ កើតមិគសិរ)

ម៉ោង ៧ (ព្រឹក) ចេញពីភោជនាគារទៅវត្តបឹងជុំ លោកឡាត់មិនិស្ត្រាទ័រ ក៏អញ្ជើញទៅដែរ ម៉ោង ៩ ដល់វត្តបឹងជុំក្នុងឃុំយឿងវ៉ា ។ មានពួកបព្វជិតនឹងគ្រហស្ថខាងវត្តបាយអឹតមកប្រជុំខ្លះផង រួមភិក្ខុសាមណេរទាំងអស់ ២០ រូប គ្រហស្ថប្រហែលជាង ១០០ នាក់មកប្រជុំ ។ វត្តបឹងជុំនេះមានលោកភិក្ខុ ១ រូបឈ្មោះស្រ៊ិនធ្វើជាគ្រូបង្រៀនអក្សរកុមារ កាលពីក្នុងឆ្នាំ ១៩៣១ បានទៅនៅរៀនរបៀបធ្វើគ្រូឯខែត្រកំពត ប្រឡងបានសញ្ញាបត្រទីគ្រូបង្រៀនហើយត្រឡប់មកនៅបង្រៀនកុមារឯវត្តនេះវិញ សព្វថ្ងៃរាជការខែត្របោះតៀងបានបើកប្រាក់បំណាយសម្រាប់ឃុំយឿងវ៉ាឲ្យជានិច្ចភត្តខែក្នុង ១ ខែ ១០ រៀល ៨០ សេន ។ យើងបាននិយាយពន្យល់ដោយសព្វគ្រប់រូបហើយឲ្យសៀវភៅខ្លះទុកជាសម្រាប់សាលារៀន ឲ្យបែករូបផ្តិតពុម្ពតាមការគួរដួបវត្តមុន ៗ រូបចេញពីវត្តនោះមក លោកឡាត់មិនិស្ត្រាទ័រ លាយើងអញ្ជើញត្រឡប់មកទីរួមខែត្រវិញ យើងបង្ហួសទៅហុងបុង (ខ្មែរហៅទន្លាប់) ម៉ោង ១០ ដល់ទៅ

វត្តទន្លាប់ក្នុងឃុំអាងបិញ ។ វត្តនេះតូចហើយរយីករយាកដុនដាបណាស់ គេរៀបទីប្រជុំនៅលើសាលាតូច ១ សាលានេះប្រក់ស្លឹក ក្រាលលំពង់ឈើធ្វើជារនាបរែងនឹងវល្លិ ។ មានតែលោកភិក្ខុ ៤ រូប គ្មានសាមណេរទេ មានគ្រហស្ថប្រហែល ៣០ នាក់មកប្រជុំ ។ វត្តនេះមានគ្រូបង្រៀនគ្រហស្ថម្នាក់ឈ្មោះណារី កាលនៅជាបព្វជិតបានទៅនៅរៀនរបៀបធ្វើគ្រូឯខេត្រកំពតជំណាលគ្នានឹងលោកភិក្ខុស្រីនវត្តបឹងជុំ ។ គួរឲ្យមានសេចក្ដីអាណិតខ្លោចចិត្តដល់អស់បណ្ដាជនជាតិខ្មែរក្នុងស្រុកហុងបុងនេះពេក ព្រោះច្រើនតែអ្នកល្ងង់ខ្លៅណាស់ ហើយក្រីក្រដុនដាប មានថែមទាំងផឹកស្រាជុំក្លិនហ្លួងស្មើរតែនឹងទាំងអស់គ្នា ហេតុទាំងនេះមកតែអំពីដំណើរប្រហែសធ្វេសឥតមានអ្នកណាដាស់តឿនក្រើនរំឭកអ្នកណា ជាដំណើរនាំឲ្យឃ្លាតឆ្ងាយអំពីសេចក្ដីអៀនខ្មាស ។ បន្ទាប់អំពីសេចក្ដីពន្យល់របស់លោកអគ្គលេខាធិការ ខ្ញុំបាននិយាយពន្យល់ដោយពាក្យទន់សុភាព (គួរឲ្យអ្នកទាំងនោះកើតសេចក្ដីនឿយណាយចាកអំពើទុច្ចរិត) អំពីទោសនៃសេចក្ដីខ្ជិលច្រអូស អំពីទោសផឹកទឹក

ស្រវឹង អំពីទោសលេងល្បែងភ្នាល់ អំពីទោសនៃសេចក្ដីព្រហើននឹងអំពីគុណសម្បត្តិនៃព្រះពុទ្ធសាសនា រួចហើយបានហៅកុមារខ្លះសិស្សសាលាវិត្តនោះមកឲ្យមើលសៀវភៅ សួរបំណោទលេខយ៉ាងស្រាល ៗ ហើយបែកសៀវភៅសំដែងអំពីទោសផឹកសុរានឹងលេងល្បែងភ្នាល់ឲ្យខ្លះ រួចឲ្យបែករូបថ្លិតពុម្ពតាមសមគួរដល់ការ ហើយត្រឡប់មកធាន់ឯសាលាឃុំអាង-បិញនៅជាប់នឹងផ្សារហុងចុង (ផ្សារទន្លាប់) ។

ម៉ោង១២កន្លះចេញទៅភ្នំព្រះចៅគារ (យួនហៅ ជួហាង បារាំងហៅថា បោណ្ណេ អាព់ល) ព្រោះគេប្រាប់ថាមានវិត្តខ្មែរតូប១នៅជិតភ្នំនោះ ។ ម៉ោង១៣កន្លះដល់ភ្នំព្រះចៅគារ ភ្នំនេះនៅក្បែរមាត់សមុទ្រ ចំពីខាងកើតឈូងសមុទ្រដែលបារាំងហៅថា "កាប់ដឹឡាតាប្ល៉ុង" (ឈូងតុម្ពូល) ព្រោះមានសណ្ឋានស្រ-ដៀងនឹងតុម្ពូល ។ ភ្នំនេះមានរូងជាគុហាពីខាងក្រោមធ្លុះរហូតពីម្ខាងទៅម្ខាង (ធ្លុះពីខាងកើតទៅខាងលិច) មានរូងកេលក្នុងពត់ពេនធ្លុះរហូតទៅខាងលើ ពន្លឺព្រះអាទិត្យបាំងភ្លឺមកបានខ្លះក្នុងរូងភ្នំនោះមានព្រះពុទ្ធរូបអង្គធំ៥បីព្រះអង្គ ជាស្នាដៃសៀម

មកសាងទុកនៅនោះ តាំងពីក្នុងពុទ្ធសករាជប្រហែលជា ២៣០០ក្នុងកាលដែលពួកយោធាសៀមលើកមកច្បាំងនឹងពួកយួន សៀមមកយកភ្នំនេះធ្វើជាបន្ទាយ បានសាងព្រះពុទ្ធរូបសន្មតព្រះនាមហៅថា "ព្រះចៅកៀរ" (ព្រះកាត់ផ្លូវសត្រូវ ឬ បង្សត្រូវ គឺការពារសត្រូវមិនឲ្យចូលមកបៀតបៀនបាន ។); លុះយូរតមកខ្មែរហៅក្លាយជា "ព្រះចៅគារ?" ។ គេនិយាយប្រាប់ថា ពួកខ្មែរច្រើនយកធាតុមកបញ្ចុះក្នុងរហែងញៀតញកភ្នំនេះ ក្នុងថ្ងៃចូលឆ្នាំខ្មែរគេតែងនាំគ្នានិមន្តលោកសង្ឃខ្មែរទៅធ្វើបុណ្យប្រគេនបង្ហាន់ បង្សុកូលរៀងរាល់ឆ្នាំ ។ សព្វថ្ងៃភ្នំនេះបានទៅជារបស់ពួកបព្វជិតយួននៅថែរក្សាជានិច្ច ប៉ុន្តែគង់បើកឱកាសឲ្យពួកខ្មែរបញ្ចុះធាតុធ្វើបុណ្យតាមទំនៀម ឥតមានហ្លួងហែងឃាត់ហាមអ្វីទេ ព្រោះព្រះពុទ្ធរូបទាំង ៣ ព្រះអង្គនោះជាទីគោរពដល់អស់ជនានុជនគេតែងទៅធ្វើសក្ការបូជា ឬបន់ស្រន់ឥតអាក់ ជាហេតុឲ្យកើតលាភសក្ការដល់ពួកបព្វជិតយួនទាំងនោះខ្លះ ៗ ផងដែរ ។

ម៉ោង ១៤ ត្រឡប់ពីភ្នំព្រះចៅគារវិមកចូលវត្តតូប ១ នៅខាងអាយឆ្ងាយអំពីភ្នំនោះប្រហែល ១ គីឡូម៉ែត្រ វត្តនេះគេទើបនឹងកសាងបំនួន ១ ឆ្នាំប៉ុណ្ណោះ គេឲ្យឈ្មោះថា "វត្តព្រះចៅគារ" តាមនាមភ្នំនោះ មានលោកភិក្ខុ ៦ រូប លោកចៅអធិការឈ្មោះអ៊ុក-ខាត់ អាយុ ២៦ ឆ្នាំ បួសបាន ៥ វស្សា បានរៀនរបៀបធ្វើគ្រូនៅសាលារៀនខេត្តកំពត បានប្រឡងមានសញ្ញាបត្រ កាលពីដើមនៅវត្តអង្គពន្លឺខណ្ឌតានី ខេត្តកំពត ។ លោកភិក្ខុទាំង ៦ រូប នេះមានឫកពារកិរិយារម្យទមបុះរបៀបបែបបទគួរឲ្យមានសេចក្ដីជ្រះថ្លាទៀតរក បេះប្រដៅកុមារសិស្សវត្តទាំងប៉ុន្មានឲ្យមានឫកពារបុះបែបបទប្លែកអំពីរបៀបវត្តទាំងអស់ក្នុងខេត្តហាតៀង ។ លុះយើងចូលទៅដល់ភ្លាមលោកចៅអធិការ ក៏ចាត់បំរើឲ្យទៅហៅប្រមូលពួកគ្រហស្ថប្រុសស្រីអំពីភូមិខ្លះ អំពីបម្កាត់ ឪឡុកខ្លះ (ព្រោះគេមិនដឹងថាយើងនឹងទៅក្នុងទីនោះទេ) បានតែ ១ ស្របក់ក៏ឃើញពួកគ្រហស្ថប្រុសស្រីប្រហែលជា ៥០ នាក់ ឈូនរមកប្រជុំ ។ យើងបានសួរសព្វគ្រប់ហើយក៏និយាយពន្យល់ជាស់តឿនរំឭក រួបឲ្យបែករូបផ្ដិតពុម្ពឲ្យខ្លះតាមគួរដល់

ការ ហើយលោកអគ្គលេខាធិការបានបិតរូបពួកជនទាំងនោះ២ លើក ។

ឈ្មោះសក់-ម៉ក់ ក្រុមប្រឹក្សាជាតិខ្មែរខេត្តបារៀង ជាអ្នកផ្តួចផ្តើមនាំអស់បណ្តាជនជាតិខ្មែរក្នុងទីដីបន់នេះ ព្រមព្រៀងគ្នាកសាងវត្តព្រះបោគារនេះឡើង ។ ខ្ញុំយល់ថា វត្តនេះតទៅអនាគត បើប្រសិនជាមានអ្នកទំនុកបំរុងដោយមាំទាំនឹងទៅជាវត្តរុងរឿងសប្បាយជាងវត្តទាំងអស់ក្នុងខេត្តបារៀង ព្រោះទីត្រង់ណោះមានសណ្ឋានទំនងល្អណាស់ គឺនៅក្បែរមាត់សមុទ្របំឈូងដែលមានលំហាខ្យល់បក់មកត្រង់ពីខាងត្បូង ទាំងផែនដីក៏រាបស្មើ សុទ្ធតែខ្សាច់មានសម្បុរសក្បុសផ្ទរផង់ ក្រឡេកមើលទៅខាងត្បូងឃើញដើមស្វាវជុះប្រុងប្រាងហែតាមក្បែរមាត់សមុទ្រ ក្រឡេកពីនោះទៅទៀតឃើញផ្ទៃសមុទ្រទឹកថ្លាខៀវអន្លង់មានកោះតូច ៗ ស្ថិតនៅរកូតជាលំដាប់ ត្រង់បន្លោះកោះទាំងនោះក្រឡេកមើលទៅឃើញល្ហល្ហេវលន្លឹមសន្លឹមជាប់កន្ទុយភ្នែក ក្រឡេកមើលទៅខាងជើងឃើញសុទ្ធតែភ្នំខៀវស្រងាត់អ័ព្ទមេឃបែកជាផ្សែង ជាទីសំដែងនូវសេចក្តីរីករាយគួរឲ្យពួកបព្វជិតគាប់

ចិត្តចង់នៅ ឬចង់ទៅសំណាក់អាស្រ័យសម្រាកសម្រានកំសាន្ត កែអផ្សុកម្តងៗ ។

ម៉ោង ១៥ យើងចេញពីវត្តព្រះពោធិវារត្រឡប់មកទីរួមខេត្តបាត់ដំបងវិញ គ្រាន់តែចូលទៅលាលោកឡាត់មិនិស្ត្រាទ័រ ហើយក៏ត្រឡប់មកតាមផ្លូវដើមចូលមកក្នុងកម្ពុជរដ្ឋ ដល់មកខណ្ឌតានឹបត់ទៅខាងជើង តពីនោះមកបត់ទៅខាងត្បូងផ្លូវព្រែកចូលទៅក្នុងខេត្តប៉ូដិក (មាត់ជ្រូក) ដែលកូស័ងស៊ុន សំដៅទៅស្រុកទ្រីតុង (ស្វាយទង ទ្រាំងត្រើយត្បូង) ម៉ោង ២០ (យប់) ដល់ទ្រីតុង ។ លោកចៅហ្វាយស្រុក គីម-ក្លូយរ៉ុត្រែត បានចាត់ចែងរៀបទីសេនាសនទុកបំរុងរង់ចាំយើងស្រេចជាមុន ដោយលោកបានជ្រាបដំណឹងតាមផ្លូវរាជការថាយើងនឹងមកដល់ទ្រីតុងក្នុងថ្ងៃនោះ ហើយលោកមានអធ្យាស្រ័យចង់ជួបនឹងយើងណាស់ ដោយសារលោកធ្លាប់បានជួបរាប់អានយើងរៀងមក ។ លោកអគ្គលេខាធិការអញ្ជើញទៅឈប់សំណាក់ឯភោជនាគារប៉ូដិក ។

## ស្រុកទ្រីតុង – ខែត្រច្បូដុក

ថ្ងៃសុក្រ ២៤ ណោវែម ១៩៣៣ (៣ កើតមិគសិរ)

ម៉ោង ៩ (ព្រឹក) ប្រជុំនៅវត្តស្វាយទងស្រុកទ្រីតុង ។ ក្នុងទីប្រជុំនេះមានជនានុជន ទាំងបព្វជិតទាំងគ្រហស្ថប្រហែល ២០០ នាក់ មានពួកបព្វជិតច្រើនវត្តមកប្រជុំក្នុងទីនេះ លោកចៅហ្វាយស្រុកទ្រីតុង (ឈ្មោះកូវ) ជាតិជាខ្មែរព្រមទាំងពួកក្រមការស្រុកនឹងពួកមន្ត្រីឃុំជាច្រើននាក់សុទ្ធតែជាពូជខ្មែរ ក៏អញ្ជើញមកក្នុងប្រជុំនេះដែរ ។ លោកអគ្គលេខាធិការបានពន្យល់តាមដំណើរកិច្ចការដោយសព្វគ្រប់ហើយ ខ្ញុំក៏និយាយពន្យល់ជាស់តឿនរំឭកតាមសមគួរដល់អាការរបស់សន្និបាត រូបឡបែករូបផ្តិតពុម្ពជួបវត្តឯទៀត ៗ រៀងមក លុះស្រេចកិច្ចការហើយយើងក៏ធ្វើភត្តកិច្ចនៅវត្តនេះ ។ វត្តស្វាយទងនេះតាំងនៅក្នុងទីប្រជុំផ្សារទ្រីតុង ជាវត្តគឺលោកចៅហ្វាយស្រុក គឹម-ក្លយ រ៉ឺតែត បានបំណាយទ្រព្យកសាងវិហារសាលាដ៏រុងរឿងគួរជាទីតាំងនៃការសិក្សាខាងវិជ្ជាសម្រាប់កុមារ នឹងវិជ្ជាខាងព្រះពុទ្ធសាសនា

បានពេញទី ប៉ុន្តែសព្វថ្ងៃនេះមិនទាន់បានតាំងការសិក្សាទាំងនោះនៅឡើយទេ លោកចៅហ្វាយស្រុក គីម-ក្លួយ ប្រាប់ខ្ញុំថា តាំងឲ្យមានការសិក្សាទាំងនោះមិនកើត ព្រោះលោកចៅអធិការសព្វថ្ងៃនេះមិនគាប់ចិត្តនឹងការសិក្សានោះ បានតាំងបង្កើតម្តងហើយ បែរជារការរក្លួសមិនស្រួល ក៏បញ្ឈប់លែងឲ្យមានទៅវិញ ។

ម៉ោង១២កន្លះ ចេញពីវត្តស្វាយទងសំដៅទៅវត្តព្រះធាតុ លោកចៅហ្វាយស្រុកទ្រីតុងក៏អញ្ជើញទៅដែរ ម៉ោង១៣កន្លះ ដល់វត្តព្រះធាតុ ក្នុងឃុំអូឡម (ខ្មែរហៅឃុំអូធំ) ។ ក្នុងទីប្រជុំនេះមានពួកបព្វជិតវត្តឯទៀត ៣វត្ត គឺវត្តស្រែបឹង ១ វត្តស្វាយជង្គុំ ១ វត្តកំភ្លឹង ១ ជា ៤ នឹងវត្តនេះ មានបព្វជិត ២៤ រូប ពួកគ្រហស្ថប្រហែលជា ២០០ នាក់ ។ យើងបាននិយាយពន្យល់តាមការគួររូបហើយឲ្យបែករូបផ្តិតពុម្ពជូនវត្តឯទៀត ៗ ។ ម៉ោង១៥កន្លះត្រឡប់មកស្វាយទងវិញ យើងហួសមកសំណាក់ឯវត្តដីក្អែងនៅជាខាងអាយផ្សារស្វាយទង ព្រោះលោកចៅអធិការឈ្មោះស ជាអន្តេវាសិករបស់ខ្ញុំ ដែលជាចៅអាវាសនេះ ព្រម

ទាំងពួកឧបាសកមានអាចារ្យវត្តជាដើម សុំឲ្យបានយើងមកសំណាក់នៅវត្តនេះ ។ លោកអគ្គលេខាធិការត្រឡប់ទៅសំណាក់ឯភោជនាគារបួដុក ។ វេលាយប់នោះមានពួកសប្បុរសបព្វជិតគ្រហស្ថជាច្រើនមកជួបជុំនៅសាលាវត្តដីក្អែង សុំសាកសួរពិគ្រោះពីធម៌អាថ៌ ខ្ញុំក៏បាននិយាយពន្យល់តាំងពីពេលយប់រហូតដល់ម៉ោង២៤ (អធ្រាត្រ) ។

ថ្ងៃសៅរ៍ ២៥ ណោវ៉ែម ១៩៣៣ (៨កើតមិគសិរ)

ម៉ោង ៧ កន្លះ(ព្រឹក) យើងចេញពីវត្តដីក្អែងត្រឡប់មកឯផ្សារស្វាយទងវិញ ហើយហួសសំដៅទៅវត្តស្វាយទាប[១] លោកចៅហ្វាយស្រុកទ្រឹតុងក៏អញ្ជើញទៅដែរ ម៉ោង៩ដល់វត្តស្វាយទាបក្នុងឃុំភ្នួ ។ ក្នុងទីប្រជុំនេះមានពួកបព្វជិតវត្តដទៃ ៤ វត្តគឺវត្តទួលជីមង់ ១ វត្តត្នោតជ្រុំ ១ វត្តខ្មោរលើ ១ វត្តទ្រៀក ១ ជា ៥ នឹងវត្តនេះ រួមបព្វជិតទាំងអស់ ២៤ រូប មានពួកគ្រហស្ថប្រហែល ១៥០ នាក់ ។ យើងបាននិយាយពន្យល់

---

១ វត្តនេះមានឈ្មោះ ៣ យ៉ាងគឺ ស្វាយទាប ពោធិ៍ទាប ពោធិ៍ល័ស គេនិយាយប្រាប់ថាឧបាសកម្នាក់ឈ្មោះ ល័ស បានវេរដីកេររបស់ខ្លួនចំពោះព្រះភិក្ខុសង្ឃ បានកសាងជាទីវត្តនេះ ។

ហើយឲ្យបែករូបផ្តិតពុម្ព រូបវិលត្រឡប់មកធ្វើភត្តកិច្ចឯវត្តដីក្អែងវិញ ។

ម៉ោង ១៤ យើងចេញទៅវត្តគោករំដែល ក្នុងឃុំត្រាក្វាង (ខ្មែរហៅឃុំបន្ទាយដែក) លោកចៅហ្វាយស្រុកទ្រឹតុងក៏អញ្ជើញទៅដែរ ទៅតែ ២០ មីនុតក៏ដល់វត្តនេះ ។ ក្នុងទីប្រជុំនេះមានពួកបព្វជិតវត្តក្រៅ ២ វត្តគឺវត្តស្វាយតាសំ ១ វត្តទឹកផុស ១ ជា ៣ នឹងវត្តនេះ រួមបព្វជិតទាំងអស់ ២៦ រូប ពួកគ្រហស្ថប្រ-ហែលជាង ១០០ នាក់ ។ យើងបាននិយាយពន្យល់តាមសមគួររួចឲ្យបែករូបផ្តិតពុម្ពជូនវត្តឯទៀត ៗ រៀងមក ។

ម៉ោង ១៥ ចេញពីវត្តគោករំដែលហួសទៅវត្ត អំពាយ-ស្វាយ ក្នុងឃុំបូងទ្រី ម៉ោង ១៦ ដល់ទៅវត្តនេះ ។ ក្នុងទីប្រជុំនេះមានពួកបព្វជិត ១៧ រូប គ្រហស្ថប្រហែលជាង ៧០ នាក់ ។ យើងបាននិយាយពន្យល់ហើយឲ្យបែករូបផ្តិតពុម្ពតាមការគួរ រូបវិលត្រឡប់មកសំណាក់ឯវត្តដីក្អែងវិញ ។ លោកអគ្គលេខាធិការនៅសំណាក់ឯភោជនាគារបូជុក ។

ថ្ងៃអាទិត្យ ២៦ ណោវែម ១៩៣៣ (៩កើតមិគសិរ)

ម៉ោង ៩ (ព្រឹក) ចេញពីវត្តជីក្អែងទៅវត្តភ្នំពីរក្រោម ក្នុងឃុំណាមគី លោកចៅហ្វាយស្រុកទ្រីតុងក៏អញ្ជើញទៅដែរ ម៉ោង ៩ កន្លះដល់វត្តនេះ ។ ក្នុងទីប្រជុំនេះមានពួកបព្វជិតវត្តក្រៅមក ២ វត្តគឺ វត្តគិរីបូព៌ ១ វត្តទួលកាស ១ ជា ៣ នឹងវត្តនេះ (ទាំង ៣ វត្តនេះសុទ្ធតែជាធម្មយុត្តិកនិកាយ) រួមបព្វជិតទាំងអស់ ១៨ រូប គ្រហស្ថប្រហែលជាង ៥០ នាក់ ។ យើងបាននិយាយពន្យល់ហើយឲ្យបែករូបផ្តិតពុម្ពតាមការគួរ រួចវិលត្រឡប់មកធ្វើភត្តកិច្ចឯវត្តជីក្អែងវិញ ។

ម៉ោង ១២ យើងចេញពីវត្តជីក្អែងទៅវត្តទំពូងក្រោម ក្នុងឃុំ លឿងភី (ខ្មែរហៅឃុំទំពូង) លោកចៅហ្វាយស្រុកទ្រីតុងក៏អញ្ជើញទៅដែរ ម៉ោង ១២ កន្លះដល់ទៅវត្តនេះ ។ មានពួកបព្វជិតពីក្រៅ ៤ វត្តគឺ វត្តគោករមៀត ១ វត្តទំពូងលើ ១ វត្តស្រែឡូង (ធម្មយុត្តិ) ១ វត្តអណ្តូងប៉ែន ១ ជា ៥ នឹងវត្តនេះ រួមបព្វជិតទាំងអស់ ២៥ រូប ពួកគ្រហស្ថប្រហែល ១៥០ នាក់ ។

យើងបាននិយាយពន្យល់រូបឲ្យបែករូបផ្ដិតពុម្ពស្រេបហើយហួស
សំដៅទៅវត្តបឹង ដោយសារលោកគ្រូចៅអធិការវត្តនេះមកទទួប
អង្វរតាំងពីម្សិលនៅវត្តដីក្រហុង សុំឲ្យធ្លៀតហួសចូលទៅវត្ត
របស់លោកផង ដើម្បីឲ្យពួកពុទ្ធសាសនិកជនជាចំណុះវត្តនោះ
បានឃើញយើងព្រមទាំងបានស្ដាប់សេចក្ដីពន្យល់ខ្លះផង ព្រោះ
មានមនុស្សល្ងង់ខ្លៅច្រើនណាស់ ស្ទើរតែនឹងទាំងអស់គ្នាក៏សឹង
ថាបាន ។ ម៉ោង ១៤ កន្លះដល់ទៅវត្តបឹង វត្តនេះនៅជាខាង
ឯជើងភ្នំអកយំ ក្នុងឃុំថ្វាក (យួនហៅ ឡាងឡេវ៉ាក) ក្នុងតុង
(ខណ្ឌ) ថាញ់ង៉ាយ ។ ក្នុងទីប្រជុំនេះមានបព្វជិតវត្តអង្គ ២ រូប
មកផងរួមទាំងអស់ ២០ រូប មានពួកគ្រហស្ថប្រហែលជាង
១០០ នាក់ ។ យើងបាននិយាយពន្យល់រូបឲ្យបែករូបផ្ដិតពុម្ព
រួចហើយត្រឡប់មកវិញ; បានធ្លៀតចូលទៅនិយាយពន្យល់
ទាហានខ្មែរ ៦ នាក់នៅសាលាឃុំក្បែរផ្សារឡាំងម៉ុយ ហើយក៏
ត្រឡប់មកសំណាក់ឯវត្តដីក្រហុងវិញ ។ លោកអគ្គលេខាធិការ
ទៅសំណាក់ឯភោជនាគារបួដុក ។

## ស្រុកទិញបៀង-បូដុក

ថ្ងៃចន្ទ ២៧ ណោវែម ១៩៣៣ (១០ កើតមិគសិរ)

ម៉ោង ៨ (ព្រឹក) យើងចេញពីវត្តជីក្អែងត្រឡប់មកឯវត្តគិរិវង្ស (ខាងអាយឯណោះវិញ) ។ ម៉ោង ៩ ដល់វត្តគិរិវង្ស[១] ក្នុងឃុំស៊ុនតូ ស្រុកទិញបៀង (ខ្មែរហៅស្រុកក្របៅ) ខេត្របូដុក យើងចូលទៅក្នុងវត្ត ស្ងាត់ឈឹងឥតមានមនុស្សមកប្រជុំឡើយ បានសួរលោកចៅអធិការ ៗ ប្រាប់ថាឥតបានដឹងដំណឹងអ្វីដល់តិចតួចថានឹងត្រូវមានការប្រជុំក្នុងវត្តនៅថ្ងៃនេះទេ ។ លោកអគ្គ-លេខាធិការ បានអញ្ជើញភ្លាមទៅជួបនឹងចៅហ្វាយស្រុកទិញបៀង (ជាតិជាយួន) ចៅហ្វាយស្រុកជូនដំណឹងថា មានសំបុត្រពីលោកឡាត់មិនិស្ត្រាទ័របូដុកបង្គាប់ជាផ្លូវរាជការបំពោះមកលើខ្ញុំយូរថ្ងៃដែរហើយ ប៉ុន្តែខ្ញុំមានកិច្ចការខាងរាជការរដ្ឋបាលច្រើនពេកក៏ធ្វេស ៗ ភ្លេចទៅ. មិនបានឲ្យដំណឹងដល់ពួកខ្មែរ ។ លោកចៅអធិការបានឲ្យវាយស្គរវត្ត ហៅពួកបាសកជើងវត្តឲ្យមក យូរបន្តិចក៏បានឃើញពួកបាសកប្រុសស្រីជាតិខ្មែរមក

---

១ ហៅថា វត្តក្រាស ឬ វត្តថ្មី ដូរឈ្មោះវិញក៏បាន ។

ម្នាក់ម្ដង ២ នាក់ម្ដងបន្ទាប់ ៗ គ្នា បានមនុស្ស ២០ នាក់ រួមទាំងភិក្ខុសាមណេរនឹងក្មេងសិស្សវត្តផងបានមនុស្សបំនួន ៣១ នាក់ ។ លោកចៅអធិការព្រមទាំងគ្រហស្ថជាតិខ្មែរទាំងអស់គ្នាញប្រាប់យើងថា ប្រជាជនជាតិខ្មែរក្នុងទីដំបន់នេះមានសេចក្ដីលំបាកណាស់ មិនដូចពួកខ្មែរខាងស្រុកទ្រឹតុងទេ ខាងស្រុកទ្រឹតុងច្រើនមានខ្មែរអ្នកបេះភាសាបារាំង ច្រើនបានធ្វើជាបីនាហ្មឺន អ្នកមានទ្រព្យសម្បត្តិក៏មានច្រើននាក់ ហើយលោកចៅហ្វាយស្រុកទ្រឹតុងក៏ជាតិជាខ្មែរទៀត ម៉្លោះហើយជាតិយួនគេច្រើនញញើត ឯស្រុកទិញបៀងនេះ ពួកខ្មែរមានបំនួនតិចណាស់ ហើយសុទ្ធតែមនុស្សល្ងង់ខ្លៅក្រីក្រលំបាក បំណែកខាងនាហ្មឺនសុទ្ធតែយួន ច្រើនតែលំអៀងបៀតបៀនពួកខ្មែរជាងពួកយួន ខ្មែរស្រុកនេះខ្លាចយួនណាស់ ព្រោះកាលបើមានអធិករណ៍ឈ្លោះប្រកែកក្ដីក្ដាំអ្វីឡើងខ្មែររមែងតែចាញ់យួនជាដរាប បើយ៉ាងគ្រាន់ណាស់បានត្រឹមតែស្មើប៉ុណ្ណោះ ខ្មែរមិនដែលឈ្នះយួនទេ ។ ពួកខ្មែរទាំងនេះមានគ្នាញអំពីសេចក្ដីលំបាកផ្សេង ៗ ក្រៅពីនេះទៅៈទៀតជាច្រើន ។ លោកចៅ

អធិការត្រួញថាវត្តនេះ រាជការយកពន្ធដីវត្ត ៦ រៀល ៗ រៀងរាល់ឆ្នាំ អាត្មាសុំលោកអគ្គលេខាធិការមេត្តាជួយប្តឹងរាជការកុំឲ្យវត្តនេះមានពន្ធ ព្រោះបាសកជាតិខ្មែរជាបំណុះវត្តនេះមានបំនួនតិចណាស់ សុទ្ធតែអ្នកក្រីក្រ ហើយឥឡូវថែមទាំងមានជាតិអមេរិកាំងបេះតែមកបញ្ចុះបញ្ចូលឲ្យខ្មែរដែលល្ងង់ខ្លៅបែរទៅចូលសាសន៍គ្រិស្តុងខ្លះទៅទៀត... ។ យើងបាននិយាយពន្យល់ដោយសព្វគ្រប់ ហើយឲ្យបែករូបថ្តិតពុម្ព រូបហើយក៏ធ្វើភត្តកិច្ចនៅវត្តនេះ ។

ម៉ោង ១៣ កន្លះ យើងបេញពីវត្តនេះទៅឯទីរួមខេត្តប៊ូដុក ម៉ោង ១៤ និង ២០ មីនុតដល់ទៅទីរួមខេត្តប៊ូដុក ។ លោកឡាត់មិនិស្រ្តាទ័រនាម វ៉ាឡាត់[១] (ឡឺរេស៊ីដង់ត៍) ខេត្តប៊ូដុកនឹងអស់លោកមន្ត្រីបារាំងក្រុមពិជ័យសង្គ្រាម មកប្រជុំគ្នារង់ចាំយើងនៅបន្ទាយក្រុមពិជ័យសង្គ្រាម បានចូលទាំងអស់គ្នាទៅក្នុងសិក្សាគារស្ថាន (ផ្ទះសម្រាប់ប្រជុំសិក្សានៃក្រុមពិជ័យសង្គ្រាម)

---

១ Valat.

មានពួកសេនាយោធាក្រុមពិជ័យសង្គ្រាមសុទ្ធតែជាតិខ្មែរ ប្រ-ហែលជាង ១០០ នាក់ មកប្រជុំរង់ចាំនៅទីនោះ ។ ខ្ញុំបាននិយាយពន្យល់អំពីវត្តប្រតិបត្តិខាងព្រះពុទ្ធសាសនា រើសរកតែសេចក្ដីណាដែលសមគួរល្មមពួកសេនាយោធាកាន់បាន ជាទំនងនាំឲ្យបានសេចក្ដីសុខនឹងសេចក្ដីចំរើន ។ ម៉ោង ១៦ កន្លះយើងចេញពីទីរួមខែត្របួជុកសំដៅទៅខែត្រឡុងធៀង (ខ្មែរហៅខែត្របារ៉ាច) ម៉ោង ១៨ ដល់ទៅទីរួមខែត្រឡុងធៀង លោកអគ្គលេខាធិការបានចូលទៅជួបនឹងលោកឡាត់មិនិស្ត្រាទ័រនាមម៉ៃយ៉ារ្ដ៍[១] (ឡឺរេ ស៊ីដង់ត៍) ខែត្រឡុងធៀង យើងទៅសំណាក់ឯភោជនាគារ ព្រោះគ្មានវត្តនៅជិតល្មមសំណាក់បានទេ ។

---

១ Maillart.



ព្រះចេតិយ ៤ ជ្រុងនៅស្រុកបេគូ (ភូមា) មានព្រះពុទ្ធរូបគ្រប់ជ្រុង
នេះគឺជ្រុងខាងត្បូងប្រហែលជាសាងក្នុងកាល ព. ស. ១,៦០០ ។

# អំពីវិធីសាងប្រាសាទនគរវត្តរបស់លោក ហ. ម៉ាល្វាល

(ត)

ប្រដាប់ប្រដាដែលយកមកប្រើក្នុងការកសាងប្រាសាទនគរវត្ត នោះក៏ដូចគ្នានឹងប្រដាប់ប្រដាដែលកសាងប្រាសាទផ្សេង ៗ ឯទៀតក្នុងសម័យបុរាណនោះដែរ លើកតែឥដ្ឋចេញ ព្រោះឥដ្ឋនេះគេកម្រយកមកប្រើណាស់ក្នុងការកសាងប្រាសាទធំ ៗ ដូច្នេះ ។

ថ្មបាយក្រៀមគេប្រើតែធ្វើឫសនឹងគ្រឹះក្រោម ។ នៅកន្លែងណាក៏មិនដែលឃើញថ្មបាយក្រៀមចេញក្រៅដែរ លើកតែត្រង់ណាដែលរបើកថ្មភក់ដែលនៅពីក្រៅចេញទៅ ហើយនឹងកំផែងដែលមានថ្មភក់នៅពីខាងលើ ។

តួប្រាសាទទាំងមូលដែលមើលឃើញទាំងប៉ុន្មានសុទ្ធតែធ្វើដោយថ្មភក់ទាំងអស់ សម្បុរប្រផេះរាងថ្លាបែបថ្មធុនអន់ ។ ជាថ្មដែលគគ្រាតខ្លាំងហើយរាងពុក ៗ ព្រោះកន្លែងដែលត្រូវភ្លៀងត្រូវសន្សើមនោះរបើករបកជាប់មកជាផ្ទាំង ៗ ។

មិនតែប៉ុណ្ណោះសោតឬភក់នេះនាំឲ្យមានស្នែកាន់ ហើយធ្វើឲ្យឬនេះមានស្នាមស ៗ យ៉ាងក្បុស ដែលនាំឲ្យមើលទៅឃើញប្រាសាទទាំងមូលនេះមានសម្បុរប្រាក់ចាស់ ។

គេយកឈើមកប្រើធ្វើមេទ្វារពីខាងលើ ហើយឯស្លាបទ្វារក៏ធ្វើពីឈើដែរ ហើយស្នូលខាងក្រោមស៊កទៅក្នុងរន្ធឬដែលឃើញមាននៅលើកន្លែងទ្វារសព្វថ្ងៃនេះ ។ ឃើញមានមេទ្វារខ្លះគង់នៅ ៗ កន្លែងរហូតដល់សព្វថ្ងៃនេះផង ។

ឯពិតានក៏ធ្វើពីឈើទាំងអស់ដែរ ហើយរបនាជាគំនូរ ។ មានបន្ទះពិតានខ្លះសល់នៅ តែរបើករបេះអស់ពាក់កណ្ដាលបន្ទះទាំងនេះទំនងជាគេដកយកចេញពីក្នុងប្រាសាទទៅរក្សាទុកឲ្យល្អ ។

មានវត្ថុទៀតខ្លះដែលធ្វើដោយឈើដែរ គឺគ្រឿងតុតាំងទីព្រះពន្លាឬជងទង់ដែលត្រូវតែមាន បើមិនក្នុងទីអាសនៈនឹងថែរក៏នៅៗទីធ្លាក្រៅដែលលើកខ្ពស់ឡើង ប៉ុន្តែមានទំនងគួរឲ្យជឿតាមសេចក្ដីឧបមាយ៉ាងនេះដែលមានគ្រឿងអាងធ្នូនល្មម គឺនៅ

កន្លែងបំឡាក់លើជញ្ជាំងថែវខ្លះ នឹងនៅលើរន្ធដំណាប់ នោះឃើញមានស្នាមជាប់នឹងផែនថ្មច្បាស់នៅឡើយ ។

ក្នុងទីនេះគេបានប្រើដែកដួបជាក្នុងការកសាងប្រាសាទខ្មែរឯទៀតៗដែរ គឺដាក់ពីក្នុងជញ្ជាំង ។

នៅប្រាសាទនគរវត្ត មានមនុស្សដែលបំផ្លាញដែលមានចិត្តខុសប្រក្រតី ខ្វះយកដែកចេញច្រើនជាងទីដទៃទៅទៀត ដោយគេត្រូវការដែកនេះណាស់ ដោយដែកទាំងនេះកប់នៅក្នុងថ្មយ៉ាងជ្រៅៗការគាស់ខ្វះយកនេះ នាំឲ្យថ្មឃ្លាតបាកចេញគ្នាពីមុខដំណ ហើយមានកន្លែងខ្លះហើបឃ្លាតយ៉ាងខ្លាំងដូចដែលយើងបានឃើញច្បាស់នឹងភ្នែកស្រាប់ ។ ដែកនេះខ្វះយកបានដោយបោះរន្ធតាមកន្លែងពីខាងក្រៅ អាស្រ័យហេតុនេះហើយបានជាឃើញមានរន្ធជាច្រើននៅលើកន្លែងខាងមុខ មាននៅក្រោមបិញ្ចើមខឿននឹងលើក្បាលសសរថែវជាដើម ។

ម្យ៉ាងវិញទៀតចំនួនដីដែលបានចេញមកក្រៅដោយការជីកគូជុំវិញកំផែងនោះ មានចំនួនធួនល្មមនឹងចាក់បំពេញនូវផ្ទៃប្រាសាទដែលលើកឲ្យខ្ពស់ឡើង ធ្វើជាខឿនទាំង ៣ ថ្នាក់ ។

បើដូច្នោះត្រូវតែនិយាយជាសម្រេចតែម្តងថារូងខាងក្រោមប្រាសាទដែលគេតែងតែនិយាយថាមាននោះ គឺមានបំពោះតែក្នុងសេចក្តីជឿរបស់ខ្មែរទេ ព្រោះខ្មែរប្រូលចិត្តជឿរឿងរ៉ាវយ៉ាងផ្តេសផ្តាសអំពីប្រាសាទទាំងនេះ ។

ថ្មដែលសាងប្រាសាទនាំយកពីភ្នំគូលែនមកដោយបណ្តែតតាមក្បូន មកដាក់ក្នុងកន្លែងណាមួយដែលជិតជាងគេ បំងាយ ១ គីឡូម៉ែត្រគតពីទ្វារកំផែងខាងកើត ហើយមានមនុស្សហាដឹកនាំយកពីទីនោះមកទៀត ។

ឯគ្រឹះនោះក៏រៀបតាមទំនងដូចជាប្រាសាទឯទៀតដែរ គឺធ្វើជាជញ្ជាំង ២ ដោយថ្មបាយក្រៀមជំរូតលើគ្នាកំពស់ ០ម៉ុ៨០ ដាក់ពីលើកំទេចថ្មដែលបុកឲ្យល្អិត ធ្វើបែបជាកំបោរស៊ីម៉ង់ស្ងួតដូច្នោះ ។

ខឿនធ្វើដោយបន្ទះថ្មភក់រៀបគ្របស្រោបពីលើថ្មបាយក្រៀម ប៉ុន្តែថ្មដែលស្រោបនេះមិនមែនស្តើងដូចជាដែលស្រោបនៅទីប្រាសាទបាយ័ននោះទេ ។

ឯជ្រុងជញ្ជាំងនោះរៀបថ្មប្រទល់មុខៗគ្នាឥតមានប្រឆ្លូសមុខ ឡើយ ការដែលគ្រាន់តែប្រទល់មុខនេះហើយនាំឲ្យមានរបើក របេះបេញជាច្រើន ។

ថ្មសុទ្ធតែធ្វើជា ៤ ជ្រុងជាជរាប ដែលប្រើសសរមូលនោះ តែក្នុងការដែលជាអាណាបសម្រាប់គាំពារពីខាងក្រៅទីធ្លាដែល លើកខ្ពស់ ឬក៏បន្ទល់ដែលទ្រទីព្រះលានខ្ពស់ឡើង ក្នុង សណ្ឋាននេះគេច្រើនប្រើថ្មទាំងដើមតែម្តង ។

សសរជំហួលខាងនោះមានគល់សិទ្ធពុម្ព ហើយបំណែក សសរវៃរនោះគ្មានដូច្នេះទេ ។

នៅកន្លែងទីលានរាងជើងក្អែក ដែលភ្ជាប់ថ្នាក់ទី ១ ទៅនឹង ថ្នាក់ទី ២ នោះ មានសសរត្រូវទឹកសើម ហើយទឹកសើមនេះស៊ី ជើងសសរដាច់អស់ក្នុងសសរមួយ ៗ ស្ទើរតែពាក់កណ្តាល ។

ជំហួលកោងនៃប្រាសាទនគរវត្ត ក៏ប្រើវិធីបន្តុបជំរួតគ្នា ដូចជាដែលធ្លាប់ប្រើក្នុងការកសាងប្រាសាទឯទៀត ៗ របស់ខ្មែរ ដែរ ។

ជាសារុបសេចក្ដីមក គេអាចនឹងពោលថា ប្រាសាទនគរវត្តកសាងមិនសូវប្រញាប់ប្រញាល់ដូចជាប្រាសាទឯទៀតៗទេ គឺសាងដោយពិនិត្យផ្ចិតផ្ចង់ដោយសំភីក្នុងការងារ ។

ប៉ុន្តែនៅមានឃើញកន្លែងខ្លះដែលមានធ្លាក់ក្បាច់មិនទាន់ហើយនៅឡើយ មានកន្លែងគោបុរនៅខាងទ្វារចូលខាងកើតជាដើម ។ ប៉ុន្តែគេដឹងទំនៀមក្នុងស្រុកខ្មែរគឺមិនត្រូវធ្វើប្រាសាទណាឲ្យហើយស្រឡះស្ពោះសោះ ។

កំពូលរបស់ប្រាសាទជ្រុងខ្លះ នឹងទីអាសនៈកណ្ដាលនោះ មើលពីខាងក្រៅទៅតាមថ្នាក់ៗដែលឡើងទៅ ឃើញមានដូចគ្នានឹងកំពូលប្រាសាទខ្មែរឯទៀតៗក្នុងសម័យបុរាណ ។ ប៉ុន្តែគេអាចនឹងសំគាល់បានជាមានធ្វើថ្នាក់ឲ្យទាបបុះបន្តិច ហើយបំ-រើនថ្នាក់ឲ្យច្រើនឡើង កាលណាបើយកទៅធៀបនឹងសម័យដែលកសាងប្រាសាទធំៗ ។

ឯកំពូលក្នុងដើមសម័យបុរាណ (ព. ស. ១៦៥០) នោះ តាមធម្មតាធ្វើជា ៣ ថ្នាក់ ឯកំពូលនគរវត្តមានដល់ទៅ ៥ ថ្នាក់ ហើយមានក្លែបត្របកឈូក ៣ ជាន់ត្រួតទៅទៀត ។

ទីធ្លាខាងក្នុងទាំងអស់សុទ្ធតែក្រាលថ្មភក់ លើកតែធ្លាថ្នាក់ទី ១ ចេញ ។ ធ្លាទាំងនេះមានខឿនថែវព័ទ្ធជុំវិញទាំង ៤ ទិស ហើយប្រសិនបើអ្នកសាង មិនមានគំនិតគិតធ្វើកន្លែងបញ្ចេញទឹកនោះ ទឹកភ្លៀងនឹងដក់នៅបានពេញក្នុងនោះ ។ ដើម្បីនឹងបញ្ចេញទឹកភ្លៀងចេញនោះ គេបានធ្វើជាផ្លូវទឹកគ្រប់ទិសទាំង ៤ដោយពោះប្រឡាយកាត់ខឿនថែវបញ្ចេញទៅក្រៅ ។ ប្រឡាយទឹកទាំងនេះ ល្មមធ្លួនតែថ្នាក់ទាំង ២ ខាងលើ ហើយចំណែកថ្នាក់ទី ១ នោះមានទឹកដក់នៅ បានជាក្នុងរដូវភ្លៀងនាំឲ្យមានជាភក់កក្នុងខឿនខាងក្រៅ ។

ឯការដែលនាំយកថ្មទៅបន្តុបនៅកន្លែងដែលខ្ពស់ ៗ នៃប្រាសាទនេះជាបំណោទ ១ ដែលនៅក្នុងកំពុងពិនិត្យពិចារណានៅឡើយ ។

ឯផ្លូវធំដែលចូលទៅកាន់ប្រាសាទនោះ គេបានចាក់ដីបំពេញឲ្យខ្ពស់ឡើងដោយមានជញ្ជាំងគាំសងខាង ហើយក្រាលថ្មភក់ពីលើដីដែលចាក់នេះទៅដោយមានកំណល់ថ្មបាយក្រៀមពីក្រោម ។

ឯសសរមូលដែលគាំជញ្ជាំងសងខាងផ្លូវក្រោមបង្កាន់ដៃនាគ ដែលឆ្លងកាត់គូខាងលិច នោះធ្វើផ្អាបគ្នាជាបី ។

មាត់គូក្រៅកំផែងទាំងអស់សុទ្ធតែមានរៀបថ្មជាថ្នាក់ មានគ្រឹះធ្វើពីថ្មបាយក្រៀម ប៉ុន្តែថ្មបាយក្រៀមទាំងនេះគេរៀបផ្ទាល់នឹងដីតែម្តងនាំឲ្យស្រុតខូចអស់ជាច្រើនកន្លែង ។

ឯស្រះតូចទាំងពីរដែលនៅជាចន្លោះបណ្ណាល័យនឹងទីព្រះលាននោះទំនងជាមានមាត់រៀបថ្មដែរ មាត់ស្រះខាងជើងនោះឃើញមានច្បាស់នៅឡើយ ។

បើថាប្រាសាទនគរវត្តទាំងមូលសង់ដោយឥតប្រើបាយអសម្រាប់ភ្ជាប់ថ្មហើយគេគ្រាន់តែយកថ្មទៅដុសសង្កត់គ្នាដើម្បីឲ្យបានខាំជាប់គ្នា នោះក៏គេប្រទះឃើញស្នាមដានថ្នាំបូកភ្ជាប់ពីក្រៅនៅ ៗ កំពូលកណ្តាល ដែលគេលាបមាសទាំងមូល ឬក៏គេលាបថ្នាំពណ៌អ្វីផង ។

អាស្រ័យដោយប្រាសាទគង់នៅល្អនោះ គេអាចនឹងឧបមាបានថាប្រាសាទនគរវត្តនេះគេមិនដែលបោះបង់ចោលដូចប្រាសាទឯទៀតៗ ឡើយ គឺមានលោកសង្ឃតែងទៅធ្វើបុណ្យ

ទានអ្វីក្នុងទីនេះមិនខាន ។ សិលាចារិកនៅទីលានជើងភ្នែក បញ្ជាក់ដល់យើងថា កាលពី ព. ស. ២០៥០ ដល់ ២២៥០ ប្រាសាទនេះទៅជាកន្លែងស័ក្តិសិទ្ធ ១ ដែលមនុស្សរាប់អាន កុះករ ។ សព្វថ្ងៃនេះនៅមានសល់បុណ្យនេះខ្លះនៅឡើយ គឺក្នុងរដូវចូលឆ្នាំខ្មែរនោះមានពួកអ្នកស្រុកឬអ្នកដំណើរទៅជួបជុំធ្វើបុណ្យក្នុងទីនោះ ។

ដរាបដល់មកក្នុងឆ្នាំ ១៩១០ នោះមានវត្ត ២ តាំងនៅៗ ក្បែរផ្លូវដែលចូលតមកវត្តនេះ បានបន្ថយចេញឆ្ងាយពីទីនេះទៅ ដើម្បីកុំឲ្យបាំងភ្នែកអ្នកទៅមើលប្រាសាទ ។

ការដែលធ្លាប់មានលោកសង្ឃនៅៗ ក្នុងទីនគរវត្តនេះ ជាហេតុដែលតាំមិនឲ្យមានដើមឈើធំដុះជ្រៀតជ្រែក តាំឲ្យអន្តរាយដូចជាប្រាសាទផ្សេងៗឯទៀត ។ ហើយពួកលោកសង្ឃទាំងនេះ តែងមានទម្លាប់នឹងជួសជុលទីកន្លែងដែលបាក់បែក ដូចយ៉ាងថ្នាក់ទី ៣ នោះបានដកយកសសរម្ហូលពីទីព្រះលាននៅឆ្ងា យកទៅដាក់ធ្វើជាមេទ្វារនៅក្រោមហោជាង ឬក៏យកទៅដាក់ជួសសសរដែលបាត់បង់ទៅ ។

ឯការដែលធ្វើជាជញ្ជាំងខាន់យ៉ាងបែបឡែរូបពីដៃ ពីសសរថៃវក្រៅទៅទ្វារខាងលិចនៃទីអាសនៈនោះ ក៏ជាការរបស់លោកសង្ឃទាំងនេះដែរ ហើយសង្ឃទាំងនេះបានធ្វើការបិទទ្វារទាំង ៤ របស់អាសនៈនេះផង ។

មានការកែប្រែជាក្រោយដោយសិទ្ធពុទ្ធ នឹងដោយបន្ទុក្សាប់ ដែលប្រហែលជាធ្វើតាំងពីក្នុងសម័យជាមួយនឹងកសាងម្ហ៊ះ ការនេះពិនិត្យឃើញនៅសងខាងទ្វារកណ្ដាលពីទិសខាងលិច ៗ [illegible]

នៅខាងមុខប៉ែកខាងកើតនៃផ្លូវដែលបាននិយាយហើយនេះ គេអាចនឹងស្មានបានថា ពីកាលក្នុងសម័យណាមួយនោះមានការកសាងពីរ (ប្រហែលជាវត្ត) ព្រោះឃើញទីដំណែលនៅឡើយ មានទំនងជាជើងជញ្ជាំង ឬសសរធ្វើដោយថ្មបាយក្រៀម នៅសងខាងផ្លូវដែលចូលទៅកាន់ប្រាសាទ ។ ការកសាងទាំងនេះជាប់គ្នានឹងផ្លូវខាងនឹងផ្លូវធ្លាកណ្ដាល ហេតុនេះហើយបានជាតាំឲ្យមានជញ្ជាំងខាន់នៅសសរថៃវក្រៅភ្ជាប់នឹងទ្វារខាងលិចនៃទីអាសនៈនោះ ។

ការរចនា ប្រដាប់តុបតែង

ប្រាសាទនគរវត្ត ក៏ដូចជាប្រាសាទឯទៀត ៗ ក្នុងសម័យបុរាណនោះដែរ គឺការរចនាតុបតែង នាំឲ្យខូចទីដែលវាល ៗ ជាច្រើន នៅសសរនឹងនៅជញ្ជាំងដែលជាងឆ្លាក់បានរចនាជាក្បាច់ក្បូរឡើង ។

ក្បាច់បំឡាក់បេះតែឆ្លាក់ដេរដាសពាសពេញទៅ ដោយឥតមានគិតពិចារណារិះរកឲ្យសមនឹងទីកន្លែងនីមួយ ៗ ឡើយ ។ ជួនកាលក្បាច់បំឡាក់ឃើញមិុតប្រាយហួសពេកមិនស៊ីសួនគ្នានឹងវិធីកសាងប្រាសាទឡើយ មានគំរូ ១ ដែលនឹងទាញយកឲ្យឃើញជាភ័ស្តុតាងអំពីរឿងនេះ ។

ទ្វារខាងលិចទាំងអស់ ជាការដែលធ្វើយ៉ាងផ្ចិតផ្ចង់បំផុតក្នុងការកសាងប្រាសាទទាំងមូលនេះ ហើយរបៀបក្បាច់រចនាដាលំអនោះគេប្រើក្បាច់យ៉ាងផ្ចិតផ្ចង់បំផុតក្នុងក្បាច់រចនាខ្មែរ មានរូបប្រកបដោយមុខយ៉ាងប្រិមប្រិយ ហើយក្បាច់ដែលនៅអមរូបក៏យ៉ាងឆើត ។ ប៉ុន្តែបើពិនិត្យសង្កេតឲ្យយូរទៅ ហើយពិចារណារកផ្ទៃពិតនោះក៏នឹងលេចសេចក្ដីដែល

ខុសប្រក្រតីឡើងទៅបំពីមុខ  គឺជាទ្វារធំទាំង ៣ ដែលនៅកណ្ដាលនោះដែលជាកន្លែងយ៉ាងសំខាន់  ព្រោះជាផ្លូវសម្រាប់ក្បួនហែស្ដេច  នោះនៅទីខាងក្នុងក្បាច់របនាមិនផ្ចិតផ្ចង់ដូចជាក្បាច់ដែលរបនាជាប់នៅទ្វារខាងទាំងពីរនៅចុងកំផែង  ដែលហៅថាទ្វារដំរីនោះឡើយ  ហើយទ្វារទាំងពីរនេះជាងកសាងគេទុកដាក់ជាទ្វារបន្ទាប់បន្សំផង ។

ក្បាច់របនាដែលឆ្លាក់លើថ្មនេះសង្កេតមើលដូចជាអ្នកឆ្លាក់ជាន់នោះឆ្លាក់ដោយងាយ  ប្រហែលនឹងយើងឆ្លាក់លើស្បែកឬក៏គូរលើសំពត់ដូច្នោះ ។

នៅប្រាសាទនគរវត្ត  បំឡាក់នៅជញ្ជាំងហាក់ដូចជាយកបន្ទះគំនូរទៅពាស  ព្រោះជាងកសាងទុកកន្លែងឲ្យជាងឆ្លាក់តិចណាស់  ហើយហាក់ដូចជាមិនបំរុងទុកឲ្យឆ្លាក់ផង  ជាងឆ្លាក់ៗរាក់ៗណាស់  ព្រោះជញ្ជាំងនោះស្ដើង ។

ម្យ៉ាងវិញទៀត  សេចក្ដីប្រាថ្នារបស់អ្នកកសាងក៏លេចច្បាស់ឡើង  ហើយបញ្ជាក់ឲ្យឃើញច្បាស់ក្នុងៗការរៀបចំនូវទ្វើន ។ ការនេះមានមុខក្រសួងយ៉ាងធំក្នុងការកសាងប្រាសាទ

ខ្មែរ គឺទៀននេះធ្វើជាជើងសម្រាប់ធ្វើឲ្យមានដំឡែ ហើយធ្វើឲ្យលេចនូវអាសនៈជាប់ឡើង បំពោះនឹងភ្នែកសាធារណជន ។

ដែលមានបែបក្បាច់របនាខ្លះនាំឲ្យមានការរិះគន់តិះតៀលនោះបំណែករូបនាគដែលជាបង្កាន់ដៃផ្ទវប្លូល នឹងជាបង្កាន់ដៃទីព្រះលាននោះអាចនឹងទុកដាក់បានថាជាគំរូយ៉ាងប្រសើរ ១ ដែលការរបនាអង្គរទុកឲ្យយើង ។

គឺជាការប្រដាប់របនាយ៉ាងធម្មតាដែលមាននៅលើខ្លួននាគត្រង់ដែលអែនស្រួលនឹងត្រង់ដែលខ្សែបន្ទាត់រត់ជួរល្អ ក្បាច់នាគដែលអើតឡើងនោះរាងបែបជាផ្លិត ហើយមើលទៅឃើញល្អគួរឲ្យគយគន់ ។

ការលាបថ្នាំទំនងជាមានមុខក្រសួងយ៉ាងសំខាន់ណាស់ដែរក្នុងការរបនាប៉ែកខាងក្នុង ហើយប្រហែលជាខាងក្រៅខ្លះផង ប៉ុន្តែជាការលំបាកនឹងបង្កុលកន្លែងឲ្យបំ នឹងលំបាកនឹងដំរូវពណ៌ថាជាពណ៌អ្វីណាស់ ព្រោះកន្លែងដែលលាបថ្នាំនេះត្រូវភ្លៀងរលុបបាត់អស់រលីងផង នឹងរលុបដោយការបន្ថែមថ្មីរបស់ពួកលោកសង្ឃផង ។ សេចក្តីនេះត្រូវតែវិនិច្ឆ័យសេចក្តី

ថា  កំពូលប្រាសាទនគរវត្តមានលាបថ្នាំពណ៌ឬលាបមាស ដូចជាប្រាសាទបាយ័ននឹងបាពួនដូច្នោះដែរ ។

ប្រាសាទសម្រាករាងជើងក្អែកដែលនៅជាបន្ទោះថ្នាក់ទី ១ នឹងថ្នាក់ទី ២  ដែលជាងកសាងបានដុតផ្ទង់នោះទំនងជាមានលាបថ្នាំយ៉ាងសំខាន់ៗ ច្រើនពណ៌  បើយើងពិនិត្យឲ្យម៉ដ្ឋចត់ទៅនឹងប្រទះឃើញស្នាមជានថ្នាំខ្លះដែលជាប់នៅមានពណ៌ក្រហមខ្ចីនៅឡើយនៅទីខ្ពស់ៗ នៃសសរផ្សេងៗ ពណ៌ក្រហមនេះគឺជាពណ៌ ១ ជាន់ខាងក្នុង ហើយគេមានទឹបមាស ១ ជាន់ពីលើនេះទៅទៀត ។

មានស្នាមមាសជាប់ខ្លះនៅឡើយ  នៅក្បាលសសរនឹងនៅក្បាំងខាងជ្រុងពាយ័ព្យនៃប្រាសាទសម្រាក ។ នៅកន្លែងខ្លះដែលនៅល្អនោះ  ខ្ញុំសំគាល់ឃើញមានស្នាមពណ៌ក្រហមនឹងខៀវជាប់នៅត្របកឈូក ។

ត្រូវតែនិយាយផងអំពីបែបយកពន្លឺក្នុងទីវៃវិថ្នាក់ទី ១ ។

ការប្រយោជន៍នឹងការពារពួកអ្នកដើរមើល  កុំឲ្យត្រូវពន្លឺខ្លាំងពេកនឹងកុំឲ្យត្រូវភ្លៀងដែលជួនកាលផាយចូលមក  នោះ

នាំឲ្យធ្វើបែរ ១ ទៀតជាប់គ្នានឹងបែរនោះតែខាងជាង ។ សេចក្តីដែលកើតមានឡើងដោយធ្វើដូច្នេះនោះ គឺជាពន្លឺមកប៉ះនឹងជញ្ជាំងដោយភាគខាងក្រោម ហើយបំណែកភាគដែលនៅខ្ពស់នោះនៅក្នុងម្លប់វិញ ជាការផ្ទុយនឹងទំលាប់យើងក្នុងសណ្ឋានដែលយើងចង់ឲ្យឃើញដំឡៃនៃផែនផ្ទាំងដែលរបនានោះ ។ ក្នុងទីប្រាសាទទាំងមូលនេះ គេអាចនឹងសំគាល់បានជាអ្នកកសាងមានសេចក្តីប្រាថ្នានឹងដាក់បង្អួចមកក្នុងទីដ៏ទាបវិញ ឃើញខុសអំពីប្រវេណីអ្នកបស្ចិមប្រទេស ដែលចូលចិត្តយកពន្លឺពីទីដ៏ខ្ពស់ ។

ឥឡូវនេះបើយើងលះបង់នូវការបន្តិចបន្តួចចេញ ហើយយើងពោលបង្រួមនូវលក្ខណៈយ៉ាងមានខ្លឹមសារ ដែលប្រាសាទនគរវត្តធ្វើឲ្យយើងគយគន់ដោយសេចក្តីពេញចិត្ត នោះយើងអាចនឹងពោលបានថាប្រាសាទនគរវត្តតាំងធ្វើលើទីដ៏ធំទូលាយស័ក្តិសមនឹងទំហំប្រាសាទនឹងតួគេហស្ថានឯទៀត ទាំងប៉ុន្មានដែលជាប់ជាមួយគ្នា ។

ផែនទីប្រាសាទនគរវត្ត រៀបចំឡើងដោយក្បួនព្វន្ត យ៉ាងប្រាជ្ញ ហើយមានរាងរៅទាំងមូលមើលពីចំងាយទៅ ឃើញស្តុកស្តម្ភដោយប្រសប់សៃស្លួន សំខាន់ដោយមានទីវាលយ៉ាងទូលាយមានស្មៅដុះពេញផ្ទៃ នឹងដោយគូជុំវិញដែលមានស្ពានឆ្លងកាត់ក្រាលថ្មនាំចូលទៅក្នុងទីធំកណ្តាលដែលបេះតែឡើងខ្ពស់ទៅៗ ។

កាលណាតែឈានផុតទ្វារធំកណ្តាលនៅទិសខាងលិចទៅ នោះនឹងមើលឃើញប្រាសាទទាំងមូលពីក្រោមស៊ុំទ្វារទៅ ហើយឃើញនូវបណ្ណាល័យទាំង២ជាផែនទីជាដំបូងនៅជាសងខាងផ្លូវថ្លាធំ ។ ហើយសេចក្តីប្លូលចិត្តរបស់ខ្មែរក្នុងការធ្វើឲ្យឃើញនូវប្រាសាទទាំងមូលនោះបេះរកខ្នាតយ៉ាងសម ដែលពួកអ្នកបំណានខាងក្បួនព្វន្តបានគិតលៃយ៉ាងត្រឹមត្រូវ ។

គេដឹងថាគេអាចនឹងមើលវត្ត ១ ឲ្យល្មមនឹងភ្នែកបានពីក្នុងចំងាយ ២ ឬ ៣ ស្លូន ធំជាងទំហំវត្តដែលធំបំផុត ។

ប្រវែងបណ្តោយថៃវិថ្នាក់ទី ១ ក្នុងមុខខាងលិចចំនួន ១៨០ ម៉ែត្រ លុះយើងទ្វេចំនួននេះជា ២ ឡើងត្រូវ ៣៦០ ម៉ែត្រ

ហើយយើងវាស់បំងាយពីទ្វារប្រាសាទមកដល់កន្លែងអ្នកដែលឈរមើល ត្រូវគត់ ៣៦០ ម៉ែត្រឥតមានល្អៀង ។

ត្រង់នេះមានសេចក្ដីសំគាល់ម្យ៉ាង គឺក្នុងប្រាសាទនគរវត្តនេះភាពភូមិហានធម្មតា មិនចូលមកជ្រែកដូចយ៉ាងក្នុងប្រាសាទផ្សេងៗឯទៀតឡើយ ឯក្នុងប្រាសាទដទៃទាំងនេះគេបានយកភាពភូមិហាននៅជិតខាងមកបញ្ចូល ដើម្បីឲ្យបានបំរើនូវសេចក្ដីលំអ ។

នៅប្រាសាទនគរវត្ត ជាងកសាងបានស្ថង់បន្ទាត់កណ្ដាលវាល ឥតមានអាស្រ័យដោយភូមិប្រទេសជិតខាង គឺគេលៃស្ទង់តែក្នុងការដែលជារបនាក្នុងទីនេះដើម្បីឲ្យឃើញការនេះបានដំឡើងល្អឡើងតែខ្លួនឯងឥតពឹងអាស្រ័យនឹងវត្ថុអ្វីផ្សេងដទៃ ។

ប្រាសាទនគរវត្ត សាងត្រូវតាមក្បួនយ៉ាងសំខាន់របស់ការរបនា គឺថាធ្វើឲ្យតួប្រាសាទទាំងមូល គេអាចនឹងមើលតែ ១ ភ្លែតទៅឃើញបានទាំងអស់ ។

លុះដើរចូលទៅខាងក្នុងប្រាសាទទៅ នោះយើងមិនមានប្រទេះអ្វីដែលជាស្ទាត់កំបាំងក្នុងចិត្ត ដូចជាដែលចូលទៅក្នុង

ប្រាសាទបាយ័នឬតាព្រហ្មឡើយ -ដែលយើងចូលទៅក្នុងប្រាសាទទាំងពីរនេះហាក់ដូចវង្វេងបាត់ក្នុងគំនរថ្ម ។ ក្នុងទីនគរវត្តនេះឃើញដូចជាច្បាស់លាស់ ហើយត្រឹមត្រូវមានបែបផែនហាក់ដូចជាដកដង្ហើមបានស្រួលឥតទើសទាក់ ។

អ្នកដើរមើល ដែលឡើងផុតកាំជណ្ដើរទៅ ដើម្បីចូលទៅក្នុងទីអាសនៈនោះនឹងឃើញកន្លែងផ្សេងៗ នៃប្រាសាទនេះលាបេញក្រោមជើងដើរជាសញាសពេញ ហើយសេចក្ដីដែលឃើញនេះ នឹងផុតត្រឹមកំពូលកណ្ដាលដែលយ៉ាងស្កុកស្គម្ភស្កឹមស្កៃយ៉ាងមានឥទ្ធានុភាព ។

បែបភាពទំនងដែលស៊ីសួនគ្នាគ្រប់កន្លែងនេះ នាំឲ្យយើងរិះគិតធៀបមើលតាំងពីប្រាសាទដំបូង ដែលកសាងតាមក្បួនខ្នាតស្រុកឥណ្ឌៀ រហូតដល់មកបែបកសាងដែលជារបតាខ្មែរបរិសុទ្ធដែលនគរវត្តនេះ អាចបញ្ជាក់ឲ្យឫទ្ធានុភាពខ្មែរនឹងការដែលជាស្នាដៃបរិសុទ្ធរបស់ខ្មែរឥតលាយឡំ ។



លោកសង្ឃភូមាកាន់ត្រាដែលព្រះករុណាសោយរាជ្យជាន់ក្រោយបំផុត
បានប្រទានមកក្រុមសង្ឃការីនៅក្រុងមណ្ឌលេ តាំងពី ព.ស. ២.៣៩៣ ។

# កម្មបថ ពិស្តារ

៣០– បរញ្ញ អភិជ្ឈាយ សមាទបេតិ គឺបបួលឬដឹកនាំអ្នកដទៃឲ្យសំឡឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបំរុងនឹងឲ្យបានមកជាទ្រព្យរបស់ខ្លួន ។

៣១– អភិជ្ឈាយ ច សមនុញ្ញោ ហោតិ គឺជាអ្នកមានចិត្តត្រេកអរក្នុងកិរិយាសំឡឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបំរុងនឹងឲ្យបានមកជាទ្រព្យរបស់ខ្លួន ។

៣២– អភិជ្ឈាយ ច វណ្ណំ ភាសតិ គឺពោលពណ៌នានូវគុណនៃកិរិយាសំឡឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបំរុងនឹងឲ្យបានមកជាទ្រព្យរបស់ខ្លួន ។

៣៣– អត្តនា ច ព្យាបន្នចិត្តោ ហោតិ គឺជាអ្នកមានគំនិតគិតប៉ងនឹងធ្វើនូវប្រយោជន៍ និងសេចក្ដីសុខអ្នកដទៃឲ្យសាបសូន្យទៅដោយខ្លួនឯង ។

៣៤– បរញ្ញ ព្យាបាទេ សមាទបេតិ គឺបបួលឬដឹកនាំអ្នកដទៃក្នុងកិរិយាធ្វើនូវប្រយោជន៍ និងសេចក្ដីសុខអ្នកដទៃឲ្យសាបសូន្យ ។

៣៥– ព្យាបាទេ ច សមនុញ្ញោ ហោតិ គឺជាអ្នកមានចិត្តត្រេកអរ ក្នុងកិរិយាធ្វើនូវប្រយោជន៍នឹងសេចក្ដីសុខអ្នកដទៃឲ្យសាបសូន្យ ។

៣៦– ព្យាបាទស្ស ច វណ្ណំ ភាសតិ គឺពោលពណ៌នានូវគុណនៃកិរិយាធ្វើនូវប្រយោជន៍នឹងសេចក្ដីសុខអ្នកដទៃឲ្យសាបសូន្យ ។

៣៧– អត្តនា ច មិច្ឆាទិដ្ឋិកោ ហោតិ គឺជាអ្នកមានគំនិតយល់ឃើញខុសហើយ ប្រកាន់ឡើងថាជាត្រូវដោយខ្លួនឯង ។

៣៨– បរញ្ច មិច្ឆាទិដ្ឋិយា សមាទបេតិ គឺបបួលឬដឹកនាំអ្នកដទៃឲ្យយល់ឃើញខុសហើយប្រកាន់ឡើងថាជាត្រូវ ។

៣៩– មិច្ឆាទិដ្ឋិយា ច សមនុញ្ញោ ហោតិ គឺជាអ្នកមានចិត្តត្រេកអរ ក្នុងកិរិយាយល់ឃើញខុសហើយប្រកាន់ឡើងថាជាត្រូវ ។

៤០– មិច្ឆាទិដ្ឋិយា ច វណ្ណំ ភាសតិ គឺពោលពណ៌នានូវគុណនៃកិរិយាយល់ឃើញខុស ហើយប្រកាន់ឡើងថាជាត្រូវ ។

ឥមេហិ ខោ ភិក្ខវេ ចត្តារីសាយ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបព្រមហើយដោយធម៌ទាំងឡាយ ៤០ ប្រការនេះឯង ដែលខ្លួនសន្សំទុកហើយនាំមកយ៉ាងណា ក៏ត្រូវតាំងនៅក្នុងអបាយយ៉ាងនោះ ។

"អ្នកឯណាបានប្រព្រឹត្តក្នុងអកុសលកម្មបថ ៤០ ប្រការដូចបានពោលមកហើយនេះ អ្នកនោះនឹងបាននូវសេចក្ដីទុក្ខសេចក្ដីវិនាសក្នុងលោកនេះនឹងបរលោកនាយ បើទុកជាមិនទាន់ឲ្យផលឲ្យឃើញច្បាស់ក្នុងលោកនេះ លុះដល់ទៅបរលោកនាយ ក៏គង់ឲ្យផលដល់អ្នកនោះពុំខានឡើយ ។

សម្ដេចព្រះបរមលោកនាថជាម្ចាស់ត្រាស់សំដែងធម៌ ៤០ ប្រការជាធម៌ទាបអាក្រក់ដូច្នេះហើយ ទើបទ្រង់សំដែងធម៌ ៤០ ប្រការដែលជាធម៌ល្អស្អាតដូច្នេះតទៅ ។

ចត្តារីសាយ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបព្រម

ហើយដោយធម៌ទាំងឡាយ ៤០ ប្រការ (ដែលខ្លួនសន្សំទុកហើយ) នាំមកយ៉ាងណា ក៏ត្រូវតាំងនៅក្នុងសួគ៌យ៉ាងនោះ ។

កតមេហិ ចត្តារីសាយ ធម៌ទាំងឡាយ ៤០ ប្រការដូចម្តេច

១– អត្តនា ច បាណាតិបាតា បដិវិរតោ ហោតិ គឺជាអ្នកមានចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ ដោយខ្លួនឯង ។

២– បរញ្ច បាណាតិបាតា វេរមណិយា សមាទបេតិ គឺ បបួល ឬដឹកនាំអ្នកដទៃឲ្យកាន់យកព្រមនូវចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ ។

៣– បាណាតិបាតា វេរមណិយា ច សមនុញ្ញោ ហោតិ គឺជាអ្នកមានចិត្តត្រេកអរ ក្នុងចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ ។

៤– បាណាតិបាតា វេរមណិយា ច វណ្ណំ ភាសតិ គឺជាអ្នកពោលពណ៌នានូវគុណនៃចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ ។

៥– អត្តនា ច អទិន្នាទានា បដិវិរតោ ហោតិ គឺជាអ្នកមានចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យដោយកាយឬដោយវាចា ដោយខ្លួនឯង ។

៦– បរញ្ច អទិន្នាទានា វេរមណិយា សមាទបេតិ គឺបបួល ឬដឹកនាំអ្នកដទៃឲ្យកាន់យកព្រមនូវចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យដោយកាយ ឬដោយវាចា ។

៧– អទិន្នាទានា វេរមណិយា ច សមនុញ្ញោ ហោតិ គឺជាអ្នកមានចិត្តត្រេកអរក្នុងចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យដោយកាយឬដោយវាចា ។

៨– អទិន្នាទានា វេរមណិយា ច វណ្ណំ ភាសតិ គឺពោលពណ៌នានូវគុណនៃចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យដោយកាយឬដោយវាចា ។

៩– អត្តនា ច កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ គឺជាអ្នកមានចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយដោយខ្លួនឯង ។

១០— បរញ្ញ កាមេសុ មិច្ឆាចារា វេរមណិយា សមា- ទបេតិ គឺបបួលឬដឹកនាំអ្នកដទៃឲ្យកាន់យកព្រមនូវចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

១១— កាមេសុ មិច្ឆាចារា វេរមណិយា ច សមនុញ្ញោ ហោតិ គឺជាអ្នកមានចិត្តត្រេកអរ ក្នុងចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

១២— កាមេសុ មិច្ឆាចារា វេរមណិយា ច វណ្ណំ ភាស- តិ គឺពោលពណ៌នានូវគុណនៃចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

១៣— អត្តនា ច មុសាវាទា បដិវិរតោ ហោតិ គឺជាអ្នកមានចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ដោយខ្លួនឯង ។

១៤— បរញ្ញ មុសាវាទា វេរមណិយា សមាទបេតិ គឺបបួលឬដឹកនាំអ្នកដទៃឲ្យកាន់យកព្រម នូវចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

១៥– មុសាវាទា វេរមណិយា ច សមនុញ្ញោ ហោតិ គឺជាអ្នកមានចិត្តត្រេកអរព្រម ក្នុងចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

១៦– មុសាវាទា វេរមណិយា ច វណ្ណំ ភាសតិ គឺពោលពណ៌នានូវគុណនៃចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

១៧– អត្តនា ច បិសុណាយ វាចាយ បដិវិរតោ ហោតិ គឺជាអ្នកមានចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យញុះញង់ស៊កសៀតបំបែកបំបាក់អ្នកដទៃ ដោយខ្លួនឯង ។

១៨– បរញ្ច បិសុណាយ វាចាយ វេរមណិយា សមាទបេតិ គឺបបួលឬដឹកនាំអ្នកដទៃឲ្យកាន់យកព្រម នូវចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យញុះញង់ស៊កសៀតបំបែកបំបាក់អ្នកដទៃ ។

១៩– បិសុណាយ វាចាយ វេរមណិយា ច សមនុញ្ញោ ហោតិ គឺជាអ្នកមានចិត្តត្រេកអរ ក្នុងចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យញុះញង់ស៊កសៀតបំបែកបំបាក់អ្នកដទៃ ។

២០– បិសុណាយ វាចាយ វេរមណិយា ប វណ្ណំ ភាសតិ គឺពោលពណ៌នានូវគុណនៃចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យញុះញង់ស៊កសៀតបំបែកបំបាក់អ្នកដទៃ ។

២១– អត្តនា ច ផរុសាយ វាចាយ បដិវិរតោ ហោតិ គឺជាអ្នកមានចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោកជេរប្រទេចអ្នកដទៃជាដើម ដោយខ្លួនឯង ។

២២– បរញ្ច ផរុសាយ វាចាយ វេរមណិយា សមាទបេតិ គឺបបួលឬដឹកនាំអ្នកដទៃឲ្យកាន់យកព្រម នូវចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោកជេរប្រទេចអ្នកដទៃជាដើម ។

២៣– ផរុសាយ វាចាយ វេរមណិយា ច សមនុញ្ញោ ហោតិ គឺជាអ្នកមានចិត្តត្រេកអរ ក្នុងចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោកជេរប្រទេចអ្នកដទៃជាដើម ។

២៤— ផរុសាយ វាចាយ វេរមណិយា ប វណ្ណំ ភាសតិ គឺពោលពណ៌នានូវគុណនៃចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោកជេរប្រទេចអ្នកដទៃជាដើម ។

២៥— អត្តនា ច សម្ផប្បលាបា បដិវិរតោ ហោតិ គឺជាអ្នកមានចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍ ដោយខ្លួនឯង ។

២៦— បរញ្ច សម្ផប្បលាបា វេរមណិយា សមាទបេតិ គឺបបួលឬដឹកនាំអ្នកដទៃឲ្យកាន់យកព្រម នូវចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

២៧— សម្ផប្បលាបា វេរមណិយា ច សមនុញ្ញោ ហោតិ គឺជាអ្នកមានចិត្តត្រេកអរនូវចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

២៨— សម្ផប្បលាបា វេរមណិយា ច វណ្ណំ ភាសតិ គឺពោលពណ៌នានូវគុណនៃចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

២៩– អត្តនា ច អនភិជ្ឈាលុ ហោតិ គឺជាអ្នកមិនមានចិត្តគិតសំឡឹងរំពៃបំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបំរុងនឹងឲ្យបានមកជារបស់ខ្លួន ដោយខ្លួនឯង ។

៣០– បរញ្ច អនភិជ្ឈាយ សមាទបេតិ គឺបបួលឬដឹកនាំអ្នកដទៃ ឲ្យកាន់យកព្រមនូវចេតនាមិនបានគិតសំឡឹងរំពៃបំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបំរុងនឹងឲ្យបានមកជារបស់ខ្លួន ។

៣១– អនភិជ្ឈាយ ច សមនុញ្ញោ ហោតិ គឺជាអ្នកមានចិត្តត្រេកអរ ក្នុងកិរិយាមិនសំឡឹងរំពៃបំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបំរុងនឹងឲ្យបានមកជាទ្រព្យរបស់ខ្លួន ។

៣២– អនភិជ្ឈាយ ច វណ្ណំ ភាសតិ គឺពោលពណ៌នានូវគុណនៃកិរិយាមិនសំឡឹងរំពៃបំពោះទ្រព្យរបស់អ្នកដទៃដោយគិតបំរុងនឹងឲ្យបានមកជាទ្រព្យរបស់ខ្លួន ។

៣៣– អត្តនា ច អព្យាបន្នចិត្តោ ហោតិ គឺជាអ្នកមិនមានចិត្តចងគំនុំគុំគួនគិតប៉ងនឹងធ្វើអ្នកដទៃ ឲ្យដល់នូវសេចក្ដីវិនាស ដោយខ្លួនឯង ។

៣៤– បរញ្ចៈ អព្យាបាទេ សមាទបេតិ គឺបបួលឬដឹកនាំអ្នកដទៃឲ្យកាន់យកព្រម នូវចិត្តដែលមិនមានគំនុំគុំគួនគិតប៉ងនឹងធ្វើអ្នកដទៃឲ្យដល់នូវសេចក្ដីវិនាស ។

៣៥– អព្យាបាទេ ច សមនុញ្ញោ ហោតិ គឺជាអ្នកមានចិត្តត្រេកអរ ក្នុងចិត្តដែលមិនមានគំនុំគុំគួនគិតប៉ងនឹងធ្វើអ្នកដទៃឲ្យដល់នូវសេចក្ដីវិនាស ។

៣៦– អព្យាបាទស្ស ច វណ្ណំ ភាសតិ គឺពោលពណ៌នានូវគុណនៃចិត្តដែលមិនមានគំនុំគុំគួនគិតប៉ងនឹងធ្វើអ្នកដទៃឲ្យដល់នូវសេចក្ដីវិនាស ។

៣៧– អត្តនា ច សម្មាទិដ្ឋិកោ ហោតិ គឺជាអ្នកមានគំនិតយល់ឃើញត្រូវពិត ហើយប្រកាន់ឡើងថាជាត្រូវមែនដោយខ្លួនឯង ។

៣៨– បរញ្ច សម្មាទិដ្ឋិយា សមាទបេតិ គឺបបួលឬដឹកនាំអ្នកដទៃឲ្យកាន់យកព្រម នូវគំនិតដែលយល់ឃើញត្រូវពិតហើយប្រកាន់ឡើងថាជាត្រូវមែន ។

៣៩– សម្មាទិដ្ឋិយា ច សមនុញ្ញោ ហោតិ គឺជាអ្នកមានចិត្តត្រេកអរ ក្នុងគំនិតដែលយល់ឃើញត្រូវពិត ហើយប្រកាន់ឡើងថាជាត្រូវមែន ។

៤០– សម្មាទិដ្ឋិយា ច វណ្ណំ ភាសតិ គឺពោលពណ៌នានូវគុណនៃគំនិតដែលយល់ឃើញត្រូវពិត ហើយប្រកាន់ឡើងថាជាត្រូវមែន ។

ឥមេហិ ខោ ភិក្ខវេ ចត្តារីសាយ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបព្រមហើយដោយធម៌ទាំងឡាយ ៤០ ប្រការ (គឺវត្ថុដែលខ្លួនសន្សំទុកហើយ) នាំមកយ៉ាងណា ក៏តាំងនៅក្នុងស្ថានសួគ៌យ៉ាងនោះ ។

"អ្នកឯណាបានប្រព្រឹត្តត្រូវតាមកុសលកម្មបថ ៤០ ប្រការដូចបានពោលមកហើយនេះ អ្នកនោះនឹងមានសេចក្ដីសុខសេចក្ដីចំរើនក្នុងលោកទាំងពីរ គឺក្នុងលោកនេះ និងបរលោកនាយជាប្រាកដ ។

បុគ្គលប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្តនឹងមានទោស ៥ យ៉ាងគឺ

១– អត្តាបិ អត្តានំ ឧបវទតិ ខ្លួនឯងរមែងពោលតិះដៀលខ្លួនឯងបាន ។

២– អនុវិច្ច វិញ្ញូ គរហន្តិ អ្នកប្រាជ្ញទាំងឡាយលោកពិចារណាហើយរមែងពោលតិះដៀលបាន ។

៣– បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ មាទកិត្តិសព្ទគឺពាក្យពោលកេរ្តិ៍ឈ្មោះអាក្រក់ផ្សាយទៅ ។

៤– សម្មូឡ្ហោ កាលំ ករោតិ មានសតិវង្វេងភ្លេចក្នុងកាលជាទីធ្វើនូវមរណៈ ។

៥– និរយំ ឧបបជ្ជតិ លុះទំលាយកាយទៅកាលណាហើយរមែងទៅកើតក្នុងនរក ។

បុគ្គលប្រព្រឹត្តល្អដោយកាយវាចាចិត្តនឹងមានអានិសង្ស ៥ យ៉ាងគឺ

១– អត្តាបិ អត្តានំ ន ឧបវទតិ ខ្លួនឯងក៏មិនពោលតិះដៀលនូវខ្លួនឯង ។

២–អនុរិច្ចវិញ្ញូ បសំសន្តិ អ្នកប្រាជ្ញទាំងឡាយលោកពិចារណាហើយរមែងពោលសរសើរ ។

៣–កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ មានកិត្តិសព្ទគឺពាក្យពោលសរសើរកេរ្តិ៍ឈ្មោះល្អផ្សាយទៅ ។

៤–អសម្មូឡ្ហោ កាលំ ករោតិ មានសតិមិនវង្វេងភ្លេចក្នុងកាលជាទីធ្វើនូវមរណៈ ។

៥–សុគតិំ សគ្គំ លោកំ ឧបបជ្ជតិ លុះទំលាយកាយទៅកាលណាហើយ ក៏រមែងទៅកាន់សុគតិគឺស្ថានសួគ៌ ។

## រឿងធ្មេញដៃបណ្ឌិត

នេះនឹងនិយាយពីរឿងធ្មេញដៃ កាលដើមឡើយមកចាប់កំណើតក្នុងពោះនាងម្ដាយ ៗ ដេកទៅយល់សប្តិតែទៀបឯព្រឹកដូចជាយល់សួង យល់សប្តិបេះដូងបានបេះទាំងផ្លែ យល់សប្តិឃើញខែ ៗ នោះពេញបូណ៌មី នាងនោះភ្ញាក់ឡើងពីដេកគិតថាសប្តិនេះល្អណាស់ បើដូច្នេះអញនឹងទៅឲ្យហោរមើលឲ្យបានដឹងជាសប្តិនោះល្អឬអាក្រក់ គិតស្រេចយកទៀនធូបទៅដល់ផ្ទះហោរ អ្នកហោរមិននៅ ៗ តែប្រពន្ធហោរ នាងនោះទៅដល់ផ្ទះហោរហើយសួរថា អ្នកហោរនៅទេ ប្រពន្ធហោរប្រាប់ថា មិននៅទេ, រកគាត់ប្ដីនាង ៗ នោះប្រាប់ថាមករកគាត់ឲ្យទាយសប្តិ ដ្បិតខ្ញុំដេកទៅយល់សប្តិទៀបឯព្រឹកហាក់ដូចយល់សួង យល់សប្តិឡើងដូងបេះបានទាំងផ្លែ យល់សប្តិឃើញខែ ៗ នោះពេញបូណ៌មី, ប្រពន្ធហោរស្ដាប់ដឹងសព្វគ្រប់ថានាងនោះនឹងកើតកូន ៗ នោះប្រុសហើយនឹងបានជាស្ដេចដឹងដូច្នោះគិតថា អញនឹងទាយឲ្យទៅជាខ្ញុំគេ គិតស្រេចថា

នាងនឹងមានកូនប្រុស ១ នឹងទៅជាខ្ញុំគេ នាងនោះស្ដាប់នាងប្រពន្ធហោរទាយដូច្នោះ ហើយក៏លាវិលមកផ្ទះវិញ ។

ដល់សម្រាលកូននោះមកប្រុស បានអាយុ ៧ ឆ្នាំដើរទៅលេងខាងផ្ទះមហាសេដ្ឋីសព្វៗថ្ងៃ ឯប្រពន្ធមហាសេដ្ឋីត្បាញលើផ្ទះ បោះត្រល់ទៅវាធ្លាក់ទៅដី ក្រឡេកមើលទៅឃើញធ្មេញដៃលេងនៅនោះស្រែកហៅថាអាដៃរើសត្រល់ឲ្យអញ ទើបធ្មេញ-ដៃសួរថាបើខ្ញុំរើសត្រល់តើឲ្យរបស់អ្វីខ្ញុំ ប្រពន្ធមហាសេដ្ឋីថាអញឲ្យអំបុកធ្មេញដៃឯង ធ្មេញដៃថាឲ្យតិចឬច្រើន នោះនាងប្រពន្ធមហាសេដ្ឋីប្រាប់ថាអញឲ្យច្រើន ទើបធ្មេញដៃរើសត្រល់ហើយអង្គុយចាំទារអំបុកអំពីប្រពន្ធមហាសេដ្ឋីថា ឲ្យអំបុកមកខ្ញុំនឹងទៅផ្ទះ ឯប្រពន្ធមហាសេដ្ឋីឲ្យយកអំបុកមកឲ្យធ្មេញដៃៗថាតិចណាស់ឲ្យច្រើនទៀត ទើបប្រពន្ធមហាសេដ្ឋីឲ្យយកអំបុកមកឲ្យធ្មេញដៃច្រើនបានមួយកញ្ជើ នោះធ្មេញដៃថា តែច្រើនទៀត នោះប្រពន្ធមហាសេដ្ឋីថា អញអស់ឲ្យច្រើនប៉ុណ្ណោះឯងហើយ ឯធ្មេញដៃស្ដាប់ហើយខឹងយំទារតែអំបុកច្រើនៗ នោះឮទៅដល់មហាសេដ្ឋីៗដើរចូលមកមើលហើយសួរថា អាដៃប្ដី

ក៏យំ ទើបប្រពន្ធមហាសេដ្ឋីប្រាប់ថា ខ្ញុំឲ្យរើសត្រល់ឲ្យខ្ញុំថា ឲ្យអំបុកច្រើន ឥឡូវខ្ញុំឲ្យមួយកញ្ជើវាថាតែច្រើនទៀត ឥឡូវនេះវាអង្គុយតែយំ នោះមហាសេដ្ឋីថាឱឯងមិនដឹងចិត្តអាដៃទេ មានតែអញឲ្យវា ទើបវាព្រមបូលចិត្ត ទើបមហាសេដ្ឋីហៅថា អាដៃមកឯណេះអញនឹងឲ្យអំបុកអាឯងច្រើន ឯធ្មេញដៃឮមហាសេដ្ឋីហៅដូច្នោះហើយ ដើរទៅតាមមហាសេដ្ឋី ទើបមហាសេដ្ឋីឲ្យយកបង្អេរ ១ មកដាក់អំបុកនឹងបង្អេរបានជាពីរដុំ ហើយសួរថា អាដៃអាមើលអំបុកឯណាច្រើន ទើបអាដៃថា នេះច្រើននេះតិច ទើបមហាសេដ្ឋីថាបើឯណាច្រើន អាឯងយកច្រើននោះចុះ ធ្មេញដៃយកអំបុកនោះហើយក៏គិតតែក្នុងចិត្តឯង អញបាញ់ប្រាជ្ញានឹងមហាសេដ្ឋីនេះហើយ អញនឹងផ្ចាញ់ប្រាជ្ញាគាត់នេះឲ្យបាន ទើបអញសុខចិត្ត ធ្មេញដៃគិតដូច្នោះស្រេចហើយ ដើរទៅដល់ម្ដាយអាពុកប្រាប់ម្ដាយថា អ្នកម៉ែទៅយកប្រាក់មហាសេដ្ឋី ខ្ញុំនឹងទៅនៅជាខ្ញុំមហាសេដ្ឋី នឹងបំរើលោកតាមចិត្តខ្ញុំប៉ង ខ្ញុំមិននៅនឹងអ្នកម៉ែទេ ម្ដាយធ្មេញដៃស្ដាប់កូនថាដូច្នោះហើយសួរកូនថា អ្នកមាសម្ដាយ ៗ

នឹងមានជំពាក់បំណុលគេក៏ទេ ហើយម្ដាយនឹងយកកូនឲ្យទៅនៅជាខ្ញុំគេនោះ ទើបធ្មេញដៃប្រាប់ម្ដាយថា ខ្ញុំនឹងទៅនៅផ្កាញ់ប្រាជ្ញាលោកមហាសេដ្ឋីទេ ឯម្ដាយស្ដាប់ហើយក៏ព្រមទៅយកប្រាក់មហាសេដ្ឋី ឲ្យកូនទៅនៅជាខ្ញុំមហាសេដ្ឋី អំពីថ្ងៃនោះឯង ។

ឯមហាសេដ្ឋីក៏ប្រើបៅធ្មេញដៃ ឲ្យកាន់ឋាសស្លាដើរតាមទៅគាល់ស្ដេច សព្វថ្ងៃៗទៅ ឯធ្មេញដៃដើរក្រជល់មិនទាន់ ដ្បិតមហាសេដ្ឋីជិះសេះ នឹងដើរមិនទាន់ បានជាមហាសេដ្ឋីស្រដីថា អាដៃឯងដើរដូចម្ដេចក៏មិនទាន់អញ ទើបធ្មេញដៃប្រាប់ថា ដ្បិតខ្ញុំខ្លាចវាជ្រុសប្រែអប់អំពីឋាសស្លា ទើបមហាសេដ្ឋីស្រដីប្រាប់ថា អំពីថ្ងៃនេះទៅ អាឯងរត់ឲ្យបានទាន់តែសេះអញ បើវាជ្រុសរបស់អ្វីកុំឈប់រើសឡើយ ធ្មេញដៃស្ដាប់ហើយឆ្លើយថាបាទ ។

លុះដល់ថ្ងៃឯក្រោយវិញទៀតនោះ ធ្មេញដៃនឹងទៅតាមមហាសេដ្ឋី ទៅដល់ស្រាយបង់ស្រែះនោះបេញហើយគាល់បើមហាសេដ្ឋីឡើងជិះសេះបរបេញទៅ ឯធ្មេញដៃក៏រត់តាម

ក្រោយសេះ ជ្រើសអស់ប្រអប់ស្លាអំពីក្នុងចង់ស្រែះនោះ នៅតែជាសស្លាហើយនឹងចង់ស្រែះនោះ លុះដល់ទៅសាលាមហាសេដ្ឋីចុះអំពីលើខ្នងសេះហើយឡើងទៅលើសាលាជួបជុំ អង្គុយនឹងអស់នាម៉ឺនធំតូចហើយហៅទៅថា អាដែយកជាសស្លាមកអញស៊ី ឯធ្មេញដែក៏យកជាសស្លាជូនទៅមហាសេដ្ឋីហើយថយមកអង្គុយនៅទីដ៏សមគួរនឹងខ្លួនឯង មហាសេដ្ឋីទទួលជាសស្លាមកហើយក៏មើលទៅមិនឃើញៗតែជាសទទេ ខ្មាសគេមិនហ៊ានស្រដីថាអ្វីៗឡើយ លុះដល់វិលមកផ្ទះវិញ ហើយហៅថា អាដែអាមកណេះ ឯធ្មេញដែឮមហាសេដ្ឋីហៅខ្លួនដូច្នោះហើយក៏ដើរចូលទៅ ។ ឯមហាសេដ្ឋីក៏សួរថា អាដែឯងដូចម្ដេចក៏ឲ្យស្លាក់ប្រអប់អស់ក៏មិនរើសឡើងវិញ ធ្មេញដែជំរាបថាខ្ញុំខ្លាចដើរមិនទាន់លោកតា បានជាខ្ញុំមិនហ៊ានឈប់រើស ដ្បិតលោកតាផ្ដាំឲ្យរត់ឲ្យតែទាន់សេះលោកតានោះឯង ឯមហាសេដ្ឋីស្រដីប្រាប់ថា បើទៅឯក្រោយជ្រុះរបស់អ្វីឲ្យរើសកុំឲ្យខាន បើមិនបានរើសអញវាយអាឯង ឯធ្មេញដែស្ដាប់ឮថាមហាសេដ្ឋីផ្ដាំដូច្នោះហើយក៏ចាំទុក ។

លុះដល់ព្រឹកឡើងនឹងទៅគាល់ ហើយឡើងជិះសេះ ឯធ្មេញដៃកាន់ថាសស្លា ដើរតាមក្រោយសេះដែលមហាសេដ្ឋីជិះនោះឯង ឯសេះនោះឯងភិជុះអាចម៍ ឯធ្មេញដៃក៏រើសអាចម៍សេះនោះដាក់ក្នុងថាសស្លានោះទាល់តែពេញ ហើយដើរតាមក្រោយទៅ ឯមហាសេដ្ឋីជិះសេះទៅដល់មុខរកៈមើលធ្មេញដៃបាត់ ។

លុះដល់ធ្មេញដៃដើរទៅដល់ក៏សួរថា អាឯងមកអោយអញនឹងសួរមើល ។ ថាអាឯងអាប្តីក៏អាឯងដើរមិនឲ្យទាន់អញ ទើបធ្មេញដៃជំរាបថា បានជាខ្ញុំដើរមិនទាន់លោកតានោះ ព្រោះខ្ញុំបានឈប់រើសអាចម៍សេះវាធ្លាក់ច្រើនណាស់ ព្រោះប្រសាសន៍លោកតាផ្តាំថា បើរបស់អ្វីវាជ្រុះសឲ្យខ្ញុំបានឈប់រើស ហេតុដូច្នោះបានជាយូរ ទើបមហាសេដ្ឋីថាអាឯងឲ្យថាសស្លាមកអញ ទើបធ្មេញដៃឲ្យថាសស្លាមកមហាសេដ្ឋី ឯមហាសេដ្ឋីមើលឃើញអាចម៍សេះនៅក្នុងថង់ស្រែះនោះ ក៏អៀនខ្មាសអស់នាម៉ឺនដែលអង្គុយនៅលើសាលាជាមួយគ្នា ហើយមហាសេដ្ឋីមិនមានស្រដីថាអ្វីៗឡើយ ហើយក៏ចុះអំពីសាលាឡើងជិះសេះបរទៅផ្ទះឯងវិញ ឯធ្មេញដៃក៏យកថាសស្លាមកហើយក៏ដើរទៅ

តាមមហាសេដ្ឋី លុះដល់ទៅផ្ទះមហាសេដ្ឋីៗហៅថា អាដៃឯង កុំដើរតាមអញទៅគាល់ឡើយ អាឯងសមតែទៅចាំបម្ការវិញ ទើបសមនឹងមុខអាឯង ហើយមហាសេដ្ឋីស្រដីប្រាប់ថា តាំងតែអំពីថ្ងៃនេះទៅ អាឯងទៅចាំបម្ការតែសព្វៗថ្ងៃទៅ ឯធ្មេញដៃស្តាប់ហើយក៏ឆ្លើយថាបាទ ហើយក៏ដើរទៅចាំបម្ការនោះដូចមហាសេដ្ឋីប្រើដូច្នោះឯង ។

ឯអស់ដំណាំនៅក្នុងបម្ការនោះសត្វគោក្របីរាស៊ីអស់ ឯធ្មេញដៃក៏នឹងមានដេញក៏ទេ លុះដល់មហាសេដ្ឋីដើរទៅមើលបម្ការនោះ ក៏មិនមានឃើញមានដំណាំអ្វីឡើយ ឃើញតែដែលគោក្របីរាស៊ីអស់ហើយហៅថា អាដៃយើយអាមកឯណោះអញនឹងសួរអាឯងមើល ឯធ្មេញដៃស្តាប់ហើយក៏ដើរចូលទៅ ហើយក៏សំពះក្រាបនៅមុខមហាសេដ្ឋី នៅស្ងៀមចាំស្តាប់មហាសេដ្ឋីនឹងថាដូចម្តេច ឯមហាសេដ្ឋីក៏សួរថា អាដៃឯងដើរទៅឯណាក៏មិនដេញគោក្របីឲ្យរាស៊ីដំណាំអស់ ទើបធ្មេញដៃឆ្លើយថាបានជាខ្ញុំបាទពុំបានដេញគោក្របីរាស៊ីដំណាំនោះ ដ្បិតលោកតាមិនផ្តាំឲ្យដេញគោក្របី លោកតាផ្តាំតែថាឲ្យខ្ញុំបាទមើល

តែបម្ការ ឥឡូវនេះបំការនោះវានៅទេ នឹងមានបាត់ក៏ទេ ឯមហាសេដ្ឋីស្តាប់ហើយក៏ស្ងៀម ហើយគិតថាអាជែនេះហៅពេញកាបណាស់ ហើយបើដូច្នេះតើនឹងប្រើការអ្វីបាន ទើបមហាសេដ្ឋីគិតថា មានតែប្រើវាឲ្យទៅឃ្វាលគោវិញ ទើបមហាសេដ្ឋីហៅថា អាជែអាឯងមកឯណេះ ទើបធ្មេញជែឮហើយឆ្លើយថាបាទ ហើយដើរចូលទៅដល់ហើយអង្គុយនៅស្ងៀម ឯមហាសេដ្ឋីក៏ប្រាប់ថា អាជែឯងទៅឃ្វាលគោសព្វថ្ងៃ ៗ ទៅកុំឲ្យខានឡើយ ឯធ្មេញជែស្តាប់ហើយក៏ជំរាបមហាសេដ្ឋីថា ឈ្មឿតខ្លួនខ្ញុំបាទឥតប្រពន្ធ ឥឡូវនេះបើលោកតាឲ្យទៅឃ្វាលគោនោះខ្ញុំបាទអរហើយ នឹងបានប្រពន្ធច្រើន ខ្ញុំបាទជំរាបយកគោញីទាំងអស់ដែលមានប៉ុន្មាននៅក្នុងរោងនេះ ឈ្មោះតែគោញីខ្ញុំបាទយកជាប្រពន្ធទាំងអស់ ។

ធ្មេញជែជំរាបមហាសេដ្ឋីរួចហើយ ក៏លាទៅសព្វថ្ងៃៗ ហើយបើមានគោឈ្មោលឯណាវាមកពាក់គោញីនោះធ្មេញជែក៏ចាប់ថាគោឈ្មោលនោះវាលួចប្រពន្ធខ្លួនហើយបង្ខុកជាច្រើនណាស់ បើមានម្ចាស់គោឈ្មោលមកសុំយក ធ្មេញជែមិនឲ្យ

ហើយប្រាប់ថា គោអ្នកឯងវាលួចប្រពន្ធអញ បើចង់បានមានតែយកប្រាក់មកឲ្យអញ ទើបអញបើកឲ្យយកទៅ បើមិនយកប្រាក់មកឲ្យអញៗមិនបើកទេ ឯអស់ម្ចាស់គោនោះកាលបើបានឮធ្មេញដៃថាដូច្នោះហើយ ក៏ត្រឡប់វិលទៅជំរាបលោកមហាសេដ្ឋីថា សូមជំរាបលោកមហាសេដ្ឋីឲ្យបានជ្រាប ដ្បិតលោកឲ្យធ្មេញដៃឃ្វាលគោនោះវាចាប់គោឈ្មោលយើងខ្ញុំរាល់គ្នាទាំងអស់គោ ២០ ឬ ៣០ វាថាគោនោះឯងទៅលួចប្រពន្ធវា ហើយវាថា គោញីទាំងអស់នោះឯង លោកមហាសេដ្ឋីឲ្យជាប្រពន្ធវា បើដូច្នេះខ្ញុំបាទទាំងអស់គ្នា ពុំសុខចិត្តនឹងធ្មេញដៃធ្វើដូច្នេះមិនត្រូវ សូមឲ្យលោកឲ្យយកគោឲ្យខ្ញុំបាទវិញ ។

ÉCOLE FRANÇAISE
BIBLIOTHÈQUE
D'EXTRÊME ORIENT